# ព្រះ

# ត្រៃបិដកបាលី

# និង

# សេចក្តីប្រែជាភាសាខ្មែរ

# អភិធម្មបិដក

# បដ្ឋាន ទុតិយភាគ

# ៨១



ផ្សព្វផ្សាយដោយសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា
ព. ស. ២៥៥៣

# ABHIDHAMMAPIṬAKA

## VIBHAṄGA

## DUTIYABHĀGA

## 81

សម្ដេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្ដេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

# និយមវចនៈ

ព្រះត្រៃបិដកត្រូវបានបង្កើតឡើង ប្រមាណ៥០០ឆ្នាំប្លាយ ក្រោយអំពីការរំលត់ព្រះខន្ធចូលកាន់ ព្រះបរមនិព្វានរបស់សម្ដេចព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូជាអម្ចាស់នៃយើងគ្រប់គ្នា ។ គ្រប់ប្រទេស អ្នកកាន់ព្រះពុទ្ធសាសនា និងប្រទេសខ្លះមួយចំនួនមិនមែនអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់អង្គការ ពុទ្ធិកសមាគម និងតាមបណ្ណាល័យជាតិធំ ៗ តែងតែបានទទួលយកមកតម្កល់ទុកធ្វើជាគ្រឹះ ដើម្បីធ្វើការស្រាវជ្រាវសិក្សាស្វែងយល់ តាមអ្វីដែលហៅថាព្រះពុទ្ធវាចា (ពុទ្ធធម៌) ។ កាលដើមឡើយគេនាំគ្នា កត់ត្រាលើស្លឹករឹត ព្រមទាំងសរសេរចារឹកលើផែនថ្ម និងលើផែនលោហៈក៏មាន លុះចំណេរតមក ក៏បាននាំគ្នាបោះពុម្ពលើក្រដាសចងក្រងជាសៀវភៅ (គម្ពីរ) រហូតបច្ចុប្បន្ននេះ បច្ចេកវិជ្ជាកាន់តែ ចម្រើនឡើង គេបានវាយបញ្ចូលក្នុងកុំព្យូទ័រ តែទោះបីជាបច្ចេកទេសម៉ាស៊ីនចម្រើនឡើងយ៉ាងណា ក៏នៅមិនអាចបោះបង់សៀវភៅចោលបានឡើយ ដូច្នេះហើយទើបយើងខ្ញុំបានខិតខំធ្វើឲ្យកើតមាន ឡើងនូវក្រុមអក្សរព្រះត្រៃបិដក ដើម្បីជួយធ្វើឲ្យអក្ខរៈខ្លះដែលរលុបមិនអាចអានច្បាស់បាន ឲ្យមាន ការច្បាស់តាមតួអក្ខរៈឡើងវិញ ។

ដោយសទ្ធាជ្រះថ្លាដ៏មុតមាំដែលមានចំពោះព្រះពុទ្ធសាសនា ហើយក៏ជាកាតព្វកិច្ចមួយដ៏ធំក្នុងតួនាទីជាពុទ្ធបរិស័ទ ដែលបានប្រគល់កាយថ្វាយជីវិត អ្នកធ្វើដំណើរតាមស្នាមព្រះបាទសម្ដេចព្រះពុទ្ធអង្គ រួមកម្លាំងទ្រទ្រង់ បានធ្វើការលះបង់កម្លាំងកាយ វាចា ចិត្ត ទ្រព្យធនផ្ទាល់ ព្រមទាំងបបួលពុទ្ធបរិស័ទ ញាតិមិត្តជិតឆ្ងាយ ក្នុងនិងក្រៅប្រទេសធ្វើឡើង ដើម្បីជាពុទ្ធបូជា ធម្មបូជា សង្ឃបូជា ។

សូមសេចក្ដីឧស្សាហ៍ក្នុងការជាកុសលនេះ សម្រេចប្រយោជន៍ជូនដល់ព្រះពុទ្ធសាសនាជូនដល់ពុទ្ធបរិស័ទ សូមបានប្រកបតែនឹងសេចក្ដីសុខចម្រើនរុងរឿង ក្នុងលោកនេះផង និងលោកដទៃខាងមុខទៀតផង ជាភិយ្យោភាពតរៀងទៅ ។

វត្តបទុមជ. ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩

បួរ-គ្រី

Printed for free distribution by
**The Corporate Body of the Buddha Educational Foundation**
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Tel: 886-2-23951198 , Fax: 886-2-23913415
Email: overseas@budaedu.org
Website:http://www.budaedu.org
Mobile Web: m.budaedu.org
**This book is strictly for free distribution, it is not to be sold.**
សម្រាប់ចែកជាធម្មទាន

# សេចក្ដីណែនាំក្នុងការអាន

១) ប្រសិនបើលោកអ្នកអាន បានឃើញពាក្យទាំងឡាយណា ដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ហើយបន្ទាប់មកបានឃើញព្យញ្ជនៈមួយតួទៀតនៅខាងចុងពាក្យនោះ សូមមេត្តាកត់សម្គាល់ថា ព្យញ្ជនៈដែលនៅខាងចុងនោះ គឺជាជើងរបស់ព្យញ្ជនៈដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ដោយកំហុសបច្ចេកទេសកុំព្យូទ័រ ។

*ឧទាហរណ៍*

-ពាក្យខ្មែរ: **សម្ល** ក្នុងពាក្យនេះ ព្យញ្ជនៈ **ល** គឺជាជើងរបស់ព្យញ្ជនៈ **ម** ដូច្នេះពាក្យនេះគឺ **សម្ល** ។

-ពាក្យបាលី: **តស្ស** គឺ **តស្ស** ។

២) ចំពោះពាក្យខ្មែរ យើងសម្រេចយកតាមវចនានុក្រមខ្មែរ របស់សម្ដេចព្រះសង្ឃរាជជោតញ្ញាណោ (**ជួន-ណាត**) ជាគោល ។ ប៉ុន្តែបើពាក្យទាំងឡាយណា ដែលអាចសរសេរតាមបែបបុរាណក៏ត្រឹមត្រូវដែរនោះ យើងខ្ញុំសូមរក្សានូវពាក្យទាំងនោះទុកដដែល ។

៣) ចំពោះ **សន្ទឹកច្រាប់ពាក្យខុស-ត្រូវ** ដែលមាននៅផ្នែកខាងចុងនៃព្រះត្រៃបិដកច្បាប់ដើម ក្រុមយើងខ្ញុំសូមមិនដាក់ទៀតទេ ព្រោះក្រុមការងារយើងបានកែតម្រូវតាមនោះរួចរាល់ហើយ ។

# អភិធម្មបិដក

## វិភង្គ ទុតិយភាគ

៨១

ព. ស. ២៥០៨

# អភិធម្មបិដកេ

# វិភង្គស្ស ទុតិយោ ភាគោ

---

## បច្ចយាការវិភង្គោ

[១] អវិជ្ជាបច្ចយា សង្ខារា សង្ខារប្បច្ចយា វិញ្ញាណំ វិញ្ញាណប្បច្ចយា នាមរូបំ នាមរូបប្បច្ចយា សឡាយតនំ សឡាយតនប្បច្ចយា ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

[២] តត្ថ កតមា អវិជ្ជា ។ ទុក្ខេ អញ្ញាណំ ទុក្ខសមុទយេ អញ្ញាណំ ទុក្ខនិរោធេ អញ្ញាណំ ទុក្ខនិរោធគាមិនិយា បដិបទាយ អញ្ញាណំ អយំ វុច្ចតិ អវិជ្ជា ។

# អភិធម្មបិដក

# វិភង្គ ទុតិយភាគ

---

# បច្ចយាការវិភង្គ

[១] *សង្ខារទាំងឡាយ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ សឡាយតនៈ កើតមាន ព្រោះនាមរូបជាបច្ច័យ ផស្សៈ កើតមាន ព្រោះសឡាយតនៈជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរាមរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ ឧបាយាសៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះឯង ។*

[២] *បណ្តាបច្ចយាការទាំងនោះ អវិជ្ជា តើដូចម្តេច ។ ការមិនដឹងក្នុងទុក្ខ ការមិនដឹងក្នុងហេតុជាទីកើតឡើងនៃទុក្ខ ការមិនដឹងក្នុងធម៌ជាទីរលត់ទៅនៃទុក្ខ ការមិនដឹងក្នុងបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ នេះហៅថា អវិជ្ជា ។*

[៣] តត្ថ កតមេ អវិជ្ជាបច្ចយា សង្ខារា ។ បុញ្ញាភិសង្ខារោ អបុញ្ញាភិសង្ខារោ អានេញ្ជាភិសង្ខារោ កាយសង្ខារោ វចីសង្ខារោ ចិត្តសង្ខារោ ។ តត្ថ កតមោ បុញ្ញាភិសង្ខារោ ។ កុសលា ចេតនា កាមាវចរា រូបាវចរា ទានមយា សីលមយា ភាវនាមយា អយំ វុច្ចតិ បុញ្ញាភិសង្ខារោ ។ តត្ថ កតមោ អបុញ្ញាភិសង្ខារោ ។ អកុសលា ចេតនា កាមាវចរា អយំ វុច្ចតិ អបុញ្ញាភិសង្ខារោ ។ តត្ថ កតមោ អានេញ្ជាភិសង្ខារោ ។ កុសលា ចេតនា អរូបាវចរា អយំ វុច្ចតិ អានេញ្ជាភិសង្ខារោ ។ តត្ថ កតមោ កាយសង្ខារោ ។ កាយសញ្ចេតនា កាយសង្ខារោ វចីសញ្ចេតនា វចីសង្ខារោ មនោសញ្ចេតនា ចិត្តសង្ខារោ ។ ឥមេ វុច្ចន្តិ អវិជ្ជាបច្ចយា សង្ខារា ។

[៤] តត្ថ កតមំ សង្ខារបច្ចយា វិញ្ញាណំ ។ ចក្ខុវិញ្ញាណំ សោតវិញ្ញាណំ ឃានវិញ្ញាណំ ជិវ្ហាវិញ្ញាណំ កាយវិញ្ញាណំ មនោវិញ្ញាណំ ឥទំ វុច្ចតិ សង្ខារបច្ចយា វិញ្ញាណំ ។

[៣] បណ្ដាបច្ចយាការទាំងនោះ សង្ខារទាំងឡាយ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ តើដូចម្ដេច ។ បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ អានេញ្ជាភិសង្ខារ កាយសង្ខារ វចីសង្ខារ ចិត្តសង្ខារ ។ បណ្ដាសង្ខារទាំងនោះ បុញ្ញាភិសង្ខារ តើដូចម្ដេច ។ ចេតនាជាកុសល ជាកាមាវចរ និងរូបាវចរ ដែលសម្រេចដោយទាន សម្រេចដោយសីល សម្រេចដោយភាវនា នេះហៅថា បុញ្ញាភិសង្ខារ ។ បណ្ដាសង្ខារទាំងនោះ អបុញ្ញាភិសង្ខារ តើដូចម្ដេច ។ ចេតនាជាអកុសល ជាកាមាវចរ នេះហៅថា អបុញ្ញាភិសង្ខារ ។ បណ្ដាសង្ខារទាំងនោះ អានេញ្ជាភិសង្ខារ តើដូចម្ដេច ។ ចេតនាជាកុសល ជាអរូបាវចរ នេះហៅថា អានេញ្ជាភិសង្ខារ ។ បណ្ដាសង្ខារទាំងនោះ កាយសង្ខារ តើដូចម្ដេច ។ កាយសញ្ចេតនា ឈ្មោះថា កាយសង្ខារ វចីសញ្ចេតនា ឈ្មោះថា វចីសង្ខារ មនោសញ្ចេតនា ឈ្មោះថា ចិត្តសង្ខារ ។ ធម៌ទាំងនេះ ហៅថា សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។

[៤] បណ្ដាបច្ចយាការទាំងនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្ដេច ។ ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ មនោវិញ្ញាណ នេះហៅថា វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ ។

[៥] តត្ថ កតមំ វិញ្ញាណប្បច្ចយា នាមរូបំ ។ អត្ថិ នាមំ អត្ថិ រូបំ ។ តត្ថ កតមំ នាមំ ។ វេទនា សញ្ញា ចេតនា ផស្សោ មនសិការោ ឥទំ វុច្ចតិ នាមំ[១] ។ តត្ថ កតមំ រូបំ ។ ចត្តារោ ច មហាភូតា ចតុន្នញ្ច មហាភូតានំ ឧបាទាយ រូបំ ឥទំ វុច្ចតិ រូបំ ។ ឥតិ ឥទញ្ច នាមំ ឥទញ្ច រូបំ ឥទំ វុច្ចតិ វិញ្ញាណប្បច្ចយា នាមរូបំ ។

[៦] តត្ថ កតមំ នាមរូបប្បច្ចយា សឡាយតនំ ។ ចក្ខាយតនំ សោតាយតនំ ឃានាយតនំ ជិវ្ហាយតនំ កាយាយតនំ មនាយតនំ ឥទំ វុច្ចតិ នាមរូបប្បច្ចយា សឡាយតនំ ។

[៧] តត្ថ កតមោ សឡាយតនប្បច្ចយា ផស្សោ ។ ចក្ខុសម្ផស្សោ សោតសម្ផស្សោ ឃានសម្ផស្សោ ជិវ្ហាសម្ផស្សោ កាយសម្ផស្សោ មនោសម្ផស្សោ អយំ វុច្ចតិ សឡាយតនប្បច្ចយា ផស្សោ ។

---

១ ឱ. ម. តត្ថ កតមំ នាមំ វេទនាខន្ធោ សញ្ញាខន្ធោ សង្ខារក្ខន្ធោ ឥទំ វុច្ចតិ នាមន្តិ ឥមេ បាឋា ទិស្សន្តិ ។

បច្ចយាការវិភង្គ សុត្តន្តភាជនីយ

[៥] បណ្តាបច្ចយាការទាំងនោះ នាមរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ តើដូចម្តេច ។ នាមក៏មាន រូបក៏មាន ។ បណ្តានាមនិងរូបនោះ នាម តើដូចម្តេច ។ វេទនា សញ្ញា ចេតនា ផស្សៈ មនសិការៈ នេះហៅថា នាម ។ បណ្តានាមនិងរូបនោះ រូប តើដូចម្តេច ។ មហាភូតរូប ៤ និងរូបដែលអាស្រ័យមហាភូតទាំង ៤ នេះហៅថា រូប ។ នាមនេះផង រូបនេះផង នេះហៅថា នាមនិងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ដោយប្រការដូច្នេះ ។

[៦] បណ្តាបច្ចយាការទាំងនោះ សឡាយតនៈ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ តើដូចម្តេច ។ ចក្ខាយតនៈ សោតាយតនៈ ឃានាយតនៈ ជិវ្ហាយតនៈ កាយាយតនៈ មនាយតនៈ នេះហៅថា សឡាយតនៈ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ ។

[៧] បណ្តាបច្ចយាការទាំងនោះ ផស្សៈ កើតមាន ព្រោះសឡាយតនៈ ជាបច្ច័យ តើដូចម្តេច ។ ចក្ខុសម្ផស្ស សោតសម្ផស្ស ឃានសម្ផស្ស ជិវ្ហាសម្ផស្ស កាយសម្ផស្ស មនោសម្ផស្ស នេះហៅថា ផស្សៈ កើតមាន ព្រោះសឡាយតនៈ ជាបច្ច័យ ។

[៨] តត្ថ កតមា ផស្សប្បច្ចយា វេទនា ។ ចក្ខុ-សម្ផស្សជា វេទនា សោតសម្ផស្សជា វេទនា ឃាន-សម្ផស្សជា វេទនា ជិវ្ហាសម្ផស្សជា វេទនា កាយ-សម្ផស្សជា វេទនា មនោសម្ផស្សជា វេទនា អយំ វុច្ចតិ ផស្សប្បច្ចយា វេទនា ។

[៩] តត្ថ កតមា វេទនាបច្ចយា តណ្ហា ។ រូប-តណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វ-តណ្ហា ធម្មតណ្ហា អយំ វុច្ចតិ វេទនាបច្ចយា តណ្ហា ។

[១០] តត្ថ កតមំ តណ្ហាបច្ចយា ឧបាទានំ ។ កាមុបាទានំ ទិដ្ឋុបាទានំ សីលព្វតុបាទានំ អត្តវា-ទុបាទានំ ឥទំ វុច្ចតិ តណ្ហាបច្ចយា ឧបាទានំ ។

[១១] តត្ថ កតមោ ឧបាទានប្បច្ចយា ភវោ ។ ទុវិធេន ភវោ អត្ថិ កម្មភវោ អត្ថិ ឧបបត្តិភវោ ។ តត្ថ កតមោ កម្មភវោ ។ បុញ្ញាភិសង្ខារោ អ-បុញ្ញាភិសង្ខារោ អានេញ្ជាភិសង្ខារោ អយំ វុច្ចតិ កម្មភវោ សព្វម្បិ ភវគាមិកម្មំ កម្មភវោ ។

[៨] បណ្ដាបច្ចយាការទាំងនោះ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តើដូចម្ដេច ។ វេទនា កើតអំពីចក្ខុសម្ផស្ស វេទនា កើតអំពីសោតសម្ផស្ស វេទនា កើតអំពីឃានសម្ផស្ស វេទនា កើតអំពីជិវ្ហាសម្ផស្ស វេទនា កើតអំពីកាយសម្ផស្ស វេទនា កើតអំពីមនោសម្ផស្ស នេះហៅថា វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ។

[៩] បណ្ដាបច្ចយាការទាំងនោះ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ តើដូចម្ដេច ។ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា នេះហៅថា តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ ។

[១០] បណ្ដាបច្ចយាការទាំងនោះ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ តើដូចម្ដេច ។ កាមុបាទាន ទិដ្ឋុបាទាន សីលព្វតុបាទាន អត្តវាទុបាទាន នេះហៅថា ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ ។

[១១] បណ្ដាបច្ចយាការទាំងនោះ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ តើដូចម្ដេច ។ ភពមាន ២ គឺកម្មភពក៏មាន ឧបបត្តិភពក៏មាន ។ បណ្ដាភពទាំងនោះ កម្មភព តើដូចម្ដេច ។ បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ អានេញ្ជាភិសង្ខារ នេះហៅថា កម្មភព សូម្បីកម្មទាំងអស់ ដែលជាដំណើរទៅកាន់ភព ក៏ឈ្មោះថា កម្មភពដែរ ។

តត្ថ កតមោ ឧបបត្តិភវោ ។ កាមភវោ រូបភវោ អរូប-
ភវោ សញ្ញាភវោ អសញ្ញាភវោ នេវសញ្ញានាសញ្ញាភវោ
ឯកវោការភវោ ចតុវោការភវោ បញ្ចវោការភវោ
អយំ វុច្ចតិ ឧបបត្តិភវោ ។ ឥតិ អយញ្ច កម្មភវោ
អយញ្ច ឧបបត្តិភវោ អយំ វុច្ចតិ ឧបាទានប្បច្ចយា
ភវោ ។

[១២] តត្ថ កតមា ភវប្បច្ចយា ជាតិ ។ យា តេសំ
តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជាតិ សញ្ជាតិ
ឱក្កន្តិ អភិនិព្វត្តិ ខន្ធានំ ធាតុភាវោ អាយតនានំ
បដិលាភោ អយំ វុច្ចតិ ភវប្បច្ចយា ជាតិ ។

[១៣] តត្ថ កតមំ ជាតិប្បច្ចយា ជរាមរណំ ។
អត្ថិ ជរា អត្ថិ មរណំ ។ តត្ថ កតមា ជរា ។

បណ្តាភពទាំងនោះ ឧបបត្តិភព តើដូចម្តេច ។ កាមភព រូបភព អរូបភព សញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព ឯកវោការ[១]ភព ចតុវោការ[២]ភព បញ្ចវោការ[៣]ភព នេះហៅថា ឧបបត្តិភព ។ កម្មភពនេះផង ឧបបត្តិភពនេះផង នេះហៅថា ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ដោយប្រការដូច្នេះ ។

[១២] បណ្តាបច្ចយាការទាំងនោះ ជាតិ កើតមាន ព្រោះភពជាបច្ច័យ តើដូចម្តេច ។ ការកើត ការកើតព្រម ការចាប់កំណើត ការកើតចំពោះ ការកើតប្រាកដនៃខន្ធទាំងឡាយ ការបានចំពោះនូវអាយតនៈទាំងឡាយ ណា របស់សត្វទាំងឡាយនោះ ៗ ក្នុងសត្តនិកាយនោះ ៗ នេះហៅថា ជាតិ កើតមាន ព្រោះភពជាបច្ច័យ ។

[១៣] បណ្តាបច្ចយាការទាំងនោះ ជរានិងមរណៈកើតមាន ព្រោះជាតិជាបច្ច័យ តើដូចម្តេច ។ ជរាក៏មាន មរណៈក៏មាន ។ បណ្តាជរានិងមរណៈ

---

១ ភពមានខន្ធ ១ គឺអសញ្ញិភព ។ ២ ភពនោះមានខន្ធ ៤ គឺអរូបភព ។ ៣ ភពមានខន្ធ ៥ គឺភពដ៏សេសក្រៅអំពីភព ២ ប្រការនេះ ។ អដ្ឋកថា (ព្រះសូត្រ) ។

យា តេសំ តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជរា ជីរណតា ខណ្ឌិច្ចំ បាលិច្ចំ វលិត្តចតា អាយុនោ សំហានិ ឥន្ទ្រិយានំ បរិបាកោ អយំ វុច្ចតិ ជរា ។ តត្ថ កតមំ មរណំ ។ យា តេសំ តេសំ សត្តានំ តម្ហា តម្ហា សត្តនិកាយា ចុតិ ចវនតា ភេទោ អន្តរធានំ មច្ចុ មរណំ កាលកិរិយា ខន្ធានំ ភេទោ កឡេវរស្ស និក្ខេបោ ជីវិតិន្ទ្រិយស្ស ឧបច្ឆេទោ ឥទំ វុច្ចតិ មរណំ ។ ឥតិ អយញ្ច ជរា ឥទញ្ច មរណំ ឥទំ វុច្ចតិ ជាតិប្បច្ចយា ជរាមរណំ ។

[១៤] តត្ថ កតមោ សោកោ ។ ញាតិព្យសនេន វា ផុដ្ឋស្ស ភោគព្យសនេន វា ផុដ្ឋស្ស រោគព្យសនេន វា ផុដ្ឋស្ស សីលព្យសនេន វា ផុដ្ឋស្ស ទិដ្ឋិព្យសនេន វា ផុដ្ឋស្ស អញ្ញតរញ្ញតរេន ព្យសនេន សមន្នាគតស្ស អញ្ញតរញ្ញតរេន ទុក្ខធម្មេន ផុដ្ឋស្ស សោកោ សោចនា សោចិតត្តំ អន្តោសោកោ អន្តោបរិសោកោ ចេតសោ បរិជ្ឈាយនា ទោមនស្សំ សោកសល្លំ អយំ វុច្ចតិ សោកោ ។

នោះ ជរា តើដូចម្តេច ។ សេចក្តីចាស់ គ្រាំគ្រា ធ្មេញបាក់ សក់ស្កូវ ស្បែកជ្រួញជ្រីវ ការរួញថយនៃអាយុ ការចាស់ទុំនៃឥន្ទ្រិយទាំងឡាយ ណា របស់សត្វទាំងឡាយនោះ ៗ ក្នុងសត្តនិកាយនោះ ៗ នេះហៅថា ជរា ។ បណ្តាជរានិងមរណៈនោះ មរណៈ តើដូចម្តេច ។ ការច្យុត ការឃ្លាត ការបែកធ្លាយ ការបាត់បង់ មច្ចុ មរណៈ កាលកិរិយា ការបែកធ្លាយនៃខន្ធទាំងឡាយ ការដាក់ចុះនូវសាកសព ការផ្តាច់ផ្តិល នូវជីវិតិន្ទ្រិយ ណា ចាកសត្តនិកាយនោះ ៗ របស់សត្វទាំងឡាយ នោះៗ នេះហៅថា មរណៈ ។ ជរានេះឯង មរណៈនេះឯង នេះហៅថា ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ដោយប្រការដូច្នេះ ។

[១៤] បណ្តាបច្ចយាការទាំងនោះ សោកៈ តើដូចម្តេច ។ សេចក្តីសោក អាការសោក ភាពនៃសេចក្តីសោក ការស្ងួតស្ងប់ខាង ក្នុង ការក្រៀមក្រំខាងក្នុង ការជ្រប់ស្រពោននៃចិត្ត ការតូចចិត្ត សរគឺ សេចក្តីសោក របស់បុគ្គលដែលត្រូវសេចក្តីវិនាសញាតិ ប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសភោគៈ ប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសគឺរោគប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសសីលប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសគឺទិដ្ឋិប៉ះពាល់ក្តី ឬប្រ-កបដោយសេចក្តីវិនាសណាមួយ ឬត្រូវទុក្ខធម៌ណាមួយប៉ះពាល់ហើយ នេះហៅថា សោកៈ ។

បច្ចយាការវិភង្គេ សុត្តន្តភាជនីយំ

[១៥] តត្ថ កតមោ បរិទេវោ ។ ញាតិព្យ-សនេន វា ផុដ្ឋស្ស ភោគព្យសនេន វា ផុដ្ឋស្ស រោគព្យសនេន វា ផុដ្ឋស្ស សីលព្យសនេន វា ផុដ្ឋស្ស ទិដ្ឋិព្យសនេន វា ផុដ្ឋស្ស អញ្ញតរញ្ញតរេន ព្យសនេន សមន្នាគតស្ស អញ្ញតរញ្ញតរេន ទុក្ខ-ធម្មេន ផុដ្ឋស្ស អាទេវោ បរិទេវោ អាទេវនា បរិ-ទេវនា អាទេវិតត្តំ បរិទេវិតត្តំ វាចា បលាបោ វិប្ប-លាបោ លាលប្បោ លាលប្បនា លាលប្បិតត្តំ អយំ វុច្ចតិ បរិទេវោ ។

[១៦] តត្ថ កតមំ ទុក្ខំ ។ យំ កាយិកំ អសាតំ កាយិកំ ទុក្ខំ កាយសម្ផស្សជំ អសាតំ ទុក្ខំ វេទយិតំ កាយសម្ផស្សជា អសាតា ទុក្ខា វេទនា ឥទំ វុច្ចតិ ទុក្ខំ ។

[១៧] តត្ថ កតមំ ទោមនស្សំ ។ យំ ចេត-សិកំ អសាតំ ចេតសិកំ ទុក្ខំ ចេតោសម្ផស្សជំ អសាតំ ទុក្ខំ វេទយិតំ ចេតោសម្ផស្សជា អសាតា ទុក្ខា វេទនា ឥទំ វុច្ចតិ ទោមនស្សំ ។

[១៥] បណ្តាបច្ចយាការទាំងនោះ បរិទេវៈ តើដូចម្តេច ។ សេចក្តីខ្សឹកខ្សួល ការទួញយំ អាការខ្សឹកខ្សួល អាការទួញយំ ភាពខ្សឹកខ្សួល ភាពទួញយំ ការពោល ការយំរៀបរាប់ ការយំអណ្តឺតអណ្តក ការពោលដដែល ៗ អាការពោលដដែល ៗ ភាពពោលដដែល ៗ របស់បុគ្គលដែលត្រូវសេចក្តីវិនាសញាតិ ប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសភោគៈប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសគឺរោគប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសសីលប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសគឺទិដ្ឋិប៉ះពាល់ក្តី ឬប្រកបដោយសេចក្តីវិនាសណាមួយ ឬក៏ត្រូវទុក្ខធម៌ណាមួយប៉ះពាល់ហើយ នេះហៅថា បរិទេវៈ ។

[១៦] បណ្តាបច្ចយាការទាំងនោះ ទុក្ខៈ តើដូចម្តេច ។ សេចក្តីមិនត្រេកអរប្រព្រឹត្តទៅក្នុងកាយ ទុក្ខប្រព្រឹត្តទៅក្នុងកាយ ការទទួលអារម្មណ៍មិនជាទីត្រេកអរ ដែលកើតអំពីកាយសម្ផស្ស វេទនា មិនជាទីត្រេកអរ ជាទុក្ខដែលកើតអំពីកាយសម្ផស្ស ណា នេះហៅថា ទុក្ខៈ ។

[១៧] បណ្តាបច្ចយាការទាំងនោះ ទោមនស្សៈ តើដូចម្តេច ។ សេចក្តីមិនត្រេកអរប្រព្រឹត្តទៅក្នុងចិត្ត ទុក្ខប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍មិនជាទីត្រេកអរ ជាទុក្ខដែលកើតអំពីចេតោសម្ផស្ស វេទនាមិនជាទីត្រេកអរ ជាទុក្ខដែលកើតអំពីចេតោសម្ផស្សណានេះហៅថាទោមនស្សៈ ។

[១៨] តត្ថ កតមោ ឧបាយាសោ ។ ញាតិព្យ-សនេន វា ផុដ្ឋស្ស ភោគព្យសនេន វា ផុដ្ឋស្ស រោគ-ព្យសនេន វា ផុដ្ឋស្ស សីលព្យសនេន វា ផុដ្ឋស្ស ទិដ្ឋិព្យសនេន វា ផុដ្ឋស្ស អញ្ញតរញ្ញតរេន ព្យសនេន សមន្នាគតស្ស អញ្ញតរញ្ញតរេន ទុក្ខធម្មេន ផុដ្ឋស្ស អាយាសោ ឧបាយាសោ អាយាសិតត្តំ ឧបាយា-សិតត្តំ អយំ វុច្ចតិ ឧបាយាសោ ។

[១៩] ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតីតិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សង្គតិ ហោតិ សមាគមោ ហោតិ សមោធានំ ហោតិ បាតុភាវោ ហោតិ តេន វុច្ចតិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតីតិ ។

សុត្តន្តភាជនីយំ ។

[២០] អវិជ្ជាបច្ចយា សង្ខារា សង្ខារប្បច្ចយា វិញ្ញាណំ វិញ្ញាណប្បច្ចយា នាមំ នាមប្បច្ចយា ឆ-ដ្ឋាយតនំ ឆដ្ឋាយតនប្បច្ចយា ផស្សោ ផស្សប្បច្ចយា

[១៨] បណ្ដាបច្ចយាការទាំងនោះ ឧបាយាសៈ តើដូចម្ដេច ។ សេចក្ដីតានតឹងចិត្ត សេចក្ដីចង្អៀតចង្អល់ចិត្ត ភាពតានតឹងចិត្ត ភាពចង្អៀតចង្អល់ចិត្ត របស់បុគ្គល ដែលត្រូវសេចក្ដីវិនាសញាតិប៉ះពាល់ក្ដី ត្រូវសេចក្ដីវិនាសភោគៈប៉ះពាល់ក្ដី ត្រូវសេចក្ដីវិនាសគឺរោគប៉ះពាល់ក្ដី ត្រូវសេចក្ដីវិនាសសីលប៉ះពាល់ក្ដី ត្រូវសេចក្ដីវិនាសគឺទិដ្ឋិប៉ះពាល់ក្ដី ឬប្រកបដោយសេចក្ដីវិនាសណាមួយ ឬក៏ត្រូវទុក្ខធម៌ណាមួយប៉ះពាល់ហើយ នេះហៅថា ឧបាយាសៈ ។

[១៩] ត្រង់ពាក្យថា ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ គឺការជួបជុំ ការមូលមក ការប្រជុំចុះ ការកើតប្រាកដ នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ព្រោះហេតុនោះ ទើបលោកពោលថា ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះឯង ។

ចប់ សុត្តន្តភាជនីយ ។

[២០] សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈកើតមាន ព្រោះអាយតនៈទី ៦ ជា

វេទនា វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

[២១] អវិជ្ជាបច្ចយា សង្ខារោ សង្ខារប្បច្ចយា វិញ្ញាណំ វិញ្ញាណប្បច្ចយា នាមំ នាមប្បច្ចយា ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ ឯវមេ-តស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

[២២] អវិជ្ជាបច្ចយា សង្ខារោ សង្ខារ-ប្បច្ចយា វិញ្ញាណំ វិញ្ញាណប្បច្ចយា នាមរូបំ នាមរូបប្បច្ចយា ឆដ្ឋាយតនំ ឆដ្ឋាយតនប្បច្ចយា ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា

បច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[២១] សង្ខារកើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ផស្សៈ កើតមាន ព្រោះនាមជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[២២] សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមនិងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ

តណ្ហា តណ្ហាបច្ចយា ឧបាទានំ ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

[២៣] អវិជ្ជាបច្ចយា សង្ខារោ សង្ខារប្បច្ចយា វិញ្ញាណំ វិញ្ញាណប្បច្ចយា នាមរូបំ នាមរូប-ប្បច្ចយា សឡាយតនំ សឡាយតនប្បច្ចយា ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ ឯវ-មេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

បច្ចយចតុក្កំ ។

[២៤] អវិជ្ជាបច្ចយា សង្ខារោ អវិជ្ជាហេតុកោ សង្ខារប្បច្ចយា វិញ្ញាណំ សង្ខារហេតុកំ វិញ្ញា-ណប្បច្ចយា នាមំ វិញ្ញាណហេតុកំ នាមប្បច្ចយា ឆដ្ឋាយតនំ នាមហេតុកំ ឆដ្ឋាយតនប្បច្ចយា

តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[២៣] សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមនិងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈ ៦ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈ ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

ចប់ បច្ចយចតុក្កៈ ។

[២៤] សង្ខារមានអវិជ្ជាជាហេតុ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណមានសង្ខារជាហេតុ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមមានវិញ្ញាណជាហេតុ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ មាននាមជាហេតុ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ មានអាយតនៈ ទី ៦

ផស្សោ ឆដ្ឋាយតនហេតុកោ ផស្សប្បច្ចយា វេទនា ផស្សហេតុកា វេទនាបច្ចយា តណ្ហា វេទនាហេតុ-កា តណ្ហាបច្ចយា ឧបាទានំ តណ្ហាហេតុកំ ឧបា-ទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ច-យា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខ-ន្ធស្ស សមុទយោ ហោតិ ។

[២៨] អវិជ្ជាបច្ចយា សង្ខារោ អវិជ្ជាហេតុកោ សង្ខារប្បច្ចយា វិញ្ញាណំ សង្ខារហេតុកំ វិញ្ញាណ-ប្បច្ចយា នាមំ វិញ្ញាណហេតុកំ នាមប្បច្ចយា ផស្សោ នាមហេតុកោ ផស្សប្បច្ចយា វេទនា ផស្សហេតុកា វេទនាបច្ចយា តណ្ហា វេទនាហេតុកា តណ្ហាបច្ចយា ឧបាទានំ តណ្ហាហេតុកំ ឧបាទា-នប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

ជាហេតុ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនាមានផស្សៈជាហេតុ កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាមានវេទនាជាហេតុ កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទាន មានតណ្ហាជាហេតុ កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[២៥] សង្ខារ មានអវិជ្ជាជាហេតុ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណមានសង្ខារជាហេតុ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមមានវិញ្ញាណជាហេតុ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ផស្សៈមាននាមជាហេតុ កើតមាន ព្រោះនាមជាបច្ច័យ វេទនាមានផស្សៈជាហេតុ កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាមានវេទនាជាហេតុ កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទាន មានតណ្ហាជាហេតុ កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[២៦] អវិជ្ជាបច្ចយា សង្ខារា អវិជ្ជាហេតុកោ សង្ខារប្បច្ចយា វិញ្ញាណំ សង្ខារហេតុកំ វិញ្ញាណប្ប-ច្ចយា នាមរូបំ វិញ្ញាណហេតុកំ នាមរូបប្បច្ចយា ឆដ្ឋាយតនំ នាមរូបហេតុកំ ឆដ្ឋាយតនប្បច្ចយា ផស្សោ ឆដ្ឋាយតនហេតុកោ ផស្សប្បច្ចយា វេទនា ផស្សហេតុកា វេទនាបច្ចយា តណ្ហា វេទនាហេតុ-កា តណ្ហាបច្ចយា ឧបាទានំ តណ្ហាហេតុកំ ឧបា-ទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្ប-ច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខ-ន្ធស្ស សមុទយោ ហោតិ ។

[២៧] អវិជ្ជាបច្ចយា សង្ខារា អវិជ្ជាហេតុកោ សង្ខារប្បច្ចយា វិញ្ញាណំ សង្ខារហេតុកំ វិញ្ញាណ-ប្បច្ចយា នាមរូបំ វិញ្ញាណហេតុកំ នាមរូប-ប្បច្ចយា សឡាយតនំ នាមរូបហេតុកំ សឡាយ-តនប្បច្ចយា ផស្សោ សឡាយតនហេតុកោ ផស្ស-ប្បច្ចយា វេទនា ផស្សហេតុកា វេទនាបច្ចយា

[២៦] សង្ខារមានអវិជ្ជាជាហេតុ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ មានសង្ខារជាហេតុ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមនិងរូប មានវិញ្ញាណជាហេតុ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈ ទី ៦ មាននាមនិងរូបជាហេតុ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ ផស្សៈ មានអាយតនៈ ទី ៦ ជាហេតុ កើតមាន ព្រោះអាយតនៈ ទី ៦ ជាបច្ច័យ វេទនា មានផស្សៈជាហេតុ កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហា មានវេទនាជាហេតុ កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទាន មានតណ្ហាជាហេតុ កើតមាន ព្រោះតណ្ហាជាបច្ច័យ ភពកើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[២៧] សង្ខារ មានអវិជ្ជាជាហេតុ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ មានសង្ខារជាហេតុ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមនិងរូប មានវិញ្ញាណជាហេតុ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈ ៦ មាននាមនិងរូបជាហេតុ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ ផស្សៈ មានអាយតនៈ ៦ ជាហេតុ កើតមាន ព្រោះអាយតនៈ ៦ ជាបច្ច័យ វេទនា មានផស្សៈជាហេតុ កើតមាន ព្រោះផស្សៈជាបច្ច័យ

តណ្ហា វេទនាហេតុកា តណ្ហាបច្ចយា ឧបាទានំ តណ្ហាហេតុកំ ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ

ហេតុចតុក្កំ ។

[២៨] អវិជ្ជាបច្ចយា សង្ខារោ អវិជ្ជាសម្បយុត្តោ សង្ខារប្បច្ចយា វិញ្ញាណំ សង្ខារសម្បយុត្តំ វិញ្ញាណប្បច្ចយា នាមំ វិញ្ញាណសម្បយុត្តំ នាមប្បច្ចយា ឆដ្ឋាយតនំ នាមសម្បយុត្តំ ឆដ្ឋាយតនប្បច្ចយា ផស្សោ ឆដ្ឋាយតនសម្បយុត្តោ ផស្សប្បច្ចយា វេទនា ផស្សសម្បយុត្តា វេទនាបច្ចយា តណ្ហា វេទនាសម្បយុត្តា តណ្ហាបច្ចយា ឧបាទានំ តណ្ហាសម្បយុត្តំ ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

តណ្ហា មានវេទនាជាហេតុ កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទាន មានតណ្ហាជាហេតុ កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិង មរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកង ទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

ចប់ ហេតុចតុក្កៈ ។

[២៨] សង្ខារ ប្រកបដោយអវិជ្ជា កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណប្រកបដោយសង្ខារ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមប្រកបដោយវិញ្ញាណ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ ប្រកបដោយនាម កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈប្រកបដោយ អាយតនៈទី ៦ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនាប្រកប ដោយផស្សៈ កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាប្រកបដោយវេទនា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានប្រកបដោយតណ្ហា កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើត មាន ព្រោះភពជាបច្ច័យ ជរានិងមរណៈកើតមាន ព្រោះជាតិជាបច្ច័យ ហេតុ ជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមានដោយអាការយ៉ាងនេះ ។

[២៩] អវិជ្ជាបច្ចយា សង្ខារោ អវិជ្ជាសម្បយុត្តោ សង្ខារប្បច្ចយា វិញ្ញាណំ សង្ខារសម្បយុត្តំ វិញ្ញាណប្បច្ចយា នាមំ វិញ្ញាណសម្បយុត្តំ នាមប្បច្ចយា ផស្សោ នាមសម្បយុត្តោ ផស្សប្បច្ចយា វេទនា ផស្សសម្បយុត្តា វេទនាបច្ចយា តណ្ហា វេទនាសម្បយុត្តា តណ្ហាបច្ចយា ឧបាទានំ តណ្ហាសម្បយុត្តំ ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

[៣០] អវិជ្ជាបច្ចយា សង្ខារោ អវិជ្ជាសម្បយុត្តោ សង្ខារប្បច្ចយា វិញ្ញាណំ សង្ខារសម្បយុត្តំ វិញ្ញាណប្បច្ចយា នាមរូបំ វិញ្ញាណសម្បយុត្តំ នាមរូបប្បច្ចយា ឆដ្ឋាយតនំ នាមរូបសម្បយុត្តំ ឆដ្ឋាយតនប្បច្ចយា ផស្សោ ឆដ្ឋាយតនសម្បយុត្តោ ផស្សប្បច្ចយា វេទនា ផស្សសម្បយុត្តា វេទនាបច្ចយា តណ្ហា វេទនាសម្បយុត្តា តណ្ហាបច្ចយា ឧបាទានំ តណ្ហាសម្បយុត្តំ ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា

[២៩] សង្ខារប្រកបដោយអវិជ្ជា កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណប្រកបដោយសង្ខារ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមប្រកបដោយវិញ្ញាណ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ផស្សៈ ប្រកបដោយនាម កើតមាន ព្រោះនាមជាបច្ច័យ វេទនាប្រកបដោយផស្សៈ កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាប្រកបដោយវេទនា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានប្រកបដោយតណ្ហា កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[៣០] សង្ខារប្រកបដោយអវិជ្ជា កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណប្រកបដោយសង្ខារ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមនិងរូបប្រកបដោយវិញ្ញាណ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ ប្រកបដោយនាមនិងរូប កើតមាន ព្រោះនាមនិងរូបជាបច្ច័យ ផស្សៈប្រកបដោយអាយតនៈទី ៦ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនាប្រកបដោយផស្សៈ កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាប្រកបដោយវេទនា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានប្រកបដោយតណ្ហា កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ

ជាតិ ជាតិប្បច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

[៣១] អវិជ្ជាបច្ចយា សង្ខារោ អវិជ្ជាសម្បយុត្តោ សង្ខារប្បច្ចយា វិញ្ញាណំ សង្ខារសម្បយុត្តំ វិញ្ញាណប្បច្ចយា នាមរូបំ វិញ្ញាណសម្បយុត្តំ នាមំ នាមរូបប្បច្ចយា សឡាយតនំ នាមសម្បយុត្តំ សឡាយតនប្បច្ចយា ផស្សោ សឡាយតនសម្បយុត្តោ ផស្សប្បច្ចយា វេទនា ផស្សសម្បយុត្តា វេទនាបច្ចយា តណ្ហា វេទនាសម្បយុត្តា តណ្ហាបច្ចយា ឧបាទានំ តណ្ហាសម្បយុត្តំ ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

សម្បយុត្តចតុក្កំ ។

[៣២] អវិជ្ជាបច្ចយា សង្ខារោ សង្ខារប្បច្ចយាបិ អវិជ្ជា សង្ខារប្បច្ចយា វិញ្ញាណំ វិញ្ញាណប្បច្ចយាបិ សង្ខារោ វិញ្ញាណប្បច្ចយា នាមំ នាមប្បច្ចយាបិ

ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[៣១] សង្ខារប្រកបដោយអវិជ្ជា កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណប្រកបដោយសង្ខារ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមនិងរូបប្រកបដោយវិញ្ញាណ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ នាមនិងអាយតនៈ ៦ ប្រកបដោយនាម កើតមាន ព្រោះនាមនិងរូបជាបច្ច័យ ផស្សៈប្រកបដោយអាយតនៈ ៦ កើតមាន ព្រោះអាយតនៈ ៦ ជាបច្ច័យ វេទនា ប្រកបដោយផស្សៈ កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាប្រកបដោយវេទនា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានប្រកបដោយតណ្ហា កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

ចប់ សម្បយុត្តចតុក្ក ។

[៣២] សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ អវិជ្ជា កើតមាន ព្រោះសង្ខារជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ សង្ខារ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ

វិញ្ញាណំ នាមប្បច្ចយា ឆដ្ឋាយតនំ ឆដ្ឋាយតនប្បច្ចយាបិ នាមំ ឆដ្ឋាយតនប្បច្ចយា ផស្សោ ផស្សប្បច្ចយាបិ ឆដ្ឋាយតនំ ផស្សប្បច្ចយា វេទនា វេទនាបច្ចយាបិ ផស្សោ វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយាបិ វេទនា តណ្ហាបច្ចយា ឧបាទានំ ឧបាទានប្បច្ចយាបិ តណ្ហា ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

[៣៣] អវិជ្ជាបច្ចយា សង្ខារោ សង្ខារប្បច្ចយាបិ អវិជ្ជា សង្ខារប្បច្ចយា វិញ្ញាណំ វិញ្ញាណប្បច្ចយាបិ សង្ខារោ វិញ្ញាណប្បច្ចយា នាមំ នាមប្បច្ចយាបិ វិញ្ញាណំ នាមប្បច្ចយា ផស្សោ ផស្សប្បច្ចយាបិ នាមំ ផស្សប្បច្ចយា វេទនា វេទនាបច្ចយាបិ ផស្សោ វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយាបិ វេទនា តណ្ហាបច្ចយា ឧបាទានំ

វិញ្ញាណ កើតមាន ព្រោះនាមជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ នាម កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះផស្សៈ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ផស្សៈ កើតមាន ព្រោះវេទនាជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ វេទនា កើតមាន ព្រោះតណ្ហាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ តណ្ហា កើតមាន ព្រោះឧបាទានជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[៣៣] សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ អវិជ្ជា កើតមាន ព្រោះសង្ខារជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ សង្ខារ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះនាមជាបច្ច័យ នាម កើតមាន ព្រោះផស្សៈជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ផស្សៈ កើតមាន ព្រោះវេទនាជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ វេទនា កើតមាន ព្រោះតណ្ហាជាបច្ច័យ ឧបាទាន កើតមាន

ឧបាទានប្បច្ចយាបិ តណ្ហា ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

[៣៤] អវិជ្ជាបច្ចយា សង្ខារោ សង្ខារប្បច្ចយាបិ អវិជ្ជា សង្ខារប្បច្ចយា វិញ្ញាណំ វិញ្ញាណប្បច្ចយាបិ សង្ខារោ វិញ្ញាណប្បច្ចយា នាមរូបំ នាមរូបប្បច្ចយាបិ វិញ្ញាណំ នាមរូបប្បច្ចយា ឆដ្ឋាយតនំ ឆដ្ឋាយតនប្ប-ច្ចយាបិ នាមរូបំ ឆដ្ឋាយតនប្បច្ចយា ផស្សោ ផស្ស-ប្បច្ចយាបិ ឆដ្ឋាយតនំ ផស្សប្បច្ចយា វេទនា វេទ-នាបច្ចយាបិ ផស្សោ វេទនាបច្ចយា តណ្ហា តណ្ហា-បច្ចយាបិ វេទនា តណ្ហាបច្ចយា ឧបាទានំ ឧបា-ទានប្បច្ចយាបិ តណ្ហា ឧបាទានប្បច្ចយា ភវោ ភវ-ប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

ព្រោះតណ្ហាជាបច្ច័យ តណ្ហា កើតមាន ព្រោះឧបាទានជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[៣៤] សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ អវិជ្ជា កើតមាន ព្រោះសង្ខារជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ សង្ខារ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ នាមនិងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ នាមនិងរូបកើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈ ទី ៦ ជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះផស្សៈ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈ ជាបច្ច័យ ផស្សៈ កើតមាន ព្រោះវេទនាជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ វេទនា កើតមាន ព្រោះតណ្ហាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ តណ្ហា កើតមាន ព្រោះឧបា-ទានជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈកើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[៣៥] អវិជ្ជាបច្ចយា សង្ខារោ សង្ខារប្បច្ចយាបិ អវិជ្ជា សង្ខារប្បច្ចយា វិញ្ញាណំ វិញ្ញាណប្បច្ចយាបិ សង្ខារោ វិញ្ញាណប្បច្ចយា នាមរូបំ នាមរូបប្បច្ចយាបិ វិញ្ញាណំ នាមរូបប្បច្ចយា សឡាយតនំ សឡាយតនប្បច្ចយាបិ នាមរូបំ សឡាយតនប្បច្ចយា ផស្សោ ផស្សប្បច្ចយាបិ សឡាយតនំ ផស្សប្បច្ចយា វេទនា វេទនាបច្ចយាបិ ផស្សោ វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយាបិ វេទនា តណ្ហាបច្ចយា ឧបាទានំ ឧបាទានប្បច្ចយាបិ តណ្ហា ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

អញ្ញមញ្ញចតុក្កំ ។

[៣៦] សង្ខារប្បច្ចយា អវិជ្ជា ។ បេ ។ វិញ្ញាណប្បច្ចយា អវិជ្ជា ។ បេ ។ នាមប្បច្ចយា អវិជ្ជា ។ បេ ។ ឆដ្ឋាយតនប្បច្ចយា អវិជ្ជា ។ បេ ។

[៣៥] សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ អវិជ្ជា កើតមាន ព្រោះសង្ខារជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ សង្ខារ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ នាមនិងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ អាយតនៈ ៦ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ នាមនិងរូប កើតមាន ព្រោះអាយតនៈ ៦ ជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈ ៦ ជាបច្ច័យ អាយតនៈ ៦ កើតមាន ព្រោះផស្សៈជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ផស្សៈ កើតមាន ព្រោះវេទនាជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ វេទនាកើតមាន ព្រោះតណ្ហាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ តណ្ហា កើតមាន ព្រោះឧបាទានជាបច្ច័យ ភពកើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

ចប់ អញ្ញមញ្ញចតុក្កៈ ។

[៣៦] អវិជ្ជា កើតមាន ព្រោះសង្ខារជាបច្ច័យ ។ បេ ។ អវិជ្ជា កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ។ បេ ។ អវិជ្ជា កើតមាន ព្រោះនាមជាបច្ច័យ ។ បេ ។ អវិជ្ជា កើតមាន ព្រោះអាយតនៈ ៦ ជាបច្ច័យ ។ បេ ។

ផស្សប្បច្ចយា អវិជ្ជា ។ បេ ។ វេទនាបច្ចយា អវិជ្ជា ។ បេ ។ តណ្ហាបច្ចយា អវិជ្ជា ។ បេ ។ ឧបាទានប្បច្ចយា អវិជ្ជា ។ បេ ។ អវិជ្ជាបច្ចយា សង្ខារោ សង្ខារប្បច្ចយា វិញ្ញាណំ វិញ្ញាណប្បច្ចយា នាមរូបំ នាមរូបប្បច្ចយា សឡាយតនំ សឡាយតនប្បច្ចយា ផស្សោ ផស្ស-ប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

មាតិកា ។

[៣៧] កតមេ ធម្មា អកុសលា ។ យស្មឹ សមយេ អកុសលំ ចិត្តំ ឧប្បន្នំ ហោតិ សោមនស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ រូបារម្មណំ វា សទ្ទារម្មណំ វា គន្ធា-រម្មណំ វា រសារម្មណំ វា ផោដ្ឋព្វារម្មណំ វា ធម្មារម្មណំ វា យំ យំ វា បនារព្ភ តស្មឹ សមយេ អវិជ្ជាបច្ចយា សង្ខារោ សង្ខារប្បច្ចយា វិញ្ញាណំ វិញ្ញាណប្បច្ចយា

*អវិជ្ជា កើតមាន ព្រោះផស្សៈជាបច្ច័យ ។ បេ ។ អវិជ្ជា កើតមាន ព្រោះវេទនាជាបច្ច័យ ។ បេ ។ អវិជ្ជា កើតមាន ព្រោះតណ្ហាជាបច្ច័យ ។ បេ ។ អវិជ្ជា កើតមាន ព្រោះឧបាទានជាបច្ច័យ ។ បេ ។ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមនិងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈ ៦ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈ ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។*

ចប់ មាតិកា ។

[៣៧] *ធម៌ទាំងឡាយ ជាអកុសល តើដូចម្តេច ។ ក្នុងសម័យណា អកុសលចិត្ត ដែលប្រកបដោយសោមនស្ស ប្រកបដោយទិដ្ឋិ មានរូបជាអារម្មណ៍ក្តី មានសំឡេងជាអារម្មណ៍ក្តី មានក្លិនជាអារម្មណ៍ក្តី មានរសជាអារម្មណ៍ក្តី មានផ្សព្វជាអារម្មណ៍ក្តី មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណា ៗ ហើយកើតឡើង ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ*

ជាមំ ជាមប្បច្ចយា ឆដ្ឋាយតនំ ឆដ្ឋាយតនប្បច្ចយា ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ ឧបាទានប្បច្ចយា ភវោ ភវ-ប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

[៣៨] តត្ថ កតមា អវិជ្ជា ។ យំ អញ្ញាណំ អទស្សនំ ។ បេ ។ អវិជ្ជាលង្គី មោហោ អកុសល-មូលំ អយំ វុច្ចតិ អវិជ្ជា ។

[៣៩] តត្ថ កតមោ អវិជ្ជាបច្ចយា សង្ខារោ ។ យា ចេតនា សញ្ចេតនា សញ្ចេតយិតត្តំ អយំ វុច្ចតិ អវិជ្ជាបច្ចយា សង្ខារោ ។

[៤០] តត្ថ កតមំ សង្ខារប្បច្ចយា វិញ្ញាណំ ។ យំ ចិត្តំ មនោ មានសំ ហទយំ បណ្ឌរំ មនោ មនាយតនំ មនិន្ទ្រិយំ វិញ្ញាណំ វិញ្ញាណក្ខន្ធោ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ សង្ខារប្បច្ចយា វិញ្ញាណំ ។

នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[៣៨] បណ្ដាបច្ចយាការទាំងនោះ អវិជ្ជា តើដូចម្ដេច ។ ការមិនដឹង មិនឃើញ ។ បេ ។ គន្លឹះគឺអវិជ្ជា មោហៈជាអកុសលមូល ណា នេះហៅថា អវិជ្ជា ។

[៣៩] បណ្ដាបច្ចយាការទាំងនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ តើដូចម្ដេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ (នូវអារម្មណ៍) ណា នេះហៅថា សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។

[៤០] បណ្ដាបច្ចយាការទាំងនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្ដេច ។ ចិត្តៈ សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ហទយៈ ធម្មជាតដ៏ផូរផង់ (គឺភវង្គចិត្ត) ហៅថា មនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ ណា នេះហៅថា វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ ។

[៤១] តត្ថ កតមំ វិញ្ញាណប្បច្ចយា នាមំ ។ វេទនាខន្ធោ សញ្ញាខន្ធោ សង្ខារក្ខន្ធោ ឥទំ វុច្ចតិ វិញ្ញាណប្បច្ចយា នាមំ ។

[៤២] តត្ថ កតមំ នាមប្បច្ចយា ឆដ្ឋាយ-តនំ ។ យំ ចិត្តំ មនោ មានសំ ហទយំ បណ្ឌរំ មនោ មនាយតនំ មនិន្ទ្រិយំ វិញ្ញាណំ វិញ្ញាណក្ខន្ធោ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ នាមប្បច្ចយា ឆដ្ឋាយតនំ ។

[៤៣] តត្ថ កតមោ ឆដ្ឋាយតនប្បច្ចយា ផស្សោ ។ យោ ផស្សោ ផុសនា សម្ផុសនា សម្ផុសិតត្តំ អយំ វុច្ចតិ ឆដ្ឋាយតនប្បច្ចយា ផស្សោ ។

[៤៤] តត្ថ កតមា ផស្សប្បច្ចយា វេទនា ។ យំ ចេតសិកំ សាតំ ចេតសិកំ សុខំ ចេតោ-សម្ផស្សជំ សាតំ សុខំ វេទយិតំ ចេតោសម្ផស្ស-ជា សាតា សុខា វេទនា អយំ វុច្ចតិ ផស្សប្បច្ចយា វេទនា ។

[៤១] បណ្តាបច្ចយាការទាំងនោះ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ។

[៤២] បណ្តាបច្ចយាការទាំងនោះ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ តើដូចម្តេច ។ ចិត្តៈ សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ហទយៈ ធម្មជាតដ៏ផូរផង់ (គឺភវង្គចិត្ត) ហៅថា មនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ ណា នេះហៅថា អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ។

[៤៣] បណ្តាបច្ចយាការទាំងនោះ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ តើដូចម្តេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិច ណា នេះហៅថា ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ ។

[៤៤] បណ្តាបច្ចយាការទាំងនោះ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តើដូចម្តេច ។ សេចក្តីឆ្ងាញ់ពីសា ប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីសុខ ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ដ៏ឆ្ងាញ់ពីសា ជាសុខ ដែលកើតអំពីចេតោសម្ផស្ស វេទនា ដ៏ឆ្ងាញ់ពីសា ជាសុខ ដែលកើតអំពីចេតោសម្ផស្ស ណា នេះហៅថា វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ ។

[៤៥] តត្ថ កតមា វេទនាបច្ចយា តណ្ហា ។ យោ រាគោ សារាគោ អនុនយោ អនុរោធោ នន្ទី នន្ទិរាគោ ចិត្តស្ស សារាគោ អយំ វុច្ចតិ វេទនា-បច្ចយា តណ្ហា ។

[៤៦] តត្ថ កតមំ តណ្ហាបច្ចយា ឧបាទានំ ។ យា ទិដ្ឋិ ទិដ្ឋិគតំ ។ បេ ។ តិត្ថាយតនំ វិបរិយេ-សគ្គាហោ ឥទំ វុច្ចតិ តណ្ហាបច្ចយា ឧបាទានំ ។

[៤៧] តត្ថ កតមោ ឧបាទានបច្ចយា ភវោ ។ ឋបេត្វា ឧបាទានំ វេទនាក្ខន្ធោ សញ្ញាក្ខន្ធោ សង្ខា-រក្ខន្ធោ វិញ្ញាណក្ខន្ធោ អយំ វុច្ចតិ ឧបាទាន-បច្ចយា ភវោ ។

[៤៨] តត្ថ កតមា ភវបច្ចយា ជាតិ ។ យា តេសំ ធម្មានំ ជាតិ សញ្ជាតិ និព្វត្តិ អភិនិព្វត្តិ បាតុភាវោ អយំ វុច្ចតិ ភវបច្ចយា ជាតិ ។

[៤៥] បណ្ដាបច្ចយាការទាំងនោះ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ តើដូចម្ដេច ។ តម្រេក តម្រេកខ្លាំង ការត្រេកអរ ការក្ដួចកាន់ ការរីករាយ ការស្រើបស្រាល តម្រេកដ៏ខ្លាំង ណា នៃចិត្ត នេះហៅថា តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ ។

[៤៦] បណ្ដាបច្ចយាការទាំងនោះ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ តើដូចម្ដេច ។ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ។ បេ ។ លទ្ធិដូចជាកំពង់គឺទិដ្ឋិ ការប្រកាន់ក្នុងការស្វែងរកខុស ណា នេះហៅថា ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ ។

[៤៧] បណ្ដាបច្ចយាការទាំងនោះ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ វៀរលែងតែឧបាទានចេញ នេះហៅថា ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ។

[៤៨] បណ្ដាបច្ចយាការទាំងនោះ ជាតិ កើតមាន ព្រោះភពជាបច្ច័យ តើដូចម្ដេច ។ ការកើត ការកើតព្រម ការផ្ដួចឡើង ការកើតចំពោះ ការកើតប្រាកដ ណា នៃធម៌ទាំងឡាយនោះ នេះហៅថា ជាតិ កើតមាន ព្រោះភពជាបច្ច័យ ។

បច្ចយាការវិភង្គ អកុសលនិទ្ទេសោ

[៤៩] តត្ថ កតមំ ជាតិប្បច្ចយា ជរាមរណំ ។ អត្ថិ ជរា អត្ថិ មរណំ ។ តត្ថ កតមា ជរា ។ យា តេសំ ធម្មានំ ជរា ជីរណតា អាយុនោ សំហានិ អយំ វុច្ចតិ ជរា ។ តត្ថ កតមំ មរណំ ។ យោ តេសំ ធម្មានំ ខយោ វយោ ភេទោ បរិភេទោ អនិច្ចតា អន្តរធានំ ឥទំ វុច្ចតិ មរណំ ។ ឥតិ អយញ្ច ជរា ឥទញ្ច មរណំ ឥទំ វុច្ចតិ ជាតិប្បច្ចយា ជរាមរណំ ។

[៥០] ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតីតិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សង្គតិ ហោតិ សមាគមោ ហោតិ សមោធានំ ហោតិ ចាតុភាវោ ហោតិ តេន វុច្ចតិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតីតិ ។

[៥១] តស្មឹ សមយេ អវិជ្ជាបច្ចយា សង្ខារោ សង្ខារប្បច្ចយា វិញ្ញាណំ វិញ្ញាណប្បច្ចយា នាមំ នាមប្បច្ចយា ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា

[៤៩] បណ្តាបច្ចយាការទាំងនោះ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ តើដូចម្តេច ។ ជរាក៏មាន មរណៈក៏មាន ។ បណ្តាជរានិងមរណៈនោះ ជរា តើដូចម្តេច ។ ការចាស់គ្រាំគ្រា ការរួញថយទៅនៃអាយុ ណា នៃធម៌ទាំងឡាយនោះ នេះហៅថា ជរា ។ បណ្តាជរានិងមរណៈនោះ មរណៈតើដូចម្តេច ។ ការអស់ទៅ ការសូន្យទៅ ការបែកធ្លាយ ការបែកខ្ចាត់ខ្ចាយ ការមិនទៀង ការបាត់បង់ ណា នៃធម៌ទាំងឡាយនោះ នេះហៅថា មរណៈ ។ ជរានេះផង មរណៈនេះផង នេះហៅថា ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ដោយប្រការដូច្នេះ ។

[៥០] ត្រង់ពាក្យថា ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ គឺការជួបជុំ ការមូលមក ការប្រជុំចុះ ការកើតប្រាកដ នៃកងទុក្ខទាំងអស់នុ៎ះ រមែងមានដោយអាការយ៉ាងនេះ ព្រោះហេតុនោះ ទើបលោកពោលថា ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[៥១] ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ផស្សៈ កើតមាន ព្រោះនាមជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ

តណ្ហាបច្ចយា ឧបាទានំ ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

[៥២] តត្ថ កតមា អវិជ្ជា ។ យំ អញ្ញាណំ អទស្សនំ ។ បេ ។ អវិជ្ជាលង្គី មោហោ អកុសលមូលំ អយំ វុច្ចតិ អវិជ្ជា ។ តត្ថ កតមោ អវិជ្ជាបច្ចយា សង្ខារោ ។ យា ចេតនា សញ្ចេតនា សញ្ចេតយិតត្តំ អយំ វុច្ចតិ អវិជ្ជាបច្ចយា សង្ខារោ ។ តត្ថ កតមំ សង្ខារប្បច្ចយា វិញ្ញាណំ ។ យំ ចិត្តំ មនោ មានសំ ។ បេ ។ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ សង្ខារប្បច្ចយា វិញ្ញាណំ ។ តត្ថ កតមំ វិញ្ញាណប្បច្ចយា នាមំ ។ វេទនាក្ខន្ធោ សញ្ញាក្ខន្ធោ សង្ខារក្ខន្ធោ ឥទំ វុច្ចតិ វិញ្ញាណប្បច្ចយា នាមំ ។ នាមប្បច្ចយា ផស្សោតិ តត្ថ កតមំ

ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[៥២] បណ្តាបច្ចយាការទាំងនោះ អវិជ្ជា តើដូចម្តេច ។ ការមិនដឹង ការមិនឃើញ ។ បេ ។ គន្លឹះ គឺអវិជ្ជា មោហៈ ជាអកុសលមូល ណា នេះហៅថា អវិជ្ជា ។ បណ្តាបច្ចយាការទាំងនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ តើដូចម្តេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ (នូវអារម្មណ៍) ណា នេះហៅថា សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្តេច ។ ចិត្តៈ សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។ បេ ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ ណា នេះហៅថា វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ។ អធិប្បាយត្រង់ពាក្យថា ផស្សៈ កើតមាន ព្រោះនាមជាបច្ច័យ ។ ចុះបណ្តាធម៌ទាំងនោះ នាម តើដូចម្តេច ។

នាមំ ។ ឋបេត្វា ផស្សំ វេទនាក្ខន្ធោ សញ្ញាក្ខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ ឥទំ វុច្ចតិ នាមំ ។ តត្ថ កតមោ នាមប្បច្ចយា ផស្សោ ។ យោ ផស្សោ ផុសនា សម្ផុសនា សម្ផុសិតត្តំ អយំ វុច្ចតិ នាមប្បច្ចយា ផស្សោ ។ បេ ។ តេន វុច្ចតិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតីតិ ។

[៤៣] តស្មឹ សមយេ អវិជ្ជាបច្ចយា សង្ខារោ សង្ខារប្បច្ចយា វិញ្ញាណំ វិញ្ញាណប្បច្ចយា នាមរូបំ នាមរូបប្បច្ចយា ឆដ្ឋាយតនំ ឆដ្ឋាយតនប្បច្ចយា ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

[៤៤] តត្ថ កតមា អវិជ្ជា ។ អយំ អញ្ញាណំ អទស្សនំ ។ បេ ។ អវិជ្ជាលង្គី មោហោ អកុសលមូលំ

វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ លើកលែងតែផស្សៈចេញ នេះហៅថា នាម ។ បណ្តាបច្ចយាការទាំងនោះ ផស្សៈ កើតមាន ព្រោះនាមជាបច្ច័យ តើដូចម្តេច ។ ផស្សៈការពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិច ណា នេះហៅថា ផស្សៈកើតមាន ព្រោះនាមជាបច្ច័យ ។ បេ ។ ព្រោះហេតុនោះ ទើបលោកហៅថា ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[៥៣] ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមនិងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[៥៤] បណ្តាបច្ចយាការទាំងនោះ អវិជ្ជា តើដូចម្តេច ។ ការមិនដឹង ការមិនឃើញ ។ បេ ។ គន្ទឹះគឺអវិជ្ជា មោហៈ ជាអកុសលមូល

អយំ វុច្ចតិ អវិជ្ជា ។ តត្ថ កតមោ អវិជ្ជាបច្ចយា សង្ខារោ ។ យា ចេតនា សញ្ចេតនា សញ្ចេតយិតត្តំ អយំ វុច្ចតិ អវិជ្ជាបច្ចយា សង្ខារោ ។ តត្ថ កតមំ សង្ខារប្បច្ចយា វិញ្ញាណំ ។ យំ ចិត្តំ មនោ មានសំ ។ បេ ។ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ សង្ខារប្បច្ចយា វិញ្ញាណំ ។ តត្ថ កតមំ វិញ្ញាណប្បច្ចយា នាមរូបំ ។ អត្ថិ នាមំ អត្ថិ រូបំ ។ តត្ថ កតមំ នាមំ ។ វេទនាខន្ធោ សញ្ញាខន្ធោ សង្ខារក្ខន្ធោ ឥទំ វុច្ចតិ នាមំ ។ តត្ថ កតមំ រូបំ ។ ចក្ខាយតនស្ស ឧបចយោ សោតាយតនស្ស ឧបចយោ ឃានាយតនស្ស ឧបចយោ ជិវ្ហាយតនស្ស ឧបចយោ កាយាយតនស្ស ឧបចយោ យំ វា បនញ្ញម្បិ អត្ថិ រូបំ ចិត្តជំ ចិត្តហេតុកំ ចិត្តសមុដ្ឋានំ ឥទំ វុច្ចតិ រូបំ ។ ឥតិ ឥទញ្ច នាមំ ឥទញ្ច រូបំ ឥទំ វុច្ចតិ វិញ្ញាណប្បច្ចយា នាមរូបំ ។ នាមរូបប្បច្ចយា ឆដ្ឋាយតនន្តិ អត្ថិ នាមំ

ណា នេះហៅថា អវិជ្ជា ។ បណ្ដាបច្ចយាការទាំងនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ តើដូចម្ដេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ (នូវអារម្មណ៍) ណា នេះហៅថា សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្ដេច ។ ចិត្តៈ សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ។ បេ ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ ណា នេះហៅថា វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ នាមនិងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ តើដូចម្ដេច ។ នាមក៏មាន រូបក៏មាន ។ បណ្ដានាមនិងរូបទាំងនោះ នាម តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម ។ បណ្ដានាមនិងរូបទាំងនោះ រូប តើដូចម្ដេច ។ ការសន្សំនៃចក្ខាយតនៈ ការសន្សំនៃសោតាយតនៈ ការសន្សំនៃឃានាយតនៈ ការសន្សំនៃជិវ្ហាយតនៈ ការសន្សំនៃកាយាយតនៈ ឬក៏រូបដទៃណា ដែលកើតអំពីចិត្ត មានចិត្តជាហេតុ មានចិត្តជាសមុដ្ឋាន នេះហៅថា រូប ។ នាមនេះផង រូបនេះផង នេះហៅថា នាមនិងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ដោយប្រការដូច្នេះ ។ អធិប្បាយត្រង់ពាក្យថា អាយតនៈទី ៦ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ នាមក៏មាន

អត្ថិ រូបំ ។ តត្ថ កតមំ នាមំ ។ វេទនាខន្ធោ សញ្ញាខន្ធោ សង្ខារក្ខន្ធោ ឥទំ វុច្ចតិ នាមំ ។ តត្ថ កតមំ រូបំ ។ យំ រូបំ និស្សាយ មនោវិញ្ញាណធាតុ វត្តតិ ឥទំ វុច្ចតិ រូបំ ។ ឥតិ ឥទញ្ច នាមំ ឥទញ្ច រូបំ ឥទំ វុច្ចតិ នាមរូបំ ។ តត្ថ កតមំ នាមរូបប្បច្ចយា ឆដ្ឋាយតនំ ។ យំ ចិត្តំ មនោ មានសំ ។ បេ ។ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ នាមរូបប្បច្ចយា ឆដ្ឋាយតនំ ។ តត្ថ កតមោ ឆដ្ឋាយតនប្បច្ចយា ផស្សោ ។ យោ ផស្សោ ផុសនា សម្ផុសនា សម្ផុសិតត្តំ អយំ វុច្ចតិ ឆដ្ឋាយតនប្បច្ចយា ផស្សោ ។ បេ ។ តេន វុច្ចតិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតីតិ ។

[៤៤] តស្មឹ សមយេ អវិជ្ជាបច្ចយា សង្ខារោ សង្ខារប្បច្ចយា វិញ្ញាណំ វិញ្ញាណប្បច្ចយា នាមរូបំ នាមរូបប្បច្ចយា សឡាយតនំ សឡាយតនប្បច្ចយា ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា

រូបក៏មាន ។ បណ្តានាមនិងរូបនោះ នាម តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម ។ បណ្តានាមនិងរូបនោះ រូប តើដូចម្តេច ។ មនោវិញ្ញាណធាតុ ប្រព្រឹត្តទៅ ព្រោះអាស្រ័យនូវរូបណា នេះហៅថា រូប ។ នាមនេះផង រូបនេះផង នេះហៅថា នាមនិងរូប ។ បណ្តាបច្ចយាការទាំងនោះ អាយតនៈទី ៦ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ តើដូចម្តេច ។ ចិត្តៈ សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។ បេ ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា អាយតនៈទី ៦ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ តើដូចម្តេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិចទង្គិចណា នេះហៅថា ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ ។ បេ ។ ព្រោះហេតុនោះ ទើបលោកថា ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[៥៥] ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមនិងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈ ៦ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈ ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈ ជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ

តណ្ហាបច្ចយា ឧបាទានំ ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

[៥៦] តត្ថ កាតមា អវិជ្ជា ។ យំ អញ្ញាណំ អទស្សនំ ។ បេ ។ អវិជ្ជាលង្គី មោហោ អកុសលមូលំ អយំ វុច្ចតិ អវិជ្ជា ។ តត្ថ កាតមោ អវិជ្ជាបច្ចយា សង្ខារោ ។ យា ចេតនា សញ្ចេតនា សញ្ចេតយិតត្តំ អយំ វុច្ចតិ អវិជ្ជាបច្ចយា សង្ខារោ ។ តត្ថ កាតមំ សង្ខារប្បច្ចយា វិញ្ញាណំ ។ យំ ចិត្តំ មនោ មានសំ ។ បេ ។ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ សង្ខារប្បច្ចយា វិញ្ញាណំ ។ តត្ថ កាតមំ វិញ្ញាណប្បច្ចយា នាមរូបំ ។ អត្ថិ នាមំ អត្ថិ រូបំ ។ តត្ថ កាតមំ នាមំ ។ វេទនាខន្ធោ សញ្ញាខន្ធោ សង្ខារក្ខន្ធោ ឥទំ វុច្ចតិ នាមំ ។ តត្ថ កាតមំ រូបំ ។ ចក្ខាយតនស្ស ឧបចយោ ។ បេ ។

ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទាន ជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[៩៦] បណ្តាបច្ចយាការទាំងនោះ អវិជ្ជា តើដូចម្តេច ។ ការមិនដឹង ការមិនឃើញ ។ បេ ។ គន្លឹះគឺអវិជ្ជា មោហៈ ជាអកុសលមូល ណា នេះហៅថា អវិជ្ជា ។ បណ្តាបច្ចយាការទាំងនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ តើដូចម្តេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ (នូវអារម្មណ៍) ណា នេះហៅថា សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្តេច ។ ចិត្តៈ សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។ បេ ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ នេះហៅថា វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ នាមនិងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ តើដូចម្តេច ។ នាមក៏មាន រូបក៏មាន ។ បណ្តានាមនិងរូបទាំងនោះ នាម តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម ។ បណ្តានាមនិងរូបទាំងនោះ រូប តើដូចម្តេច ។ ការសន្សំនៃចក្ខាយតនៈ ។ បេ ។

កាយាយតនស្ស ឧបចយោ យំ វា បនញ្ញម្បិ អត្ថិ រូបំ ចិត្តជំ ចិត្តហេតុកំ ចិត្តសមុដ្ឋានំ ឥទំ វុច្ចតិ រូបំ ។ ឥតិ ឥទញ្ច នាមំ ឥទញ្ច រូបំ ឥទំ វុច្ចតិ វិញ្ញាណប្បច្ចយា នាម-រូបំ ។ នាមរូបប្បច្ចយា សឡាយតនន្តិ អត្ថិ នាមំ អត្ថិ រូបំ ។ តត្ថ កតមំ នាមំ ។ វេទនាខន្ធោ សញ្ញាខន្ធោ សង្ខារក្ខន្ធោ ឥទំ វុច្ចតិ នាមំ ។ តត្ថ កតមំ រូបំ ។ ចត្តារោ ច មហាភូតា យញ្ច រូបំ និស្សាយ មនោវិញ្ញាណធាតុ វត្តតិ ឥទំ វុច្ចតិ រូបំ ។ ឥតិ ឥទញ្ច នាមំ ឥទញ្ច រូបំ ឥទំ វុច្ចតិ នាមរូបំ ។ តត្ថ កតមំ នាម-រូបប្បច្ចយា សឡាយតនំ ។ ចក្ខាយតនំ សោតា-យតនំ ឃានាយតនំ ជិវ្ហាយតនំ កាយាយតនំ ម-នាយតនំ ឥទំ វុច្ចតិ នាមរូបប្បច្ចយា សឡាយត-នំ ។ តត្ថ កតមោ សឡាយតនប្បច្ចយា ផស្សោ ។ យោ ផស្សោ ផុសនា សម្ផុសនា សម្ផុសិតត្តំ អយំ វុច្ចតិ សឡាយតនប្បច្ចយា ផស្សោ ។ បេ ។

ការសន្សំនៃកាយាយតនៈ ឬក៏រូបដទៃណា ដែលកើតអំពីចិត្ត មានចិត្តជាហេតុ មានចិត្តជាសមុដ្ឋាន នេះហៅថា រូប ។ នាមនេះផង រូបនេះផង នេះហៅថា នាមនិងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ដោយប្រការដូច្នេះ ។ អធិប្បាយត្រង់ពាក្យថា អាយតនៈ ៦ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ ។ នាមក៏មាន រូបក៏មាន ។ បណ្តានាមនិងរូបនោះ នាម តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម ។ បណ្តានាមនិងរូបទាំងនោះ រូប តើដូចម្តេច ។ មហាភូតរូបទាំង ៤ ក្តី មនោវិញ្ញាណធាតុ ប្រព្រឹត្តទៅ ព្រោះអាស្រ័យនូវរូបណាក្តី នេះហៅថា រូប ។ នាមនេះផង រូបនេះផង នេះហៅថា នាមនិងរូប ដោយប្រការដូច្នេះ ។ បណ្តាបច្ចយាការទាំងនោះ អាយតនៈ ៦ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ តើដូចម្តេច ។ ចក្ខាយតនៈ ១ សោតាយតនៈ ១ ឃានាយតនៈ ១ ជិវ្ហាយតនៈ ១ កាយាយតនៈ ១ មនាយតនៈ ១ នេះហៅថា អាយតនៈ ៦ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ ផស្សៈ កើតមាន ព្រោះសឡាយតនៈជាបច្ច័យ តើដូចម្តេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិច ណា នេះហៅថា ផស្សៈ កើតមាន ព្រោះ អាយតនៈ ៦ ជាបច្ច័យ ។ បេ ។

តេន វុច្ចតិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតីតិ ។

បច្ចយចតុក្កំ ។

[៩៧] តស្មឹ សមយេ អវិជ្ជាបច្ចយា សង្ខារោ អវិជ្ជាហេតុកោ សង្ខារប្បច្ចយា វិញ្ញាណំ សង្ខារហេតុកំ វិញ្ញាណប្បច្ចយា នាមំ វិញ្ញាណហេតុកំ នាមប្បច្ចយា ឆដ្ឋាយតនំ នាមហេតុកំ ឆដ្ឋាយតនប្បច្ចយា ផស្សោ ឆដ្ឋាយតនហេតុកោ ផស្សប្បច្ចយា វេទនា ផស្សហេតុកា វេទនាបច្ចយា តណ្ហា វេទនាហេតុកា តណ្ហាបច្ចយា ឧបាទានំ តណ្ហាហេតុកំ ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

[៩៨] តត្ថ កតមា អវិជ្ជា ។ យំ អញ្ញាណំ អទស្សនំ ។ បេ ។ អវិជ្ជាលង្គី មោហោ អកុសលមូលំ អយំ វុច្ចតិ អវិជ្ជា ។ តត្ថ កតមោ អវិជ្ជាបច្ចយា សង្ខារោ អវិជ្ជាហេតុកោ ។

ព្រោះហេតុនោះ ទើបលោកពោលថា ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

ចប់ បច្ចយចតុក្កៈ ។

[៥៧] ក្នុងសម័យនោះ សង្ខារមានអវិជ្ជាជាហេតុ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណមានសង្ខារជាហេតុ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមមានវិញ្ញាណជាហេតុ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ មាននាមជាហេតុ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈមានអាយតនៈទី ៦ ជាហេតុ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនាមានផស្សៈជាហេតុ កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាមានវេទនាជាហេតុ កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានមានតណ្ហាជាហេតុ កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[៥៨] បណ្ដាបច្ចយាការទាំងនោះ អវិជ្ជា តើដូចម្ដេច ។ ការមិនដឹង ការមិនឃើញ ។ បេ ។ គន្លឹះគឺអវិជ្ជា មោហៈ ជាអកុសលមូល ណា នេះហៅថា អវិជ្ជា ។ បណ្ដាបច្ចយាការទាំងនោះ សង្ខារមានអវិជ្ជាជាហេតុ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ តើដូចម្ដេច ។

៣១



យា ចេតនា សញ្ចេតនា សញ្ចេតយិតត្តំ អយំ វុច្ចតិ អវិជ្ជាបច្ចយា សង្ខារោ អវិជ្ជាហេតុកោ ។ តត្ថ កតមំ សង្ខារប្បច្ចយា វិញ្ញាណំ សង្ខារហេតុកំ ។ យំ ចិត្តំ មនោ មានសំ ។ បេ ។ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ សង្ខារប្បច្ចយា វិញ្ញាណំ សង្ខារហេតុកំ ។ តត្ថ កតមំ វិញ្ញាណប្បច្ចយា នាមំ វិញ្ញាណ-ហេតុកំ ។ វេទនាខន្ធោ សញ្ញាខន្ធោ សង្ខារក្ខន្ធោ ឥទំ វុច្ចតិ វិញ្ញាណប្បច្ចយា នាមំ វិញ្ញាណហេតុ-កំ ។ តត្ថ កតមំ នាមប្បច្ចយា ឆដ្ឋាយតនំ នាម-ហេតុកំ ។ យំ ចិត្តំ មនោ មានសំ ។ បេ ។ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ នាមប្បច្ចយា ឆដ្ឋា-យតនំ នាមហេតុកំ ។ តត្ថ កតមោ ឆដ្ឋាយត-នប្បច្ចយា ផស្សោ ឆដ្ឋាយតនហេតុកោ ។ យោ ផស្សោ ផុសនា សម្ផុសនា សម្ផុសិតត្តំ អយំ វុច្ចតិ ឆដ្ឋាយតនប្បច្ចយា ផស្សោ ឆដ្ឋាយតនហេតុកោ ។

ចេតនា ការសន្សំ ភាពនៃការសន្សំ (នូវអារម្មណ៍) ណា នេះហៅថា សង្ខារមានអវិជ្ជាជាហេតុ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ វិញ្ញាណមានសង្ខារជាហេតុ កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។ បេ ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ ណា នេះហៅថា វិញ្ញាណមានសង្ខារជាហេតុ កើតមាន ព្រោះសង្ខារជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ នាមមានវិញ្ញាណជាហេតុ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ តើដូចម្តេច ។ វេទនា-ខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាមមានវិញ្ញាណជាហេតុ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ អាយតនៈទី ៦ មាននាមជាហេតុ កើតមាន ព្រោះនាមជាបច្ច័យ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។ បេ ។ មនោ-វិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ ណា នេះហៅថា អាយតនៈទី ៦ មាននាមជាហេតុ កើតមាន ព្រោះនាមជាបច្ច័យ ។ បណ្តាបច្ច-យាការទាំងនោះ ផស្សៈមានអាយតនៈទី ៦ ជាហេតុ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ តើដូចម្តេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិច ណា នេះហៅថា ផស្សៈមានអាយតនៈទី ៦ ជាហេតុ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ ។

ជាទុក្ខាបដិបទាទន្ធាភិញ្ញា ជាសុញ្ញតៈ ជាវិបាក ព្រោះភាពនៃលោកុត្តរកុសលជ្ឈាននោះឯង ដែលលោកបានធ្វើហើយ ចម្រើនហើយ (ភិក្ខុនេះ) ឈ្មោះថា ពិចារណានូវកាយ ក្នុងកាយ ក្នុងសម័យនោះ ការរឭក ការនឹកឃើញ ។ បេ ។ ការរឭកត្រូវ សតិសម្ពោជ្ឈង្គ ជាអង្គមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សតិប្បដ្ឋាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសតិប្បដ្ឋាន ។ ចុះភិក្ខុពិចារណា នូវវេទនា ក្នុងវេទនាទាំងឡាយ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកៈ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្តៈ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ផស្សៈក៏មាន ។ បេ ។ អវិក្ខេបៈ ក៏មាន ធម៌ទាំងនេះ ជាកុសល ភិក្ខុស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ជាសុញ្ញតៈ ជាវិបាក ព្រោះភាពនៃលោកុត្តរកុសលជ្ឈាននោះឯង ដែលលោកបានធ្វើហើយ ចម្រើនហើយ (ភិក្ខុនេះ) ឈ្មោះថាពិចារណា នូវវេទនា ក្នុងវេទនាទាំងឡាយ ក្នុងសម័យនោះ ការរឭក ការរឭកឃើញ ។ បេ ។ ការរឭកត្រូវ សតិសម្ពោជ្ឈង្គ

មគ្គង្គំ មគ្គបរិយាបន្នំ ឥទំ វុច្ចតិ សតិប្បដ្ឋានំ អវសេសា ធម្មា សតិប្បដ្ឋានសម្បយុត្តា ។ កថញ្ច ភិក្ខុ ចិត្តេ ចិត្តានុបស្សី វិហរតិ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ ផស្សោ ហោតិ ។ បេ ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា តស្សេវ លោកុត្តរស្ស កុសលស្ស ឈានស្ស កតត្តា ភាវិតត្តា វិបាកំ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ សុញ្ញតំ ចិត្តេ ចិត្តានុបស្សី យា តស្មឹ សមយេ សតិ អនុស្សតិ ។ បេ ។ សម្មាសតិ សតិសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ ឥទំ វុច្ចតិ សតិប្បដ្ឋានំ អវសេសា ធម្មា សតិប្បដ្ឋានសម្បយុត្តា ។ កថញ្ច ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ ។ ឥធ ភិក្ខុ យស្មឹ សមយេ

ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សតិប្បដ្ឋាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសតិប្បដ្ឋាន ។ ចុះភិក្ខុពិចារណា នូវចិត្ត ក្នុងចិត្ត តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកៈ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្ដៈ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ផស្សៈក៏មាន ។ បេ ។ អវិក្ខេបៈ ក៏មាន ធម៌ទាំងនេះ ជាកុសល ភិក្ខុស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ជាសុញ្ញតៈ ជាវិបាក ព្រោះភាពនៃលោកុត្តរកុសលជ្ឈាននោះឯង ដែលលោកបានធ្វើហើយ ចម្រើនហើយ (ភិក្ខុនេះ) ឈ្មោះថា ពិចារណា នូវចិត្ត ក្នុងចិត្ត ក្នុងសម័យនោះ ការរឭក ការនឹកឃើញ ។ បេ ។ ការរឭកត្រូវ សតិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សតិប្បដ្ឋាន ធម៌ទាំងឡាយ ដ៏សេស ក៏ឈ្មោះថា ប្រកបដោយសតិប្បដ្ឋាន ។ ចុះភិក្ខុ ពិចារណា នូវធម៌ ក្នុងធម៌ទាំងឡាយ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ

លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ ផស្សោ ហោតិ ។ បេ ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា តស្សេវ លោកុត្តរស្ស កុសលស្ស ឈានស្ស កតត្តា ភាវិតត្តា វិបាកំ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ សុញ្ញតំ ធម្មេសុ ធម្មានុបស្សី យា តស្មឹ សមយេ សតិ អនុស្សតិ ។ បេ ។ សម្មាសតិ សតិសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ ឥទំ វុច្ចតិ សតិប្បដ្ឋានំ អវសេសា ធម្មា សតិប្បដ្ឋានសម្បយុត្តា ។

តត្ថ កតមំ សតិប្បដ្ឋានំ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ ផស្សោ ហោតិ ។ បេ ។

ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកៈ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្តៈ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ផស្សៈ ក៏មាន ។ បេ ។ អវិក្ខេបៈ ក៏មាន ធម៌ទាំងនេះ ជាកុសល ភិក្ខុស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធា-ភិញ្ញា ជាសុញ្ញតៈ ជាវិបាក ព្រោះភាពនៃលោកុត្តរកុសលជ្ឈាននោះឯង ដែលលោកបានធ្វើហើយ ចម្រើនហើយ (ភិក្ខុនេះ) ឈ្មោះថាពិចារណា នូវធម៌ ក្នុងធម៌ទាំងឡាយ ក្នុងសម័យនោះ ការរឭកការនឹកឃើញ ។ បេ ។ ការរឭកត្រូវ សតិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គរាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សតិប្បដ្ឋាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសតិប្បដ្ឋាន ។ បណ្តាធម៌ទាំងនោះសតិប្បដ្ឋាន តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកៈ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្តៈ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ផស្សៈ ក៏មាន ។ បេ ។

អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា តស្សេវ លោកុត្តរស្ស កុសលស្ស ឈានស្ស កតត្តា ភាវិតត្តា វិបាកំ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ សុញ្ញតំ ធម្មេសុ ធម្មានុបស្សី យា តស្មឹ សមយេ សតិ អនុស្សតិ ។ បេ ។ សម្មាសតិ សតិសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ ឥទំ វុច្ចតិ សតិប្បដ្ឋានំ អវសេសា ធម្មា សតិប្បដ្ឋានសម្បយុត្តា ។

អភិធម្មភាជនីយំ ។

[២០៨] ចត្តារោ សតិប្បដ្ឋានា ឥធ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ វេទនាសុ វេទនានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ចិត្តេ ចិត្តានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ចតុន្នំ សតិប្បដ្ឋានានំ

អវិក្ខេបៈ ក៏មាន ធម៌ទាំងនេះ ជាកុសល ភិក្ខុ ស្ងាត់ចាកកាម ទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ជាសុញ្ញតៈ ជាវិបាក ព្រោះភាពនៃលោកុត្តរកុសលជ្ឈាននោះឯង ដែលលោកបានធ្វើហើយ ចម្រើនហើយ (ភិក្ខុនេះ) ឈ្មោះថា ពិចារណា នូវធម៌ ក្នុងធម៌ទាំងឡាយ ក្នុងសម័យនោះ ការរឭក ការនឹកឃើញ ។ បេ ។ ការរឭកត្រូវ សតិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សតិប្បដ្ឋាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសតិប្បដ្ឋាន ។

ចប់ អភិធម្មភាជនីយ ។

[២០៨] សតិប្បដ្ឋាន ៤ គឺ ភិក្ខុក្នុងសាសនានេះ ពិចារណា នូវកាយ ក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់អភិជ្ឈានិងទោមនស្ស ក្នុងលោក ១ ពិចារណា នូវវេទនា ក្នុងវេទនាទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់អភិជ្ឈានិងទោមនស្ស ក្នុងលោក ១ ពិចារណា នូវចិត្ត ក្នុងចិត្ត មានព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់អភិជ្ឈា និងទោមនស្ស ក្នុងលោក ១ ពិចារណា នូវធម៌ ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មាតីកម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោក ១ ។ បណ្តាសតិប្បដ្ឋានទាំង ៤

សតិប្បដ្ឋានវិភង្គ បញ្ហាបុច្ឆកំ

កតិ កុសលា កតិ អកុសលា កតិ អព្យាកតា ។ បេ ។ កតិ សរណា កតិ អរណា ។

[២០៩] សិយា កុសលា សិយា អព្យាកតា សិយា សុខាយ វេទនាយ សម្បយុត្តា សិយា អទុក្ខ-មសុខាយ វេទនាយ សម្បយុត្តា សិយា វិបាកា សិយា វិបាកធម្មធម្មា អនុបាទិន្នុបាទានិយា អ-សង្កិលិដ្ឋាសង្កិលេសិកា សិយា សវិតក្កសវិចារា សិយា អវិតក្កវិចារមត្តា សិយា អវិតក្កាវិចារា សិយា បីតិសហគតា សិយា សុខសហគតា សិយា ឧបេក្ខាសហគតា នេវ ទស្សនេន ន ភាវនាយ បហាតព្វា នេវ ទស្សនេន ន ភាវនាយ បហាតព្វ-ហេតុកា សិយា អបចយគាមិនោ សិយា នេវាចយ-គាមិនោ នាបចយគាមិនោ សិយា សេក្ខា សិយា អសេក្ខា អប្បមាណា អប្បមាណារម្មណា បណីតា សិយា សម្មត្តនិយតា សិយា អនិយតា មគ្គារម្មណា សិយា មគ្គហេតុកា សិយា មគ្គាធិបតិនោ សិយា

សតិប្បដ្ឋាន ជាកុសលប៉ុន្មាន ជាអកុសលប៉ុន្មាន ជាអព្យាក្រឹតប៉ុន្មាន ។ បេ ។ ជាសរណៈ(១)ប៉ុន្មាន ជាអរណៈ(២)ប៉ុន្មាន ។

[២០៩] សតិប្បដ្ឋាន ៤ ជាកុសលក៏មាន ជាអព្យាក្រឹតក៏មាន ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនា ក៏មាន ជាវិបាកក៏មាន ជាធម៌មានវិបាកជាប្រក្រតី តែមិនមានកម្មប្រកបដោយកិលេសមានតណ្ហាជាដើមកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទាន តែមិនសៅហ្មង ទាំងមិនគួរដល់សេចក្ដីសៅហ្មង ក៏មាន ប្រកបដោយវិតក្កៈទាំងប្រកបដោយវិចារៈ ក៏មាន មិនមានវិតក្កៈមានត្រឹមតែវិចារៈ ក៏មាន មិនមានវិតក្កៈទាំងមិនមានវិចារៈ ក៏មាន ប្រទ្បាំដោយបីតិ ក៏មាន ប្រទ្បាំដោយសុខ ក៏មាន ប្រទ្បាំដោយឧបេក្ខា ដែលមិនគួរលះ ដោយទស្សនៈ មិនគួរលះ ដោយភាវនា មានហេតុដែលមិនគួរលះ ដោយទស្សនៈ ទាំងមិនគួរលះ ដោយភាវនា ក៏មាន ដល់នូវការមិនសន្សំ ក៏មាន មិនដល់នូវការសន្សំកពូនឡើង ទាំងមិនដល់នូវការមិនសន្សំ ក៏មាន ជាសេក្ខៈ ក៏មាន ជាអសេក្ខៈ ដែលមិនមានប្រមាណ មានអារម្មណ៍ប្រមាណមិនបាន ជាធម៌ដ៏ប្រសើរ ក៏មាន មានសភាពត្រូវនិងទៀង ក៏មាន មិនទៀង ដែលមានមគ្គជាអារម្មណ៍ ក៏មាន មានមគ្គជាហេតុ ក៏មាន មានមគ្គជាអធិបតី ក៏មាន

១ ប្រែថា ប្រកបដោយធម៌ជាសត្រូវ ថា ញុំាងសត្វឲ្យកន្ទក់កន្ទេញ ឲ្យស្ដាយស្រណោះ ។ ២ ប្រែថា ធម៌មិនមែនជាសត្រូវ ថា មិនញុំាងសត្វឲ្យកន្ទក់កន្ទេញឬមិនឲ្យស្ដាយស្រណោះ ។

ន វត្តព្វា មគ្គហេតុកាតិបិ មគ្គាធិបតិនោតិបិ សិយា ឧប្បន្នា សិយា អនុប្បន្នា សិយា ឧប្បាទិនោ សិយា អតីតា សិយា អនាគតា សិយា បច្ចុប្បន្នា ន វត្តព្វា អតីតារម្មណាតិបិ អនាគតារម្មណាតិបិ បច្ចុប្បន្នារម្មណាតិបិ សិយា អជ្ឈត្តា សិយា ពហិទ្ធា សិយា អជ្ឈត្តពហិទ្ធា ពហិទ្ធារម្មណា អនិទស្សនាប្បដិឃា ។

[២១០] ន ហេតូ សហេតុកា ហេតុសម្បយុត្តា ន វត្តព្វា ហេតូ ចេវ សហេតុកា ចាតិ សហេតុកា ចេវ ន ច ហេតូ ន វត្តព្វា ហេតូ ចេវ ហេតុសម្បយុត្តា ចាតិ ហេតុសម្បយុត្តា ចេវ ន ច ហេតូ ន ហេតូ សហេតុកា ។ សប្បច្ចយា សង្ខតា អនិទស្សនា អប្បដិឃា អរូបា លោកុត្តរា កេនចិ វិញ្ញេយ្យា កេនចិ ន វិញ្ញេយ្យា ។ នោ អាសវា អនាសវា អាសវវិប្បយុត្តា ន វត្តព្វា អាសវា ចេវ

មិនគួរពោលថា មានមគ្គជាហេតុផង ថា មានមគ្គជាអធិបតីផង ក៏មាន កើតឡើងហើយ ក៏មាន មិនទាន់កើតឡើងហើយ ក៏មាន បម្រុងនឹងកើតឡើង ក៏មាន ជាអតីត ក៏មាន ជាអនាគត ក៏មាន ជាបច្ចុប្បន្ន តែមិនគួរពោលថា មានអារម្មណ៍ជាអតីតផង ថា មានអារម្មណ៍ជាអនាគតផង ថា មានអារម្មណ៍ជាបច្ចុប្បន្នផង ក៏មាន ជាខាងក្នុង ក៏មាន ជាខាងក្រៅ ក៏មាន ជាខាងក្នុងទាំងខាងក្រៅ ដែលមានអារម្មណ៍ជាខាងក្រៅ មិនប្រកបដោយការឃើញ ទាំងមិនប្រកបដោយការប៉ះពាល់ ក៏មាន ។

[២១០] សតិប្បដ្ឋាន ៤ មិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុ ប្រកបដោយហេតុ មិនគួរពោលថា ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុទេ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុ មិនគួរពោលថា ជាហេតុ ទាំងប្រកបដោយហេតុឡើយ គ្រាន់តែប្រកបដោយហេតុ តែមិនមែនហេតុ មិនមែនហេតុ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ ។ សតិប្បដ្ឋាន ៤ ប្រកបដោយបច្ច័យ ត្រូវបច្ច័យតាក់តែង មិនប្រកបដោយការឃើញ មិនប្រកបដោយការប៉ះពាល់ មិនមានរូប ជាលោកុត្តរ គួរដឹងដោយវិញ្ញាណណាមួយ មិនគួរដឹងដោយវិញ្ញាណណាមួយ ។ សតិប្បដ្ឋាន ៤ មិនមែនអាសវៈ មិនមានអាសវៈ ប្រាសចាកអាសវៈ មិនគួរពោលថា ជាអាសវៈ ទាំង

សាសវា ចាតិបិ សាសវា ចេវ នោ ច អាសវាតិបិ ន វត្តព្វា អាសវា ចេវ អាសវសម្បយុត្តា ចាតិបិ អាសវសម្បយុត្តា ចេវ នោ ច អាសវាតិបិ អា-សវវិប្បយុត្តអនាសវា ។ នោ សញ្ញោជនា ។ បេ ។ នោ គន្ថា ។ បេ ។ នោ ឱឃា ។ បេ ។ នោ យោគា ។ បេ ។ នោ នីវរណា ។ បេ ។ នោ បរាមាសា ។ បេ ។ សារម្មណា នោ ចិត្តា ចេតសិកា ចិត្តសម្បយុត្តា ចិត្តសំសដ្ឋា ចិត្តសមុដ្ឋានា ចិត្តសហភុនោ ចិត្តានុ-បរិវត្តិនោ ចិត្តសំសដ្ឋសមុដ្ឋានា ចិត្តសំសដ្ឋសមុដ្ឋាន-សហភុនោ ចិត្តសំសដ្ឋសមុដ្ឋានានុបរិវត្តិនោ ពាហិរា នុបាទា អនុបាទិន្នា ។ នុបាទានា ។ បេ ។ នោ កិ-លេសា ។ បេ ។ ន ទស្សនេន បហាតព្វា ន ភាវ-នាយ បហាតព្វា ន ទស្សនេន បហាតព្វហេតុកា ន ភាវនាយ បហាតព្វហេតុកា សិយា សវិតក្កា សិ-យា អវិតក្កា សិយា សវិចារា សិយា អវិចារា សិយា

ប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ថា ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនជាអាសវៈផងទេ មិនគួរពោលថា ជាអាសវៈ ទាំងប្រកបដោយអាសវៈផង ថា ប្រកបដោយអាសវៈ តែមិនមែនអាសវៈផងឡើយ គឺជាធម៌ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ។ សតិប្បដ្ឋាន ៤ មិនមែនសញ្ញោជនៈ ។ បេ ។ មិនមែនគន្ថៈ ។ បេ ។ មិនមែនឱឃៈ ។ បេ ។ មិនមែនយោគៈ ។ បេ ។ មិនមែននីវរណៈ ។ បេ ។ មិនមែនបរាមាសៈ ។ បេ ។ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ មិនមែនចិត្ត ជាចេតសិក ប្រកបដោយចិត្ត ច្រឡំដោយចិត្ត តាំងឡើងដោយចិត្ត កើតជាមួយនឹងចិត្ត ប្រព្រឹត្តទៅតាមចិត្ត ច្រឡំទាំងតាំងឡើងដោយចិត្ត ច្រឡំទាំងតាំងឡើងទាំងកើតជាមួយនឹងចិត្ត ច្រឡំទាំងតាំងឡើងទាំងប្រព្រឹត្តទៅតាមចិត្ត ជាខាងក្រៅ មិនមែនឧបាទា ដែលកិលេសមានតណ្ហាជាដើមមិនកាន់យក ។ សតិប្បដ្ឋាន ៤ មិនមែនឧបាទាន ។ បេ ។ មិនមែនកិលេស ។ បេ ។ មិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា មានហេតុមិនគួរលះដោយទស្សនៈ មានហេតុមិនគួរលះដោយភាវនា ប្រកបដោយវិតក្កៈ ក៏មាន មិនមានវិតក្កៈ ក៏មាន ប្រកបដោយវិចារៈ ក៏មាន មិនមានវិចារៈ ក៏មាន

សប្បីតិកា សិយា អប្បីតិកា សិយា បីតិសហគតា សិយា ន បីតិសហគតា សិយា សុខសហគតា សិយា ន សុខសហគតា សិយា ឧបេក្ខាសហគតា សិយា ន ឧបេក្ខាសហគតា ន កាមាវចរា ន រូបាវចរា ន អរូបាវចរា អបរិយាបន្នា សិយា និ-យ្យានិកា សិយា អនិយ្យានិកា សិយា និយតា សិយា អនិយតា អនុត្តរា អរណាតិ ។

បញ្ហាបុច្ឆកំ ។

សតិប្បដ្ឋានវិភង្គោ សមត្តោ ។

ប្រកបដោយបីតិក៏មាន មិនមានបីតិក៏មាន ប្រទ្បំដោយបីតិក៏មាន មិនប្រទ្បំដោយបីតិក៏មាន ប្រទ្បំដោយសុខក៏មាន មិនប្រទ្បំដោយសុខក៏មាន ប្រទ្បំដោយឧបេក្ខាក៏មាន មិនប្រទ្បំដោយឧបេក្ខា តែមិនមែនកាមាវចរ មិនមែនរូបាវចរ មិនមែនអរូបាវចរ ជាអបរិយាបន្នៈក៏មាន ជានិយ្យានិកៈក៏មាន ជាអនិយ្យានិកៈក៏មាន ជានិយតៈក៏មាន ជាអនិយតៈ ជាអនុត្តរៈ ជាអរណៈក៏មាន ។

ចប់ បញ្ហាបុច្ឆកៈ ។

ចប់ សតិប្បដ្ឋានវិភង្គ ។

# សម្មប្បធានវិភង្គោ

[២១១] ចត្តារោ សម្មប្បធានា ឥធ ភិក្ខុ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។

[២១២] កថញ្ច ភិក្ខុ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ តត្ថ កតមេ អនុប្បន្នា បាបកា អកុសលា ធម្មា ។

# សម្មប្បធានវិភង្គ

[២១១] សម្មប្បធាន ៤ គឺ ភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើត មិនឲ្យកើតឡើង ១ ញុំាងឆន្ទៈ ឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីលះនូវពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ១ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ ដែលមិនទាន់កើត ឲ្យកើតឡើង ១ ញុំាងឆន្ទៈ ឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសល-ធម៌ ដែលកើតហើយ ឲ្យឋិតនៅ មិនឲ្យវិនាស ឲ្យរឹងរឹតតែដុះដាលធំទូលាយ ចម្រើន ពេញលេញ ១ ។

[២១២] ចុះភិក្ខុញុំាងឆន្ទៈ ឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើត មិនឲ្យកើតឡើង តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ ពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើតឡើង តើដូចម្តេច ។

តីណិ អកុសលមូលានិ លោភោ ទោសោ មោហោ តទេកដ្ឋា ច កិលេសា តំសម្បយុត្តោ វេទនាខន្ធោ សញ្ញាខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ តំសមុដ្ឋានំ កាយកម្មំ វចីកម្មំ មនោកម្មំ ឥមេ វុច្ចន្តិ អនុប្បន្នា ចាបកា អកុសលា ធម្មា ។ ឥតិ ឥមេសំ អនុប្បន្នានំ ចាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។

[២១៣] ឆន្ទំ ជនេតីតិ តត្ថ កតមោ ឆន្ទោ ។ យោ ឆន្ទោ ឆន្ទិកតា កត្តុកម្យតា កុសលោ ធម្មច្ឆន្ទោ អយំ វុច្ចតិ ឆន្ទោ ឥមំ ឆន្ទំ ជនេតិ សញ្ជនេតិ ឧដ្ឋាបេតិ សមុដ្ឋាបេតិ និព្វត្តេតិ អភិនិព្វត្តេតិ តេន វុច្ចតិ ឆន្ទំ ជនេតីតិ ។

[២១៤] វាយមតីតិ តត្ថ កតមោ វាយាមោ ។ យោ ចេតសិកោ វីរិយារម្ភោ ។ បេ ។ សម្មាវាយាមោ អយំ វុច្ចតិ វាយាមោ ឥមិនា វាយាមេន ឧបេតោ ហោតិ សមុបេតោ ឧចាគតោ សមុចាគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ តេន វុច្ចតិ វាយមតីតិ ។

អកុសលមូល ៣ គឺ លោភៈ ទោសៈ មោហៈ និងពួកកិលេស ដែលឋិតនៅជាមួយនឹងអកុសលមូលនោះ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ដែលប្រកបដោយកិលេសនោះ កាយកម្ម វចីកម្ម មនោកម្ម ដែលតាំងឡើងដោយខន្ធនោះ ធម៌ទាំងនេះហៅថា អកុសលធម៌ ដ៏លាមក ដែលមិនទាន់កើតឡើង ។ ភិក្ខុ ញុាំងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុាំងអកុសលធម៌ ដ៏លាមកទាំងនេះ ដែលមិនទាន់កើត មិនឲ្យកើតឡើង ដោយប្រការដូច្នេះ ។

[២១៣] ត្រង់ពាក្យថា ញុាំងឆន្ទៈឲ្យកើត មានសេចក្តីថា បណ្តាពាក្យទាំងនោះ ឆន្ទៈ តើដូចម្តេច ។ សេចក្តីប្រាថ្នា ភាពនៃបុគ្គលមានសេចក្តីប្រាថ្នា ភាពនៃបុគ្គលប្រាថ្នាដើម្បីធ្វើ សេចក្តីប្រាថ្នាធម៌ជាកុសល ណា នេះហៅថា ឆន្ទៈ ភិក្ខុញុាំងឆន្ទៈនេះ ឲ្យកើត ឲ្យលូតលាស់ ឲ្យដុះដាល ឲ្យតាំងឡើង ឲ្យចម្រើនឡើង ឲ្យកើតឡើង ព្រោះហេតុនោះ ទើបពោលថា ញុាំងឆន្ទៈឲ្យកើត ។

[២១៤] ត្រង់ពាក្យថា សង្វាត មានសេចក្តីថា បណ្តាពាក្យទាំងនោះ សេចក្តីសង្វាត តើដូចម្តេច ។ សេចក្តីប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សម្មាវាយាមៈ ណា នេះហៅថា សេចក្តីសង្វាត ភិក្ខុជាអ្នកព្រមព្រៀង មូលមិត្រ ចូលទៅជិត អែបនែប កៀកកើយ ប្រដិតប្រដី ប្រកបព្រមដោយសេចក្តីសង្វាតនេះ ព្រោះហេតុនោះ ទើបពោលថា សង្វាត ។

១៦៩



[២១៥] វីរិយំ អារភតីតិ តត្ថ កតមំ វីរិយំ ។ យោ ចេតសិកោ វីរិយារម្ភោ ។ បេ ។ សម្មាវាយាមោ ឥទំ វុច្ចតិ វីរិយំ ឥមំ វីរិយំ អារភតិ សមារភតិ អាសេវតិ ភាវេតិ ពហុលីករោតិ តេន វុច្ចតិ វីរិយំ អារភតីតិ ។

[២១៦] ចិត្តំ បគ្គណ្ហាតីតិ តត្ថ កតមំ ចិត្តំ ។ យំ ចិត្តំ មនោ មានសំ ។ បេ ។ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ ចិត្តំ ឥមំ ចិត្តំ បគ្គណ្ហាតិ សម្បគ្គណ្ហាតិ ឧបត្ថម្ភេតិ បច្ចុបត្ថម្ភេតិ តេន វុច្ចតិ ចិត្តំ បគ្គណ្ហាតីតិ ។

[២១៧] បទហតីតិ តត្ថ កតមំ បធានំ ។ យោ ចេតសិកោ វីរិយារម្ភោ ។ បេ ។ សម្មាវាយាមោ ឥទំ វុច្ចតិ បធានំ ឥមិនា បធានេន ឧបេតោ ហោតិ ។ បេ ។ សមន្នាគតោ តេន វុច្ចតិ បទហតីតិ ។

[២១៥] ត្រង់ពាក្យថា ប្រារព្ធព្យាយាម មានសេចក្តីថា បណ្តាពាក្យទាំងនោះ ការព្យាយាម តើដូចម្តេច ។ សេចក្តីប្រារព្ធព្យាយាមប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សម្មាវាយាមៈ ណា នេះហៅថា ការព្យាយាម ភិក្ខុប្រារព្ធ កាន់យកត្រូវ គប់រក អប់រំ ធ្វើឲ្យច្រើន នូវការព្យាយាមនោះ ព្រោះហេតុនោះ ទើបពោលថា ប្រារព្ធព្យាយាម ។

[២១៦] ត្រង់ពាក្យថា ផ្គងចិត្ត មានសេចក្តីថា បណ្តាពាក្យទាំងនោះ ចិត្ត តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។ បេ ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ ណា នេះហៅថា ចិត្ត ភិក្ខុផ្គង តម្រង់ ជ្រោមជ្រែង ទប់ទល់ទុក នូវចិត្តនេះ ព្រោះហេតុនោះ ទើបពោលថា ផ្គងចិត្ត ។

[២១៧] ត្រង់ពាក្យថា ប្រឹងប្រែង មានសេចក្តីថា បណ្តាពាក្យទាំងនោះ ការប្រឹងប្រែង តើដូចម្តេច ។ សេចក្តីប្រារព្ធព្យាយាមប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សម្មាវាយាមៈ ណា នេះហៅថា ការប្រឹងប្រែង ភិក្ខុជាអ្នកព្រមព្រៀង ។ បេ ។ ប្រកបព្រម ដោយការប្រឹងប្រែងនេះ ព្រោះហេតុនោះ ទើបពោលថា ប្រឹងប្រែង ។

[២១៨] កតមញ្ច ភិក្ខុ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ តត្ថ កតមេ ឧប្បន្នា បាបកា អកុសលា ធម្មា ។ តីណិ អកុសលមូលានិ លោភោ ទោសោ មោហោ តទេកដ្ឋា ច កិលេសា តំសម្បយុត្តោ វេទនាខន្ធោ សញ្ញាខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ តំសមុដ្ឋានំ កាយកម្មំ វចីកម្មំ មនោកម្មំ ឥមេ វុច្ចន្តិ ឧប្បន្នា បាបកា អកុសលា ធម្មា ។ ឥតិ ឥមេសំ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។

[២១៩] ឆន្ទំ ជនេតីតិ តត្ថ កតមោ ឆន្ទោ ។ យោ ឆន្ទោ ឆន្ទិកតា កត្តុកម្យតា កុសលោ ធម្មច្ឆន្ទោ អយំ វុច្ចតិ ឆន្ទោ ឥមំ ឆន្ទំ ជនេតិ សញ្ជនេតិ ឧដ្ឋាបេតិ សមុដ្ឋាបេតិ និព្វត្តេតិ អភិនិព្វត្តេតិ តេន វុច្ចតិ ឆន្ទំ ជនេតីតិ ។

[២១៨] ចុះភិក្ខុញ៉ាំងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីលះនូវពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ តើដូចម្ដេច ។ បណ្ដាធម៌ទាំងនោះ ពួកអកុសសធម៌ដ៏លាមកដែលកើតឡើងហើយ តើដូចម្ដេច ។ អកុសលមូល ៣ គឺ លោភៈទោសៈ មោហៈ និងពួកកិលេស ដែលឋិតនៅជាមួយនឹងអកុសល-មូលនោះ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ដែលប្រកបដោយកិលេសនោះ កាយកម្ម វចីកម្ម មនោកម្ម ដែលតាំងឡើងដោយខន្ធនោះ ធម៌ទាំងនេះ ហៅថា ពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ។ ភិក្ខុញ៉ាំងឆន្ទៈឲ្យកើត សង្វាតប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីលះនូវពួកអកុសលធម៌ដ៏លាមកទាំងនេះ ដែលកើតឡើងហើយ ដោយប្រការដូច្នេះ ។

[២១៩] ត្រង់ពាក្យថា ញ៉ាំងឆន្ទៈឲ្យកើត មានសេចក្ដីថាបណ្ដាបទទាំងនោះ ឆន្ទៈ តើដូចម្ដេច ។ សេចក្ដីប្រាថ្នា ភាពនៃបុគ្គលមានសេចក្ដីប្រាថ្នា ភាពនៃបុគ្គលអ្នកប្រាថ្នាដើម្បីធ្វើ សេចក្ដីប្រា-ថ្នាធម៌ជាកុសល ណា នេះហៅថា ឆន្ទៈ ភិក្ខុញ៉ាំងឆន្ទៈនេះ ឲ្យកើតឲ្យលូតលាស់ ឲ្យដុះដាល ឲ្យតាំងឡើង ឲ្យចម្រើនឡើង ឲ្យកើតឡើង ព្រោះហេតុនោះ ទើបពោលថា ញ៉ាំងឆន្ទៈឲ្យកើត ។

[២២០] វាយមតីតិ តត្ថ កតមោ វាយា-
មោ ។ យោ ចេតសិកោ វីរិយារម្ភោ ។ បេ ។
សម្មាវាយាមោ អយំ វុច្ចតិ វាយាមោ ឥមិនា
វាយាមេន ឧបេតោ ហោតិ ។ បេ ។ សមន្នាគតោ
តេន វុច្ចតិ វាយមតីតិ ។

[២២១] វីរិយំ អារភតីតិ តត្ថ កតមំ
វីរិយំ ។ យោ ចេតសិកោ វីរិយារម្ភោ ។ បេ ។
សម្មាវាយាមោ ឥទំ វុច្ចតិ វីរិយំ ឥមំ វីរិយំ
អារភតិ សមារភតិ អាសេវតិ ភាវេតិ ពហុលីករោតិ
តេន វុច្ចតិ វីរិយំ អារភតីតិ ។

[២២២] ចិត្តំ បគ្គណ្ហាតីតិ តត្ថ កតមំ
ចិត្តំ ។ យំ ចិត្តំ មនោ មានសំ ។ បេ ។
តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ ចិត្តំ ឥមំ
ចិត្តំ បគ្គណ្ហាតិ សម្បគ្គណ្ហាតិ ឧបត្ថម្ភេតិ បច្ចុប-
ត្ថម្ភេតិ តេន វុច្ចតិ ចិត្តំ បគ្គណ្ហាតីតិ ។

[២២០] ត្រង់ពាក្យថា សង្វាត មានសេចក្តីថា បណ្តាពាក្យទាំងនោះ សេចក្តីសង្វាត តើដូចម្តេច ។ សេចក្តីប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សម្មាវាយាមៈ ណា នេះហៅថា សេចក្តីសង្វាត ភិក្ខុជាអ្នកព្រមព្រៀង ។ បេ ។ ប្រកបព្រម ដោយសេចក្តីសង្វាតនេះ ព្រោះហេតុនោះ ទើបពោលថា សង្វាត ។

[២២១] ត្រង់ពាក្យថា ប្រារព្ធព្យាយាម មានសេចក្តីថា បណ្តាពាក្យទាំងនោះ ការព្យាយាម តើដូចម្តេច ។ សេចក្តីប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សម្មាវាយាមៈ ណា នេះហៅថា ការព្យាយាម ភិក្ខុប្រារព្ធ កាន់យកត្រូវ គប់រក អប់រំ ធ្វើឲ្យច្រើន នូវការព្យាយាមនេះ ព្រោះហេតុនោះ ទើបពោលថា ប្រារព្ធព្យាយាម ។

[២២២] ត្រង់ពាក្យ ផ្គងចិត្ត មានសេចក្តីថា បណ្តាពាក្យទាំងនោះ ចិត្ត តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។ បេ ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ ណា នេះហៅថា ចិត្ត ភិក្ខុផ្គង តម្រង់ ជ្រោមជ្រែង ទប់ទល់ទុក នូវចិត្តនោះ ព្រោះហេតុនោះ ទើបពោលថា ផ្គងចិត្ត ។

[២២៣] បគ្គហោតិ តត្ថ កតមំ បគ្គហំ ។ យោ ចេតសិកោ វីរិយារម្ភោ ។ បេ ។ សម្មាវាយាមោ ឥទំ វុច្ចតិ បគ្គហំ ឥមិនា បគ្គហេន ឧបេតោ ហោតិ ។ បេ ។ សមន្នាគតោ តេន វុច្ចតិ បគ្គហោតិ ។

[២២៤] កថញ្ច ភិក្ខុ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ តត្ថ កតមេ អនុប្បន្នា កុសលា ធម្មា ។ តីណិ កុសលមូលានិ អលោភោ អទោសោ អមោហោ តំសម្បយុត្តោ វេទនាខន្ធោ សញ្ញាខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ តំសមុដ្ឋានំ កាយកម្មំ វចីកម្មំ មនោកម្មំ ឥមេ វុច្ចន្តិ អនុប្បន្នា កុសលា ធម្មា ។ ឥតិ ឥមេសំ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។

[២២៥] ឆន្ទំ ជនេតីតិ ។ បេ ។ វាយមតីតិ ។ បេ ។ វីរិយំ អារភតីតិ ។ បេ ។ ចិត្តំ បគ្គណ្ហាតីតិ ។ បេ ។ បទហតីតិ តត្ថ កតមំ បធានំ ។

[២២៣] ត្រង់ពាក្យថា ប្រឹងប្រែង មានសេចក្តីថា បណ្តាពាក្យទាំងនោះ ការប្រឹងប្រែង តើដូចម្តេច ។ សេចក្តីប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សម្មាវាយាមៈ ណា នេះហៅថា ការប្រឹងប្រែង ភិក្ខុជាអ្នកព្រមព្រៀង ។ បេ ។ ប្រកបព្រម ដោយការប្រឹងប្រែងនេះ ព្រោះហេតុនោះ ទើបពោលថា ប្រឹងប្រែង ។

[២២៤] ចុះភិក្ខុញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ ដែលមិនទាន់កើត ឲ្យកើតឡើង តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ ពួកកុសលធម៌ ដែលមិនទាន់កើតឡើង តើដូចម្តេច ។ កុសលមូល ៣ គឺ អលោភៈ អទោសៈ អមោហៈ និងវេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ដែលប្រកបដោយកុសលមូលនោះ កាយកម្ម វចីកម្ម មនោកម្ម ដែលតាំងឡើងដោយខន្ធនោះ ធម៌ទាំងនេះហៅថា ពួកកុសលធម៌ ដែលមិនទាន់កើតឡើង ។ ភិក្ខុញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធ-ព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ទាំងនេះ ដែលមិនទាន់កើត ឲ្យកើតឡើង ដោយប្រការដូច្នេះ ។

[២២៥] ត្រង់ពាក្យថា ញុំាងឆន្ទៈឲ្យកើត ។ បេ ។ ត្រង់ពាក្យថា សង្វាត ។ បេ ។ ត្រង់ពាក្យថា ប្រារព្ធព្យាយាម ។ បេ ។ ត្រង់ពាក្យថា ផ្គងចិត្ត ។ បេ ។ ត្រង់ពាក្យថា ប្រឹងប្រែង មានសេចក្តីថា បណ្តាពាក្យទាំងនោះ ការប្រឹងប្រែង តើដូចម្តេច ។

យោ ចេតសិកោ វីរិយារម្ភោ ។ បេ ។ សម្មាវាយាមោ ឥទំ វុច្ចតិ បធានំ ឥមិនា បធានេន ឧបេតោ ហោតិ ។ បេ ។ សមន្នាគតោ តេន វុច្ចតិ បទហតីតិ ។

[២២៦] កតមញ្ច ភិក្ខុ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ តត្ថ កតមេ ឧប្បន្នា កុសលា ធម្មា ។ តីណិ កុសលមូលានិ អលោភោ អទោសោ អមោហោ តំសម្បយុត្តោ វេទនាខន្ធោ សញ្ញាខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ តំសមុដ្ឋានំ កាយកម្មំ វចីកម្មំ មនោកម្មំ ឥមេ វុច្ចន្តិ ឧប្បន្នា កុសលា ធម្មា ។ ឥតិ ឥមេសំ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។

សេចក្តីប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សម្មាវាយាមៈ ណា នេះហៅថា ការប្រឹងប្រែង ភិក្ខុជាអ្នកព្រមព្រៀង ។ បេ ។ ប្រកបព្រម ដោយការប្រឹងប្រែងនេះ ព្រោះហេតុនោះ ទើបពោលថា ប្រឹងប្រែង ។

[២២៦] ចុះភិក្ខុញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គង ចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ ដែលកើតហើយ ឲ្យឋិត នៅ មិនឲ្យវិនាស ឲ្យរឹងរឹតតែដុះដាល ធំទូលាយ ចម្រើន ពេញលេញ តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ ពួកកុសលធម៌ ដែលកើតឡើង ហើយ តើដូចម្តេច ។ កុសលមូល ៣ គឺ អលោភៈ អទោសៈ អមោហៈ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ដែល ប្រកបដោយកុសលមូលនោះ កាយកម្ម វចីកម្ម មនោកម្ម ដែល តាំងឡើងដោយខន្ធនោះ ធម៌ទាំងនេះហៅថា ពួកកុសលធម៌ ដែល កើតឡើងហើយ ។ ភិក្ខុញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យា-យាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងកុសលធម៌ទាំងនេះ ដែលកើត ហើយ ឲ្យឋិតនៅ មិនឲ្យវិនាស ឲ្យរឹងរឹតតែដុះដាល ធំទូលាយ ចម្រើន ពេញលេញ ដោយប្រការដូច្នេះ ។

[២២៧] ឋិតិយាតិ យា ឋិតិ សោ អសម្មោសោ យោ អសម្មោសោ សោ ភិយ្យោភាវោ យោ ភិយ្យោភាវោ តំ វេបុល្លំ យំ វេបុល្លំ សា ភាវនា យា ភាវនា សា បារិបូរិ ។

[២២៨] ឆន្ទំ ជនេតីតិ ។ បេ ។ វាយមតីតិ ។ បេ ។ វីរិយំ អារភតីតិ ។ បេ ។ ចិត្តំ បគ្គណ្ហាតីតិ ។ បេ ។ បទហតីតិ តត្ថ កតមំ បធានំ យោ ចេតសិកោ វីរិយារម្ភោ ។ បេ ។ សម្មាវាយាមោ ឥទំ វុច្ចតិ បធានំ ឥមិនា បធានេន ឧបេតោ ហោតិ ។ បេ ។ សមន្នាគតោ តេន វុច្ចតិ បទហតីតិ ។

## សុត្តន្តភាជនីយំ ។

[២២៩] ចត្តារោ សម្មប្បធានា ឥធ ភិក្ខុ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ

[២២៧] ពាក្យថា ឲ្យឋិតនៅ គឺការឋិតនៅ ណា នោះឈ្មោះថាសេចក្តីមិនវិនាស ឯសេចក្តីមិនវិនាស ណា នោះឈ្មោះថា ការរឹងរឹតតែដុះដាលឡើង ការរឹងរឹតតែដុះដាលឡើង ណា នោះឈ្មោះថាធំទូលាយ ការធំទូលាយ ណា នោះឈ្មោះថា ការចម្រើន ការចម្រើន ណា នោះឈ្មោះថា ការពេញលេញ ។

[២២៨] ត្រង់ពាក្យថា ញុំាងឆន្ទៈឲ្យកើត ។ បេ ។ ត្រង់ពាក្យថា សង្វាត ។ បេ ។ ត្រង់ពាក្យថា ប្រារព្ធព្យាយាម ។ បេ ។ ត្រង់ពាក្យថា ផ្គងចិត្ត ។ បេ ។ ត្រង់ពាក្យថា ប្រឹងប្រែង សេចក្តីថា បណ្តាពាក្យទាំងនោះ ការប្រឹងប្រែង តើដូចម្តេច សេចក្តីប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សម្មាវាយាមៈ ណា នេះហៅថា ប្រឹងប្រែង ភិក្ខុជាអ្នកព្រមព្រៀង ។ បេ ។ ប្រកបព្រម ដោយការប្រឹងប្រែងនេះ ព្រោះហេតុនោះ ទើបពោលថា ប្រឹងប្រែង ។

ចប់ សុត្តន្តភាជនីយ ។

[២២៩] សម្មប្បធាន ៤ គឺ ភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើត មិនឲ្យកើតឡើង ១ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីលះនូវពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ១ ញុំាងឆន្ទៈឲ្យកើត សង្វាត

វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ អនុប្ប-
ន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ
វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ
ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោ-
សាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូ-
រិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ
បគ្គណ្ហាតិ បទហតិ ។

[២៣០] កថញ្ច ភិក្ខុ អនុប្បន្នានំ បាប-
កានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ
ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ
បទហតិ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ
ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ
បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ
កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហ-
រតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ អនុ-
ប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បា-
ទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ
បគ្គណ្ហាតិ បទហតិ ។

ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញ៉ាំងពួកកុសលធម៌ ដែលមិនទាន់កើត ឲ្យកើតឡើង ១ ញ៉ាំងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញ៉ាំងពួកកុសលធម៌ ដែលកើតហើយ ឲ្យឋិតនៅ មិនឲ្យវិនាស ឲ្យរឹងរឹតតែដុះដាល ធំទូលាយ ចម្រើន ពេញលេញ ១ ។

[២៣០] ចុះភិក្ខុញ៉ាំងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញ៉ាំងពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើត មិនឲ្យកើតឡើង តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេស) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទា ទន្ធាភិញ្ញា ក្នុងសម័យនោះ ភិក្ខុញ៉ាំងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញ៉ាំងពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើត មិនឲ្យកើតឡើង ។

[២៣១] ឆន្ទំ ជនេតីតិ តត្ថ កតមោ ឆន្ទោ ។ យោ ឆន្ទោ ឆន្ទីកតា កត្តុកម្យតា កុសលោ ធម្មច្ឆន្ទោ អយំ វុច្ចតិ ឆន្ទោ ឥមំ ឆន្ទំ ជនេតិ សញ្ជនេតិ ឧដ្ឋាបេតិ សមុដ្ឋាបេតិ និព្វត្តេតិ អភិ-និព្វត្តេតិ តេន វុច្ចតិ ឆន្ទំ ជនេតីតិ ។

[២៣២] វាយមតីតិ តត្ថ កតមោ វាយាមោ ។ យោ ចេតសិកោ វីរិយារម្ភោ និក្កមោ បរក្កមោ ឧយ្យាមោ វាយាមោ ឧស្សាហោ ឧស្សោឡ្ហី ថាមោ ឋិតិ អសិថិលបរក្កមតា អនិក្ខិត្តច្ឆន្ទតា អនិក្ខិត្ត-ធុរតា ធុរសម្បគ្គាហោ វីរិយំ វីរិយិន្ទ្រិយំ វីរិយពលំ សម្មាវាយាមោ វីរិយសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយា-បន្នំ អយំ វុច្ចតិ វាយាមោ ឥមិនា វាយាមេន ឧ-បេតោ ហោតិ សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ តេន វុច្ចតិ វាយមតីតិ ។

[២៣១] ត្រង់ពាក្យថា ញ៉ាំងឆន្ទៈឲ្យកើត មានសេចក្តីថា បណ្តាពាក្យទាំងនោះ ឆន្ទៈ តើដូចម្តេច ។ សេចក្តីប្រាថ្នា ភាពនៃបុគ្គលមានសេចក្តីប្រាថ្នា ភាពនៃបុគ្គលប្រាថ្នាដើម្បីធ្វើ សេចក្តីប្រាថ្នាធម៌ជាកុសល ណា នេះហៅថា ឆន្ទៈ ភិក្ខុញ៉ាំងឆន្ទៈនេះ ឲ្យកើត ឲ្យលូតលាស់ ឲ្យដុះដាល ឲ្យតាំងឡើង ឲ្យចម្រើន ឲ្យកើតឡើង ព្រោះហេតុនោះ ទើបពោលថា ញ៉ាំងឆន្ទៈឲ្យកើត ។

[២៣២] ត្រង់ពាក្យថា សង្វាត មានសេចក្តីថា បណ្តាពាក្យទាំងនោះ សេចក្តីសង្វាត តើដូចម្តេច ។ ការប្រារព្ធព្យាយាមប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីឱហាត សង្វាត ខិតខំ ព្យាយាម ឧស្សាហ៍ ប្រឹងប្រែង ខ្មីឃ្មាត ខ្នះខ្នែង ខ្ជាប់ខ្ជួនមិនបន្ធូរបន្ថយ មិនដាក់ចោលនូវសេចក្តីប្រាថ្នា មិនទម្លាក់ធុរៈចេញ ផ្គងទុកនូវធុរៈ វីរិយៈ វីរិយិន្ទ្រិយ វីរិយពលៈ សម្មាវាយាមៈ វីរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សេចក្តីសង្វាត ភិក្ខុជាអ្នកព្រមព្រៀង មូលមិត្រ ចូលទៅជិត អែបនែប កៀកកើយ ប្រជិតប្រជីប្រកបព្រម ដោយសេចក្តីសង្វាតនេះ ព្រោះហេតុនោះ ទើបពោលថា សង្វាត ។

[២៣៣] វីរិយំ អារភតីតិ តត្ថ កតមំ វីរិយំ ។ យោ ចេតសិកោ វីរិយារម្ភោ ។ បេ ។ សម្មាវាយាមោ វីរិយសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ ឥទំ វុច្ចតិ វីរិយំ ឥមំ វីរិយំ អារភតិ សមារភតិ អាសេវតិ ភាវេតិ ពហុលីករោតិ តេន វុច្ចតិ វីរិយំ អារភតីតិ ។

[២៣៤] ចិត្តំ បគ្គណ្ហាតីតិ តត្ថ កតមំ ចិត្តំ ។ យំ ចិត្តំ មនោ មានសំ ។ បេ ។ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ ចិត្តំ ឥមំ ចិត្តំ បគ្គណ្ហាតិ សម្បគ្គណ្ហាតិ ឧបត្ថម្ភេតិ បច្ចុបត្ថម្ភេតិ តេន វុច្ចតិ ចិត្តំ បគ្គណ្ហាតីតិ ។

[២៣៥] បទហតីតិ តត្ថ កតមំ សម្មប្បធានំ ។ យោ ចេតសិកោ វីរិយារម្ភោ ។ បេ ។ សម្មាវាយាមោ វីរិយសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ ឥទំ វុច្ចតិ សម្មប្បធានំ អវសេសា ធម្មា សម្មប្បធានសម្បយុត្តា ។

[២៣៣] ត្រង់ពាក្យថា ប្រារព្ធព្យាយាម មានសេចក្ដីថា បណ្ដាពាក្យទាំងនោះ ការព្យាយាម តើដូចម្ដេច ។ ការប្រារព្ធព្យាយាមប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សម្មាវាយាមៈ វីរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា ការព្យាយាម ភិក្ខុប្រារព្ធ កាន់យកត្រូវ គប់រក អប់រំ ធ្វើឲ្យច្រើន នូវការព្យាយាមនេះ ព្រោះហេតុនោះ ទើបពោលថា ប្រារព្ធព្យាយាម ។

[២៣៤] ត្រង់ពាក្យថា ផ្គងចិត្ត មានសេចក្ដីថា បណ្ដាពាក្យទាំងនោះ ចិត្ត តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ។ បេ ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ ណា នេះហៅថា ចិត្ត ភិក្ខុ ផ្គង តម្រង់ ជ្រោមជ្រែង ទប់ទល់ទុក នូវចិត្តនេះ ព្រោះហេតុនោះ ទើបពោលថា ផ្គងចិត្ត ។

[២៣៥] ត្រង់ពាក្យថា ប្រឹងប្រែង មានសេចក្ដីថា បណ្ដាពាក្យទាំងនោះ សម្មប្បធាន តើដូចម្ដេច ។ សេចក្ដីប្រារព្ធព្យាយាមប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សម្មាវាយាមៈ វីរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សម្មប្បធាន ពួកធម៌ដ៏សេសក៏ឈ្មោះថា ប្រកបដោយសម្មប្បធាន ។

[២៣៦] កថញ្ច ភិក្ខុ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។

[២៣៧] ឆន្ទំ ជនេតីតិ ។ បេ ។ វាយមតីតិ ។ បេ ។ វីរិយំ អារភតីតិ ។ បេ ។ ចិត្តំ បគ្គណ្ហាតីតិ ។ បេ ។ បទហតីតិ តត្ថ កតមំ សម្មប្បធានំ ។ យោ ចេតសិកោ វីរិយារម្ភោ ។ បេ ។ សម្មាវាយាមោ វីរិយសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ ឥទំ វុច្ចតិ សម្មប្បធានំ អវសេសា ធម្មា សម្មប្បធានសម្បយុត្តា ។

[២៣៦] ចុះភិក្ខុ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីលះនូវពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្ដៈ) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ភិក្ខុឈ្មោះថា ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីលះនូវពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ។

[២៣៧] ត្រង់ពាក្យថា ញុំាងឆន្ទៈឲ្យកើត ។ បេ ។ ត្រង់ពាក្យថា សង្វាត ។ បេ ។ ត្រង់ពាក្យថា ប្រារព្ធព្យាយាម ។ បេ ។ ត្រង់ពាក្យថា ផ្គងចិត្ត ។ បេ ។ ត្រង់ពាក្យថា ប្រឹងប្រែង មានសេចក្ដីថា បណ្ដាពាក្យទាំងនោះ សម្មប្បធាន តើដូចម្ដេច ។ សេចក្ដីប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សម្មាវាយាមៈ វីរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សម្មប្បធាន ពួកធម៌ដ៏សេស ក៏ឈ្មោះថា ប្រកបដោយសម្មប្បធាន ។

១៧៩



[២៣៨] កថញ្ច ភិក្ខុ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។

[២៣៩] ឆន្ទំ ជនេតីតិ ។ បេ ។ វាយមតីតិ ។ បេ ។ វីរិយំ អារភតីតិ ។ បេ ។ ចិត្តំ បគ្គណ្ហាតីតិ ។ បេ ។ បទហតីតិ តត្ថ កតមំ សម្មប្បធានំ ។ យោ ចេតសិកោ វីរិយារម្ភោ ។ បេ ។ សម្មាវាយាមោ វីរិយសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ ឥទំ វុច្ចតិ សម្មប្បធានំ អវសេសា ធម្មា សម្មប្បធានសម្បយុត្តា ។

[២៣៨] ចុះភិក្ខុញ៉ាំងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញ៉ាំងពួកកុសលធម៌ ដែលមិនទាន់កើត ឲ្យកើតឡើង តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្តៈ) ដើម្បីលះបង់នូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ភិក្ខុឈ្មោះថាញ៉ាំងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញ៉ាំងពួកកុសលធម៌ ដែលមិនទាន់កើត ឲ្យកើតឡើង ។

[២៣៩] ត្រង់ពាក្យថា ញ៉ាំងឆន្ទៈឲ្យកើត ។ បេ ។ ត្រង់ពាក្យថា សង្វាត ។ បេ ។ ត្រង់ពាក្យថា ប្រារព្ធព្យាយាម ។ បេ ។ ត្រង់ពាក្យថា ផ្គងចិត្ត ។ បេ ។ ត្រង់ពាក្យថា ប្រឹងប្រែង មានសេចក្តីថា បណ្តាពាក្យទាំងនោះ សម្មប្បធាន តើដូចម្តេច ។ សេចក្តីប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សម្មាវាយាមៈ វីរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សម្មប្បធាន ពួកធម៌ដ៏សេស ក៏ឈ្មោះថា ប្រកបដោយសម្មប្បធាន ។

[២៤០] កតមញ្ច ភិក្ខុ ឧប្បន្នានំ កុស-
លានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោ-
ភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ
ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ
បទហតិ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុ-
ត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ
ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា
វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបស-
ម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ ស-
មយេ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា
អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ
បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ
ចិត្តំ បគ្គណ្ហាតិ បទហតិ ។

[២៤១] ឋិតិយាតិ យា ឋិតិ សោ អស-
ម្មោសោ យោ អសម្មោសោ សោ ភិយ្យោភាវោ យោ
ភិយ្យោភាវោ តំ វេបុល្លំ យំ វេបុល្លំ សា ភាវនា
យា ភាវនា សា បារិបូរិ ។

[២៨០] ចុះភិក្ខុ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ ដែលកើតហើយ ឲ្យឋិតនៅ មិនឲ្យវិនាស ឲ្យរីងរឹតតែដុះដាល ធំទូលាយ ចម្រើន ពេញ-លេញ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្ដៈ) ដើម្បីលះបង់នូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋម-ភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ភិក្ខុឈ្មោះថា ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ ដែលកើតហើយ ឲ្យឋិតនៅ មិនឲ្យវិនាស ឲ្យរីងរឹតតែដុះដាល ធំទូលាយ ចម្រើន ពេញលេញ ។

[២៨១] ត្រង់ពាក្យថា ឲ្យឋិតនៅ គឺការឋិតនៅ ណា នោះឈ្មោះថា សេចក្ដីមិនវិនាស ឯសេចក្ដីមិនវិនាស ណា នោះឈ្មោះថា ការរីងរឹតតែដុះដាលឡើង ការរីងរឹតតែដុះដាលឡើង ណា នោះឈ្មោះថា ធំទូលាយ ការធំទូលាយ ណា នោះឈ្មោះថា ការចម្រើន ការចម្រើន ណា នោះឈ្មោះថា ការពេញលេញ ។

[២៤២] ឆន្ទំ ជនេតីតិ តត្ថ កតមោ ឆន្ទោ ។ យោ ឆន្ទោ ឆន្ទិកតា កត្តុកម្យតា កុសលោ ធម្មច្ឆន្ទោ អយំ វុច្ចតិ ឆន្ទោ ឥមំ ឆន្ទំ ជនេតិ សញ្ជនេតិ ឧដ្ឋាបេតិ សមុដ្ឋាបេតិ និព្វត្តេតិ អភិ-និព្វត្តេតិ តេន វុច្ចតិ ឆន្ទំ ជនេតីតិ ។

[២៤៣] វាយមតីតិ តត្ថ កតមោ វាយា-មោ ។ យោ ចេតសិកោ វីរិយារម្ភោ ។ បេ ។ សម្មាវាយាមោ វីរិយសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិ-យាបន្នំ អយំ វុច្ចតិ វាយាមោ ឥមិនា វាយាមេន ឧបេតោ ហោតិ ។ បេ ។ សមន្នាគតោ តេន វុច្ចតិ វាយមតីតិ ។

[២៤៤] វីរិយំ អារភតីតិ តត្ថ កតមំ វីរិយំ ។ យោ ចេតសិកោ វីរិយារម្ភោ ។ បេ ។ សម្មាវាយា-មោ វីរិយសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ ឥទំ វុច្ចតិ វីរិយំ ឥមំ វីរិយំ អារភតិ សមារភតិ អាសេវតិ ភាវេតិ ពហុលីករោតិ តេន វុច្ចតិ វីរិយំ អារភតីតិ ។

[២៨២] ត្រង់ពាក្យថា ញុាំងឆន្ទៈឲ្យកើត មានសេចក្តីថា បណ្តាពាក្យទាំងនោះ ឆន្ទៈ តើដូចម្តេច ។ សេចក្តីប្រាថ្នា ភាពនៃបុគ្គលមានសេចក្តីប្រាថ្នា ភាពនៃបុគ្គលអ្នកប្រាថ្នាដើម្បីធ្វើ សេចក្តីប្រាថ្នាធម៌ជាកុសល ណា នេះហៅថា ឆន្ទៈ ភិក្ខុ ញុាំងឆន្ទៈនេះឲ្យកើត ឲ្យលូតលាស់ ឲ្យដុះដាល ឲ្យតាំងឡើង ឲ្យចម្រើនឡើង ឲ្យកើតឡើង ព្រោះហេតុនោះ ទើបពោលថា ញុាំងឆន្ទៈឲ្យកើត ។

[២៨៣] ត្រង់ពាក្យថា សង្វាត មានសេចក្តីថា បណ្តាពាក្យទាំងនោះ សេចក្តីសង្វាត តើដូចម្តេច ។ សេចក្តីប្រារព្ធព្យាយាមប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សម្មាវាយាមៈ គឺវីរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សេចក្តីសង្វាត ភិក្ខុជាអ្នកព្រមព្រៀង ។ បេ ។ ប្រកបព្រម ដោយសេចក្តីសង្វាតនេះ ព្រោះហេតុនោះ ទើបពោលថា សង្វាត ។

[២៨៤] ត្រង់ពាក្យថា ប្រារព្ធព្យាយាម មានសេចក្តីថា បណ្តាពាក្យទាំងនោះ ការព្យាយាម តើដូចម្តេច ។ សេចក្តីប្រារព្ធព្យាយាមប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សម្មាវាយាមៈ វីរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា ការព្យាយាម ភិក្ខុប្រារព្ធ កាន់យកត្រូវ គប់រក អប់រំ ធ្វើឲ្យច្រើន នូវការព្យាយាមនេះ ព្រោះហេតុនោះ ទើបពោលថា ប្រារព្ធព្យាយាម ។

[២៤៥] ចិត្តំ បគ្គណ្ហាតីតិ តត្ថ កតមំ ចិត្តំ ។ យំ ចិត្តំ មនោ មានសំ ។ បេ ។ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ ចិត្តំ ឥមំ ចិត្តំ បគ្គណ្ហាតិ សម្បគ្គណ្ហាតិ ឧបត្ថម្ភេតិ បច្ចុបត្ថម្ភេតិ តេន វុច្ចតិ ចិត្តំ បគ្គណ្ហាតីតិ ។

[២៤៦] បទហតីតិ តត្ថ កតមំ សម្មប្ប-ធានំ ។ យោ ចេតសិកោ វីរិយារម្ភោ ។ បេ ។ សម្មាវាយាមោ វីរិយសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយា-បន្នំ ឥទំ វុច្ចតិ សម្មប្បធានំ អវសេសា ធម្មា សម្មប្បធានសម្បយុត្តា ។

[២៤៧] តត្ថ កតមំ សម្មប្បធានំ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ យោ តស្មឹ សមយេ ចេតសិកោ វីរិ-យារម្ភោ ។ បេ ។ សម្មាវាយាមោ វីរិយសម្ពោជ្ឈង្គោ

[២៨៥] ត្រង់ពាក្យថា ផ្គងចិត្ត មានសេចក្តីថា បណ្តាពាក្យទាំងនោះ ចិត្ត តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។ បេ ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា ចិត្ត ភិក្ខុផ្គង តម្រង់ ជ្រោមជ្រែង ទប់ទល់ទុក នូវចិត្តនេះ ព្រោះហេតុនោះ ទើបពោលថា ផ្គងចិត្ត ។

[២៨៦] ត្រង់ពាក្យថា ប្រឹងប្រែង មានសេចក្តីថា បណ្តាពាក្យទាំងនោះ សម្មប្បធាន តើដូចម្តេច ។ សេចក្តីប្រារព្ធព្យាយាមប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សម្មាវាយាមៈ វីរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សម្មប្បធាន ពួកធម៌ដ៏សេស ដែលប្រកបដោយសម្មប្បធាន (ក៏ឈ្មោះថា សម្មប្បធានដែរ) ។

[២៨៧] បណ្តាពាក្យទាំងនោះ សម្មប្បធាន តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្តៈ) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ សេចក្តីប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សម្មាវាយាមៈ វីរិយ-

មគ្គង្គំ មគ្គបរិយាបន្នំ ឥទំ វុច្ចតិ សម្មប្បធានំ អវសេសា ធម្មា សម្មប្បធានសម្បយុត្តា ។

អភិធម្មភាជនីយំ ។

[២៤៨] ចត្តារោ សម្មប្បធានា ឥធ ភិក្ខុ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ ចតុន្នំ សម្មប្បធានានំ កតិ កុសលា កតិ អកុសលា កតិ អព្យាកតា ។ បេ ។ កតិ សរណា កតិ អរណា ។

សម្មប្បធានវិភង្គ បញ្ហាបុច្ឆកៈ

សម្មោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សម្មប្ប-ធាន ពួកធម៌ដ៏សេស ក៏ឈ្មោះថា ប្រកបដោយសម្មប្បធាន ។

ចប់ អភិធម្មភាជនីយ ។

[២៤៨] សម្មប្បធាន ៤ គឺ ភិក្ខុក្នុងសាសនានេះ ញុំាំងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាំងពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើត មិនឲ្យកើតឡើង ១ ញុំាំងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីលះនូវពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ១ ញុំាំងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាំងពួកកុសលធម៌ ដែលមិនទាន់កើត ឲ្យកើតឡើង ១ ញុំាំងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាំងពួកកុសល-ធម៌ ដែលកើតហើយ ឲ្យឋិតនៅ មិនឲ្យវិនាស ឲ្យរឹងរឹតតែដុះដាលធំទូលាយ ចម្រើន ពេញលេញ ។ បណ្តាសម្មប្បធានទាំង ៤ សម្មប្ប-ធាន ជាកុសលប៉ុន្មាន ជាអកុសលប៉ុន្មាន ជាអព្យាក្រឹតប៉ុន្មាន ។ បេ ។ ជាសរណៈប៉ុន្មាន ជាអរណៈប៉ុន្មាន ។

[២៤៩] កុសលាយេវ សិយា សុខាយ វេ-
ទនាយ សម្បយុត្តា សិយា អទុក្ខមសុខាយ វេទ-
នាយ សម្បយុត្តា វិបាកធម្មធម្មា អនុបាទិន្នានុ-
បាទានិយា អសង្កិលិដ្ឋាសង្កិលេសិកា សិយា
សវិតក្កសវិចារា សិយា អវិតក្កវិចារមត្តា សិយា
អវិតក្កាវិចារា សិយា បីតិសហគតា សិយា
សុខសហគតា សិយា ឧបេក្ខាសហគតា នេវ
ទស្សនេន ន ភាវនាយ បហាតព្វា នេវ ទស្ស-
នេន ន ភាវនាយ បហាតព្វហេតុកា អបចយគា-
មិនោ សេក្ខា អប្បមាណា អប្បមាណារម្មណា
បណីតា សម្មត្តនិយតា ន មគ្គារម្មណា មគ្គហេ-
តុកា សិយា មគ្គាធិបតិនោ សិយា ន វត្តព្វា
មគ្គាធិបតិនោតិ សិយា ឧប្បន្នា សិយា អនុប្បន្នា
ន វត្តព្វា ឧប្បាទិនោតិ សិយា អតីតា សិយា
អនាគតា សិយា បច្ចុប្បន្នា ន វត្តព្វា អតីតារម្ម-
ណាតិបិ អនាគតារម្មណាតិបិ បច្ចុប្បន្នារម្មណាតិបិ
សិយា អជ្ឈត្តា សិយា ពហិទ្ធា សិយា អជ្ឈត្ត-
ពហិទ្ធា ពហិទ្ធារម្មណា អនិទស្សនាប្បដិឃា ។

[៤៤៩] សម្មប្បធាន ៤ ជាកុសលតែមួយយ៉ាង ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនា តែមានវិបាកធម៌ជាប្រក្រតី ដែលកិលេសមានតណ្ហាជាដើមមិនកាន់យក ទាំងមិនជាប្រយោជន៍ដល់ឧបាទាន មិនសៅហ្មង ទាំងមិនគួរដល់សេចក្ដីសៅហ្មងក៏មាន ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈក៏មាន មិនមានវិតក្កៈ មានត្រឹមតែវិចារៈក៏មាន មិនមានវិតក្កៈ មិនមានវិចារៈក៏មាន ប្រទាំដោយបីតិក៏មាន ប្រទាំដោយសុខក៏មាន ប្រទាំដោយឧបេក្ខា តែមិនគួរលះដោយទស្សនៈ ទាំងមិនគួរលះ ដោយភាវនា មានហេតុមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្ដៈ) ជារបស់សេក្ខបុគ្គល មានប្រមាណមិនបាន មានអារម្មណ៍ប្រមាណមិនបាន ដ៏ឧត្ដម មានសភាពត្រូវនិងទៀង មិនមានមគ្គជាអារម្មណ៍ មានមគ្គជាហេតុក៏មាន មានមគ្គជាអធិបតីក៏មាន មិនគួរពោលថា មានមគ្គជាអធិបតីក៏មាន ដែលកើតឡើងហើយក៏មាន មិនទាន់កើតហើយក៏មាន មិនគួរពោលថា បម្រុងនឹងកើតទេ ជាអតីតក៏មាន ជាអនាគតក៏មាន ជាបច្ចុប្បន្ន តែមិនគួរពោលថា មានអារម្មណ៍ជាអតីតផង ថា មានអារម្មណ៍ជាអនាគតផង ថា មានអារម្មណ៍ជាបច្ចុប្បន្នផងក៏មាន ជាខាងក្នុងក៏មាន ជាខាងក្រៅក៏មាន ជាខាងក្នុងនិងខាងក្រៅ មានអារម្មណ៍ជាខាងក្រៅ មិនប្រកបដោយការឃើញ ទាំងមិនប្រកបដោយការប៉ះពាល់ក៏មាន ។

សម្មប្បធានវិភង្គេ បញ្ហាបុច្ឆកំ

[២៤០] ន ហេតុ សហេតុកា ហេតុសម្ប-
យុត្តា ន វត្តព្វា ហេតូ ចេវ សហេតុកា ចាតិ
សហេតុកា ចេវ ន ច ហេតូ ន វត្តព្វា ហេតូ
ចេវ ហេតុសម្បយុត្តា ចាតិ ហេតុសម្បយុត្តា ចេវ
ន ច ហេតូ ន ហេតូ សហេតុកា ។ សប្បច្ច-
យា សង្ខតា អនិទស្សនា អប្បដិឃា អរូបា លោ-
កុត្តរា កេនចិ វិញ្ញេយ្យា កេនចិ ន វិញ្ញេយ្យា ។
នោ អាសវា អនាសវា អាសវវិប្បយុត្តា ន វត្តព្វា
អាសវា ចេវ សាសវា ចាតិបិ សាសវា ចេវ នោ
ច អាសវាតិបិ ន វត្តព្វា អាសវា ចេវ អាសវ-
សម្បយុត្តា ចាតិបិ អាសវសម្បយុត្តា ចេវ នោ
ច អាសវាតិបិ អាសវវិប្បយុត្តអនាសវា ។ នោ
សញ្ញោជនា ។ បេ ។ នោ គន្ថា ។ បេ ។
នោ ឱឃា ។ បេ ។ នោ យោគា ។ បេ ។
នោ នីវរណា ។ បេ ។ នោ បរាមាសា ។ បេ ។
សារម្មណា នោ ចិត្តា ចេតសិកា ចិត្តសម្បយុត្តា

[២៥០] សម្មប្បធាន ៤ មិនមែនជាហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុ ប្រកបដោយហេតុ មិនគួរពោលថា ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុទេ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុ មិនគួរពោលថា ជាហេតុ ទាំងប្រកបដោយហេតុឡើយ គ្រាន់តែប្រកបដោយហេតុ តែមិនមែនហេតុ មិនមែនហេតុគ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ ។ សម្មប្បធាន ៤ ប្រកបដោយបច្ច័យ ត្រូវបច្ច័យតាក់តែង មិនប្រកបដោយការឃើញ មិនប្រកបដោយការប៉ះពាល់ មិនមានរូប ជាលោកុត្តរៈ គួរដឹងដោយវិញ្ញាណណាមួយ មិនគួរដឹងដោយវិញ្ញាណណាមួយ ។ សម្មប្បធាន ៤ មិនមែនជាអាសវៈ មិនមានអាសវៈ ប្រាសចាកអាសវៈ មិនគួរពោលថា អាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ថា ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនអាសវៈផងទេ មិនគួរពោលថា អាសវៈ ទាំងប្រកបដោយអាសវៈផង ថា ប្រកបដោយអាសវៈ តែមិនមែនជាអាសវៈផងឡើយ គឺជាធម៌ ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ។ សម្មប្បធាន ៤ មិនមែនសញ្ញោជនៈ ។ បេ ។ មិនមែនគន្ថៈ ។ បេ ។ មិនមែនឱឃៈ ។ បេ ។ មិនមែនយោគៈ ។ បេ ។ មិនមែននីវរណៈ ។ បេ ។ មិនមែនបរាមាសៈ ។ បេ ។ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ មិនមែនចិត្ត ជាចេតសិក ប្រកបដោយចិត្ត

ចិត្តសំសដ្ឋា ចិត្តសមុដ្ឋានា ចិត្តសហភុនោ ចិត្តានុបរិវត្តិនោ ចិត្តសំសដ្ឋសមុដ្ឋានា ចិត្តសំសដ្ឋសមុដ្ឋានសហភុនោ ចិត្តសំសដ្ឋសមុដ្ឋានានុបរិវត្តិនោ ពាហិរា នុបាទា អនុបាទិន្នា ។ នុបាទានា ។ បេ ។ នោ កិលេសា ។ បេ ។ ន ទស្សនេន បហាតព្វា ន ភាវនាយ បហាតព្វា ន ទស្សនេន បហាតព្វហេតុកា ន ភាវនាយ បហាតព្វហេតុកា សិយា សវិតក្កា សិយា អវិតក្កា សិយា សវិចារា សិយា អវិចារា សិយា សប្បីតិកា សិយា អប្បីតិកា សិយា បីតិសហគតា សិយា ន បីតិសហគតា សិយា សុខសហគតា សិយា ន សុខសហគតា សិយា ឧបេក្ខាសហគតា សិយា ន ឧបេក្ខាសហគតា ន កាមាវចរា ន រូបាវចរា ន អរូបាវចរា អបរិយាបន្នា និយ្យានិកា និយតា អនុត្តរា អរណាតិ ។

បញ្ហាបុច្ឆកំ ។

សម្មប្បធានវិភង្គោ សមត្តោ ។

---

ប្រទ្បំដោយចិត្ត តាំងឡើងដោយចិត្ត កើតជាមួយនឹងចិត្ត ប្រព្រឹត្តទៅតាមចិត្ត ប្រទ្បំ ទាំងតាំងឡើងដោយចិត្ត ប្រទ្បំ ទាំងតាំងឡើង ទាំងកើតជាមួយនឹងចិត្ត ប្រទ្បំ ទាំងតាំងឡើង ទាំងប្រព្រឹត្តទៅតាមចិត្ត ជាខាងក្រៅ មិនមែនឧបាទា ដែលកិលេសមានតណ្ហាជាដើម មិនកាន់យក ។ សម្មប្បធាន ៤ មិនមែនឧបាទាន ។ បេ ។ មិនមែនកិលេស ។ បេ ។ មិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា មានហេតុមិនគួរលះដោយទស្សនៈ មានហេតុមិនគួរលះដោយភាវនា ប្រកបដោយវិតក្កៈក៏មាន មិនមានវិតក្កៈក៏មាន ប្រកបដោយវិចារៈក៏មាន មិនមានវិចារៈក៏មាន ប្រកបដោយបីតិក៏មាន មិនមានបីតិក៏មាន ប្រទ្បំដោយបីតិក៏មាន មិនប្រទ្បំដោយបីតិក៏មាន ប្រទ្បំដោយសុខក៏មាន មិនប្រទ្បំដោយសុខក៏មាន ប្រទ្បំដោយឧបេក្ខាក៏មាន មិនប្រទ្បំដោយឧបេក្ខា តែមិនមែនកាមាវចរ មិនមែនរូបាវចរ មិនមែនអរូបាវចរ ជាអបរិយាបន្នៈ ជានិយ្យានិកៈ ជានិយតៈ ជាអនុត្តរៈ ជាអរណៈ ក៏មាន ។

ចប់ បញ្ហាបុច្ឆកៈ ។

ចប់ សម្មប្បធានវិភង្គ ។

---

# ឥទ្ធិបាទវិភង្គោ

[២៤១] ចត្តារោ ឥទ្ធិបាទា ឥធ ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ វីរិយសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ចិត្តសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។

[២៤២] កថញ្ច ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ ឆន្ទញ្ចេ ភិក្ខុ អធិបតឹ ករិត្វា លភតិ សមាធឹ លភតិ ចិត្តស្ស ឯកគ្គតំ អយំ វុច្ចតិ ឆន្ទសមាធិ ។ សោ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ

# ឥទ្ធិបាទវិភង្គ

[២៥១] ឥទ្ធិបាទ ៤ គឺ ភិក្ខុក្នុងសាសនានេះ ចម្រើននូវឥទ្ធិ-បាទ ប្រកបដោយឆន្ទសមាធិ និងបធានសង្ខារ ១ ចម្រើននូវឥទ្ធិបាទ ប្រកបដោយវិរិយសមាធិ និងបធានសង្ខារ ១ ចម្រើននូវឥទ្ធិបាទ ប្រកបដោយចិត្តសមាធិ និងបធានសង្ខារ ១ ចម្រើននូវឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិ និងបធានសង្ខារ ១ ។

[២៥២] ចុះភិក្ខុ ចម្រើននូវឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិ និងបធានសង្ខារ តើដូចម្តេច ។ បើភិក្ខុ ធ្វើឆន្ទៈឲ្យជាអធិបតី រមែងបាននូវសមាធិ បាននូវភាពនៃចិត្តមានអារម្មណ៍មូលតែមួយ នេះហៅថា ឆន្ទសមាធិ ។ ភិក្ខុនោះ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកអកុសលធម៌ដ៏លាមកដែលមិនទាន់កើត មិនឲ្យកើតឡើង ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីលះនូវពួកអកុសលធម៌ដ៏លាមកដែលកើតហើយ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ ដែលមិនទាន់កើត ឲ្យកើតឡើង

បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វិរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឥមេ វុច្ចន្តិ បធានសង្ខារា ។ ឥតិ អយញ្ច ឆន្ទសមាធិ ឥមេ ច បធានសង្ខារា តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា ឆន្ទសមាធិប្បធានសង្ខារោត្វេវ សំខ្យំ គច្ឆតិ ។

[២៨៣] តត្ថ កតមោ ឆន្ទោ ។ យោ ឆន្ទោ ឆន្ទិកតា កត្តុកម្យតា កុសលោ ធម្មច្ឆន្ទោ អយំ វុច្ចតិ ឆន្ទោ ។ តត្ថ កតមោ សមាធិ ។ យា ចិត្តស្ស ឋិតិ សណ្ឋិតិ អវដ្ឋិតិ អវិសាហារោ អវិក្ខេបោ អវិសាហដមានសតា សមថោ សមាធិន្ទ្រិយំ សមាធិពលំ សម្មាសមាធិ អយំ វុច្ចតិ សមាធិ ។ តត្ថ កតមោ បធានសង្ខារោ ។ យោ ចេតសិកោ វិរិយារម្ភោ និក្កមោ បរក្កមោ ឧយ្យាមោ វាយាមោ ឧស្សាហោ ឧស្សោឡ្ហី ថាមោ ឋិតិ អសិថិលបរក្កមតា អនិក្ខិត្តច្ឆន្ទតា អនិក្ខិត្តធុរតា ធុរសម្បគ្គាហោ វិរិយំ វិរិយិន្ទ្រិយំ

ញ៉ាំងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញ៉ាំងពួកកុសលធម៌ ដែលកើតហើយ ឲ្យឋិតនៅ មិនឲ្យវិនាស ឲ្យរឹងរឹតតែដុះដាល ធំទូលាយ ចម្រើន ពេញលេញ ធម៌ទាំងនេះ ហៅថា បធានសង្ខារ ។ ឆន្ទសមាធិនេះផង បធានសង្ខារ នេះផង ដល់នូវការរាប់ថា ឆន្ទសមាធិ និងបធានសង្ខារ ព្រោះប្រមូលរួបរួម នូវធម៌នោះក្នុងទីជាមួយគ្នា ដោយប្រការដូច្នេះ ។

[២៥៣] បណ្តា ធម៌ទាំងនោះ ឆន្ទៈ តើដូចម្តេច ។ សេចក្តីប្រាថ្នា ភាពនៃបុគ្គលមានសេចក្តីប្រាថ្នា ភាពនៃបុគ្គលប្រាថ្នាដើម្បីធ្វើ ការប្រាថ្នាធម៌ជាកុសល ណា នេះហៅថា ឆន្ទៈ ។ បណ្តាធម៌ទាំងនោះ សមាធិ តើដូចម្តេច ។ ការតាំងនៅ ការខ្ជាប់ខ្ជួន ការឋិតនៅស៊ប់ ការមិនឃ្លេងឃ្លោង ការមិនរាយមាយ ភាពនៃចិត្តមិនឃ្លេងឃ្លោង ការស្ងប់រម្ងាប់ សមាធិន្ទ្រិយ សមាធិពលៈ សម្មាសមាធិ ណា នៃចិត្ត នេះហៅថា សមាធិ ។ បណ្តាធម៌ទាំងនោះ បធាន-សង្ខារ តើដូចម្តេច ។ ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ការឧិហាត សង្វាត ខិតខំ ព្យាយាម ឧស្សាហ៍ ប្រឹងប្រែង ខ្មីឃ្មាត ខ្នះខ្នែង សេចក្តីសង្វាតមិនបន្ធូរបន្ថយ មិនដាក់ចោលនូវសេចក្តីប្រាថ្នា មិនទម្លាក់ធុរៈចេញ ផ្គងទុកនូវធុរៈ វីរិយៈ វីរិយិន្ទ្រិយ

វីរិយពលំ សម្មាវាយាមោ អយំ វុច្ចតិ បធាន-សង្ខារោ ។ ឥតិ ឥមិនា ច ឆន្ទេន ឥមិនា ច សមាធិនា ឥមិនា ច បធានសង្ខារេន ឧបេតោ ហោតិ សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ តេន វុច្ចតិ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតោតិ ។

[២៨៤] ឥទ្ធីតិ យា តេសំ ធម្មានំ ឥទ្ធិ សមិទ្ធិ ឥជ្ឈនា សមិជ្ឈនា លាភោ បដិលាភោ បត្តិ សម្បត្តិ ផុសនា សច្ឆិកិរិយា ឧបសម្បទា ។ ឥទ្ធិបាទោតិ តថាភូតស្ស វេទនាខន្ធោ សញ្ញាខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ ។ ឥទ្ធិបាទំ ភាវេតីតិ តេ ធម្មេ អាសេវតិ ភាវេតិ ពហុលីករោតិ តេន វុច្ចតិ ឥទ្ធិបាទំ ភាវេតីតិ ។

[២៨៥] កថញ្ច ភិក្ខុ វីរិយសមាធិប្បធាន-សង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ វីរិយញ្ចេ ភិក្ខុ អធិបតឹ ករិត្វា លភតិ សមាធឹ លភតិ ចិត្តស្ស ឯកគ្គតំ អយំ វុច្ចតិ វីរិយសមាធិ ។

វីរិយពលៈ សម្មាវាយាមៈ ណា នេះហៅថា បធានសង្ខារ ។ ភិក្ខុ ជាអ្នកព្រមព្រៀង មូលមិត្រ ចូលទៅជិត អែបនែប កៀកកើយ ប្រ-ជិតប្រជី ប្រកបព្រម ដោយឆន្ទៈនេះផង ដោយសមាធិនេះផង ដោយបធានសង្ខារនេះផង ព្រោះហេតុនោះ ទើបពោលថា ប្រកបដោយឆន្ទ-សមាធិ និងបធានសង្ខារ ដោយប្រការដូច្នេះ ។

[២៥៤] ពាក្យថា ឥទ្ធិ បានដល់ ការសម្រេច ការសម្រេចព្រម អាការសម្រេច អាការសម្រេចព្រម ការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ កិរិយាធ្វើឲ្យជាក់ច្បាស់ ការបានគ្រប់គ្រាន់ នូវធម៌ទាំងឡាយនោះ ។ ពាក្យថា ឥទ្ធិបាទ គឺ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ របស់បុគ្គលមានសភាពដូច្នោះ ។ ពាក្យថា ចម្រើននូវឥទ្ធិបាទ គឺ ភិក្ខុគប់រក អប់រំ ធ្វើឲ្យច្រើន នូវធម៌ទាំងនោះ ព្រោះហេតុនោះ ទើបពោលថា ចម្រើននូវឥទ្ធិបាទ ។

[២៥៥] ចុះភិក្ខុចម្រើននូវឥទ្ធិបាទ ប្រកបដោយវីរិយសមាធិនិងបធាន-សង្ខារ តើដូចម្តេច ។ បើភិក្ខុ ធ្វើវីរិយៈឲ្យជាអធិបតី រមែងបាននូវសមាធិ បាននូវភាពនៃចិត្តមានអារម្មណ៍មូលតែមួយ នេះហៅថា វីរិយសមាធិ ។

សោ អនុប្បន្នានំ ចាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ អកុសលានំ ធម្មានំ បហានាយ ។ បេ ។ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ។ បេ ។ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ ចារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឥមេ វុច្ចន្តិ បធានសង្ខារា ។ ឥតិ អយញ្ច វីរិយ-សមាធិ ឥមេ ច បធានសង្ខារា តទេកជ្ឈំ អភិ-សញ្ញូហិត្វា អភិសង្ខិបិត្វា វីរិយសមាធិប្បធានសង្ខា-រោត្វេវ សំខ្យំ គច្ឆតិ ។

[២៨៦] តត្ថ កតមំ វីរិយំ ។ យោ ចេតសិ-កោ វីរិយារម្ភោ ។ បេ ។ សម្មាវាយាមោ ឥទំ វុច្ចតិ វីរិយំ ។ តត្ថ កតមោ សមាធិ ។ យា ចិត្តស្ស ឋិតិ សណ្ឋិតិ អវដ្ឋិតិ អវិសាហារោ អវិក្ខេបោ អវិសាហដមានសតា សមថោ សមាធិន្ទ្រិយំ ស-មាធិពលំ សម្មាសមាធិ អយំ វុច្ចតិ សមាធិ ។

ភិក្ខុនោះ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើត មិនឲ្យកើតឡើង ដើម្បីលះ នូវពួកអកុសលធម៌ដ៏លាមក ដែលកើតហើយ ។ បេ ។ ដើម្បីញុំាងពួកកុសលធម៌ ដែលមិនទាន់កើត ឲ្យកើតឡើង ។ បេ ។ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ ដែលកើតហើយ ឲ្យឋិតនៅ មិនឲ្យវិនាស ឲ្យរីងរឹតតែដុះដាល ធំទូលាយ ចម្រើន ពេញលេញ ធម៌ទាំងនេះ ហៅថា បធានសង្ខារ ។ វិរិយសមាធិនេះផង បធានសង្ខារទាំងនេះផង ដល់នូវការរាប់ថា វិរិយសមាធិ និងបធានសង្ខារ ព្រោះប្រមូលរួបរួមនូវធម៌នោះ ក្នុងទីជាមួយគ្នា ដោយប្រការដូច្នេះ ។

[២៩៦] បណ្តាធម៌ទាំងនោះ វិរិយៈ តើដូចម្តេច ។ ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សម្មាវាយាមៈ ណា នេះហៅថា វិរិយៈ ។ បណ្តាធម៌ទាំងនោះ សមាធិ តើដូចម្តេច ។ ការតាំងនៅ ការខ្ជាប់ខ្ជួន ការឋិតនៅស៊ប់ ការមិនឃ្វេងឃ្វាង ការមិនរាយមាយ ភាពនៃចិត្តមិនឃ្វេងឃ្វាង ការស្ងប់រម្ងាប់ សមាធិន្ទ្រិយ សមាធិពលៈ សម្មាសមាធិ ណា នៃចិត្ត នេះហៅថា សមាធិ ។

តត្ថ កតមោ បធានសង្ខារោ ។ យោ ចេតសិកោ វីរិយារម្ភោ ។ បេ ។ សម្មាវាយាមោ អយំ វុច្ចតិ បធានសង្ខារោ ។ ឥតិ ឥមិនា ច វីរិយេន ឥមិនា ច សមាធិនា ឥមិនា ច បធានសង្ខារេន ឧបេតោ ហោតិ ។ បេ ។ សមន្នាគតោ តេន វុច្ចតិ វីរិយសមាធិប្បធានសង្ខារសមន្នាគតោតិ ។

[២៤៧] ឥទ្ធីតិ យា តេសំ ធម្មានំ ឥទ្ធិ សមិទ្ធិ ឥជ្ឈនា សមិជ្ឈនា លាភោ បដិលាភោ បត្តិ សម្បត្តិ ផុសនា សច្ឆិកិរិយា ឧបសម្បទា ។ ឥទ្ធិបាទោតិ តថាភូតស្ស វេទនាខន្ធោ សញ្ញាខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ ។ ឥទ្ធិបាទំ ភាវេតីតិ តេ ធម្មេ អាសេវតិ ភាវេតិ ពហុលីករោតិ តេន វុច្ចតិ ឥទ្ធិបាទំ ភាវេតីតិ ។

[២៤៨] កថញ្ច ភិក្ខុ ចិត្តសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ ចិត្តញ្ចេ ភិក្ខុ អធិបតឹ ករិត្វា លភតិ សមាធឹ លភតិ ចិត្តស្ស ឯកគ្គតំ អយំ វុច្ចតិ ចិត្តសមាធិ ។

បណ្តាធម៌ទាំងនោះ បធានសង្ខារ តើដូចម្តេច ។ ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សម្មាវាយាមៈ ណា នេះហៅថា បធានសង្ខារ ។ ភិក្ខុជាអ្នកព្រមព្រៀង ។ បេ ។ ប្រកបព្រម ដោយវីរិយៈ នេះផង ដោយសមាធិនេះផង ដោយបធានសង្ខារនេះផង ព្រោះ ហេតុនោះ ទើបហៅថា ប្រកបដោយវីរិយសមាធិ និងបធានសង្ខារ ដោយប្រការដូច្នេះ ។

[២៩៧] ត្រង់ពាក្យថា ឥទ្ធិ បានដល់ ការសម្រេច ការ សម្រេចព្រម អាការសម្រេច អាការសម្រេចព្រម ការបាន ការ បានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ កិរិយាធ្វើឲ្យ ជាក់ច្បាស់ ការបានគ្រប់គ្រាន់ នូវធម៌ទាំងឡាយនោះ ។ ពាក្យថា ឥទ្ធិបាទ គឺ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ របស់ បុគ្គលមានសភាពដូច្នេះ ។ ពាក្យថា ចម្រើននូវឥទ្ធិបាទ គឺភិក្ខុគប់ រក អប់រំ ធ្វើឲ្យច្រើន នូវធម៌ទាំងឡាយនោះ ព្រោះហេតុនោះ ទើប ពោលថា ចម្រើននូវឥទ្ធិបាទ ។

[២៩៨] ចុះភិក្ខុចម្រើននូវឥទ្ធិបាទ ប្រកបដោយចិត្តសមាធិនិងបធាន-សង្ខារ តើដូចម្តេច ។ បើភិក្ខុ ធ្វើចិត្តឲ្យជាអធិបតី រមែងបាននូវសមាធិ បាននូវភាពនៃចិត្តមានអារម្មណ៍មូលតែមួយ នេះហៅថា ចិត្តសមាធិ ។

សោ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ។ បេ ។ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ។ បេ ។ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឥមេ វុច្ចន្តិ បធានសង្ខារា ។ ឥតិ អយញ្ច ចិត្តសមាធិ ឥមេ ច បធានសង្ខារា តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា ចិត្តសមាធិប្បធានសង្ខារោត្វេវ សំខ្យំ គច្ឆតិ ។

[២៨៩] តត្ថ កតមំ ចិត្តំ ។ យំ ចិត្តំ មនោ មានសំ ។ បេ ។ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ ចិត្តំ ។ តត្ថ កតមោ សមាធិ ។ យា ចិត្តស្ស ឋិតិ ។ បេ ។ សម្មាសមាធិ អយំ វុច្ចតិ សមាធិ ។ តត្ថ កតមោ បធានសង្ខារោ ។ យោ ចេតសិកោ វីរិយារម្ភោ ។ បេ ។ សម្មាវាយាមោ អយំ វុច្ចតិ បធានសង្ខារោ ។

ភិក្ខុនោះ ញ៉ាំងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញ៉ាំងពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើត មិនឲ្យកើតឡើង ដើម្បីលះនូវពួកអកុសលធម៌ដ៏លាមក ដែលកើតហើយ ។ បេ ។ ដើម្បីញ៉ាំងកុសលធម៌ទាំងឡាយ ដែលមិនទាន់កើត ឲ្យកើតឡើង ។ បេ ។ ញ៉ាំងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញ៉ាំងពួកកុសលធម៌ ដែលកើតហើយ ឲ្យឋិតនៅ មិនឲ្យវិនាស ឲ្យរឹងរឹតតែដុះដាល ធំទូលាយ ចម្រើន ពេញលេញ ធម៌ទាំងនេះហៅថា បធានសង្ខារ ។ ចិត្តសមាធិនេះផង បធានសង្ខារនេះផង ដល់នូវការរាប់ថា ចិត្តសមាធិនិងបធានសង្ខារ ព្រោះប្រមូលរួបរួមនូវធម៌នោះ ក្នុងទីជាមួយគ្នា ដោយប្រការដូច្នេះ ។

[២៥៩] បណ្តាពាក្យទាំងនោះ ចិត្ត តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។ បេ ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ ណា នេះហៅថា ចិត្ត ។ បណ្តាធម៌ទាំងនោះ សមាធិ តើដូចម្តេច ។ ការតាំងនៅ នៃចិត្ត ។ បេ ។ សម្មាសមាធិ ណា នេះ ហៅថា សមាធិ ។ បណ្តាធម៌ទាំងនោះ បធានសង្ខារ តើដូចម្តេច ។ ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សម្មាវាយាមៈ ណា នេះហៅថា បធានសង្ខារ ។

ឥតិ ឥមិនា ច ចិត្តេន ឥមិនា ច សមាធិនា ឥមិនា ច បធានសង្ខារេន ឧបេតោ ហោតិ ។ បេ ។ សមន្នាគតោ តេន វុច្ចតិ ចិត្តសមាធិប្បធានសង្ខារសមន្នាគតោតិ ។

[២៦០] ឥទ្ធីតិ យា តេសំ ធម្មានំ ឥទ្ធិ សមិទ្ធិ ឥជ្ឈនា សមិជ្ឈនា លាភោ បដិលាភោ បត្តិ សម្បត្តិ ផុសនា សច្ឆិកិរិយា ឧបសម្បទា ។ ឥទ្ធិបាទោតិ តថាភូតស្ស វេទនាខន្ធោ សញ្ញាខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ ។ ឥទ្ធិបាទំ ភាវេតីតិ តេ ធម្មេ អាសេវតិ ភាវេតិ ពហុលីករោតិ តេន វុច្ចតិ ឥទ្ធិបាទំ ភាវេតីតិ ។

[២៦១] កថញ្ច ភិក្ខុ វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ វីមំសញ្ចេ ភិក្ខុ អធិបតឹ ករិត្វា លភតិ សមាធឹ លភតិ ចិត្តស្ស ឯកគ្គតំ អយំ វុច្ចតិ វីមំសាសមាធិ ។ សោ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ

ភិក្ខុជាអ្នកព្រមព្រៀង ។ បេ ។ ប្រកបព្រម ដោយចិត្តនេះផង ដោយសមាធិនេះផង ដោយបធានសង្ខារនេះផង ព្រោះហេតុនោះ ទើបពោលថា ចិត្តសមាធិនិងបធានសង្ខារ ដោយប្រការដូច្នេះ ។

[២៦០] ពាក្យថា ឥទ្ធិ បានដល់ការសម្រេច ការសម្រេចព្រម អាការសម្រេច អាការសម្រេចព្រម ការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ កិរិយាធ្វើឲ្យជាក់ច្បាស់ ការបានគ្រប់គ្រាន់ នូវធម៌ទាំងឡាយនោះ ។ ពាក្យថា ឥទ្ធិបាទ គឺ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ របស់បុគ្គលមានសភាពដូច្នោះ ។ ពាក្យថា ចម្រើននូវឥទ្ធិបាទ គឺ ភិក្ខុ គប់រក អប់រំ ធ្វើឲ្យច្រើន នូវធម៌ទាំងនោះ ព្រោះហេតុនោះ ទើបពោលថា ចម្រើននូវឥទ្ធិបាទ ។

[២៦១] ចុះភិក្ខុ ចម្រើននូវឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ តើដូចម្តេច ។ បើភិក្ខុធ្វើនូវវីមំសាឲ្យជាអធិបតី រមែងបាននូវសមាធិ បាននូវភាពនៃចិត្តមានអារម្មណ៍មូលតែមួយ នេះហៅថា វីមំសាសមាធិ ។ ភិក្ខុនោះ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើត មិនឲ្យកើតឡើង ដើម្បីលះនូវពួកអកុសលធម៌ដ៏លាមក

បហានាយ ។ បេ ។ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ។ បេ ។ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឥមេ វុច្ចន្តិ បធានសង្ខារា ។ ឥតិ អយញ្ច វីមំសាសមាធិ ឥមេ ច បធានសង្ខារា តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា វីមំសាសមាធិប្បធានសង្ខារោត្វេវ សំខ្យំ គច្ឆតិ ។

[២៦២] តត្ថ កតមា វីមំសា ។ យា បញ្ញា បជានានា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ អយំ វុច្ចតិ វីមំសា ។ តត្ថ កតមោ សមាធិ ។ យា ចិត្តស្ស ឋិតិ ។ បេ ។ សម្មាសមាធិ អយំ វុច្ចតិ សមាធិ ។ តត្ថ កតមោ បធានសង្ខារោ ។ យោ ចេតសិកោ វីរិយារម្ភោ ។ បេ ។ សម្មាវាយាមោ អយំ វុច្ចតិ បធានសង្ខារោ ។ ឥតិ ឥមាយ ច វីមំសាយ ឥមិនា ច សមាធិនា ឥមិនា ច បធានសង្ខារេន ឧបេតោ ហោតិ ។ បេ ។ សមន្នាគតោ តេន វុច្ចតិ វីមំសាសមាធិប្បធានសង្ខារសមន្នាគតោតិ ។

ដែលកើតហើយ ។ បេ ។ ដើម្បីញុំាងពួកកុសលធម៌ ដែលមិនទាន់កើត ឲ្យកើតឡើង ។ បេ ។ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ ដែលកើតហើយ ឲ្យឋិតនៅ មិនឲ្យវិនាស ឲ្យរឹងរឹតតែដុះដាល ធំទូលាយ ចម្រើនពេញលេញ ធម៌ទាំងនេះហៅថា បធានសង្ខារ ។ វីមំសាសមាធិនេះផង បធានសង្ខារទាំងនេះផង ដល់នូវការរាប់ថា វីមំសាសមាធិនិងបធានសង្ខារ ព្រោះប្រមូលរួបរួមនូវធម៌នោះក្នុងទីជាមួយគ្នា ដោយប្រការដូច្នេះ ។

[២៦២] បណ្ដាធម៌ទាំងនោះ វីមំសា តើដូចម្ដេច ។ បញ្ញាការដឹងច្បាស់ ។ បេ ។ អមោហៈ ធម្មវិចយៈ សម្មាទិដ្ឋិ ណានេះហៅថា វីមំសា ។ បណ្ដាធម៌ទាំងនោះ សមាធិ តើដូចម្ដេច ។ ការតាំងនៅ នៃចិត្ត ។ បេ ។ សម្មាសមាធិ ណា នេះហៅថាសមាធិ ។ បណ្ដាធម៌ទាំងនោះ បធានសង្ខារ តើដូចម្ដេច ។ ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សម្មាវាយាមៈ ណានេះហៅថា បធានសង្ខារ ។ ភិក្ខុ ជាអ្នកព្រមព្រៀង ។ បេ ។ ប្រកបព្រម ដោយវីមំសានេះផង ដោយសមាធិនេះផង ដោយបធានសង្ខារនេះផង ព្រោះហេតុនោះ ទើបពោលថា ប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ដោយប្រការដូច្នេះ ។

[២៦៣] ឥទ្ធីតិ យា តេសំ ធម្មានំ ឥទ្ធិ សមិទ្ធិ ឥជ្ឈនា សមិជ្ឈនា លាភោ បដិលាភោ បត្តិ សម្បត្តិ ផុសនា សច្ឆិកិរិយា ឧបសម្បទា ។ ឥទ្ធិបាទោតិ តថាភូតស្ស វេទនាក្ខន្ធោ សញ្ញាក្ខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ ។ ឥទ្ធិបាទំ ភាវេតីតិ តេ ធម្មេ អាសេវតិ ភាវេតិ ពហុលីករោតិ តេន វុច្ចតិ ឥទ្ធិបាទំ ភាវេតីតិ ។

សុត្តន្តភាជនីយំ ។

[២៦៤] ចត្តារោ ឥទ្ធិបាទា ឥធ ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ វីរិយសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ចិត្តសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។

[២៦៥] កថញ្ច ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ

[២៦៣] ពាក្យថា ឥទ្ធិ បានដល់ការសម្រេច ការសម្រេចព្រម អាការសម្រេច អាការសម្រេចព្រម ការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ កិរិយាធ្វើឲ្យជាក់ច្បាស់ ការបានគ្រប់គ្រាន់ នូវធម៌ទាំងឡាយនោះ ។ ពាក្យថា ឥទ្ធិបាទ គឺ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ របស់បុគ្គលមានសភាពដូច្នោះ ។ ពាក្យថា ចម្រើននូវឥទ្ធិបាទ គឺ ភិក្ខុគប់រក អប់រំ ធ្វើឲ្យច្រើន នូវធម៌ទាំងនោះ ព្រោះហេតុនោះ ទើបពោលថា ចម្រើននូវឥទ្ធិបាទ ។

ចប់ សុត្តន្តភាជនីយ ។

[២៦៤] ឥទ្ធិបាទ ៤ គឺ ភិក្ខុក្នុងសាសនានេះ ខំចម្រើននូវឥទ្ធិបាទប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ១ ចម្រើននូវឥទ្ធិបាទ ប្រកបដោយវីរិយសមាធិនិងបធានសង្ខារ ១ ចម្រើននូវឥទ្ធិបាទ ប្រកបដោយចិត្ត-សមាធិនិងបធានសង្ខារ ១ ចម្រើននូវឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ១ ។

[២៦៥] ចុះភិក្ខុ ចម្រើននូវឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ តើដូចម្តេច ។ ក្នុងសម័យ ណា ភិក្ខុក្នុងសាសនានេះ ចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្ដៈ) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន

ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។

[២៦៦] តត្ថ កតមោ ឆន្ទោ ។ យោ ឆន្ទោ ឆន្ទិកតា កត្តុកម្យតា កុសលោ ធម្មច្ឆន្ទោ អយំ វុច្ចតិ ឆន្ទោ ។ តត្ថ កតមោ សមាធិ ។ យា ចិត្តស្ស ឋិតិ ។ បេ ។ សម្មាសមាធិ សមាធិសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ សមាធិ ។ តត្ថ កតមោ បធានសង្ខារោ ។ យោ ចេតសិកោ វីរិយារម្ភោ ។ បេ ។ សម្មាវាយាមោ វីរិយសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ បធានសង្ខារោ ។ ឥតិ ឥមិនា ច ឆន្ទេន ឥមិនា ច សមាធិនា ឥមិនា ច បធានសង្ខារេន ឧបេតោ ហោតិ ។ បេ ។ សមន្នាគតោ តេន វុច្ចតិ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតោតិ ។

[២៦៧] ឥទ្ធីតិ យា តេសំ ធម្មានំ ឥទ្ធិ សមិទ្ធិ ឥជ្ឈនា សមិជ្ឈនា លាភោ បដិលាភោ បត្តិ សម្បត្តិ ផុសនា សច្ឆិកិរិយា ឧបសម្បទា ។ ឥទ្ធិបាទោតិ

ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ភិក្ខុ ឈ្មោះថា ចម្រើននូវឥទ្ធិ-បាទ ប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ។

[២៦៦] បណ្ដាធម៌ទាំងនោះ ឆន្ទៈ តើដូចម្ដេច ។ សេចក្ដីប្រាថ្នា ភាពនៃបុគ្គលមានសេចក្ដីប្រាថ្នា ភាពនៃបុគ្គលប្រាថ្នាដើម្បីធ្វើការប្រាថ្នាធម៌ជាកុសល ណា នេះហៅថា ឆន្ទៈ ។ បណ្ដាធម៌ទាំងនោះ សមាធិ តើដូចម្ដេច ។ ការតាំងនៅ នៃចិត្ត ។ បេ ។ សម្មាសមាធិ សមាធិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សមាធិ ។ បណ្ដាធម៌ទាំងនោះ បធានសង្ខារ តើដូចម្ដេច ។ ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សម្មាវាយាមៈ វីរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា បធានសង្ខារ ។ ភិក្ខុជាអ្នកព្រមព្រៀង ។ បេ ។ ប្រកបព្រម ដោយឆន្ទៈនេះផង ដោយសមាធិនេះផង ដោយបធានសង្ខារនេះផង ព្រោះហេតុនោះ ទើបពោលថា ប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ដោយប្រការដូច្នេះ ។

[២៦៧] ពាក្យថា ឥទ្ធិ បានដល់ការសម្រេច ការសម្រេចព្រម អាការសម្រេច អាការសម្រេចព្រម ការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ កិរិយាធ្វើឲ្យជាក់ច្បាស់ ការបានគ្រប់គ្រាន់ នូវធម៌ទាំងឡាយនោះ ។ ពាក្យថា ឥទ្ធិបាទ

តថាភូតស្ស ផស្សោ ។ បេ ។ បគ្គាហោ អវិក្ខេ-
ចោ ។ ឥទ្ធិបាទំ ភាវេតីតិ តេ ធម្មេ អាសេវតិ
ភាវេតិ ពហុលីករោតិ តេន វុច្ចតិ ឥទ្ធិបាទំ ភាវេតីតិ ។

[២៦៨] កតមញ្ច ភិក្ខុ វីរិយសមាធិប្បធានស-
ង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ ឥធ ភិក្ខុ យស្មឹ
សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អប-
ចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា
បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ
ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ
សមយេ វីរិយសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិ-
ចាទំ ភាវេតិ ។

[២៦៩] តត្ថ កតមំ វីរិយំ ។ យោ ចេត-
សិកោ វីរិយារម្ភោ ។ បេ ។ សម្មាវាយាមោ វីរិយ-
សម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ ឥទំ វុច្ចតិ វីរិយំ
តត្ថ កតមោ សមាធិ ។ យា ចិត្តស្ស ឋិតិ ។ បេ ។
សម្មាសមាធិ សមាធិសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយា-
បន្នំ អយំ វុច្ចតិ សមាធិ ។ តត្ថ កតមោ បធានស-
ង្ខារោ ។ យោ ចេតសិកោ វីរិយារម្ភោ ។ បេ ។

គឺការពាល់ត្រូវ ។ បេ ។ ការផ្គង់ទុក សេចក្តីមិនរាយមាយ របស់បុគ្គលមានសភាពដូច្នោះ ។ ពាក្យថា ចម្រើននូវឥទ្ធិបាទ គឺ ភិក្ខុគប់រក អប់រំ ធ្វើឲ្យច្រើន នូវធម៌ទាំងនោះ ព្រោះហេតុនោះ ទើបពោលថា ចម្រើន នូវឥទ្ធិបាទ ។

[២៦៨] ចុះភិក្ខុ ចម្រើននូវឥទ្ធិបាទ ប្រកបដោយវីរិយសមាធិនិង បធានសង្ខារ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្ដៈ) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខា-បដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ភិក្ខុ ឈ្មោះថា ចម្រើននូវឥទ្ធិបាទ ប្រកបដោយវីរិយសមាធិនិងបធានសង្ខារ ។

[២៦៩] បណ្តាធម៌ទាំងនោះ វីរិយៈ តើដូចម្តេច ។ ការប្រា-រព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សម្មាវាយាមៈ វីរិយសម្ពោ-ជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា វីរិយៈ ។ បណ្តាធម៌ទាំងនោះ សមាធិ តើដូចម្តេច ។ ការតាំងនៅ នៃចិត្ត ។ បេ ។ សម្មាសមាធិ សមាធិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូល ក្នុងមគ្គ ណា នេះហៅថា សមាធិ ។ បណ្តាធម៌ទាំងនោះ បធាន-សង្ខារ តើដូចម្តេច ។ ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។

សម្មាវាយាមោ វីរិយសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ បធានសង្ខារោ ។ ឥតិ ឥមិនា ច វីរិយេន ឥមិនា ច សមាធិនា ឥមិនា ច បធានសង្ខារេន ឧបេតោ ហោតិ ។ បេ ។ សមន្នាគតោ តេន វុច្ចតិ វីរិយសមាធិប្បធានសង្ខារសមន្នាគតោតិ ។

[២៧០] ឥទ្ធីតិ យា តេសំ ធម្មានំ ឥទ្ធិ សមិទ្ធិ ឥជ្ឈនា សមិជ្ឈនា លាភោ បដិលាភោ បត្តិ សម្បត្តិ ផុសនា សច្ឆិកិរិយា ឧបសម្បទា ។ ឥទ្ធិបាទោតិ តថាភូតស្ស ផស្សោ ។ បេ ។ បគ្គាហោ អវិក្ខេបោ ។ ឥទ្ធិបាទំ ភាវេតីតិ តេ ធម្មេ អាសេវតិ ភាវេតិ ពហុលីករោតិ តេន វុច្ចតិ ឥទ្ធិបាទំ ភាវេតីតិ ។

[២៧១] កថញ្ច ភិក្ខុ ចិត្តសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ

សម្មាវាយាមៈ វីរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា បធានសង្ខារ ភិក្ខុជាអ្នកព្រមព្រៀង ។ បេ ។ ប្រកបព្រម ដោយវីរិយៈនេះផង ដោយសមាធិនេះផង ដោយបធានសង្ខារនេះផង ព្រោះហេតុនោះ ទើបពោលថា ប្រកបដោយវីរិយសមាធិនិងបធានសង្ខារ ដោយប្រការដូច្នេះ ។

[២៧០] ពាក្យថា ឥទ្ធិ គឺ បានដល់ការសម្រេច ការសម្រេចព្រម អាការសម្រេច អាការសម្រេចព្រម ការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ កិរិយាធ្វើឲ្យជាក់ច្បាស់ ការបានគ្រប់គ្រាន់ នូវធម៌ទាំងឡាយនោះ ។ ពាក្យថា ឥទ្ធិបាទ គឺ ការពាល់ត្រូវ ។ បេ ។ ការផ្គងទុក សេចក្តីមិនរាយមាយ របស់បុគ្គលមានសភាពដូច្នោះ ។ ពាក្យថា ចម្រើននូវឥទ្ធិបាទ គឺ ភិក្ខុគប់រក អប់រំ ធ្វើឲ្យច្រើន នូវធម៌ទាំងឡាយនោះ ព្រោះហេតុនោះ ទើបពោលថា ចម្រើននូវឥទ្ធិបាទ ។

[២៧១] ចុះភិក្ខុ ចម្រើននូវឥទ្ធិបាទ ប្រកបដោយចិត្តសមាធិនិងបធានសង្ខារ តើដូចម្តេច ។ ក្នុងសម័យ ណា ភិក្ខុក្នុងសាសនានេះ ចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្តៈ) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន

ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ ចិត្តសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិ-បាទំ ភាវេតិ ។

[២៧២] តត្ថ កតមំ ចិត្តំ ។ យំ ចិត្តំ មនោ មានសំ ។ បេ ។ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ ចិត្តំ ។ តត្ថ កតមោ សមាធិ ។ យា ចិត្តស្ស ឋិតិ ។ បេ ។ សម្មាសមាធិ សមាធិសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ សមាធិ ។ តត្ថ កតមោ បធានសង្ខារោ ។ យោ ចេតសិកោ វីរិ-យារម្ភោ ។ បេ ។ សម្មាវាយាមោ វីរិយសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ បធានសង្ខារោ ។ ឥតិ ឥមិនា ច ចិត្តេន ឥមិនា ច សមាធិនា ឥមិនា ច បធានសង្ខារេន ឧបេតោ ហោតិ ។ បេ ។ សមន្នាគតោ តេន វុច្ចតិ ចិត្តសមាធិប្បធានសង្ខារ-សមន្នាគតោតិ ។

ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ភិក្ខុ ឈ្មោះថាចម្រើននូវឥទ្ធិបាទ ប្រកបដោយចិត្តសមាធិនិងបធានសង្ខារ ។

[២៧២] បណ្តាធម៌ទាំងនោះ ចិត្ត តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។ បេ ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ ណា នេះហៅថា ចិត្ត ។ បណ្តាធម៌ទាំងនោះ សមាធិ តើដូចម្តេច ។ ការតាំងនៅ នៃចិត្ត ។ បេ ។ សម្មាសមាធិ សមាធិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សមាធិ ។ បណ្តាធម៌ទាំងនោះ បធានសង្ខារ តើដូចម្តេច ។ ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សម្មាវាយាមៈ វីរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា បធានសង្ខារ ។ ភិក្ខុជាអ្នកព្រមព្រៀង ។ បេ ។ ប្រកបព្រម ដោយចិត្តនេះផង ដោយសមាធិនេះផង ដោយបធានសង្ខារនេះផង ព្រោះហេតុនោះ ទើបពោលថា ប្រកបដោយចិត្តសមាធិនិងបធានសង្ខារ ដោយប្រការដូច្នេះ ។

[២៧៣] ឥទ្ធីតិ យា តេសំ ធម្មានំ ឥទ្ធិ សមិទ្ធិ ឥជ្ឈនា សមិជ្ឈនា លាភោ បដិលាភោ បត្តិ សម្បត្តិ ផុសនា សច្ឆិកិរិយា ឧបសម្បទា ។ ឥទ្ធិបាទោតិ តថាភូតស្ស ផស្សោ ។ បេ ។ បគ្គាហោ អវិក្ខេបោ ។ ឥទ្ធិបាទំ ភាវេតីតិ តេ ធម្មេ អាសេវតិ ភាវេតិ ពហុលីករោតិ តេន វុច្ចតិ ឥទ្ធិបាទំ ភាវេតីតិ ។

[២៧៤] កថញ្ច ភិក្ខុ វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។

[២៧៣] ពាក្យថា ឥទ្ធិ បានដល់ការសម្រេច ការសម្រេចព្រម អាការសម្រេច អាការសម្រេចព្រម ការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ កិរិយាធ្វើឲ្យជាក់ច្បាស់ ការបានគ្រប់គ្រាន់ នូវធម៌ទាំងឡាយនោះ ។ ពាក្យថា ឥទ្ធិបាទ គឺ ការពាល់ត្រូវ ។ បេ ។ ការផ្គងទុក សេចក្តីមិនរាយមាយ របស់បុគ្គលមានសភាពដូច្នោះ ។ ពាក្យថា ចម្រើននូវឥទ្ធិបាទ គឺ ភិក្ខុគប់រកអប់រំ ធ្វើឲ្យច្រើន នូវធម៌ទាំងឡាយនោះ ព្រោះហេតុនោះ ទើបពោលថា ចម្រើននូវឥទ្ធិបាទ ។

[២៧៤] ចុះភិក្ខុ ចម្រើននូវឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្ដៈ) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ភិក្ខុ ឈ្មោះថា ចម្រើននូវឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ។

[២៧៤] តត្ថ កតមា វីមំសា ។ យា បញ្ញា បជានា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ វីមំសា ។ តត្ថ កតមោ សមាធិ ។ យា ចិត្តស្ស ឋិតិ ។ បេ ។ សម្មាសមាធិ សមាធិសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ សមាធិ ។ តត្ថ កតមោ បធានសង្ខារោ ។ យោ ចេតសិកោ វីរិយារម្ភោ ។ បេ ។ សម្មាវាយាមោ វីរិយសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ បធានសង្ខារោ ។ ឥតិ ឥមាយ ច វីមំសាយ ឥមិនា ច សមាធិនា ឥមិនា ច បធានសង្ខារេន ឧបេតោ ហោតិ សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ តេន វុច្ចតិ វីមំសាសមាធិប្បធានសង្ខារសមន្នាគតោតិ ។

[២៧៥] បណ្ដាធម៌ទាំងនោះ វីមំសា តើដូចម្ដេច ។ បញ្ញា ការដឹងច្បាស់ ។ បេ ។ អមោហៈ ធម្មវិចយៈ សម្មាទិដ្ឋិ ធម្មវិចយ-សម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា វីមំសា ។ បណ្ដាធម៌ទាំងនោះ សមាធិ តើដូចម្ដេច ។ ការតាំងនៅនៃចិត្ត ។ បេ ។ សម្មាសមាធិ សមាធិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សមាធិ ។ បណ្ដាធម៌ទាំងនោះ បធាន-សង្ខារ តើដូចម្ដេច ។ ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សម្មាវាយាមៈ វីរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា បធានសង្ខារ ។ ភិក្ខុ ជាអ្នកព្រមព្រៀង មូលមិត្រ ចូលទៅជិត អែបនែប កៀកកើយ ប្រជិតប្រជី ប្រកប ព្រម ដោយវីមំសានេះផង ដោយសមាធិនេះផង ដោយបធានសង្ខារនេះផង ព្រោះហេតុនោះ ទើបពោលថា ប្រកបដោយវីមំសាសមាធិ និងបធានសង្ខារ ដោយប្រការដូច្នេះ ។

[២៧៦] ឥទ្ធីតិ យា តេសំ ធម្មានំ ឥទ្ធិ សមិទ្ធិ ឥជ្ឈនា សមិជ្ឈនា លាភោ បដិលាភោ បត្តិ សម្បត្តិ ផុសនា សច្ឆិកិរិយា ឧបសម្បទា ។ ឥទ្ធិបាទោតិ តថាភូតស្ស ផស្សោ ។ បេ ។ បគ្គាហោ អវិក្ខេបោ ។ ឥទ្ធិបាទំ ភាវេតីតិ តេ ធម្មេ អាសេវតិ ភាវេតិ ពហុលីករោតិ តេន វុច្ចតិ ឥទ្ធិបាទំ ភាវេតីតិ ។

[២៧៧] ចត្តារោ ឥទ្ធិបាទា ឆន្ទិទ្ធិបាទោ វីរិយិទ្ធិបាទោ ចិត្តិទ្ធិបាទោ វីមំសិទ្ធិបាទោ ។

[២៧៨] តត្ថ កតមោ ឆន្ទិទ្ធិបាទោ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ យោ តស្មឹ សមយេ ឆន្ទោ ឆន្ទិកតា កត្តុកម្យតា កុសលោ ធម្មច្ឆន្ទោ អយំ វុច្ចតិ ឆន្ទិទ្ធិបាទោ អវសេសា ធម្មា ឆន្ទិទ្ធិបាទសម្បយុត្តា ។

[២៧៦] ពាក្យថា ឥទ្ធិ បានដល់ការសម្រេច ការសម្រេចព្រម អាការសម្រេច អាការសម្រេចព្រម ការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ កិរិយាធ្វើឲ្យជាក់ច្បាស់ ការបានគ្រប់គ្រាន់ នូវធម៌ទាំងឡាយនោះ ។ ពាក្យថា ឥទ្ធិបាទ គឺ ការពាល់ត្រូវ ។ បេ ។ ការផ្គងទុក សេចក្ដីមិនរាយមាយ របស់ បុគ្គលមានសភាពដូច្នោះ ។ ពាក្យថា ចម្រើននូវឥទ្ធិបាទ គឺ ភិក្ខុគប់រក អប់រំ ធ្វើឲ្យច្រើន នូវធម៌ទាំងឡាយនោះ ព្រោះហេតុនោះ ទើបពោលថា ចម្រើននូវឥទ្ធិបាទ ។

[២៧៧] ឥទ្ធិបាទ ៤ យ៉ាង គឺ ឆន្ទិទ្ធិបាទ ១ វីរិយិទ្ធិបាទ ១ ចិត្តិទ្ធិបាទ ១ វីមំសិទ្ធិបាទ ១ ។

[២៧៨] បណ្ដាឥទ្ធិបាទទាំងនោះ ឆន្ទិទ្ធិបាទ តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្ដៈ) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ សេចក្ដីប្រាថ្នា ភាពនៃបុគ្គលមានសេចក្ដីប្រាថ្នា ភាពនៃបុគ្គលប្រាថ្នាដើម្បីធ្វើ ការប្រាថ្នាធម៌ជាកុសល ណា នេះហៅថា ឆន្ទិទ្ធិបាទ ពួកធម៌ដ៏សេស ក៏ឈ្មោះថា ប្រកបដោយឆន្ទិទ្ធិបាទ ។

[២៧៩] តត្ថ កតមោ វីរិយិទ្ធិបាទោ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វីរិយាធិបតេយ្យំ ... ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ យោ តស្មឹ សមយេ ចេតសិកោ វីរិយារម្ភោ ។ បេ ។ សម្មាវាយាមោ វីរិយសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ វីរិយិទ្ធិបាទោ អវសេសា ធម្មា វីរិយិទ្ធិបាទសម្បយុត្តា ។

[២៨០] តត្ថ កតមោ ចិត្តិទ្ធិបាទោ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វីរិយាធិបតេយ្យំ ... ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ យំ តស្មឹ សមយេ ចិត្តំ មនោ មានសំ ។ បេ ។ តជ្ជា មនោវិញ្ញាណធាតុ អយំ វុច្ចតិ ចិត្តិទ្ធិបាទោ អវសេសា ធម្មា ចិត្តិទ្ធិបាទសម្បយុត្តា ។

[២៧៩] បណ្ដាឥទ្ធិបាទទាំងនោះ វីរិយិទ្ធិបាទ តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្តៈ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សម្មាវាយាមៈ វីរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា វីរិយិទ្ធិបាទ ពួកធម៌ដ៏សេស ក៏ឈ្មោះថា ប្រកបដោយវីរិយិទ្ធិបាទ ។

[២៨០] បណ្ដាឥទ្ធិបាទទាំងនោះ ចិត្តិទ្ធិបាទ តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្តៈ) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ។ បេ ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណធាតុនោះ ណា នេះហៅថា ចិត្តិទ្ធិបាទ ពួកធម៌ដ៏សេស ក៏ឈ្មោះថា ប្រកបដោយចិត្តិទ្ធិបាទ ។

[២៨១] តត្ថ កតមោ វីមំសិទ្ធិបាទោ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ យា តស្មឹ សមយេ បញ្ញា បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ វីមំសិទ្ធិបាទោ អវសេសា ធម្មា វីមំសិទ្ធិបាទសម្បយុត្តា ។

អភិធម្មភាជនីយំ ។

[២៨២] ចត្តារោ ឥទ្ធិបាទា ឥធ ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ វិរិយសមាធិ ... ចិត្តសមាធិ ... វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ ចតុន្នំ ឥទ្ធិបាទានំ កតិ កុសលា កតិ អកុសលា កតិ អព្យាកតា ។ បេ ។ កតិ សរណា កតិ អរណា ។

[២៨១] បណ្ដាឥទ្ធិបាទទាំងនោះ វីមំសិទ្ធិបាទ តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្ដៈ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ បញ្ញា ការដឹងច្បាស់ ។ បេ ។ អមោហៈ ធម្មវិចយៈ សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា វីមំសិទ្ធិបាទ ពួកធម៌ដ៏សេស ក៏ឈ្មោះថា ប្រកបដោយវីមំសិទ្ធិបាទ ។

ចប់ អភិធម្មភាជនីយ ។

[២៨២] ឥទ្ធិបាទ ៤ គឺ ភិក្ខុក្នុងសាសនានេះ ចម្រើននូវឥទ្ធិបាទប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ១ វីរិយសមាធិ. . .១ ចិត្តសមាធិ...១ ចម្រើននូវឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ១ ។ បណ្ដាឥទ្ធិបាទទាំង ៤ ឥទ្ធិបាទ ជាកុសលប៉ុន្មាន ជាអកុសលប៉ុន្មាន ជាអព្យាក្រឹតប៉ុន្មាន ។ បេ ។ ជាសរណៈប៉ុន្មាន ជាអរណៈប៉ុន្មាន ។

[២៨៣] កុសលាយេវ សិយា សុខាយ វេទនាយ សម្បយុត្តា សិយា អទុក្ខមសុខាយ វេទនាយ សម្បយុត្តា វិបាកធម្មធម្មា អនុបាទិន្នានុបាទានិយា អសង្កិលិដ្ឋាសង្កិលេសិកា សិយា សវិតក្កសវិចារា សិយា អវិតក្កវិចារមត្តា សិយា អវិតក្កាវិចារា សិយា បីតិសហគតា សិយា សុខសហគតា សិយា ឧបេក្ខាសហគតា នេវ ទស្សនេន ន ភាវនាយ បហាតព្វា នេវ ទស្សនេន ន ភាវនាយ បហាតព្វហេតុកា អបចយគាមិនោ សេក្ខា អប្បមាណា អប្បមាណារម្មណា បណីតា សម្មត្តនិយតា ន មគ្គារម្មណា មគ្គហេតុកា ន មគ្គាធិបតិនោ សិយា ឧប្បន្នា សិយា អនុប្បន្នា ន វត្តព្វា ឧប្បាទិនោតិ សិយា អតីតា សិយា អនាគតា សិយា បច្ចុប្បន្នា ន វត្តព្វា អតីតារម្មណាតិបិ អនាគតារម្មណាតិបិ បច្ចុប្បន្នារម្មណាតិបិ សិយា អជ្ឈត្តា សិយា ពហិទ្ធា សិយា អជ្ឈត្តពហិទ្ធា ពហិទ្ធារម្មណា អនិទស្សនាប្បដិឃា ។

[២៨៣] ឥទ្ធិបាទ ៤ ជាកុសលតែមួយយ៉ាង ប្រកបដោយសុខ-វេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនា តែមានវិបាកធម៌ជាប្រក្រតី ដែលកិលេសមានតណ្ហាជាដើមមិនកាន់យក ទាំងមិនជាប្រយោជន៍ដល់ឧបាទាន មិនសៅហ្មង ទាំងមិនគួរដល់នូវសេចក្ដីសៅហ្មងក៏មាន ប្រកបដោយវិតក្កៈនិងវិចារៈក៏មាន មិនមានវិតក្កៈ មានត្រឹមតែវិចារៈក៏មាន មិនមានវិតក្កៈ មិនមានវិចារៈក៏មាន ប្រទ្បំដោយបីតិក៏មាន ប្រទ្បំដោយសុខក៏មាន ប្រទ្បំដោយឧបេក្ខា ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាធម៌មានហេតុដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្ដៈ) ជារបស់សេក្ខៈ ជាធម៌មានប្រមាណមិនមាន មានអារម្មណ៍ប្រមាណមិនមាន ជាធម៌ដ៏ឧត្តម មានសភាពត្រូវនិងទៀង មិនមែនមានមគ្គជាអារម្មណ៍ មានមគ្គជាហេតុ មិនមែនមានមគ្គជាអធិបតី ក៏មាន កើតឡើងហើយ ក៏មាន មិនទាន់កើតឡើង តែមិនគួរពោលថា បម្រុងនឹងកើតឡើង ក៏មាន ជាអតីត ក៏មាន ជាអនាគត ក៏មាន ជាបច្ចុប្បន្ន តែមិនគួរពោលថា មានអារម្មណ៍ជាអតីតផង ថា មានអារម្មណ៍ជាអនាគតផង ថា មានអារម្មណ៍ជាបច្ចុប្បន្នផង ក៏មាន ជាខាងក្នុង ក៏មាន ជាខាងក្រៅ ក៏មាន ខាងក្នុងទាំងខាងក្រៅ មានអារម្មណ៍ជាខាងក្រៅ មិនប្រកបដោយការឃើញ ទាំងមិនប្រកបដោយការប៉ះពាល់ ក៏មាន ។

[២៨៤] វីមំសិទ្ធិបាទោ ហេតុ តយោ ឥទ្ធិបាទា ន ហេតូ ។ សហេតុកា ហេតុសម្បយុត្តា ។ វីមំសិទ្ធិបាទោ ហេតុ ចេវ សហេតុកោ ច តយោ ឥទ្ធិបាទា ន វត្តព្វា ហេតូ ចេវ សហេតុកា ចាតិ សហេតុកា ចេវ ន ច ហេតូ ។ វីមំសិទ្ធិបាទោ ហេតុ ចេវ ហេតុសម្បយុត្តោ ច តយោ ឥទ្ធិបាទា ន វត្តព្វា ហេតូ ចេវ ហេតុសម្បយុត្តា ចាតិ ហេតុសម្បយុត្តា ចេវ ន ច ហេតូ ។ តយោ ឥទ្ធិបាទា ន ហេតូ សហេតុកា វីមំសិទ្ធិបាទោ ន វត្តព្វោ ន ហេតុ សហេតុកោតិបិ ន ហេតុ អហេតុកោតិបិ ។

[២៨៥] សប្បច្ចយា សង្ខតា អនិទស្សនា អប្បដិឃា អរូបា លោកុត្តរា កេនចិ វិញ្ញេយ្យា កេនចិ ន វិញ្ញេយ្យា ។ នោ អាសវា អនាសវា អាសវវិប្បយុត្តា ន វត្តព្វា អាសវា ចេវ សាសវា ចាតិបិ សាសវា ចេវ នោ ច អាសវាតិបិ ន វត្តព្វា អាសវា ចេវ អាសវសម្បយុត្តា ចាតិបិ

[២៨៤] វីមំសិទ្ធិបាទ ជាហេតុ ឥទ្ធិបាទ ៣ មិនមែនជាហេតុ ។ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ ប្រកបដោយហេតុ ។ វីមំសិទ្ធិបាទ ជាហេតុផង ប្រព្រឹត្តទៅជាមួយនឹងហេតុផង ឥទ្ធិបាទ ៣ មិនគួរពោលថា ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុទេ គឺគ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនជាហេតុ ។ វីមំសិទ្ធិបាទ ជាហេតុផង ប្រកបដោយហេតុផង ឥទ្ធិបាទ ៣ មិនគួរពោលថា ជាហេតុ ទាំងប្រកបដោយហេតុឡើយ គ្រាន់តែប្រកបដោយហេតុ តែមិនមែនជាហេតុ ។ ឥទ្ធិបាទ ៣ មិនមែនជាហេតុ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ វីមំសិទ្ធិបាទ មិនគួរពោលថា មិនមែនជាហេតុ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុផង ថា មិនមែនជាហេតុ ទាំងឥតហេតុផង ។

[២៨៥] ឥទ្ធិបាទ ៤ ប្រកបដោយបច្ច័យ ត្រូវបច្ច័យតាក់តែង មិនប្រកបដោយការឃើញ មិនមានការប៉ះពាល់ ជាអរូប ជាលោកុត្តរៈ ដែលគប្បីដឹងដោយវិញ្ញាណណាមួយ (មានចក្ខុវិញ្ញាណជាដើម) មិនគប្បីដឹង ដោយវិញ្ញាណណាមួយ ។ ឥទ្ធិបាទ ៤ មិនមែនអាសវៈ ទាំងមិនមានអាសវៈ ប្រាសចាកអាសវៈ មិនគួរពោលថា ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ថា ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនជាអាសវៈផងទេ មិនគួរពោលថា ជាអាសវៈទាំងប្រកបដោយអាសវៈផង

អាសវសម្បយុត្តា ចេវ នោ ច អាសវាតិបិ អាសវវិប្បយុត្តអនាសវា ។ នោ សញ្ញោជនា ។ បេ ។ នោ គន្ថា ។ បេ ។ នោ ឱឃា ។ បេ ។ នោ យោគា ។ បេ ។ នោ នីវរណា ។ បេ ។ នោ បរាមាសា ។ បេ ។

[២៨៦] សារម្មណា ។ តយោ ឥទ្ធិបាទា នោ ចិត្តា ចិត្តិទ្ធិបាទោ ចិត្តំ ។ តយោ ឥទ្ធិបាទា ចេតសិកា ចិត្តិទ្ធិបាទោ អចេតសិកោ ។ តយោ ឥទ្ធិបាទា ចិត្តសម្បយុត្តា ចិត្តិទ្ធិបាទោ ន វត្តព្វោ ចិត្តេន សម្បយុត្តោតិបិ ចិត្តេន វិប្បយុត្តោតិបិ ។ តយោ ឥទ្ធិបាទា ចិត្តសំសដ្ឋា ចិត្តិទ្ធិបាទោ ន វត្តព្វោ ចិត្តេន សំសដ្ឋោតិបិ ចិត្តេន វិសំសដ្ឋោតិបិ ។ តយោ ឥទ្ធិបាទា ចិត្តសមុដ្ឋានា ចិត្តិទ្ធិបាទោ នោ ចិត្តសមុដ្ឋានោ ។ តយោ ឥទ្ធិបាទា ចិត្តសហភុនោ ចិត្តិទ្ធិបាទោ នោ ចិត្តសហភូ ។ តយោ ឥទ្ធិបាទា ចិត្តានុបរិវត្តិនោ ចិត្តិទ្ធិបាទោ នោ ចិត្តានុបរិវត្តិ ។ តយោ ឥទ្ធិបាទា ចិត្តសំសដ្ឋសមុដ្ឋានា ចិត្តិទ្ធិបាទោ នោ ចិត្តសំសដ្ឋសមុដ្ឋានោ ។

ថាប្រកបដោយអាសវៈ តែមិនមែនជាអាសវៈផងឡើយ គឺជាធម៌ប្រាស ចាកអាសវៈ ទាំងមិនមានអាសវៈ ។ ឥទ្ធិបាទ ៤ មិនមែនសញ្ញោជនៈ ។ បេ ។ មិនមែនគន្ថៈ ។ បេ ។ មិនមែនឱឃៈ ។ បេ ។ មិនមែន យោគៈ ។ បេ ។ មិនមែននីវរណៈ ។ បេ ។ មិនមែនបរាមាសៈ ។ បេ ។

[២៨៦] ឥទ្ធិបាទ ៤ ប្រកបដោយអារម្មណ៍ ។ ឥទ្ធិបាទ ៣ មិនមែនចិត្ត ចិត្តិទ្ធិបាទ ជាចិត្ត ។ ឥទ្ធិបាទ ៣ ជាចេតសិក ចិត្តិទ្ធិបាទ មិនមែនចេតសិក ។ ឥទ្ធិបាទ ៣ ប្រកបដោយចិត្ត ចិត្តិទ្ធិបាទ មិនគួរពោលថា ប្រកបដោយចិត្តផង ថា ប្រាសចាកចិត្តផង ឡើយ ។ ឥទ្ធិបាទ ៣ ប្រឡំដោយចិត្ត ចិត្តិទ្ធិបាទ មិនគួរពោលថា ប្រឡំដោយចិត្តផង ថា មិនប្រឡំដោយចិត្តផងទេ ។ ឥទ្ធិបាទ ៣ តាំង ឡើង អំពីចិត្ត ចិត្តិទ្ធិបាទ មិនមែនតាំងឡើង អំពីចិត្ត ។ ឥទ្ធិបាទ ៣ កើតជាមួយនឹងចិត្ត ចិត្តិទ្ធិបាទ មិនមែនកើតជាមួយនឹងចិត្ត ។ ឥទ្ធិបាទ ៣ ប្រព្រឹត្តទៅតាមចិត្ត ចិត្តិទ្ធិបាទ មិនមែនប្រព្រឹត្តទៅតាមចិត្ត ។ ឥទ្ធិបាទ ៣ ប្រឡំទាំងតាំងឡើងអំពីចិត្ត ចិត្តិទ្ធិបាទ មិនប្រឡំមិនតាំងឡើងអំពីចិត្ត ។

តយោ ឥទ្ធិបាទា ចិត្តសំសដ្ឋសមុដ្ឋានសហភុនោ ចិត្តិទ្ធិបាទោ នោ ចិត្តសំសដ្ឋសមុដ្ឋានសហភូ ។ តយោ ឥទ្ធិបាទា ចិត្តសំសដ្ឋសមុដ្ឋានានុបរិវត្តិនោ ចិត្តិទ្ធិបាទោ នោ ចិត្តសំសដ្ឋសមុដ្ឋានានុបរិវត្តិ ។ តយោ ឥទ្ធិបាទា ពាហិរា ចិត្តិទ្ធិបាទោ អជ្ឈត្តិកោ ។ នុបាទា អនុបាទិន្នា ។

[២៨៧] នុបាទានា ។ បេ ។ នោ កិលេសា ។ បេ ។ ន ទស្សនេន បហាតព្វា ន ភាវនាយ បហាតព្វា ន ទស្សនេន បហាតព្វហេតុកា ន ភាវនាយ បហាតព្វហេតុកា សិយា សវិតក្កា សិយា អវិតក្កា សិយា សវិចារា សិយា អវិចារា សិយា សប្បីតិកា សិយា អប្បីតិកា សិយា បីតិសហគតា សិយា ន បីតិសហគតា សិយា សុខសហគតា សិយា ន សុខសហគតា សិយា ឧបេក្ខាសហគតា សិយា ន ឧបេក្ខាសហគតា ន កាមាវចរា ន រូបាវចរា ន អរូបាវចរា អបរិយាបន្នា និយ្យានិកា និយតា អនុត្តរា អរណាតិ ។

បញ្ហាបុច្ឆកំ ។

ឥទ្ធិបាទវិភង្គោ សមត្តោ ។

---

ឥទ្ធិបាទ ៣ ប្រទ្បំ ទាំងតាំងឡើង ទាំងកើតជាមួយនឹងចិត្ត ចិត្តិទ្ធិបាទ មិនប្រទ្បំ មិនតាំងឡើង មិនកើតជាមួយនឹងចិត្ត ។ ឥទ្ធិបាទ ៣ ប្រទ្បំ ទាំងតាំងឡើង ទាំងប្រព្រឹត្តទៅតាមចិត្ត ចិត្តិទ្ធិបាទ មិនប្រទ្បំ មិនតាំងឡើង មិនប្រព្រឹត្តទៅតាមចិត្ត ។ ឥទ្ធិបាទ ៣ ជាខាងក្រៅ ចិត្តិទ្ធិបាទ ជាខាងក្នុង ។ ឥទ្ធិបាទ ៤ មិនមែនឧបាទា ដែលកិលេស មានតណ្ហានិងទិដ្ឋិជាដើមមិនកាន់យកហើយ ។

[២៨៧] ឥទ្ធិបាទ ៤ មិនមែនឧបាទាន ។ បេ ។ មិនមែនកិលេស ។ បេ ។ មិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា មានហេតុមិនគួរលះដោយទស្សនៈ មានហេតុមិនគួរលះដោយភាវនា ប្រកបដោយវិតក្កៈក៏មាន មិនមានវិតក្កៈក៏មាន ប្រកបដោយវិចារៈក៏មាន មិនមានវិចារៈក៏មាន ប្រកបដោយបីតិក៏មាន មិនមានបីតិក៏មាន ប្រទ្បំដោយបីតិក៏មាន មិនប្រទ្បំដោយបីតិក៏មាន ប្រទ្បំដោយសុខក៏មាន មិនប្រទ្បំដោយសុខក៏មាន ប្រទ្បំដោយឧបេក្ខាក៏មាន មិនប្រទ្បំដោយឧបេក្ខា តែមិនមែនជាកាមាវចរ មិនមែនជារូបាវចរ មិនមែនជាអរូបាវចរ ជាអបរិយាបន្នៈ ជានិយ្យានិកៈ ជានិយតៈ ជាអនុត្តរៈ ជាអរណៈ ក៏មាន ។

ចប់ បញ្ហាបុច្ឆកៈ ។

ចប់ ឥទ្ធិបាទវិភង្គ ។

# ពោជ្ឈង្គវិភង្គោ

[២៨៨] សត្ត ពោជ្ឈង្គា សតិសម្ពោជ្ឈង្គោ ធម្មវិចយសម្ពោជ្ឈង្គោ វីរិយសម្ពោជ្ឈង្គោ បីតិសម្ពោជ្ឈង្គោ បស្សទ្ធិសម្ពោជ្ឈង្គោ សមាធិសម្ពោជ្ឈង្គោ ឧបេក្ខាសម្ពោជ្ឈង្គោ ។

[២៨៩] តត្ថ កតមោ សតិសម្ពោជ្ឈង្គោ ។ ឥធ ភិក្ខុ សតិមា ហោតិ បរមេន សតិនេបក្កេន សមន្នាគតោ ចិរកតម្បិ ចិរភាសិតម្បិ សរិតា អនុស្សរិតា អយំ វុច្ចតិ សតិសម្ពោជ្ឈង្គោ ។ សោ តថាសតោ វិហរន្តោ តំ ធម្មំ បញ្ញាយ វិចិនតិ បវិចិនតិ[១] បរិវីមំសំ អាបជ្ជតិ អយំ វុច្ចតិ ធម្មវិចយសម្ពោជ្ឈង្គោ ។ តស្ស តំ ធម្មំ បញ្ញាយ វិចិនតោ បវិចិនតោ[២] បរិវីមំសំ អាបជ្ជតោ អារទ្ធំ ហោតិ វីរិយំ អសល្លីនំ អយំ វុច្ចតិ វីរិយសម្ពោជ្ឈង្គោ ។ អារទ្ធវីរិយស្ស ឧប្បជ្ជតិ បីតិ និរាមិសា អយំ វុច្ចតិ បីតិសម្ពោជ្ឈង្គោ ។ បីតិមនស្ស កាយោបិ បស្សម្ភតិ ចិត្តំបិ បស្សម្ភតិ អយំ វុច្ចតិ បស្សទ្ធិសម្ពោជ្ឈង្គោ ។

---

១ ម. បវិចរតិ ។ ២ ម. បវិចរតោ ។

# ពោជ្ឈង្គវិភង្គ

[២៨៨] ពោជ្ឈង្គ ៧ គឺ សតិសម្ពោជ្ឈង្គ ១ ធម្មវិចយសម្ពោជ្ឈង្គ ១ វីរិយសម្ពោជ្ឈង្គ ១ បីតិសម្ពោជ្ឈង្គ ១ បស្សទ្ធិសម្ពោជ្ឈង្គ ១ សមាធិសម្ពោជ្ឈង្គ ១ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។

[២៨៩] បណ្តាសម្ពោជ្ឈង្គទាំងនោះ សតិសម្ពោជ្ឈង្គ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានស្មារតី ប្រកបដោយស្មារតី និងបញ្ញាខ្ជាប់ខ្ជួនដ៏ប្រសើរ ជាអ្នករឭក នឹកឃើញ នូវអំពើដែលខ្លួន ឬអ្នកដទៃធ្វើហើយ អស់កាលយូរក្តី នូវពាក្យដែលខ្លួន ឬអ្នកដទៃនិយាយហើយ អស់កាលយូរក្តី នេះហៅថា សតិសម្ពោជ្ឈង្គ ។ ភិក្ខុនោះ ជាអ្នកមានស្មារតី មានសភាពដូច្នោះ រមែងពិនិត្យ សង្កេតនូវធម៌នោះ ដោយបញ្ញា រមែងដល់នូវការពិចារណាជុំវិញ នេះហៅថា ធម្មវិចយសម្ពោជ្ឈង្គ ។ កាលភិក្ខុនោះ ពិនិត្យ សង្កេត នូវធម៌នោះដោយបញ្ញា ដល់នូវការពិចារណាជុំវិញ វីរិយៈជាគុណដែលខ្ជួនប្រារព្ធហើយ មិនរួញរា ក៏មាន នេះហៅថា វីរិយសម្ពោជ្ឈង្គ ។ កាលភិក្ខុមានព្យាយាមប្រារព្ធហើយ បីតិប្រាសចាកអាមិសៈ ក៏កើតឡើង នេះហៅថា បីតិសម្ពោជ្ឈង្គ ។ កាលភិក្ខុ មានចិត្តប្រកបដោយបីតិ កាយក៏ស្ងប់រម្ងាប់ ចិត្តក៏ស្ងប់រម្ងាប់ នេះហៅថា បស្សទ្ធិសម្ពោជ្ឈង្គ ។

បស្សទ្ធកាយស្ស សុខិនោ ចិត្តំ សមាធិយតិ អយំ វុច្ចតិ សមាធិសម្ពោជ្ឈង្គោ ។ សោ តថាសមាហិតំ ចិត្តំ សាធុកំ អជ្ឈុបេក្ខិតា ហោតិ អយំ វុច្ចតិ ឧបេក្ខាសម្ពោជ្ឈង្គោ ។

[២៩០] សត្ត ពោជ្ឈង្គា សតិសម្ពោជ្ឈង្គោ ធម្មវិចយសម្ពោជ្ឈង្គោ វីរិយសម្ពោជ្ឈង្គោ បីតិសម្ពោជ្ឈង្គោ បស្សទ្ធិសម្ពោជ្ឈង្គោ សមាធិសម្ពោជ្ឈង្គោ ឧបេក្ខាសម្ពោជ្ឈង្គោ ។

[២៩១] តត្ថ កាតមោ សតិសម្ពោជ្ឈង្គោ ។ អត្ថិ អជ្ឈត្តំ ធម្មេសុ សតិ អត្ថិ ពហិទ្ធា ធម្មេសុ សតិ ។ យទបិ[១] អជ្ឈត្តំ ធម្មេសុ សតិ តទបិ[២] សតិសម្ពោជ្ឈង្គោ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។ យទបិ ពហិទ្ធា ធម្មេសុ សតិ តទបិ សតិសម្ពោជ្ឈង្គោ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។

១ ឱ. សព្វត្ថ ឋានេសុ យទាបីតិ ទិស្សន្តិ ។ ២ ឱ. សព្វត្ថ ឋានេសុ តទាបីតិ ទិស្សន្តិ ។

កាលភិក្ខុមានកាយស្ងប់រម្ងាប់ មានសេចក្ដីសុខ ចិត្តក៏តម្កល់នៅមាំ នេះហៅថា សមាធិសម្ពោជ្ឈង្គ ។ ភិក្ខុនោះជាអ្នកពិចារណាឃើញដោយប្រពៃ នូវចិត្តដែលតម្កល់ទុកល្អ មានសភាពដូច្នោះ នេះហៅថា ឧបេក្ខាសម្ពោជ្ឈង្គ ។

[២៩០] ពោជ្ឈង្គ ៧ គឺ សតិសម្ពោជ្ឈង្គ ១ ធម្មវិចយសម្ពោជ្ឈង្គ ១ វីរិយសម្ពោជ្ឈង្គ ១ បីតិសម្ពោជ្ឈង្គ ១ បស្សទ្ធិសម្ពោជ្ឈង្គ ១ សមាធិសម្ពោជ្ឈង្គ ១ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។

[២៩១] បណ្ដាសម្ពោជ្ឈង្គទាំងនោះ សតិសម្ពោជ្ឈង្គ តើដូចម្ដេច ។ សតិក្នុងធម៌ទាំងឡាយ ខាងក្នុងក៏មាន សតិក្នុងធម៌ទាំងឡាយ ខាងក្រៅក៏មាន ។ បើសតិក្នុងធម៌ទាំងឡាយខាងក្នុង មាន ក្នុងកាលណា សតិសម្ពោជ្ឈង្គ ក៏ប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ក្នុងកាលនោះដែរ ។ បើសតិក្នុងធម៌ទាំងឡាយខាងក្រៅ មាន ក្នុងកាលណា សតិសម្ពោជ្ឈង្គ ក៏ប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ក្នុងកាលនោះដែរ ។

[២៩២] តត្ថ កតមោ ធម្មវិចយសម្ពោជ្ឈ-ង្គោ ។ អត្ថិ អជ្ឈត្តំ ធម្មេសុ បវិចយោ អត្ថិ ពហិទ្ធា ធម្មេសុ បវិចយោ ។ យទបិ អជ្ឈត្តំ ធម្មេសុ បវិចយោ តទបិ ធម្មវិចយសម្ពោជ្ឈង្គោ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។ យទបិ ពហិទ្ធា ធម្មេសុ បវិចយោ តទបិ ធម្ម-វិចយសម្ពោជ្ឈង្គោ អភិញ្ញាយ សម្ពោធាយ និព្វា-នាយ សំវត្តតិ ។

[២៩៣] តត្ថ កតមោ វីរិយសម្ពោជ្ឈង្គោ ។ អត្ថិ កាយិកំ វីរិយំ អត្ថិ ចេតសិកំ វីរិយំ ។ យទបិ កាយិកំ វីរិយំ តទបិ វីរិយសម្ពោជ្ឈ-ង្គោ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។ យទបិ ចេតសិកំ វីរិយំ តទបិ វីរិយសម្ពោជ្ឈង្គោ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។

[២៩២] បណ្ដាសម្ពោជ្ឈង្គទាំងនោះ ធម្មវិចយសម្ពោជ្ឈង្គ តើដូចម្ដេច ។ ការសង្កេតក្នុងធម៌ទាំងឡាយ ខាងក្នុងក៏មាន ការសង្កេតក្នុងធម៌ទាំងឡាយ ខាងក្រៅក៏មាន ។ បើការសង្កេតក្នុងធម៌ទាំងឡាយខាងក្នុង មានក្នុងកាលណា ធម្មវិចយសម្ពោជ្ឈង្គ ក៏ប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ក្នុងកាលនោះដែរ ។ បើការសង្កេតក្នុងធម៌ទាំងឡាយខាងក្រៅ មានក្នុងកាលណា ធម្មវិចយសម្ពោជ្ឈង្គ ក៏ប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ក្នុងកាលនោះដែរ ។

[២៩៣] បណ្ដាសម្ពោជ្ឈង្គទាំងនោះ វីរិយសម្ពោជ្ឈង្គ តើដូចម្ដេច ។ វីរិយៈប្រព្រឹត្តទៅក្នុងកាយក៏មាន វីរិយៈប្រព្រឹត្តទៅក្នុងចិត្តក៏មាន ។ បើវីរិយៈប្រព្រឹត្តទៅក្នុងកាយ មានក្នុងកាលណា វីរិយសម្ពោជ្ឈង្គ ក៏ប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ក្នុងកាលនោះដែរ ។ បើវីរិយៈប្រព្រឹត្តទៅក្នុងចិត្ត មានក្នុងកាលណា វីរិយសម្ពោជ្ឈង្គ ក៏ប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ក្នុងកាលនោះដែរ ។

[២៩៤] តត្ថ កតមោ បីតិសម្ពោជ្ឈង្គោ ។ អត្ថិ សវិតក្កសវិចារា បីតិ អត្ថិ អវិតក្កាវិចារា បីតិ ។ យាបិ សវិតក្កសវិចារា បីតិ តាបិ បីតិសម្ពោជ្ឈង្គោ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។ យាបិ អវិតក្កាវិចារា បីតិ តាបិ បីតិ-សម្ពោជ្ឈង្គោ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។

[២៩៥] តត្ថ កតមោ បស្សទ្ធិសម្ពោជ្ឈង្គោ ។ អត្ថិ កាយប្បស្សទ្ធិ អត្ថិ ចិត្តប្បស្សទ្ធិ ។ យាបិ កាយប្បស្សទ្ធិ តាបិ បស្សទ្ធិសម្ពោជ្ឈង្គោ អភិញ្ញា-យ សម្ពោធាយ និព្វានាយ សំវត្តតិ ។ យាបិ ចិត្តប្បស្សទ្ធិ តាបិ បស្សទ្ធិសម្ពោជ្ឈង្គោ អភិញ្ញា-យ សម្ពោធាយ និព្វានាយ សំវត្តតិ ។

[២៩៨] បណ្ដាសម្ពោជ្ឈង្គទាំងនោះ បីតិសម្ពោជ្ឈង្គ តើដូចម្ដេច ។ បីតិ ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈក៏មាន បីតិ មិនមានវិតក្កៈ មិនមានវិចារៈក៏មាន ។ បើបីតិ ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ មាន ក្នុងកាលណា បីតិសម្ពោជ្ឈង្គ ក៏ប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ក្នុងកាលនោះដែរ ។ បើបីតិ មិនមានវិតក្កៈ មិនមានវិចារៈ មាន ក្នុងកាលណា បីតិសម្ពោជ្ឈង្គ ក៏ប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ក្នុងកាលនោះដែរ ។

[២៩៩] បណ្ដាសម្ពោជ្ឈង្គទាំងនោះ បស្សទ្ធិសម្ពោជ្ឈង្គ តើដូចម្ដេច ។ កាយប្បស្សទ្ធិ (សេចក្ដីស្ងប់កាយ) ក៏មាន ចិត្តប្បស្សទ្ធិ (សេចក្ដីស្ងប់ចិត្ត) ក៏មាន ។ បើកាយប្បស្សទ្ធិ មាន ក្នុងកាលណា បស្សទ្ធិសម្ពោជ្ឈង្គ ក៏ប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ក្នុងកាលនោះដែរ ។ បើចិត្តប្បស្សទ្ធិ មាន ក្នុងកាលណា បស្សទ្ធិសម្ពោជ្ឈង្គ ក៏ប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ក្នុងកាលនោះដែរ ។

[២៩៦] តត្ថ កតមោ សមាធិសម្ពោជ្ឈង្គោ ។ អត្ថិ សវិតក្កោ សវិចារោ សមាធិ អត្ថិ អវិតក្កោ អវិចារោ សមាធិ ។ យទបិ សវិតក្កោ សវិចារោ សមាធិ តទបិ សមាធិសម្ពោជ្ឈង្គោ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។ យទបិ អវិតក្កោ អវិចារោ សមាធិ តទបិ សមាធិសម្ពោជ្ឈង្គោ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។

[២៩៧] តត្ថ កតមោ ឧបេក្ខាសម្ពោជ្ឈង្គោ ។ អត្ថិ អជ្ឈត្តំ ធម្មេសុ ឧបេក្ខា អត្ថិ ពហិទ្ធា ធម្មេសុ ឧបេក្ខា ។ យទបិ អជ្ឈត្តំ ធម្មេសុ ឧបេក្ខា តទបិ ឧបេក្ខាសម្ពោជ្ឈង្គោ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។ យទបិ ពហិទ្ធា ធម្មេសុ ឧបេក្ខា តទបិ ឧបេក្ខាសម្ពោជ្ឈង្គោ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។

[២៩៦] បណ្ដាសម្ពោជ្ឈង្គទាំងនោះ សមាធិសម្ពោជ្ឈង្គ តើដូចម្ដេច ។ សមាធិប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈក៏មាន សមាធិមិនមានវិតក្កៈ មិនមានវិចារៈក៏មាន ។ បើសមាធិប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ មានក្នុងកាលណា សមាធិសម្ពោជ្ឈង្គ ក៏ប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ក្នុងកាលនោះដែរ ។ បើសមាធិមិនមានវិតក្កៈ មិនមានវិចារៈ មានក្នុងកាលណា សមាធិសម្ពោជ្ឈង្គ ក៏ប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ក្នុងកាលនោះដែរ ។

[២៩៧] បណ្ដាសម្ពោជ្ឈង្គទាំងនោះ ឧបេក្ខាសម្ពោជ្ឈង្គ តើដូចម្ដេច ។ ឧបេក្ខាក្នុងធម៌ទាំងឡាយខាងក្នុងក៏មាន ឧបេក្ខាក្នុងធម៌ទាំងឡាយខាងក្រៅក៏មាន ។ បើឧបេក្ខាក្នុងធម៌ទាំងឡាយខាងក្នុង មានក្នុងកាលណា ឧបេក្ខាសម្ពោជ្ឈង្គ ក៏ប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ក្នុងកាលនោះដែរ ។ បើឧបេក្ខាក្នុងធម៌ទាំងឡាយខាងក្រៅ មានក្នុងកាលណា ឧបេក្ខាសម្ពោជ្ឈង្គ ក៏ប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ក្នុងកាលនោះដែរ ។

[២៩៨] សត្ត ពោជ្ឈង្គា សតិសម្ពោជ្ឈង្គោ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គោ ។ តត្ថ កតមោ សតិសម្ពោជ្ឈង្គោ ។ ឥធ ភិក្ខុ សតិសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ធម្មវិចយសម្ពោជ្ឈង្គំ ភាវេតិ វីរិយសម្ពោជ្ឈង្គំ ភាវេតិ បីតិសម្ពោជ្ឈង្គំ ភាវេតិ បស្សទ្ធិសម្ពោជ្ឈង្គំ ភាវេតិ សមាធិសម្ពោជ្ឈង្គំ ភាវេតិ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិ-ស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។

សុត្តន្តភាជនីយំ ។

[២៩៩] សត្ត ពោជ្ឈង្គា សតិសម្ពោជ្ឈង្គោ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គោ ។ តត្ថ កតមេ សត្ត ពោជ្ឈង្គា ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិ-បទំ ទន្ធាភិញ្ញំ តស្មឹ សមយេ សត្ត ពោជ្ឈង្គា ហោន្តិ សតិសម្ពោជ្ឈង្គោ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គោ ។

[២៩៨] ពោជ្ឈង្គ ៧ គឺ សតិសម្ពោជ្ឈង្គ ១ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។ បណ្តាសម្ពោជ្ឈង្គទាំងនោះ សតិសម្ពោជ្ឈង្គ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ចម្រើននូវសតិសម្ពោជ្ឈង្គ ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវនិរោធ ជាគ្រឿងឈមទៅកាន់ការលះ ចម្រើននូវធម្មវិចយសម្ពោជ្ឈង្គ ចម្រើននូវវីរិយសម្ពោជ្ឈង្គ ចម្រើននូវបីតិសម្ពោជ្ឈង្គ ចម្រើននូវបស្សទ្ធិសម្ពោជ្ឈង្គ ចម្រើននូវសមាធិសម្ពោជ្ឈង្គ ចម្រើននូវឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវនិរោធ ជាគ្រឿងឈមទៅកាន់ការលះ ។

ចប់ សុត្តន្តភាជនីយ ។

[២៩៩] ពោជ្ឈង្គ ៧ គឺ សតិសម្ពោជ្ឈង្គ ១ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។ បណ្តាធម៌ទាំងនោះ ពោជ្ឈង្គ ៧ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្ដៈ) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ពោជ្ឈង្គ ៧ យ៉ាង គឺ សតិសម្ពោជ្ឈង្គ ១ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គ ១ ក៏កើតមាន ។

[៣០០] តត្ថ កតមោ សតិសម្ពោជ្ឈង្គោ ។ យា សតិ អនុស្សតិ ។ បេ ។ សម្មាសតិ សតិសម្ពោជ្ឈ-ង្គោ មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ សតិសម្ពោ-ជ្ឈង្គោ ។

[៣០១] តត្ថ កតមោ ធម្មវិចយសម្ពោជ្ឈង្គោ ។ យា បញ្ញា បជានដា ។ បេ ។ អមោហោ ធម្មវិ-ចយោ សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ ធម្មវិចយសម្ពោជ្ឈង្គោ ។

[៣០២] តត្ថ កតមោ វីរិយសម្ពោជ្ឈង្គោ ។ យោ ចេតសិកោ វីរិយារម្ភោ ។ បេ ។ សម្មាវាយាមោ វីរិយសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ វីរិយសម្ពោជ្ឈង្គោ ។

[៣០៣] តត្ថ កតមោ បីតិសម្ពោជ្ឈង្គោ ។ យា បីតិ ចាមោជ្ជំ អាមោទនា បមោទនា ហាសោ បហាសោ វិត្តិ ឱទគ្យំ អត្តមនតា ចិត្តស្ស បីតិ-សម្ពោជ្ឈង្គោ អយំ វុច្ចតិ បីតិសម្ពោជ្ឈង្គោ ។

[៣០០] បណ្ដាសម្ពោជ្ឈង្គទាំងនោះ សតិសម្ពោជ្ឈង្គ តើដូចម្ដេច ។ ការរឭក ការនឹកឃើញ ។ បេ ។ ការរឭកត្រូវ សតិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សតិសម្ពោជ្ឈង្គ ។

[៣០១] បណ្ដាសម្ពោជ្ឈង្គទាំងនោះ ធម្មវិចយសម្ពោជ្ឈង្គ តើដូចម្ដេច ។ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណានូវធម៌ ការយល់ត្រូវ ធម្មវិចយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា ធម្មវិចយសម្ពោជ្ឈង្គ ។

[៣០២] បណ្ដាសម្ពោជ្ឈង្គទាំងនោះ វីរិយសម្ពោជ្ឈង្គ តើដូចម្ដេច ។ ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សម្មាវាយាមៈ វីរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា វីរិយសម្ពោជ្ឈង្គ ។

[៣០៣] បណ្ដាសម្ពោជ្ឈង្គទាំងនោះ បីតិសម្ពោជ្ឈង្គ តើដូចម្ដេច ។ សេចក្ដីឆ្អែតចិត្ត សេចក្ដីរីករាយ សេចក្ដីសប្បាយ សេចក្ដីស្រួល ការស្រស់ស្រាយ ការញញឹមញញែម អំណរ ការអណ្ដែតអណ្ដូង សេចក្ដីត្រេកអរនៃចិត្ត បីតិសម្ពោជ្ឈង្គ ណា នេះហៅថា បីតិសម្ពោជ្ឈង្គ ។

[៣០៤] តត្ថ កតមោ បស្សទ្ធិសម្ពោជ្ឈង្គោ ។ យា វេទនាក្ខន្ធស្ស សញ្ញាក្ខន្ធស្ស សង្ខារក្ខន្ធស្ស វិញ្ញាណក្ខន្ធស្ស បស្សទ្ធិ បដិប្បស្សទ្ធិ បស្សម្ភនា បដិប្បស្សម្ភនា បដិប្បស្សម្ភិតត្តំ បស្សទ្ធិសម្ពោជ្ឈង្គោ អយំ វុច្ចតិ បស្សទ្ធិសម្ពោជ្ឈង្គោ ។

[៣០៥] តត្ថ កតមោ សមាធិសម្ពោជ្ឈង្គោ ។ យា ចិត្តស្ស ឋិតិ ។ បេ ។ សម្មាសមាធិ សមាធិសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ សមាធិសម្ពោជ្ឈង្គោ ។

[៣០៦] តត្ថ កតមោ ឧបេក្ខាសម្ពោជ្ឈង្គោ ។ យា ឧបេក្ខា ឧបេក្ខនា អជ្ឈុបេក្ខនា មជ្ឈត្តតា ចិត្តស្ស ឧបេក្ខាសម្ពោជ្ឈង្គោ អយំ វុច្ចតិ ឧបេក្ខាសម្ពោជ្ឈង្គោ ។

ឥមេ វុច្ចន្តិ សត្ត ពោជ្ឈង្គា អវសេសា ធម្មា សត្តហិ សម្ពោជ្ឈង្គេហិ សម្បយុត្តា ។

[៣០៤] បណ្ដាសម្ពោជ្ឈង្គទាំងនោះ បស្សទ្ធិសម្ពោជ្ឈង្គ តើដូចម្ដេច ។ សេចក្ដីស្ងប់ សេចក្ដីរម្ងាប់ ការស្ងប់ ការរម្ងាប់ ភាពនៃការស្ងប់រម្ងាប់ នៃវេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ បស្សទ្ធិសម្ពោជ្ឈង្គ ណា នេះហៅថា បស្សទ្ធិសម្ពោជ្ឈង្គ ។

[៣០៥] បណ្ដាសម្ពោជ្ឈង្គទាំងនោះ សមាធិសម្ពោជ្ឈង្គ តើដូចម្ដេច ។ ការតាំងនៅ នៃចិត្ត ។ បេ ។ ការតម្កល់ចិត្តដោយប្រពៃ សមាធិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សមាធិសម្ពោជ្ឈង្គ ។

[៣០៦] បណ្ដាសម្ពោជ្ឈង្គទាំងនោះ ឧបេក្ខាសម្ពោជ្ឈង្គ តើដូចម្ដេច ។ ការរំពឹងឃើញ អាការរំពឹងឃើញ ការរំពឹងឃើញជាក់ ភាពនៃចិត្តតាំងនៅជាកណ្ដាល ឧបេក្ខាសម្ពោជ្ឈង្គ ណា នេះហៅថា ឧបេក្ខាសម្ពោជ្ឈង្គ ។

ធម៌ទាំងនេះ ហៅថា ពោជ្ឈង្គ ៧ យ៉ាង ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថាប្រកបដោយសម្ពោជ្ឈង្គទាំង ៧ ។

[៣០៧] សត្ត ពោជ្ឈង្គា សតិសម្ពោជ្ឈង្គោ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គោ ។ តត្ថ កតមោ សតិសម្ពោជ្ឈង្គោ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ យា តស្មឹ សមយេ សតិ អនុស្សតិ ។ បេ ។ សម្មាសតិ សតិសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ សតិសម្ពោជ្ឈង្គោ អវសេសា ធម្មា សតិសម្ពោជ្ឈង្គសម្បយុត្តា ។ បេ ។ អវសេសា ធម្មា ធម្មវិចយសម្ពោជ្ឈង្គសម្បយុត្តា ។ បេ ។ អវសេសា ធម្មា វីរិយសម្ពោជ្ឈង្គសម្បយុត្តា ។ បេ ។ អវសេសា ធម្មា បីតិសម្ពោជ្ឈង្គសម្បយុត្តា ។ បេ ។ អវសេសា ធម្មា បស្សទ្ធិសម្ពោជ្ឈង្គសម្បយុត្តា ។ បេ ។ អវសេសា ធម្មា សមាធិសម្ពោជ្ឈង្គសម្បយុត្តា ។ តត្ថ កតមោ ឧបេក្ខាសម្ពោជ្ឈង្គោ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ

[៣០៧] ពោជ្ឈង្គ ៧ យ៉ាងគឺ សតិសម្ពោជ្ឈង្គ ១ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។ បណ្តាសម្ពោជ្ឈង្គទាំងនោះ សតិសម្ពោជ្ឈង្គ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្ដៈ) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ការរឭក ការនឹកឃើញ ។ បេ ។ ការរឭកត្រូវ សតិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សតិសម្ពោជ្ឈង្គ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថាប្រកបដោយសតិសម្ពោជ្ឈង្គ ។ បេ ។ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថាប្រកបដោយធម្មវិចយសម្ពោជ្ឈង្គ ។ បេ ។ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថាប្រកបដោយវីរិយសម្ពោជ្ឈង្គ ។ បេ ។ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថាប្រកបដោយបីតិសម្ពោជ្ឈង្គ ។ បេ ។ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថាប្រកបដោយបស្សទ្ធិសម្ពោជ្ឈង្គ ។ បេ ។ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសមាធិសម្ពោជ្ឈង្គ ។ បណ្តាសម្ពោជ្ឈង្គទាំងនោះ ឧបេក្ខាសម្ពោជ្ឈង្គ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើននូវលោកុត្តជ្ឈាន ជានិយ្យានិកធម៌

អបចយគាមឹ និដ្ឋិគតានំ បហានាយ បឋមាយ ភូ-
មិយា បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ
ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ
យា តស្មឹ សមយេ ឧបេក្ខា ឧបេក្ខនា អជ្ឈុបេ-
ក្ខនា មជ្ឈត្តតា ចិត្តស្ស ឧបេក្ខាសម្ពោជ្ឈង្គោ អយំ
វុច្ចតិ ឧបេក្ខាសម្ពោជ្ឈង្គោ អវសេសា ធម្មា ឧ-
បេក្ខាសម្ពោជ្ឈង្គសម្បយុត្តា ។

[៣០៨] សត្ត ពោជ្ឈង្គា សតិសម្ពោជ្ឈង្គោ
។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គោ ។ តត្ថ កតមេ
សត្ត ពោជ្ឈង្គា ។ ឥធ ភិក្ខុ យស្មឹ សមយេ
លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយ-
គាមឹ និដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា
បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ
ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធា-
ភិញ្ញំ តស្មឹ សមយេ ផស្សោ ហោតិ ។ បេ ។
អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា តស្សេវ
លោកុត្តរស្ស កុសលស្ស ឈានស្ស កតត្តា
ភាវិតត្តា វិបាកំ វិវិច្ចេវ កាមេហិ ។ បេ ។

ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្ដៈ) ដើម្បីលះនូវទដ្ឋិទាំង-ឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ការរំពឹងឃើញ អាការរំពឹងឃើញ ការរំពឹងឃើញជាក់ ភាពនៃចិត្តតាំងនៅជាកណ្ដាល ឧបេក្ខាសម្ពោជ្ឈង្គ ណា នេះហៅថា ឧបេក្ខាសម្ពោ-ជ្ឈង្គ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឧបេក្ខាសម្ពោជ្ឈង្គ ។

[៣០៨] ពោជ្ឈង្គ ៧ យ៉ាង គឺ សតិសម្ពោជ្ឈង្គ ១ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។ បណ្ដាធម៌ទាំងនោះ ពោជ្ឈង្គ ៧ តើដូចម្ដេច ។ ក្នុងសម័យ ណា ភិក្ខុក្នុងសាសនានេះ ចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្ដៈ) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ផស្សៈ ក៏កើតមាន ។ បេ ។ អវិក្ខេបៈ ក៏កើតមាន ធម៌ទាំងនេះ ជាកុសល ភិក្ខុស្ងាត់ចាកកាមទាំងឡាយ ។ បេ ។

បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ សុញ្ញតំ តស្មឹ សមយេ សត្ត ពោជ្ឈង្គា ហោន្តិ សតិសម្ពោជ្ឈង្គោ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គោ ។ តត្ថ កតមោ សតិសម្ពោជ្ឈង្គោ ។ យា សតិ អនុស្សតិ ។ បេ ។ សម្មាសតិ សតិសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ សតិសម្ពោជ្ឈង្គោ ។ បេ ។ តត្ថ កតមោ ឧបេក្ខាសម្ពោជ្ឈង្គោ ។ យា ឧបេក្ខា ឧបេក្ខនា អជ្ឈុបេក្ខនា មជ្ឈត្តតា ចិត្តស្ស ឧបេក្ខាសម្ពោជ្ឈង្គោ អយំ វុច្ចតិ ឧបេក្ខាសម្ពោជ្ឈង្គោ ។ ឥមេ វុច្ចន្តិ សត្ត ពោជ្ឈង្គា អវសេសា ធម្មា សត្តហិ ពោជ្ឈង្គេហិ សម្បយុត្តា ។

[៣០៩] សត្ត ពោជ្ឈង្គា សតិសម្ពោជ្ឈង្គោ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គោ ។ តត្ថ កតមោ សតិសម្ពោជ្ឈង្គោ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ

ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ជាសុញ្ញតៈ ជាវិបាក ព្រោះភាពនៃលោកុត្តរកុសលជ្ឈាននោះឯង ដែលលោកបានធ្វើហើយ ចម្រើនហើយ ក្នុងសម័យនោះ ពោជ្ឈង្គ ៧ គឺ សតិសម្ពោជ្ឈង្គ ១ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គ ១ ក៏កើតមាន ។ បណ្តាសម្ពោជ្ឈង្គទាំងឡាយនោះ សតិសម្ពោជ្ឈង្គ តើដូចម្តេច ។ ការរឭក ការនឹកឃើញ ។ បេ ។ ការរឭកត្រូវ សតិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សតិសម្ពោជ្ឈង្គ ។ បេ ។ បណ្តាសម្ពោជ្ឈង្គទាំងនោះ ឧបេក្ខាសម្ពោជ្ឈង្គ តើដូចម្តេច ។ ការរំពឹងឃើញ អាការរំពឹងឃើញ ការរំពឹងឃើញជាក់ ភាពនៃចិត្តតាំងនៅជាកណ្តាល ឧបេក្ខាសម្ពោជ្ឈង្គ ណា នេះហៅថា ឧបេក្ខាសម្ពោជ្ឈង្គ ។ ធម៌ទាំងនេះ ហៅថា ពោជ្ឈង្គ ៧ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថាប្រកបដោយសម្ពោជ្ឈង្គ ៧ ។

[៣០៩] ពោជ្ឈង្គ ៧ យ៉ាង គឺ សតិសម្ពោជ្ឈង្គ ១ ។ បេ ។ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។ បណ្តាសម្ពោជ្ឈង្គទាំងនោះ សតិសម្ពោជ្ឈង្គ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្តៈ) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន

ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ ផស្សោ ហោតិ ។ បេ ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា តស្សេវ លោកុត្តរស្ស កុសលស្ស ឈានស្ស កតត្តា ភាវិតត្តា វិបាកំ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ សុញ្ញតំ យា តស្មឹ សមយេ សតិ អនុស្សតិ ។ បេ ។ សម្មាសតិ សតិសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ សតិសម្ពោជ្ឈង្គោ អវសេសា ធម្មា សតិសម្ពោជ្ឈង្គសម្បយុត្តា ។ បេ ។ អវសេសា ធម្មា ធម្មវិចយសម្ពោជ្ឈង្គសម្បយុត្តា ។ បេ ។ អវសេសា ធម្មា វីរិយសម្ពោជ្ឈង្គសម្បយុត្តា ។ បេ ។ អវសេសា ធម្មា បីតិសម្ពោជ្ឈង្គសម្បយុត្តា ។ បេ ។ អវសេសា ធម្មា បស្សទ្ធិសម្ពោជ្ឈង្គសម្បយុត្តា ។ បេ ។ អវសេសា ធម្មា សមាធិសម្ពោជ្ឈង្គសម្បយុត្តា ។ តត្ថ កតមោ ឧបេក្ខាសម្ពោជ្ឈង្គោ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ

ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ផស្សៈ ក៏កើតមាន ។ បេ ។ អវិក្ខេបៈ ក៏កើតមាន ធម៌ទាំងនេះជាកុសល ភិក្ខុស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ជាសុញ្ញតៈ ជាវិបាក ព្រោះភាពនៃលោកុត្តរកុសលជ្ឈាននោះឯង ដែលលោកបានធ្វើហើយ ចម្រើនហើយ ក្នុងសម័យនោះ ការរលឹក ការនឹកឃើញ ។ បេ ។ ការរលឹកត្រូវ សតិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សតិសម្ពោជ្ឈង្គ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសតិសម្ពោជ្ឈង្គ ។ បេ ។ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយធម្មវិចយសម្ពោជ្ឈង្គ ។ បេ ។ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយវីរិយសម្ពោជ្ឈង្គ ។ បេ ។ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយបីតិសម្ពោជ្ឈង្គ ។ បេ ។ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយបស្សទ្ធិសម្ពោជ្ឈង្គ ។ បេ ។ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថាប្រកបដោយសមាធិសម្ពោជ្ឈង្គ ។ បណ្ដាសម្ពោជ្ឈង្គទាំងនោះ ឧបេក្ខាសម្ពោជ្ឈង្គ តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្ដៈ)

និជ្ជិកតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ ផស្សោ ហោតិ ។ បេ ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា តស្សេវ លោកុត្តរស្ស កុសលស្ស ឈានស្ស កតត្តា ភាវិតត្តា វិបាកំ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ សុញ្ញតំ យា តស្មឹ សមយេ ឧបេក្ខា ឧបេក្ខនា អជ្ឈុបេក្ខនា មជ្ឈត្តតា ចិត្តស្ស ឧបេក្ខាសម្ពោជ្ឈង្គោ អយំ វុច្ចតិ ឧបេក្ខាសម្ពោជ្ឈង្គោ អវសេសា ធម្មា ឧបេក្ខាសម្ពោជ្ឈង្គសម្បយុត្តា ។

អភិធម្មភាជនីយំ ។

[៣១០] សត្ត ពោជ្ឈង្គា សតិសម្ពោជ្ឈង្គោ ធម្មវិចយសម្ពោជ្ឈង្គោ វីរិយសម្ពោជ្ឈង្គោ បីតិសម្ពោជ្ឈង្គោ បស្សទ្ធិសម្ពោជ្ឈង្គោ សមាធិសម្ពោជ្ឈង្គោ ឧបេក្ខាសម្ពោជ្ឈង្គោ ។ សត្តន្នំ ពោជ្ឈង្គានំ កតិ កុសលា កតិ អកុសលា កតិ អព្យាកតា ។ បេ ។ កតិ សរណា កតិ អរណា ។

*ដើម្បីលះនូវទិដ្ឋិទាំងឡាយ  ដើម្បីដល់នូវបឋមភូមិ  ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ផស្ស: ក៏កើតមាន ។ បេ ។ អវិក្ខេប: ក៏កើតមាន ធម៌ទាំងនេះជាកុសល ភិក្ខុស្ងាត់ ចាកកាមទាំងឡាយ ។ បេ ។ ហើយ ចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ជាសុញ្ញត: ជាវិបាក ព្រោះភាពនៃលោកុត្តរកុសលជ្ឈាននោះឯង  ដែលលោកបានធ្វើហើយ ចម្រើនហើយ ក្នុងសម័យនោះ ការរំពឹងឃើញ អាការរំពឹងឃើញ ការរំពឹងឃើញជាក់ ភាពនៃចិត្តតាំងនៅជាកណ្តាល ឧបេក្ខាសម្ពោជ្ឈង្គ ណា នេះហៅថា ឧបេក្ខាសម្ពោជ្ឈង្គ ធម៌ទាំងឡាយដ៏សេស ក៏ ឈ្មោះថាប្រកបដោយឧបេក្ខាសម្ពោជ្ឈង្គ ។*

ចប់  អភិធម្មភាជនីយ  ។

[៣១០] *ពោជ្ឈង្គ ៧ គឺ សតិសម្ពោជ្ឈង្គ ១ ធម្មវិចយសម្ពោជ្ឈង្គ ១ វីរិយសម្ពោជ្ឈង្គ ១ បីតិសម្ពោជ្ឈង្គ ១ បស្សទ្ធិសម្ពោជ្ឈង្គ ១ សមាធិសម្ពោជ្ឈង្គ ១ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។ បណ្តាពោជ្ឈង្គ ទាំង ៧ ពោជ្ឈង្គ ជាកុសលប៉ុន្មាន ជាអកុសលប៉ុន្មាន ជាអព្យាក្រឹត ប៉ុន្មាន ។ បេ ។ ជាសរណ:ប៉ុន្មាន ជាអរណ:ប៉ុន្មាន ។*

[៣១១] សិយា កុសលា សិយា អព្យាកតា ។ បីតិសម្ពោជ្ឈង្គោ សុខាយ វេទនាយ សម្បយុត្តោ ឆ ពោជ្ឈង្គា សិយា សុខាយ វេទនាយ សម្បយុត្តា សិយា អទុក្ខមសុខាយ វេទនាយ សម្បយុត្តា ។ សិយា វិបាកា សិយា វិបាកធម្មធម្មា អនុបា-ទិន្នានុបាទានិយា អសង្កិលិដ្ឋាសង្កិលេសិកា សិយា សវិតក្កសវិចារា សិយា អវិតក្កវិចារមត្តា សិយា អវិតក្កាវិចារា ។ បីតិសម្ពោជ្ឈង្គោ ន បីតិសហ-គតោ សុខសហគតោ ន ឧបេក្ខាសហគតោ ឆ ពោជ្ឈង្គា សិយា បីតិសហគតា សិយា សុខសហគតា សិយា ឧបេក្ខាសហគតា ។ នេវ ទស្សនេន ន ភាវនាយ បហាតព្វា នេវ ទស្សនេន ន ភាវនាយ បហាតព្វហេតុកា សិយា អបចយគាមិ-នោ សិយា នេវាចយគាមិនោ នាបចយគាមិនោ សិយា សេក្ខា សិយា អសេក្ខា អប្បមាណា អប្បមាណា-រម្មណា បណីតា សិយា សម្មត្តនិយតា សិយា អនិ-យតា ន មគ្គារម្មណា សិយា មគ្គហេតុកា សិយា មគ្គាធិបតិនោ សិយា ន វត្តព្វា មគ្គហេតុកាតិបិ

[៣១១] ពោជ្ឈង្គ ៧ ជាកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។ បីតិសម្ពោជ្ឈង្គ ប្រកបដោយសុខវេទនា ពោជ្ឈង្គ ៦ ប្រកបដោយសុខ-វេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនា ក៏មាន ។ ពោជ្ឈង្គ ៧ ជាវិបាកក៏មាន មានវិបាកធម៌ជាប្រក្រតី មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទាន ជាធម៌មិនសៅហ្មង ទាំងមិនគួរដល់សេចក្តីសៅហ្មងក៏មាន ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈក៏មាន មិនមានវិតក្កៈ មានត្រឹមតែវិចារៈក៏មាន មិនមានវិតក្កៈ មិនមានវិចារៈក៏មាន ។ បីតិសម្ពោជ្ឈង្គ មិនប្រទ្បំដោយបីតិ តែប្រទ្បំដោយសុខ មិនប្រទ្បំដោយឧបេក្ខា ពោជ្ឈង្គ ៦ ប្រទ្បំដោយបីតិក៏មាន ប្រទ្បំដោយសុខក៏មាន ប្រទ្បំដោយឧបេក្ខាក៏មាន ។ ពោជ្ឈង្គ ៧ មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនា មានហេតុមិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនា មិនដល់នូវការសន្សំ (នូវកិលេសវដ្តៈ) ក៏មាន មិនដល់នូវការសន្សំ (នូវកិ-លេសវដ្តៈ) ទាំងមិនដល់នូវការមិនសន្សំ (នូវកិលេសវដ្តៈ) ក៏មាន ជារបស់សេក្ខៈក៏មាន ជារបស់អសេក្ខៈ មានប្រមាណមិនបាន មានអា-រម្មណ៍ប្រមាណមិនបាន ជាសភាពឧត្តមក៏មាន មានសភាពត្រូវ និង ទៀងក៏មាន មិនទៀង មិនមានមគ្គជាអារម្មណ៍ក៏មាន មានមគ្គជាហេតុ ក៏មាន មានមគ្គជាអធិបតីក៏មាន មិនគួរពោលថា មានមគ្គជាហេតុផង

មគ្គាធិបតិនោតិបិ សិយា ឧប្បន្នា សិយា អនុប្បន្នា សិយា ឧប្បាទិនោ សិយា អតីតា សិយា អនាគតា សិយា បច្ចុប្បន្នា ន វត្តព្វា អតីតារម្មណាតិបិ អនាគតារម្មណាតិបិ បច្ចុប្បន្នារម្មណាតិបិ សិយា អជ្ឈត្តា សិយា ពហិទ្ធា សិយា អជ្ឈត្តពហិទ្ធា ពហិទ្ធារម្មណា អនិទស្សនាប្បដិឃា ។

[៣១២] ធម្មវិចយសម្ពោជ្ឈង្គោ ហេតុ ន ពោជ្ឈង្គា ន ហេតូ ។ សហេតុកា ហេតុសម្បយុត្តា ។ ធម្មវិចយសម្ពោជ្ឈង្គោ ហេតុ ចេវ សហេតុកោ ច ន ពោជ្ឈង្គា ន វត្តព្វា ហេតូ ចេវ សហេតុកា ចាតិ សហេតុកា ចេវ ន ច ហេតូ ។ ធម្មវិចយសម្ពោជ្ឈង្គោ ហេតុ ចេវ ហេតុសម្បយុត្តោ ច ន ពោជ្ឈង្គា ន វត្តព្វា ហេតូ ចេវ ហេតុសម្បយុត្តា ចាតិ ហេតុសម្បយុត្តា ចេវ ន ច ហេតូ ។ ន ពោជ្ឈង្គា ន ហេតូ សហេតុកា ធម្មវិចយសម្ពោជ្ឈង្គោ ន វត្តព្វោ ន ហេតុ សហេតុកោតិបិ ន ហេតុ អហេតុកោតិបិ ។

ថា មានមគ្គជាអធិបតីផងក៏មាន កើតឡើងហើយក៏មាន មិនទាន់កើតឡើងក៏មាន ប្រមុងនឹងកើតឡើងក៏មាន ជាអតីតក៏មាន ជាអនាគតក៏មាន ជាបច្ចុប្បន្ន តែមិនគួរពោលថា មានអារម្មណ៍ជាអតីតផង ថា មានអារម្មណ៍ជាអនាគតផង ថា មានអារម្មណ៍ជាបច្ចុប្បន្នផងក៏មាន ជាខាងក្នុងក៏មាន ជាខាងក្រៅក៏មាន ទាំងខាងក្នុងទាំងខាងក្រៅ មានអារម្មណ៍ជាខាងក្រៅ មិនប្រកបដោយការឃើញ ទាំងមិនប្រកបដោយការប៉ះពាល់ក៏មាន ។

[៣១២] ធម្មវិចយសម្ពោជ្ឈង្គ ជាហេតុ ពោជ្ឈង្គ ៦ មិនមែនហេតុ ។ ពោជ្ឈង្គ ៧ ប្រព្រឹត្តទៅជាមួយនឹងហេតុ ទាំងប្រកបដោយហេតុ ។ ធម្មវិចយសម្ពោជ្ឈង្គ ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុ ពោជ្ឈង្គ ៦ មិនគួរពោលថា ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុទេ គឺ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនជាហេតុ ។ ធម្មវិចយសម្ពោជ្ឈង្គ ជាហេតុ ទាំងប្រកបដោយហេតុ ពោជ្ឈង្គ ៦ មិនគួរពោលថា ជាហេតុ ទាំងប្រកបដោយហេតុឡើយ គឺ គ្រាន់តែប្រកបដោយហេតុ តែមិនមែនជាហេតុ ។ ពោជ្ឈង្គ ៦ មិនមែនហេតុ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ ធម្មវិចយសម្ពោជ្ឈង្គ មិនគួរពោល ថា មិនមែនហេតុ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុផង ថា មិនមែនហេតុ ទាំងឥតហេតុដូច្នេះផងទេ ។

[៣១៣] សប្បច្ចយា សង្ខតា អនិទស្សនា អប្បដិឃា អរូបា លោកុត្តរា កេនចិ វិញ្ញេយ្យា កេនចិ ន វិញ្ញេយ្យា ។ នោ អាសវា អនាសវា អាសវវិប្បយុត្តា ន វត្តព្វា អាសវា ចេវ សាសវា ចាតិបិ សាសវា ចេវ នោ ច អាសវាតិបិ ន វត្តព្វា អាសវា ចេវ អាសវសម្បយុត្តា ចាតិបិ អាសវសម្បយុត្តា ចេវ នោ ច អាសវាតិបិ អាសវវិប្បយុត្តអនាសវា ។ នោ សញ្ញោជនា ។ បេ ។ នោ គន្ថា ។ បេ ។ នោ ឱឃា ។ បេ ។ នោ យោគា ។ បេ ។ នោ នីវរណា ។ បេ ។ នោ បរាមាសា ។ បេ ។ សារម្មណា នោ ចិត្តា ចេតសិកា ចិត្តសម្បយុត្តា ចិត្តសំសដ្ឋា ចិត្តសមុដ្ឋានា ចិត្តសហភុនោ ចិត្តានុបរិវត្តិនោ ចិត្តសំសដ្ឋសមុដ្ឋានា ចិត្តសំសដ្ឋសមុដ្ឋានសហភុនោ ចិត្តសំសដ្ឋសមុដ្ឋានានុបរិវត្តិនោ ពាហិរា នុបាទា អនុបាទិន្នា ។ នុបាទានា ។ បេ ។ នោ កិលេសា ។ បេ ។

[៣១៣] ពោជ្ឈង្គ ៧ ប្រកបដោយបច្ច័យ ត្រូវបច្ច័យតាក់តែង មិនប្រកបដោយការឃើញ មិនប្រកបដោយការប៉ះពាល់ មិនមានរូប ជាលោកុត្តរៈ ដែលគប្បីដឹងដោយវិញ្ញាណណាមួយ ដែលមិនគប្បីដឹងដោយវិញ្ញាណណាមួយ ។ មិនមែនអាសវៈ ទាំងមិនមានអាសវៈ ប្រាសចាកអាសវៈ មិនគួរពោល ថា ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ថា ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនអាសវៈផងឡើយ មិនគួរពោល ថា ជាអាសវៈ ទាំងប្រកបដោយអាសវៈផង ថា ប្រកបដោយអាសវៈ តែមិនមែនជាអាសវៈផងទេ គឺ ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ។ មិនមែនសញ្ញោជនៈ ។ បេ ។ មិនមែនគន្ថៈ ។ បេ ។ មិនមែនឱឃៈ ។ បេ ។ មិនមែនយោគៈ ។ បេ ។ មិនមែននីវរណៈ ។ បេ ។ មិនមែនបរាមាសៈ ។ បេ ។ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ មិនមែនចិត្ត ជាចេតសិក ប្រកបដោយចិត្ត ច្រឡំដោយចិត្ត តាំងឡើងអំពីចិត្ត កើតជាមួយនឹងចិត្ត ប្រព្រឹត្តទៅតាមចិត្ត ច្រឡំ ទាំងតាំងឡើងអំពីចិត្ត ច្រឡំ ទាំងតាំងឡើង ទាំងកើតជាមួយនឹងចិត្ត ច្រឡំ ទាំងតាំងឡើង ទាំងប្រព្រឹត្តតាមនូវចិត្ត ជាខាងក្រៅ មិនមែនឧបាទា មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យកហើយ ។ មិនមែនឧបាទាន ។ បេ ។ មិនមែនកិលេស ។ បេ ។

[៣១៤] ន ឧស្សនេន បហាតព្វា ន ភាវនាយ បហាតព្វា ន ឧស្សនេន បហាតព្វហេតុកា ន ភាវនាយ បហាតព្វហេតុកា សិយា សវិតក្កា សិយា អវិតក្កា សិយា សវិចារា សិយា អវិចារា ។ បីតិសម្ពោជ្ឈង្គោ អប្បីតិកោ ឆ ពោជ្ឈង្គា សិយា សប្បីតិកា សិយា អប្បីតិកា ។ បីតិសម្ពោជ្ឈង្គោ ន បីតិសហគតោ ឆ ពោជ្ឈង្គា សិយា បីតិសហគតា សិយា ន បីតិសហគតា ។ បីតិសម្ពោជ្ឈង្គោ សុខ-សហគតោ ឆ ពោជ្ឈង្គា សិយា សុខសហគតា សិយា ន សុខសហគតា ។ បីតិសម្ពោជ្ឈង្គោ ន ឧបេក្ខាសហគតោ ឆ ពោជ្ឈង្គា សិយា ឧបេក្ខា-សហគតា សិយា ន ឧបេក្ខាសហគតា ។ ន កាមាវចរា ន រូបាវចរា ន អរូបាវចរា អបរិយា-បន្នា សិយា និយ្យានិកា សិយា អនិយ្យានិកា សិយា និយតា សិយា អនិយតា អនុត្តរា អរណាតិ ។

បញ្ហាបុច្ឆកំ ។

ពោជ្ឈង្គវិភង្គោ សមត្តោ ។

---

ពោជ្ឈង្គវិភង្គ បញ្ហាបុច្ឆកៈ

[៣១៤] *ពោជ្ឈង្គ ៧ មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនា មានហេតុមិនគួរលះដោយទស្សនៈ មានហេតុមិនគួរលះដោយភាវនា ប្រកបដោយវិតក្កៈក៏មាន មិនមានវិតក្កៈក៏មាន ប្រកបដោយវិចារៈក៏មាន មិនមានវិចារៈក៏មាន ។ បីតិសម្ពោជ្ឈង្គ មិនមានបីតិ ពោជ្ឈង្គ ៦ ប្រកបដោយបីតិក៏មាន មិនមានបីតិក៏មាន ។ បីតិ-សម្ពោជ្ឈង្គ មិនប្រកបព្រមដោយបីតិ ពោជ្ឈង្គ ៦ ប្រកបព្រមដោយបីតិក៏មាន មិនប្រកបព្រមដោយបីតិក៏មាន ។ បីតិសម្ពោជ្ឈង្គ ប្រកបព្រមដោយសុខ ពោជ្ឈង្គ ៦ ប្រកបព្រមដោយសុខក៏មាន មិនប្រកបព្រមដោយសុខក៏មាន ។ បីតិ-សម្ពោជ្ឈង្គ មិនប្រកបព្រមដោយឧបេក្ខា ពោជ្ឈង្គ ៦ ប្រកបព្រមដោយឧបេក្ខាក៏មាន មិនប្រកបព្រមដោយឧបេក្ខាក៏មាន ។ ពោជ្ឈង្គ ៧ មិនមែនកាមា-វចរ មិនមែនរូបាវចរ មិនមែនអរូបាវចរ ជាអបរិយាបន្នៈ ជានិយ្យានិកៈក៏មាន ជាអនិយ្យានិកៈក៏មាន ជានិយតៈក៏មាន ជាអនិយតៈ ជាអនុត្តរៈ ជាអរណៈក៏មាន ។*

ចប់ បញ្ហាបុច្ឆកៈ ។

ចប់ ពោជ្ឈង្គវិភង្គ ។

# មគ្គវិភង្គោ

[៣១៥] អរិយោ អដ្ឋង្គិកោ មគ្គោ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មា-វាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ។

[៣១៦] តត្ថ កតមា សម្មាទិដ្ឋិ ។ ទុក្ខេ ញាណំ ទុក្ខសមុទយេ ញាណំ ទុក្ខនិរោធេ ញាណំ ទុក្ខនិរោធគាមិនិយា បដិបទាយ ញាណំ អយំ វុច្ចតិ សម្មាទដ្ឋិ ។

[៣១៧] តត្ថ កតមោ សម្មាសង្កប្បោ ។ នេក្ខម្មសង្កប្បោ អព្យាបាទសង្កប្បោ អវិហឹសាសង្ក-ប្បោ អយំ វុច្ចតិ សម្មាសង្កប្បោ ។

[៣១៨] តត្ថ កតមា សម្មាវាចា ។ មុសា-វាទា វេរមណី បិសុណាយ វាចាយ វេរមណី ផរុសាយ វាចាយ វេរមណី សម្ផប្បលាបា វេរមណី អយំ វុច្ចតិ សម្មាវាចា ។

[៣១៩] តត្ថ កតមោ សម្មាកម្មន្តោ ។

# មគ្គវិភង្គ

[៣១៥] អរិយមគ្គមានអង្គ ៨ ។ មគ្គមានអង្គ ៨ គឺ អ្វីខ្លះ ។ គឺ សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ ។

[៣១៦] បណ្តាអរិយមគ្គទាំងនោះ សម្មាទិដ្ឋិ តើដូចម្តេច ។ ការដឹងក្នុងកងទុក្ខ ការដឹងក្នុងទុក្ខសមុទ័យ ការដឹងក្នុងទុក្ខនិរោធ ការដឹងក្នុងទុក្ខនិរោធគាមិនីបដិបទា នេះហៅថា សម្មាទិដ្ឋិ ។

[៣១៧] បណ្តាអរិយមគ្គទាំងនោះ សម្មាសង្កប្បៈ តើដូចម្តេច ។ ការត្រិះរិះក្នុងការចេញចាកកាម ការត្រិះរិះក្នុងការមិនព្យាបាទ ការត្រិះរិះក្នុងការមិនបៀតបៀន នេះហៅថា សម្មាសង្កប្បៈ ។

[៣១៨] បណ្តាអរិយមគ្គទាំងនោះ សម្មាវាចា តើដូចម្តេច ។ ចេតនាជាហេតុវៀរចាកមុសាវាទ ចេតនាជាហេតុវៀរចាកបិសុណាវាចា ចេតនាជាហេតុវៀរចាកផរុសវាចា ចេតនាជាហេតុវៀរចាកសម្ផប្បលាបៈ នេះហៅថា សម្មាវាចា ។

[៣១៩] បណ្តាអរិយមគ្គទាំងនោះ សម្មាកម្មន្តៈ តើដូចម្តេច ។

បាណាតិបាតា វេរមណី អទិន្នាទានា វេរមណី កាមេសុ មិច្ឆាចារា វេរមណី អយំ វុច្ចតិ សម្មាកម្មន្តោ ។

[៣២០] តត្ថ កតមោ សម្មាអាជីវោ ។ ឥធ អរិយស្បាវកោ មិច្ឆាអាជីវំ បហាយ សម្មាអាជីវេន ជីវិតំ កប្បេតិ អយំ វុច្ចតិ សម្មាអាជីវោ ។

[៣២១] តត្ថ កតមោ សម្មាវាយាមោ ។ ឥធ ភិក្ខុ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្ត បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ អយំ វុច្ចតិ សម្មាវាយាមោ ។

ចេតនាជាហេតុវៀរចាកបាណាតិបាត ចេតនាជាហេតុវៀរចាកអទិន្នាទាន ចេតនាជាហេតុវៀរចាកកាមេសុមិច្ឆាចារ នេះហៅថា សម្មាកម្មន្តៈ ។

[៣២០] បណ្តាអរិយមគ្គទាំងនោះ សម្មាអាជីវៈ តើដូចម្តេច ។ អរិយសាវ័កក្នុងសាសនានេះ លះបង់ការចិញ្ចឹមជីវិតខុស សម្រេចជីវិតដោយការចិញ្ចឹមជីវិតត្រូវ នេះហៅថា សម្មាអាជីវៈ ។

[៣២១] បណ្តាអរិយមគ្គទាំងនោះ សម្មាវាយាមៈ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈ (សេចក្តីប្រាថ្នា) ឲ្យកើតឡើង សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើត មិនឲ្យកើតឡើង ញុំាងឆន្ទៈឲ្យកើតឡើង សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីលះនូវពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ញុំាងឆន្ទៈឲ្យកើតឡើង សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ ដែលមិនទាន់កើត ឲ្យកើតឡើង ញុំាងឆន្ទៈឲ្យកើតឡើង សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ ដែលកើតឡើងហើយ ឲ្យឋិតនៅ មិនឲ្យវិនាស ឲ្យរឹងរឹតតែដុះដាល ធំទូលាយ ចម្រើន ពេញលេញ នេះហៅថា សម្មាវាយាមៈ ។

[៣៦២] តត្ថ កតមា សម្មាសតិ ។ ឥធ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈា-ទោមនស្សំ វេទនាសុ វេទនានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈា-ទោមនស្សំ ចិត្តេ ចិត្តានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈា-ទោមនស្សំ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈា-ទោមនស្សំ អយំ វុច្ចតិ សម្មាសតិ ។

[៣៦៣] តត្ថ កតមោ សម្មាសមាធិ ។ ឥធ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋ-មំ ឈានំ ឧបសម្បជ្ជ វិហរតិ វិតក្កវិចារានំ វូប-សមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ

[៣២២] បណ្ដាអរិយមគ្គទាំងនោះ សម្មាសតិ តើដូចម្ដេច ។ ភិក្ខុក្នុងសាសនានេះ ពិចារណានូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្ដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្ស ក្នុងលោក ពិចារណានូវវេទនាក្នុងវេទនាទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្ដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោក ពិចារណានូវចិត្តក្នុងចិត្ត មានព្យាយាមជាគ្រឿងដុតកម្ដៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោក ពិចារណានូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្ដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោក នេះហៅថា សម្មាសតិ ។

[៣២៣] បណ្ដាអរិយមគ្គទាំងនោះ សម្មាសមាធិ តើដូចម្ដេច ។ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលកាន់បឋមជ្ឈានប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ មានបីតិនិងសុខដែលកើតអំពីវិវេក ព្រោះរម្ងាប់នូវវិតក្កៈ និងវិចារៈ ចូលកាន់ទុតិយជ្ឈាន

ឧបសម្បជ្ជ វិហរតិ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេតិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ អយំ វុច្ចតិ សម្មាសមាធិ ។

[៣២៤] អរិយោ អដ្ឋង្គិកោ មគ្គោ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ។

[៣២៥] តត្ថ កតមា សម្មាទិដ្ឋិ ។ ឥធ ភិក្ខុ សម្មាទិដ្ឋឹ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ បេ ។ សម្មាសង្កប្បំ ភាវេតិ ។ បេ ។ សម្មាវាចំ ភាវេតិ ។ បេ ។

ជាទីផូរផង់ក្នុងសន្តាន មានភាពនៃចិត្តដ៏ប្រសើរ មិនមានវិតក្កៈ មិនមានវិចារៈ មានបីតិ និងសុខ ដែលកើតអំពីសមាធិ ព្រោះការវិនាសនៃបីតិ ជាបុគ្គលព្រងើយផង មានសតិ និងសម្បជញ្ញៈផង រមែងទទួលនូវសុខដោយនាមកាយផង ចូលកាន់តតិយជ្ឈាន ដែលព្រះអរិយៈទាំង-ឡាយតែងសរសើរថា បុគ្គលដែលបានតតិយជ្ឈាន តែងមានចិត្តព្រងើយជាអ្នកមានស្មារតី នៅជាសុខ ព្រោះការលះបង់សុខផង ព្រោះការលះបង់ទុក្ខផង ព្រោះការវិនាសទៅនៃសោមនស្សនិងទោមនស្សក្នុងកាលមុនផង លោកក៏ចូលកាន់ចតុត្ថជ្ឈាន ដែលឥតទុក្ខឥតសុខ មានសតិដ៏បរិសុទ្ធដោយឧបេក្ខា នេះហៅថា សម្មាសមាធិ ។

[៣២៤] អរិយមគ្គមានអង្គ ៨ ។ អរិយមគ្គមានអង្គ ៨ គឺអ្វីខ្លះ ។ គឺ សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ ។

[៣២៥] បណ្តាអរិយមគ្គទាំងនោះ សម្មាទិដ្ឋិ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ចម្រើនសម្មាទិដ្ឋិ ដែលអាស្រ័យវិវេក អាស្រ័យការប្រាសចាកតម្រេក អាស្រ័យនិរោធ ឈមទៅក្នុងការលះបង់ ។ បេ ។ ចម្រើនសម្មាសង្កប្បៈ ។ បេ ។ ចម្រើនសម្មាវាចា ។ បេ ។

សម្មាកម្មន្តំ ភាវេតិ ។ បេ ។ សម្មាអាជីវំ ភាវេតិ ។ បេ ។ សម្មាវាយាមំ ភាវេតិ ។ បេ ។ សម្មាសតឹ ភាវេតិ ។ បេ ។ សម្មាសមាធឹ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។

សុត្តន្តភាជនីយំ ។

[៣៦៦] អដ្ឋង្គិកោ មគ្គោ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ តត្ថ កតមោ អដ្ឋង្គិកោ មគ្គោ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ អដ្ឋង្គិកោ មគ្គោ ហោតិ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។

[៣៦៧] តត្ថ កតមា សម្មាទិដ្ឋិ ។ យា បញ្ញា បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ សម្មាទិដ្ឋិ ។

ចម្រើនសម្មាកម្មន្តៈ ។ បេ ។ ចម្រើនសម្មាអាជីវៈ ។ បេ ។ ចម្រើនសម្មាវាយាមៈ ។ បេ ។ ចម្រើនសម្មាសតិ ។ បេ ។ ចម្រើនសម្មាសមាធិ ដែលអាស្រ័យវិវេក អាស្រ័យការប្រាសចាកតម្រេក អាស្រ័យនិរោធ ឈមទៅក្នុងការលះបង់ ។

ចប់ សុត្តន្តភាជនីយ ។

[៣២៦] មគ្គមានអង្គ ៨ គឺ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ បណ្តាធម៌ទាំងនោះ មគ្គមានអង្គ ៨ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្តៈ) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ មគ្គមានអង្គ ៨ គឺ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ក៏កើតមាន ។

[៣២៧] បណ្តាអរិយមគ្គទាំងនោះ សម្មាទិដ្ឋិ តើដូចម្តេច ។ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការសង្កេតនូវធម៌ សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណានេះហៅថា សម្មាទិដ្ឋិ ។

[៣២៨] តត្ថ កតមោ សម្មាសង្កប្បោ ។ យោ តក្កោ វិតក្កោ សង្កប្បោ អប្បនា ព្យប្បនា ចេតសោ អភិនិរោបនា សម្មាសង្កប្បោ មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ សម្មាសង្កប្បោ ។

[៣២៩] តត្ថ កតមា សម្មាវាចា ។ យា ចតូហិ វចីទុច្ចរិតេហិ អារតិ វិរតិ បដិវិរតិ វេរមណី អកិរិយា អករណំ អនជ្ឈាបត្តិ វេលាអនតិក្កមោ សេតុឃាតោ សម្មាវាចា មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ សម្មាវាចា ។

[៣៣០] តត្ថ កតមោ សម្មាកម្មន្តោ ។ យា តីហិ កាយទុច្ចរិតេហិ អារតិ វិរតិ បដិវិរតិ វេរមណី អកិរិយា អករណំ អនជ្ឈាបត្តិ វេលាអនតិក្កមោ សេតុឃាតោ សម្មាកម្មន្តោ មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ សម្មាកម្មន្តោ ។

[៣៣១] តត្ថ កតមោ សម្មាអាជីវោ ។

[៣២៨] បណ្ដាអរិយមគ្គទាំងនោះ សម្មាសង្កប្បៈ តើដូចម្ដេច ។ សេចក្ដីត្រិះរិះ ការរិះគិត ការនឹកក្នក ការរំពឹង ការជញ្ជឹង ការលើកចិត្តឡើង សម្មាសង្កប្បៈ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សម្មាសង្កប្បៈ ។

[៣២៩] បណ្ដាអរិយមគ្គទាំងនោះ សម្មាវាចា តើដូចម្ដេច ។ ការវៀរ ការចៀសវាង ការវៀរស្រឡះ ការវាកចេញ ចាកវចីទុច្ចរិត ៤ គឺការមិនសាង ការមិនធ្វើ ការមិនប្រព្រឹត្ត ការមិនល្មើសឲ្យហួសដែន ការសម្លាប់ហេតុ (ដោយអរិយមគ្គ) សម្មាវាចា ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សម្មាវាចា ។

[៣៣០] បណ្ដាអរិយមគ្គទាំងនោះ សម្មាកម្មន្តៈ តើដូចម្ដេច ។ ការវៀរ ការចៀសវាង វៀរស្រឡះ ការវាកចេញ ចាកកាយទុច្ចរិត ៣ គឺ ការមិនសាង ការមិនធ្វើ ការមិនប្រព្រឹត្ត ការមិនល្មើសឲ្យហួសដែន ការសម្លាប់ហេតុ (ដោយអរិយមគ្គ) សម្មាកម្មន្តៈ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សម្មាកម្មន្តៈ ។

[៣៣១] បណ្ដាអរិយមគ្គទាំងនោះ សម្មាអាជីវៈ តើដូចម្ដេច ។

យា មិច្ឆាអាជីវា អារតិ វិរតិ បដិវិរតិ វេរមណី អកិរិយា អករណំ អនជ្ឈាបត្តិ វេលាអនតិក្កមោ សេតុឃាតោ សម្មាអាជីវោ មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ សម្មាអាជីវោ ។

[៣៣២] តត្ថ កតមោ សម្មាវាយាមោ ។ យោ ចេតសិកោ វីរិយារម្ភោ ។ បេ ។ សម្មាវាយាមោ វីរិយសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ សម្មាវាយាមោ ។

[៣៣៣] តត្ថ កតមា សម្មាសតិ ។ យា សតិ អនុស្សតិ ។ បេ ។ សម្មាសតិ សតិសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ សម្មាសតិ ។

[៣៣៤] តត្ថ កតមោ សម្មាសមាធិ ។ យា ចិត្តស្ស ឋិតិ ។ បេ ។ សម្មាសមាធិ សមាធិសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ សម្មាសមាធិ ។ អយំ វុច្ចតិ អដ្ឋង្គិកោ មគ្គោ អវសេសា ធម្មា អដ្ឋង្គិកេន មគ្គេន សម្បយុត្តា ។

ការវៀរ ការចៀសវាង ការវៀរស្រឡះ ការងាកចេញ ចាកមិច្ឆាអាជីវៈ គឺការមិនសាង ការមិនធ្វើ ការមិនប្រព្រឹត្ត ការមិនល្មើសឲ្យហួសដែន ការសម្លាប់ហេតុ (ដោយអរិយមគ្គ) សម្មាអាជីវៈ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សម្មាអាជីវៈ ។

[៣៣២] បណ្តាអរិយមគ្គទាំងនោះ សម្មាវាយាមៈ តើដូចម្តេច ។ ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សម្មាវាយាមៈ វីរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សម្មាវាយាមៈ ។

[៣៣៣] បណ្តាអរិយមគ្គទាំងនោះ សម្មាសតិ តើដូចម្តេច ។ ការរឭក ការនឹកឃើញ ។ បេ ។ សម្មាសតិ សតិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សម្មាសតិ ។

[៣៣៤] បណ្តាអរិយមគ្គទាំងនោះ សម្មាសមាធិ តើដូចម្តេច ។ ការឋិតនៅ នៃចិត្ត ។ បេ ។ សម្មាសមាធិ សមាធិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សម្មាសមាធិ ។ នេះ ហៅថា មគ្គមានអង្គ ៨ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមគ្គមានអង្គ ៨ ។

[៣៣៤] បញ្ចង្គិកោ មគ្គោ សម្មាទិដ្ឋិ សម្មា-សង្កប្បោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ។ តត្ថ កតមោ បញ្ចង្គិកោ មគ្គោ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ បញ្ចង្គិកោ មគ្គោ ហោតិ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាយាមោ សម្មាសតិ សម្មា-សមាធិ ។ តត្ថ កតមា សម្មាទិដ្ឋិ ។ យា បញ្ញា បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ សម្មាទិដ្ឋិ ។ តត្ថ កតមោ សម្មាសង្កប្បោ ។ យោ តក្កោ វិតក្កោ សង្កប្បោ ។ បេ ។ មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ សម្មាសង្កប្បោ ។ តត្ថ កតមោ សម្មាវាយាមោ ។ យោ ចេតសិកោ វិរិយា-រម្ភោ ។ បេ ។ សម្មាវាយាមោ វិរិយសម្ពោជ្ឈង្គោ

[៣៣៥] មគ្គមានអង្គ ៥ គឺ សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ ។ បណ្ដាធម៌ទាំងនោះ មគ្គមានអង្គ ៥ តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្ដៈ) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ មគ្គមានអង្គ ៥ គឺ សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ ក៏រមែងមាន ។ បណ្ដាអរិយមគ្គទាំងនោះ សម្មាទិដ្ឋិ តើដូចម្ដេច ។ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការសង្កេតនូវធម៌ សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សម្មាទិដ្ឋិ ។ បណ្ដាអរិយមគ្គទាំងនោះ សម្មាសង្កប្បៈ តើដូចម្ដេច ។ សេចក្ដីត្រិះរិះ ការរិះគិត ការនឹកភ្នក ។ បេ ។ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សម្មាសង្កប្បៈ ។ បណ្ដាអរិយមគ្គទាំងនោះ សម្មាវាយាមៈ តើដូចម្ដេច ។ ការប្រារព្ធព្យាយាមប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សម្មាវាយាមៈ វីរិយសម្ពោជ្ឈង្គ

មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ សម្មាវាយាមោ ។ តត្ថ កតមា សម្មាសតិ ។ យា សតិ អនុស្សតិ ។ បេ ។ សម្មាសតិ សតិសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ សម្មាសតិ ។ តត្ថ កតមោ សម្មាសមាធិ ។ យា ចិត្តស្ស ឋិតិ ។ បេ ។ សម្មាសមាធិ សមាធិសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ សម្មាសមាធិ ។ អយំ វុច្ចតិ បញ្ចង្គិកោ មគ្គោ អវសេសា ធម្មា បញ្ចង្គិកេន មគ្គេន សម្បយុត្តា ។

[៣៣៦] បញ្ចង្គិកោ មគ្គោ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ។ តត្ថ កតមា សម្មាទិដ្ឋិ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ យា តស្មឹ សមយេ បញ្ញា បជានានា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គោ

ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សម្មាវាយាមៈ ។ បណ្តាអរិយមគ្គទាំងនោះ សម្មាសតិ តើដូចម្តេច ។ ការរឭក ការនឹកឃើញ ។ បេ ។ សម្មាសតិ សតិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សម្មាសតិ ។ បណ្តាអរិយមគ្គទាំងនោះ សម្មាសមាធិ តើដូចម្តេច ។ ការឋិតនៅនៃចិត្ត ។ បេ ។ សម្មាសមាធិ សមាធិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សម្មាសមាធិ ។ នេះ ហៅថា មគ្គមានអង្គ ៥ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថាប្រកបដោយមគ្គមានអង្គ ៥ ។

[៣៣៦] មគ្គមានអង្គ ៥ គឺ សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ ។ បណ្តាអរិយមគ្គទាំងនោះ សម្មាទិដ្ឋិ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចំរើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្តៈ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការសង្កេតនូវធម៌ សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គ

មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ សម្មាទិដ្ឋិ អវសេ-
សា ធម្មា សម្មាទិដ្ឋិយា សម្បយុត្តា ។ បេ ។
អវសេសា ធម្មា សម្មាសង្កប្បេន សម្បយុត្តា ។ បេ ។
អវសេសា ធម្មា សម្មាវាយាមេន សម្បយុត្តា
។ បេ ។ អវសេសា ធម្មា សម្មាសតិយា សម្ប-
យុត្តា ។ តត្ថ កតមោ សម្មាសមាធិ ។ ឥធ
ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ
និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ
បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។
បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ
ទន្ធាភិញ្ញំ យា តស្មឹ សមយេ ចិត្តស្ស ឋិតិ ។ បេ ។
សម្មាសមាធិ សមាធិសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិ-
យាបន្នំ អយំ វុច្ចតិ សម្មាសមាធិ អវសេសា
ធម្មា សម្មាសមាធិនា សម្បយុត្តា ។

[៣៣៧] អដ្ឋង្គិកោ មគ្គោ សម្មាទិដ្ឋិ ។ បេ ។
សម្មាសមាធិ ។ តត្ថ កតមោ អដ្ឋង្គិកោ មគ្គោ ។
ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ

ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សម្មាទិដ្ឋិ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថាប្រកបដោយសម្មាទិដ្ឋិ ។ បេ ។ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថាប្រកបដោយសម្មាសង្កប្បៈ ។ បេ ។ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថាប្រកបដោយសម្មាវាយាមៈ ។ បេ ។ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថាប្រកបដោយសម្មាសតិ ។ បណ្ដា អរិយមគ្គទាំងនោះ សម្មាសមាធិ តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្ដៈ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ការបិតនៅនៃចិត្ត ។ បេ ។ សម្មាសមាធិ សមាធិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សម្មាសមាធិ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថាប្រកបដោយសម្មាសមាធិ ។

[៣៣៧] មគ្គមានអង្គ ៨ គឺ សម្មាទិដ្ឋិ ។ បេ ។ សម្មា-សមាធិ ។ បណ្ដាធម៌ទាំងនោះ មគ្គមានអង្គ ៨ តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិក-

ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ ផស្សោ ហោតិ ។ បេ ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា តស្សេវ លោកុត្តរស្ស កុសលស្ស ឈានស្ស កតត្តា ភាវិតត្តា វិបាកំ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ សុញ្ញតំ តស្មឹ សមយេ អដ្ឋង្គិកោ មគ្គោ ហោតិ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ[១] អយំ វុច្ចតិ អដ្ឋង្គិកោ មគ្គោ អវសេសា ធម្មា អដ្ឋង្គិកេន មគ្គេន សម្បយុត្តា ។

---

១ ឱ. ឥតោ បរំ តត្ថ កតមា សម្មាទិដ្ឋិ យា បញ្ញា បជាននា...អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ សម្មាទិដ្ឋិ ។ តត្ថ កតមោ សម្មាសង្កប្បោ ... សម្មាវាចា ... សម្មាកម្មន្តោ ... សម្មាអាជីវោ សម្មាវាយាមោ ... សម្មាសតិ ... ។ តត្ថ កតមោ សម្មាសមាធិ យា ចិត្តស្ស ឋិតិ ... សម្មាសមាធិ សមាធិសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ សម្មាសមាធីតិ ឥមេ បាឋា ទិស្សន្តិ ។

ធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្ដៈ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។ បេ ។ អវិក្ខេបៈក៏កើតមាន ធម៌ទាំងនេះ ជាកុសល ភិក្ខុស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ជាសុញ្ញតៈ ជាវិបាក ព្រោះភាពនៃលោកុត្តរ-កុសលជ្ឈាននោះឯង ដែលលោកបានធ្វើហើយ ចម្រើនហើយ ក្នុងសម័យនោះ មគ្គ មានអង្គ ៨ គឺសម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិក៏កើតមាន នេះហៅថា មគ្គមានអង្គ ៨ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថាប្រកបដោយមគ្គមានអង្គ ៨ ។

[៣៣៨] បញ្ចង្គិកោ មគ្គោ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ។ តត្ថ កតមោ បញ្ចង្គិកោ មគ្គោ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ ផស្សោ ហោតិ ។ បេ ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា តស្សេវ លោកុត្តរស្ស កុសលស្ស ឈានស្ស កតត្តា ភាវិតត្តា វិបាកំ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ សុញ្ញតំ តស្មឹ សមយេ បញ្ចង្គិកោ មគ្គោ ហោតិ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ អយំ វុច្ចតិ បញ្ចង្គិកោ មគ្គោ អវសេសា ធម្មា បញ្ចង្គិកេន មគ្គេន សម្បយុត្តា ។

[៣៣៨] មគ្គមានអង្គ ៥ គឺ សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ ។ បណ្តាធម៌ទាំងនោះ មគ្គមានអង្គ ៥ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្តៈ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលបឋមជ្ឈាន ជាទុក្ខាបដិ-បទាទន្ធាភិញ្ញា ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។ បេ ។ អវិក្ខេបៈ ក៏កើតមាន ធម៌ទាំងនេះជាកុសល ភិក្ខុស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ជាសុញ្ញតៈ ជាវិបាក ព្រោះភាពនៃលោកុត្តរកុសលជ្ឈាននោះឯង ដែលលោកបានធ្វើហើយ ចម្រើនហើយ ក្នុងសម័យនោះ មគ្គមានអង្គ ៥ គឺ សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ ក៏កើតមាន នេះហៅថា មគ្គមានអង្គ ៥ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមគ្គមានអង្គ ៥ ។

[៣៣៩] បញ្ចង្គិកោ មគ្គោ សម្មាទិដ្ឋិ សម្មា-
សង្កប្បោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ។
តត្ថ កតមា សម្មាទិដ្ឋិ ។ ឥធ ភិក្ខុ យស្មឹ សមយេ
លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ
ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា
វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ
វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ ផស្សោ
ហោតិ ។ បេ ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា
កុសលា តស្សេវ លោកុត្តរស្ស កុសលស្ស ឈាន-
ស្ស កតត្តា ភាវិតត្តា វិបាកំ វិវិច្ចេវ កាមេហិ ។ បេ ។
បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិ-
ញ្ញំ សុញ្ញតំ យា តស្មឹ សមយេ បញ្ញា បជាននា ។ បេ ។
អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ធម្មវិចយសម្ពោ-
ជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ សម្មាទិដ្ឋិ
អវសេសា ធម្មា សម្មាទិដ្ឋិយា សម្បយុត្តា ។ បេ ។
អវសេសា ធម្មា សម្មាសង្កប្បេន សម្បយុត្តា ។ បេ ។
អវសេសា ធម្មា សម្មាវាយាមេន សម្បយុត្តា ។ បេ ។

[៣៣៩] មគ្គមានអង្គ ៨ គឺ សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ ។ បណ្តាអរិយមគ្គទាំងនោះ សម្មាទិដ្ឋិ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្តៈ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។ បេ ។ អវិក្ខេបៈក៏កើតមាន ធម៌ទាំងនេះជាកុសល ភិក្ខុស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ជាសុញ្ញតៈ ជាវិបាក ព្រោះភាពនៃលោកុត្តរកុសលជ្ឈាននោះឯង ដែលលោកបានធ្វើហើយ ចម្រើនហើយ ក្នុងសម័យនោះ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការសង្កេតនូវធម៌ សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សម្មាទិដ្ឋិ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសម្មាទិដ្ឋិ ។ បេ ។ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសម្មាសង្កប្បៈ ។ បេ ។ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសម្មាវាយាមៈ ។ បេ ។

អវសេសា ធម្មា សម្មាសតិយា សម្បយុត្តា ។ តត្ថ កតមោ សម្មាសមាធិ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ ផស្សោ ហោតិ ។ បេ ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា តស្សេវ លោកុត្ត-រស្ស កុសលស្ស ឈានស្ស កតត្តា ភាវិតត្តា វិបាកំ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ សុញ្ញតំ យា តស្មឹ សមយេ ចិត្តស្ស ឋិតិ សណ្ឋិតិ អវដ្ឋិតិ អវិសាហារោ អវិក្ខេបោ អវិសាហដមានសតា សមថោ សមាធិន្ទ្រិយំ សមាធិពលំ សម្មាសមាធិ សមាធិសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ សម្មាសមាធិ អវសេសា ធម្មា សម្មាសមាធិនា សម្បយុត្តា ។

ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសម្មាសតិ ។ បណ្ដា អរិយមគ្គទាំងនោះ សម្មាសមាធិ តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុ ក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿង ដល់នូវការមិនសន្សំ (នូវកិលេសវដ្ដៈ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បី ដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់ បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ផស្សៈក៏កើត មាន ។ បេ ។ អវិក្ខេបៈក៏កើតមាន ធម៌ទាំងនេះជាកុសល ភិក្ខុស្ងាត់ ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទា ទន្ធាភិញ្ញា ជាសុញ្ញតៈ ជាវិបាក ព្រោះភាពនៃលោកុត្តរកុសលជ្ឈាននោះ ឯង ដែលលោកបានធ្វើហើយ ចម្រើនហើយ ក្នុងសម័យនោះ ការឋិត នៅនៃចិត្ត ការតាំងនៅ ការតាំងនៅស៊ប់ សេចក្ដីមិនរសេមរសាម សេចក្ដីមិនរាយមាយ ភាពនៃចិត្តមិនរួញរា សមថៈ សមាធិន្ទ្រិយ សមាធិពលៈ សម្មាសមាធិ សមាធិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់ បញ្ចូលក្នុងមគ្គ ណា នេះហៅថា សម្មាសមាធិ ធម៌ទាំងឡាយ ដ៏សេស ក៏ឈ្មោះថាប្រកបដោយសម្មាសមាធិ ។

ចប់ អភិធម្មភាជនីយ ។

[៣៤០] អរិយោ អដ្ឋង្គិកោ មគ្គោ ។ សេ-យ្យថីទំ ។ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មា-សតិ សម្មាសមាធិ ។ អដ្ឋន្នំ មគ្គង្គានំ កតិ កុ-សលា កតិ អកុសលា កតិ អព្យាកតា ។ បេ ។ កតិ សរណា កតិ អរណា ។

[៣៤១] សិយា កុសលា សិយា អព្យាកតា ។ សម្មាសង្កប្បោ សុខាយ វេទនាយ សម្បយុត្តោ សត្ត មគ្គង្គា សិយា សុខាយ វេទនាយ សម្បយុត្តា សិយា អទុក្ខមសុខាយ វេទនាយ សម្បយុត្តា ។ សិយា វិបាកា សិយា វិបាកធម្មធម្មា អនុ-បាទិន្នានុបាទានិយា អសង្កិលិដ្ឋាសង្កិលេសិកា ។ សម្មាសង្កប្បោ អវិតក្កវិចារមត្តោ សត្ត មគ្គង្គា សិយា សវិតក្កសវិចារា សិយា អវិតក្កវិចារមត្តា សិយា អវិតក្កាវិចារា ។ សម្មាសង្កប្បោ បីតិ-សហគតោ សុខសហគតោ ន ឧបេក្ខាសហ-គតោ សត្ត មគ្គង្គា សិយា បីតិសហគតា សិយា សុខសហគតា សិយា ឧបេក្ខាសហគតា ។

[៣៤០] *អរិយមគ្គមានអង្គ ៨ ។ អរិយមគ្គមានអង្គ ៨ គឺអ្វី ខ្លះ ។ សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ ។ បណ្តាអង្គមគ្គទាំង ៨ អង្គមគ្គ ជាកុសលប៉ុន្មាន ជាអកុសលប៉ុន្មាន ជាអព្យាក្រឹតប៉ុន្មាន ។ បេ ។ ជាសរណៈប៉ុន្មាន ជាអរណៈប៉ុន្មាន ។*

[៣៤១] *អង្គមគ្គ ៨ ជាកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។ សម្មាសង្កប្បៈ ប្រកបដោយសុខវេទនា អង្គមគ្គ ៧ ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ។ អង្គមគ្គ ៨ ជាវិបាកក៏មាន មានវិបាកធម៌ជាប្រក្រតី ដែលមានកម្មប្រកបដោយកិលេសមានតណ្ហាជាដើមមិនកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទានជាធម៌មិនសៅហ្មង ទាំងមិនគួរដល់សេចក្តីសៅហ្មងក៏មាន ។ សម្មាសង្កប្បៈ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ អង្គមគ្គ ៧ ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈក៏មាន មិនមានវិតក្កៈ មានត្រឹមតែវិចារៈក៏មាន មិនមានវិតក្កៈ មិនមានវិចារៈក៏មាន ។ សម្មាសង្កប្បៈ ប្រទាំដោយបីតិ ប្រទាំដោយសុខ តែមិនប្រទាំដោយឧបេក្ខា អង្គមគ្គ ៧ ប្រទាំដោយបីតិក៏មាន ប្រទាំដោយសុខក៏មាន ប្រទាំដោយឧបេក្ខាក៏មាន ។*

នេវ ទស្សនេន ន ភាវនាយ បហាតព្វា នេវ ទស្ស-
នេន ន ភាវនាយ បហាតព្វហេតុកា សិយា អបច-
យគាមិនោ សិយា នេវាចយគាមិនោ នាបចយគាមិ-
នោ សិយា សេក្ខា សិយា អសេក្ខា អប្បមាណា
អប្បមាណារម្មណា បណីតា សិយា សម្មត្តនិយតា
សិយា អនិយតា ន មគ្គារម្មណា សិយា មគ្គហេតុ-
កា សិយា មគ្គាធិបតិនោ សិយា ន វត្តព្វា មគ្គហេ-
តុកាតិបិ មគ្គាធិបតិនោតិបិ សិយា ឧប្បន្នា សិយា
អនុប្បន្នា សិយា ឧប្បាទិនោ សិយា អតីតា សិយា
អនាគតា សិយា បច្ចុប្បន្នា ន វត្តព្វា អតីតារម្ម-
ណាតិបិ អនាគតារម្មណាតិបិ បច្ចុប្បន្នារម្មណាតិបិ
សិយា អជ្ឈត្តា សិយា ពហិទ្ធា សិយា អជ្ឈត្តព-
ហិទ្ធា ពហិទ្ធារម្មណា អនិទស្សនាប្បដិឃា ។

[៣៤២] សម្មាទិដ្ឋិ ហេតុ សត្ត មគ្គង្គា ន
ហេតូ ។ សហេតុកា ហេតុសម្បយុត្តា ។ សម្មាទិដ្ឋិ
ហេតុ ចេវ សហេតុកា ច សត្ត មគ្គង្គា ន វត្តព្វា

អដ្ឋមគ្គ ៨ មិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា មានហេតុមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្តៈ) ក៏មាន មិនដល់នូវការសន្សំទាំងមិនដល់នូវការមិនសន្សំក៏មាន ជារបស់សេក្ខៈក៏មាន ជារបស់អសេក្ខៈ មានប្រមាណមិនបាន មានអារម្មណ៍ប្រមាណមិនបាន ជាសភាពដ៏ឧត្តមក៏មាន មានសភាពត្រូវនិងទៀងក៏មាន មានសភាពមិនទៀងមិនមែនមានមគ្គជាអារម្មណ៍ក៏មាន មានមគ្គជាហេតុក៏មាន មានមគ្គជាអធិបតីក៏មាន មិនគួរពោល ថា មានមគ្គជាហេតុផង ថា មានមគ្គជាអធិបតីផងក៏មាន កើតឡើងហើយក៏មាន មិនទាន់កើតឡើងក៏មាន បម្រុងនឹងកើតឡើងក៏មាន ជាអតីតក៏មាន ជាអនាគតក៏មាន ជាបច្ចុប្បន្នតែមិនគួរពោលថា មានអារម្មណ៍ជាអតីតផង ថា មានអារម្មណ៍ជាអនាគតផង ថា មានអារម្មណ៍ជាបច្ចុប្បន្នផងក៏មាន ជាខាងក្នុងក៏មាន ជាខាងក្រៅក៏មាន ទាំងខាងក្នុងទាំងខាងក្រៅ មានអារម្មណ៍ជាខាងក្រៅមិនប្រកបដោយការឃើញ ទាំងមិនប្រកបដោយការប៉ះពាល់ក៏មាន ។

[៣៤២] សម្មាទិដ្ឋិ ជាហេតុ អដ្ឋមគ្គ ៧ មិនមែនហេតុ ។ អដ្ឋមគ្គ ៨ ប្រព្រឹត្តទៅជាមួយនឹងហេតុ ប្រកបដោយហេតុ ។ សម្មាទិដ្ឋិ ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុ អដ្ឋមគ្គ ៧ មិនគួរពោល

ហេតូ ចេវ សហេតុកា ចាតិ សហេតុកា ចេវ ន ច ហេតូ ។ សម្មាទិដ្ឋិ ហេតុ ចេវ ហេតុសម្បយុត្តា ច សត្ត មគ្គង្គា ន វត្តព្វា ហេតូ ចេវ ហេតុសម្បយុត្តា ចាតិ ហេតុសម្បយុត្តា ចេវ ន ច ហេតូ ។ សត្ត មគ្គង្គា ន ហេតូ សហេតុកា សម្មាទិដ្ឋិ ន វត្តព្វា ន ហេតុ សហេតុកាតិបិ ន ហេតុ អហេតុកាតិបិ ។

[៣៤៣] សប្បច្ចយា សង្ខតា អនិទស្សនា អប្បដិឃា អរូបា លោកុត្តរា កេនចិ វិញ្ញេយ្យា កេនចិ ន វិញ្ញេយ្យា ។ នោ អាសវា អនាសវា អាសវវិប្បយុត្តា ន វត្តព្វា អាសវា ចេវ សាសវា ចាតិបិ សាសវា ចេវ នោ ច អាសវាតិបិ ន វត្តព្វា អាសវា ចេវ អាសវសម្បយុត្តា ចាតិបិ អាសវសម្បយុត្តា ចេវ នោ ច អាសវាតិបិ អាសវវិប្បយុត្តអនាសវា ។ នោ សញ្ញោជនា ។ បេ ។ នោ គន្ថា ។ បេ ។ នោ ឱឃា ។ បេ ។ នោ យោគា ។ បេ ។

ថា ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុទេ គឺគ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនជាហេតុ ។ សម្មាទិដ្ឋិ ជាហេតុ ទាំងប្រកបដោយហេតុ អង្គមគ្គ ៧ មិនគួរពោល ថា ជាហេតុ ទាំងប្រកបដោយហេតុដូច្នេះឡើយ គឺគ្រាន់តែប្រកបដោយហេតុ តែមិនមែនជាហេតុ ។ អង្គមគ្គ ៧ មិនមែនហេតុ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ សម្មាទិដ្ឋិ មិនគួរពោល ថា មិនមែនហេតុ គ្រាន់តែប្រព្រឹត្តទៅ ជាមួយនឹងហេតុផង ថា មិនមែនហេតុ ទាំងឥតហេតុផងឡើយ ។

[៣៤៣] អង្គមគ្គ ៨ ប្រកបដោយបច្ច័យ ត្រូវបច្ច័យតាក់តែង មិនប្រកបដោយការឃើញ មិនប្រកបដោយការប៉ះពាល់ មិនមានរូប ជាលោកុត្តរ គប្បីដឹងដោយវិញ្ញាណណាមួយ មិនគប្បីដឹងដោយវិញ្ញាណណាមួយ ។ អង្គមគ្គ ៨ មិនមែនអាសវៈ មិនមានអាសវៈ ប្រាសចាកអាសវៈ មិនគួរពោល ថា ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ថា ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនអាសវៈផងឡើយ មិនគួរពោលថា ជាអាសវៈ ទាំងប្រកបដោយអាសវៈផង ថា ប្រកបដោយអាសវៈ តែមិនមែនអាសវៈផងទេ គឺប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ។ អង្គមគ្គ ៨ មិនមែនសញ្ញោជនៈ ។ បេ ។ មិនមែនគន្ថៈ ។ បេ ។ មិនមែនឱឃៈ ។ បេ ។ មិនមែនយោគៈ ។ បេ ។

នោ នីវរណា ។ បេ ។ នោ បរាមាសា ។ បេ ។ សារម្មណា នោ ចិត្តា ចេតសិកា ចិត្តសម្បយុត្តា ចិត្តសំសដ្ឋា ចិត្តសមុដ្ឋានា ចិត្តសហភុនោ ចិត្តានុបរិវត្តិនោ ចិត្តសំសដ្ឋសមុដ្ឋានា ចិត្តសំសដ្ឋសមុដ្ឋានសហភុនោ ចិត្តសំសដ្ឋសមុដ្ឋានានុបរិវត្តិនោ ពាហិរា នុបាទា អនុបាទិន្នា ។ នុបាទានា ។ បេ ។ នោ កិលេសា ។ បេ ។

[៣៤៤] ន ទស្សនេន បហាតព្វា ន ភាវនាយ បហាតព្វា ន ទស្សនេន បហាតព្វហេតុកា ន ភាវនាយ បហាតព្វហេតុកា ។ សម្មាសង្កប្បោ អវិតក្កោ សត្ត មគ្គង្គា សិយា សវិតក្កា សិយា អវិតក្កា ។ សម្មាសង្កប្បោ សវិចារោ សត្ត មគ្គង្គា សិយា សវិចារា សិយា អវិចារា ។ សម្មាសង្កប្បោ សប្បីតិកោ សត្ត មគ្គង្គា សិយា សប្បីតិកា សិយា អប្បីតិកា ។ សម្មាសង្កប្បោ បីតិសហគតោ សត្ត មគ្គង្គា សិយា បីតិសហគតា សិយា ន បីតិសហគតា ។ សម្មាសង្កប្បោ

មិនមែននីវរណៈ ។ បេ ។ មិនមែនបរាមាសៈ ។ បេ ។ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ មិនមែនចិត្ត ជាចេតសិក ប្រកបដោយចិត្ត ច្រឡំដោយចិត្ត កើតឡើងអំពីចិត្ត កើតជាមួយនឹងចិត្ត ប្រព្រឹត្តទៅតាមចិត្ត ច្រឡំ ទាំងកើតឡើងអំពីចិត្ត ច្រឡំ ទាំងតាំងឡើង ទាំងកើតឡើងជាមួយនឹងចិត្ត ច្រឡំ ទាំងតាំងឡើង ទាំងប្រព្រឹត្តទៅតាមចិត្ត ជាខាងក្រៅ មិនមែនឧបាទា មានកម្មប្រកបដោយកិលេសមានតណ្ហាជាដើមមិនកាន់យក ។ មិនមែនឧបាទាន ។ បេ ។ មិនមែនកិលេស ។ បេ ។

[៣៤៤] អដ្ឋង្គិកមគ្គ ៨ មិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា មានហេតុមិនគួរលះដោយទស្សនៈ មានហេតុមិនគួរលះដោយភាវនា ។ សម្មាសង្កប្បៈ មិនមានវិតក្កៈ អដ្ឋង្គិកមគ្គ ៧ ប្រកបដោយវិតក្កៈក៏មាន មិនមានវិតក្កៈក៏មាន ។ សម្មាសង្កប្បៈ ប្រកបដោយវិចារៈ អដ្ឋង្គិកមគ្គ ៧ ប្រកបដោយវិចារៈក៏មាន មិនមានវិចារៈក៏មាន ។ សម្មាសង្កប្បៈ ប្រកបដោយបីតិ អដ្ឋង្គិកមគ្គ ៧ ប្រកបដោយបីតិក៏មាន មិនមានបីតិក៏មាន ។ សម្មាសង្កប្បៈ ច្រឡំដោយបីតិ អដ្ឋង្គិកមគ្គ ៧ ច្រឡំដោយបីតិក៏មាន មិនច្រឡំដោយបីតិក៏មាន ។ សម្មាសង្កប្បៈ

សុខសហគតោ សត្ត មគ្គង្គា សិយា សុខសហគតា សិយា ន សុខសហគតា ។ សម្មាសង្កប្បោ ន ឧបេក្ខាសហគតោ សត្ត មគ្គង្គា សិយា ឧបេក្ខាសហគតា សិយា ន ឧបេក្ខាសហគតា ។ ន កាមាវចរា ន រូបាវចរា ន អរូបាវចរា អបរិយាបន្នា សិយា និយ្យានិកា សិយា អនិយ្យានិកា សិយា និយតា សិយា អនិយតា អនុត្តរា អរណាតិ ។

បញ្ហាបុច្ឆកំ ។

មគ្គវិភង្គោ សមត្តោ ។

---

ប្រទ្បំដោយសុខ អង្គមគ្គ ៧ ប្រទ្បំដោយសុខ ក៏មាន មិនប្រទ្បំដោយសុខក៏មាន ។ សម្មាសង្កប្បៈ មិនប្រទ្បំដោយឧបេក្ខា អង្គមគ្គ ៧ ប្រទ្បំដោយឧបេក្ខាក៏មាន មិនប្រទ្បំដោយឧបេក្ខាក៏មាន ។ មិនមែនកាមាវចរ មិនមែនរូបាវចរ មិនមែនអរូបាវចរ ជាអបរិយាបន្នៈ ជានិយ្យានិកៈក៏មាន ជាអនិយ្យានិកៈក៏មាន ជានិយតៈក៏មាន ជាអនិយតៈ ជាអនុត្តរៈ ជាអរណៈក៏មាន ។

ចប់ បញ្ហាបុច្ឆកៈ ។

ចប់ មគ្គវិភង្គ ។

---

# ឈានវិភង្គោ

[៣៤៩] ឥធ ភិក្ខុ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ ឥន្ទ្រិយេសុ គុត្តទ្វារោ ភោជនេ មត្តញ្ញូ បុព្វរត្តាបររត្តំ ជាគរិយានុយោគមនុយុត្តោ សាតច្ចំ នេបក្កំ ពោធិបក្ខិកានំ ធម្មានំ ភាវនានុយោគមនុយុត្តោ ។ សោ អភិក្កន្តេ បដិក្កន្តេ សម្បជានការី ហោតិ អាលោកិតេ វិលោកិតេ សម្បជានការី ហោតិ សម្មិញ្ជិតេ បសារិតេ សម្បជានការី ហោតិ សង្ឃាដិបត្តចីវរធារណេ សម្បជានការី ហោតិ អសិតេ បីតេ ខាយិតេ សាយិតេ សម្បជានការី ហោតិ ឧច្ចារបស្សាវកម្មេ សម្បជានការី ហោតិ គតេ ឋិតេ និសិន្នេ សុត្តេ ជាគរិតេ ភាសិតេ តុណ្ហីភាវេ សម្បជានការី ហោតិ ។ សោ វិវិត្តំ សេនាសនំ ភជតិ អរញ្ញំ រុក្ខមូលំ បព្វតំ កន្ទរំ គិរិគុហំ សុសានំ វនបត្ថំ អព្ភោកាសំ បលាលបុញ្ជំ អប្បសទ្ទំ អប្បនិគ្ឃោសំ វិជនវាតំ មនុស្សរាហសេយ្យកំ

# ឈានវិភង្គ

[៣៤៥] ភិក្ខុ ក្នុងសាសនានេះ ជាអ្នកសង្រួមក្នុងបាតិមោក្ខសំវរៈ សម្រេចឥរិយាបថ បរិបូណ៌ដោយអាចារៈនិងគោចរ ឃើញភ័យក្នុងទោសទាំងឡាយមានប្រមាណតិច សមាទានសិក្សា ក្នុងសិក្ខាបទទាំង-ឡាយ មានទ្វារគ្រប់គ្រងក្នុងឥន្ទ្រិយទាំងឡាយ ជាអ្នកដឹងប្រមាណក្នុងភោជន ប្រកបរឿយ ៗ ក្នុងការព្យាយាមជាគ្រឿងភ្ញាក់រលឹក ក្នុងពេលមុនរាត្រីនិងក្រោយរាត្រី ប្រកបរឿយ ៗ ក្នុងការព្យាយាមចម្រើន នូវធម៌ទាំងឡាយ ជាចំណែកនៃការត្រាស់ដឹង ជាប់មិនដាច់ ចាស់ក្វា ។ ភិក្ខុនោះ ជាអ្នកធ្វើសេចក្ដីដឹងខ្លួន ក្នុងការដើរទៅមុខ និងការឈានថយក្រោយ ធ្វើសេចក្ដីដឹងខ្លួន ក្នុងការក្រឡេកមើលទៅមុខ និងការក្រឡេកមើលទៅទិសផ្សេង ៗ ធ្វើសេចក្ដីដឹងខ្លួន ក្នុងការបត់ដៃជើង និងការលាតដៃជើង ធ្វើសេចក្ដីដឹងខ្លួន ក្នុងការទ្រទ្រង់សង្ឃាដី បាត្រ និងចីវរ ធ្វើសេចក្ដីដឹងខ្លួន ក្នុងការបរិភោគភោជន ការផឹកទឹក ការទំពាស៊ីខាទនីយៈ និងការជញ្ជាប់ (នូវភេសជ្ជៈ មានសប្បិជាដើម) ធ្វើសេចក្ដីដឹងខ្លួន ក្នុងការបន្ទោបង់ឧច្ចារៈបស្សាវៈ ធ្វើសេចក្ដីដឹងខ្លួន ក្នុងការដើរ ឈរ អង្គុយ ដេក-លក់ ភ្ញាក់ឡើង និយាយ ឬ ការស្ងៀម ។ ភិក្ខុនោះ គប់រក ទីសេ-នាសនៈដ៏ស្ងាត់ គឺព្រៃតូច គល់ឈើ ភ្នំ ជ្រោះភ្នំ គុហាភ្នំ ព្រៃស្មសាន ព្រៃញៀតស្បាត ទីវាល គំនរចំបើង ទីមិនមានសំឡេង ទីមិនគឹកកង ទីប្រាសចាកខ្យល់ដែលកើតអំពីសរីរៈនៃជន ទីស្ងាត់កំបាំងរបស់មនុស្ស

បដិសល្លានសារុប្បំ ។ សោ អរញ្ញគតោ វា រុក្ខ-
មូលគតោ វា សុញ្ញាគារគតោ វា និសីទតិ បល្លង្កំ
អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ
ឧបដ្ឋបេត្វា ។ សោ អភិជ្ឈំ លោកេ បហាយ
វិគតាភិជ្ឈេន ចេតសា វិហរតិ អភិជ្ឈាយ ចិត្តំ ប-
រិសោធេតិ ព្យាបាទប្បទោសំ បហាយ អព្យាបន្ន-
ចិត្តោ វិហរតិ សព្វបាណភូតហិតានុកម្បី ព្យាបា-
ទប្បទោសា ចិត្តំ បរិសោធេតិ ថីនមិទ្ធំ បហាយ
វិគតថីនមិទ្ធោ វិហរតិ អាលោកសញ្ញី សតោ សម្ប-
ជានោ ថីនមិទ្ធា ចិត្តំ បរិសោធេតិ ឧទ្ធច្ចកុក្កុច្ចំ
បហាយ អនុទ្ធតោ វិហរតិ អជ្ឈត្តំ វូបសន្តចិត្តោ
ឧទ្ធច្ចកុក្កុច្ចា ចិត្តំ បរិសោធេតិ វិចិកិច្ឆំ បហាយ
តិណ្ណវិចិកិច្ឆោ វិហរតិ អកថង្កថី កុសលេសុ ធម្មេសុ
វិចិកិច្ឆាយ ចិត្តំ បរិសោធេតិ ។ សោ ឥមេ បញ្ច
នីវរណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ
ទុព្វលីករណេ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ
ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ

ទីសមគួរដល់ការពួនសម្ងំ ។ ភិក្ខុនោះ ទៅកាន់ព្រៃក្តី ទៅកាន់ម្លប់ឈើក្តី ទៅកាន់ផ្ទះស្ងាត់ក្តី អង្គុយផ្គត់ភ្នែន តាំងកាយឲ្យត្រង់ តម្កល់សតិឲ្យមានមុខឆ្ពោះទៅរក (កម្មដ្ឋាន) ។ ភិក្ខុនោះ លះបង់អភិជ្ឈាក្នុងលោក មានចិត្តប្រាសចាកអភិជ្ឈា ជម្រះចិត្តឲ្យស្អាតចាកអភិជ្ឈា លះបង់ព្យាបាទនិងសេចក្តីប្រទូស្ត មានចិត្តមិនព្យាបាទ មានសេចក្តីអនុគ្រោះនូវប្រយោជន៍ដល់សត្វមានជីវិតទាំងអស់ ជម្រះចិត្តឲ្យស្អាតចាកព្យាបាទនិងសេចក្តីប្រទូស្ត លះបង់ថីនមិទ្ធៈ ជាអ្នកប្រាសចាកថីនមិទ្ធៈ មានសេចក្តីសម្គាល់ជាពន្លឺ ជាអ្នកមានសតិនិងសម្បជញ្ញៈ ជម្រះចិត្តឲ្យស្អាតចាកថីនមិទ្ធៈ លះបង់ឧទ្ធច្ចកុក្កុច្ចៈ ជាអ្នកមិនរាយមាយ មានចិត្តស្ងប់រម្ងាប់ខាងក្នុងសន្តាន ជម្រះចិត្តឲ្យស្អាតចាកឧទ្ធច្ចកុក្កុច្ចៈ លះបង់វិចិកិច្ឆា ជាអ្នកឆ្លងចាកវិចិកិច្ឆា មិនមានសេចក្តីងឿងឆ្ងល់ ក្នុងកុសលធម៌ទាំងឡាយ ជម្រះចិត្តឲ្យស្អាតចាកវិចិកិច្ឆា ។ ភិក្ខុនោះ លុះលះបង់នីវរណៈទាំង ៥ នេះ ដែលជាគ្រឿងសៅហ្មងនៃចិត្ត ដែលធ្វើបញ្ញាឲ្យមានកម្លាំងថយ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយចូលកាន់បឋមជ្ឈាន

២៤៧



ឧបសម្បជ្ជ វិហរតិ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជានោ សុខញ្ច កាយេន បដិ-សំវេទេតិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិចារិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃ-សញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧប-សម្បជ្ជ វិហរតិ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ

ដែលប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ មានបីតិនិងសុខ ដែលកើតអំពីវិវេក ភិក្ខុនោះ ព្រោះរម្ងាប់វិតក្កៈនិងវិចារៈ ក៏ចូលកាន់ទុតិយជ្ឈាន ជាធម្មជាតកើតមានខាងក្នុងសន្តាន ប្រកបដោយសេចក្ដីជ្រះថ្លាគឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខ ដែលកើតអំពីសមាធិគឺបឋមជ្ឈាន ភិក្ខុនោះ ព្រោះនឿយណាយចាកបីតិផង ប្រកបដោយឧបេក្ខាផង មានស្មារតីដឹងខ្លួនផង ទទួលសុខដោយនាមកាយផង ក៏ចូលកាន់តតិយជ្ឈាន ដែលព្រះអរិយៈទាំងឡាយតែងសរសើរថា បុគ្គលដែលបានតតិយជ្ឈាន ជាអ្នកប្រកបដោយឧបេក្ខា មានស្មារតីនៅជាសុខ ភិក្ខុនោះ ព្រោះលះសុខផង ព្រោះលះទុក្ខផង ព្រោះអស់ទៅនៃសោមនស្សនិងទោមនស្សក្នុងកាលមុនផង ក៏ចូលកាន់ចតុត្ថជ្ឈាន ជាធម្មជាតមានអារម្មណ៍មិនមែនទុក្ខមិនមែនសុខគឺឧបេក្ខា មានសតិដ៏បរិសុទ្ធដោយឧបេក្ខា ភិក្ខុនោះ ព្រោះកន្លងរូបសញ្ញា ព្រោះអស់ទៅនៃបដិឃសញ្ញា ព្រោះការមិនធ្វើទុកក្នុងចិត្ត នូវនានត្តសញ្ញា ដោយសព្វគ្រប់ ក៏ចូលកាន់អាកាសានញ្ចាយតនជ្ឈាន ដោយបរិកម្មថា អាកាសមិនមានទីបំផុត ភិក្ខុនោះ ព្រោះកន្លងអាកាសានញ្ចាយតនជ្ឈាន ដោយសព្វគ្រប់ ក៏ចូលកាន់វិញ្ញាណញ្ចាយតនជ្ឈាន ដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុត

ឧបសម្បជ្ជ វិហរតិ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧប-សម្បជ្ជ វិហរតិ សព្វសោ អាកិញ្ចញ្ញាយតនំ សម-តិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ។

មាតិកា ។

[៣៤៦] ឥធាតិ ឥមិស្សា ទិដ្ឋិយា ឥមិស្សា ខន្តិយា ឥមិស្សា រុចិយា ឥមស្មឹ អាទាយេ ឥម-ស្មឹ ធម្មេ ឥមស្មឹ វិនយេ ឥមស្មឹ ធម្មវិនយេ ឥ-មស្មឹ បាវចនេ ឥមស្មឹ ព្រហ្មចរិយេ ឥមស្មឹ សត្ថុ-សាសនេ តេន វុច្ចតិ ឥធាតិ ។

[៣៤៧] ភិក្ខូតិ សមញ្ញាយ ភិក្ខុ បដិ-ញ្ញាយ ភិក្ខុ ភិក្ខតីតិ ភិក្ខុ ភិក្ខកោតិ ភិក្ខុ ភិក្ខាចរិយំ អជ្ឈុបគតោតិ ភិក្ខុ ភិន្នបដធរោតិ ភិក្ខុ ភិន្ទតិ បាបកេ អកុសលេ ធម្មេតិ ភិក្ខុ ភិន្នត្តា បាបកានំ អកុសលានំ ធម្មានំ ភិក្ខុ ឱធិសោ កិលេសានំ បហានា ភិក្ខុ

ភិក្ខុនោះ ព្រោះកន្លងវិញ្ញាណញ្ចាយតនជ្ឈានដោយសព្វគ្រប់ ក៏ចូលកាន់អាកិញ្ចញ្ញាយតនជ្ឈាន ដោយបរិកម្មថា វត្ថុតិចតួចមិនមាន ភិក្ខុនោះព្រោះកន្លងអាកិញ្ចញ្ញាយតនជ្ឈានដោយសព្វគ្រប់ ក៏ចូលកាន់នេវសញ្ញា-នាសញ្ញាយតនជ្ឈាន ។

ចប់មាតិកា ។

[៣៤៦] ត្រង់ពាក្យថា នេះ គឺ ក្នុងការឃើញនេះ ក្នុងការគាប់ចិត្តនេះ ក្នុងការចូលចិត្តនេះ ក្នុងការប្រកាន់នេះ ក្នុងធម៌នេះ ក្នុងវិន័យនេះ ក្នុងធម៌និងវិន័យនេះ ក្នុងពាក្យជាប្រធាននេះ ក្នុងព្រហ្មចរិ-យៈនេះ ក្នុងសាសនានៃព្រះសាស្តានេះ ព្រោះហេតុនោះ ទើបពោលថា នេះ ។

[៣៤៧] ត្រង់ពាក្យថា ភិក្ខុ គឺ ឈ្មោះថា ភិក្ខុ ព្រោះឈ្មោះ ឈ្មោះថាភិក្ខុ ព្រោះការប្តេជ្ញា ឈ្មោះថាភិក្ខុ ព្រោះសូម ឈ្មោះថាភិក្ខុ ព្រោះជាអ្នកសូម ឈ្មោះថាភិក្ខុ ព្រោះជាអ្នកចូលទៅកាន់ទីត្រាច់ទៅដើម្បីសូម ឈ្មោះថាភិក្ខុ ព្រោះជាអ្នកទ្រទ្រង់សំពត់កាត់ដាច់ ឈ្មោះថាភិក្ខុ ព្រោះទម្លាយអកុសលធម៌ទាំងឡាយដ៏លាមក ឈ្មោះថាភិក្ខុ ព្រោះហេតុទម្លាយអកុសលធម៌ទាំងឡាយដ៏លាមក ឈ្មោះថាភិក្ខុ ព្រោះការលះកិលេសទាំងឡាយដោយចំណែក ឈ្មោះថាភិក្ខុ

អជោជិសោ កិលេសានំ បហាជា ភិក្ខុ សេក្ខោ ភិក្ខុ អសេក្ខោ ភិក្ខុ នេវសេក្ខា ជាសេក្ខោ ភិក្ខុ អគ្គោ ភិក្ខុ ភទ្រោ ភិក្ខុ មណ្ឌោ ភិក្ខុ សារោ ភិក្ខុ សមគ្គេន សង្ឃេន ញត្តិចតុត្ថេន កម្មេន អកុប្បេន ឋានារហេន ឧបសម្បន្នោតិ ភិក្ខុ ។

[៣៤៨] ចាតិមោក្ខន្តិ សីលំ បតិដ្ឋា អាទិ ចរណំ សញ្ញមោ សំវរោ មុខំ បមុខំ[១] កុសលានំ ធម្មានំ សមាបត្តិយា ។ សំវរោតិ កាយិកោ អវីតិក្កមោ វាចសិកោ អវីតិក្កមោ កាយិកវាចសិកោ អវីតិក្កមោ ។ សំវុតោតិ ឥមិនា ចាតិមោក្ខសំវរេន ឧបេតោ ហោតិ សមុបេតោ ឧចាគតោ សមុចាគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ តេន វុច្ចតិ ចាតិមោក្ខសំវរសំវុតោតិ ។

[៣៤៩] វិហរតីតិ ឥរិយតិ វត្តតិ ចាលេតិ យបេតិ យាបេតិ ចរតិ វិហរតិ តេន វុច្ចតិ វិហរតីតិ ។

---

១ ម. មោក្ខំ បមោក្ខំ ។

ព្រោះការលះកិលេសទាំងឡាយដោយមិនមានចំណែក បុគ្គលជាសេក្ខៈ ឈ្មោះថាភិក្ខុ បុគ្គលជាអសេក្ខៈ ឈ្មោះថាភិក្ខុ បុគ្គលជាសេក្ខៈ ក៏មិនមែន ជាអសេក្ខៈក៏មិនមែន ឈ្មោះថាភិក្ខុ បុគ្គលប្រសើរ ឈ្មោះថាភិក្ខុ បុគ្គលចម្រើន ឈ្មោះថាភិក្ខុ បុគ្គលផូរផង់ ឈ្មោះថាភិក្ខុ បុគ្គលមានខ្លឹម ឈ្មោះថាភិក្ខុ បុគ្គលដែលសង្ឃព្រមព្រៀងគ្នាឲ្យឧបសម្បទាដោយញត្តិចតុត្ថកម្ម ដែលមិនកម្រើកគួរដល់ហេតុ ឈ្មោះថាភិក្ខុ ។

[៣៤៨] ត្រង់ពាក្យថា បាតិមោក្ខ បានដល់សីល ការតាំងមាំ កិច្ចខាងដើម ការប្រព្រឹត្ត ការសង្រួម ការរវាំង ប្រធាន ប្រមុខ នៃការដល់នូវកុសលធម៌ទាំងឡាយ ។ ពាក្យថា សំវរៈ គឺការមិនកន្លងដែលប្រព្រឹត្តទៅក្នុងកាយ ការមិនកន្លងដែលប្រព្រឹត្តទៅក្នុងវាចា ការមិនកន្លងដែលប្រព្រឹត្តទៅក្នុងកាយ និងក្នុងវាចា ។ ពាក្យថា ជាអ្នកសង្រួម គឺជាអ្នកព្រមព្រៀង មូលមិត្រ ចូលទៅជិត អែបនែបកៀកកើយ ប្រជិតប្រជី ប្រកបព្រម ដោយការសង្រួមក្នុងបាតិមោក្ខនេះ ព្រោះហេតុនោះ ទើបពោលថា ជាអ្នកសង្រួមក្នុងបាតិមោក្ខសំវរៈ ។

[៣៤៩] ត្រង់ពាក្យថា សម្រេចឥរិយាបថ គឺ សម្រេច ប្រព្រឹត្ត រក្សា រស់នៅ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ត្រាច់ទៅ នៅ ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

[៣៨០] អាចារគោចរសម្បន្នោតិ អត្ថិ អាចារោ អត្ថិ អនាចារោ ។ តត្ថ កតមោ អនាចារោ ។ កាយិកោ វីតិក្កមោ វាចសិកោ វីតិក្កមោ កាយិកវាចសិកោ វីតិក្កមោ អយំ វុច្ចតិ អនាចារោ សព្វម្បិ ទុស្សីល្យំ អនាចារោ ឥធេកច្ចោ វេឡុទានេន វា បត្តទានេន វា បុប្ផទានេន វា ផលទានេន វា សិនានទានេន វា ទន្តកដ្ឋទានេន វា ចាតុកម្យតាយ[១] វា មុគ្គសូបតាយ វា បារិភដ្យតាយ វា ជង្ឃបេសនិកេន វា អញ្ញតរញ្ញតរេន វា ពុទ្ធប្បដិកុដ្ឋេន មិច្ឆាអាជីវេន ជីវិតំ កប្បេតិ អយំ វុច្ចតិ អនាចារោ ។ តត្ថ កតមោ អាចារោ ។ កាយិកោ អវីតិក្កមោ វាចសិកោ អវីតិក្កមោ កាយិកវាចសិកោ អវីតិក្កមោ អយំ វុច្ចតិ អាចារោ សព្វោបិ សីលសំវរោ អាចារោ ឥធេកច្ចោ ន វេឡុទានេន ន បត្តទានេន ន

១ ម. ចាតុកម្យតាយ ។

[៣៥០] ត្រង់ពាក្យថា បរិបូណ៌ដោយអាចារៈនិងគោចរ អធិប្បាយថា អាចារៈក៏មាន អនាចារៈក៏មាន ។ បណ្ដាអាចារៈនិងអនាចារៈនោះ អនាចារៈ តើដូចម្ដេច ។ ការប្រព្រឹត្តកន្លងប្រកបដោយកាយ ការប្រព្រឹត្តកន្លងប្រកបដោយវាចា ការប្រព្រឹត្តកន្លងប្រកបដោយកាយ និងវាចា នេះហៅថា អនាចារៈ សូម្បីភាពនៃភិក្ខុទ្រុស្តសីលទាំងអស់ ក៏ឈ្មោះថាអនាចារៈ គឺ ភិក្ខុខ្លះ ក្នុងសាសនានេះ ចិញ្ចឹមជីវិតដោយការឲ្យឫស្សីខ្លះ ឲ្យស្លឹកឈើខ្លះ ឲ្យផ្កាឈើខ្លះ ឲ្យផ្លែឈើខ្លះ ឲ្យគ្រឿងលម្អិតសម្រាប់លាបខ្លះ ឲ្យឈើស្ទន់ខ្លះ ដោយភាពជាអ្នកបន្ទាបបន្ទន់កាយខ្លះ ដោយការពោលវាចាដូចជាសម្លសណ្ដែកបាយខ្លះ ដោយការបីថ្នមកូនរបស់ត្រកូលខ្លះ ដោយការបម្រើត្រកូលដោយកម្លាំងស្មងខ្លះ ដោយមិច្ឆាអាជីវៈណាមួយ ដែលព្រះពុទ្ធទ្រង់តិះដៀលហើយខ្លះ នេះហៅថា អនាចារៈ ។ បណ្ដាអនាចារៈ និងអាចារៈនោះ អាចារៈ តើដូចម្ដេច ។ ការមិនប្រព្រឹត្តកន្លងប្រកបដោយកាយ ការមិនប្រព្រឹត្តកន្លងប្រកបដោយវាចា ការមិនប្រព្រឹត្តកន្លងប្រកបដោយកាយនិងវាចា នេះហៅថា អាចារៈ សូម្បីការសង្រួមក្នុងសីលទាំងអស់ ក៏ឈ្មោះថាអាចារៈ គឺ ភិក្ខុខ្លះ ក្នុងសាសនានេះ មិនចិញ្ចឹមជីវិតដោយការឲ្យឫស្សី មិនចិញ្ចឹមជីវិតដោយការឲ្យស្លឹកឈើ មិន

បុប្ផទានេន ន ផលទានេន ន សិនានទានេន ន ទន្ត-កដ្ឋទានេន ន ចាតុកម្យតាយ ន មុគ្គសូបតាយ ន បារិភដ្យតាយ ន ជង្ឃបេសនិកេន ន អញ្ញតរញ្ញត-រេន ពុទ្ធប្បដិកុដ្ឋេន មិច្ឆាអាជីវេន ជីវិតំ កប្បេតិ អយំ វុច្ចតិ អាចារោ ។ គោចរោតិ អត្ថិ គោចរោ អត្ថិ អគោចរោ ។ តត្ថ កតមោ អគោចរោ ។ ឥធេកច្ចោ វេសិយាគោចរោ វា ហោតិ វិធវាគោចរោ វា ថុល្ល-កុមារីគោចរោ វា បណ្ឌកគោចរោ វា ភិក្ខុនីគោចរោ វា បានាគារគោចរោ វា សំសដ្ឋោ វិហរតិ រាជូហិ រាជមហាមត្តេហិ តិត្ថិយេហិ តិត្ថិយសាវកេហិ អ-ននុលោមិកេន គិហិសំសគ្គេន យានិ វា បន តានិ កុលានិ អស្សទ្ធានិ អប្បសន្នានិ អនោបានភូតានិ អក្កោសកបរិភាសកានិ អនត្ថកាមានិ អហិតកា-មានិ អផាសុកាមានិ អយោគក្ខេមកាមានិ ភិក្ខូនំ ភិក្ខុនីនំ ឧបាសកានំ ឧបាសិកានំ តថារូបានិ

ចិញ្ចឹមជីវិតដោយការឲ្យផ្កាឈើ មិនចិញ្ចឹមជីវិតដោយការឲ្យផ្លែឈើ មិនចិញ្ចឹមជីវិតដោយការឲ្យគ្រឿងលម្អិតសម្រាប់លាប មិនចិញ្ចឹមជីវិតដោយការឲ្យឈើស្ទន់ មិនចិញ្ចឹមជីវិតដោយការបន្ទាបបន្ទន់កាយ មិនចិញ្ចឹមជីវិតដោយការពោលវាចាដូចជាសម្ដុសណ្តែកបាយ មិនចិញ្ចឹមជីវិតដោយការបីបំមកូនរបស់ត្រកូល មិនចិញ្ចឹមជីវិតដោយការបម្រើត្រកូលដោយកម្លាំងស្មង មិនចិញ្ចឹមជីវិតដោយមិច្ឆាអាជីវៈណាមួយ ដែលព្រះពុទ្ធទ្រង់តិះដៀលហើយ នេះហៅថា អាចារៈ ។ ពាក្យថាគោចរ មានសេចក្តីថា គោចរក៏មាន អគោចរក៏មាន ។ បណ្តាគោចរ និងអគោចរនោះ អគោចរ តើដូចម្តេច ។ ភិក្ខុខ្លះ ក្នុងសាសនានេះ ជាអ្នកត្រាច់ទៅកាន់ទីនៃស្ត្រីពេស្យាខ្លះ ត្រាច់ទៅកាន់ទីនៃស្ត្រីមេម៉ាយខ្លះ ត្រាច់ទៅកាន់ទីនៃស្ត្រីក្រមុំខ្លះ ត្រាច់ទៅកាន់ទីនៃមនុស្សបណ្ឌកខ្លះ ត្រាច់ទៅកាន់ទីនៃភិក្ខុនីខ្លះ ត្រាច់ទៅកាន់រោងសុរាខ្លះ ជាអ្នកច្រឡូកច្រឡំដោយពួកស្តេច ដោយពួកមហាមាត្ររបស់ស្តេច ដោយពួកតិរ្ថិយ ដោយពួកសាវ័ករបស់តិរ្ថិយ ឬ ដោយការច្រឡូកច្រឡំនឹងគ្រហស្ថ មិនសមគួរ មួយទៀត ត្រកូលណាដែលមិនមានសទ្ធា មិនជ្រះថ្លា មិនមែនជាអណ្តូង ជាអ្នកជេរប្រទេចផ្តាសា មិនប្រាថ្នាសេចក្តីចម្រើន មិនប្រាថ្នាប្រយោជន៍ មិនប្រាថ្នាសេចក្តីសប្បាយ មិនប្រាថ្នាសេចក្តីក្សេម ចាកយោគៈ ដល់ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកាឡើយ ភិក្ខុនោះ

កុលានិ សេវតិ ភជតិ បយិរុបាសតិ អយំ វុច្ចតិ អគោចរោ ។ តត្ថ កតមោ គោចរោ ។ ឥធេកច្ចោ ន វេសិយាគោចរោ ហោតិ ន វិធវាគោចរោ ន ថុល្លកុមារីគោចរោ ន បណ្ឌកគោចរោ ន ភិក្ខុនីគោចរោ ន បានាគារគោចរោ ន សំសដ្ឋោ វិហរតិ រាជូហិ រាជមហាមត្តេហិ តិត្ថិយេហិ តិត្ថិយសាវកេហិ អននុលោមិកេន គិហិសំសគ្គេន យានិ វា បន តានិ កុលានិ សទ្ធានិ បសន្នានិ ឱបានភូតានិ កាសាវបជ្ជោតានិ ឥសិវាតបដិវាតានិ អត្ថកាមានិ ហិតកាមានិ ផាសុកាមានិ យោគក្ខេមកាមានិ ភិក្ខូនំ ភិក្ខុនីនំ ឧបាសកានំ ឧបាសិកានំ តថារូបានិ កុលានិ សេវតិ ភជតិ បយិរុបាសតិ អយំ វុច្ចតិ គោចរោ ។ ឥតិ ឥមិនា ច អាចារេន ឥមិនា ច គោចរេន ឧបេតោ ហោតិ ។ បេ ។ សមន្នាគតោ តេន វុច្ចតិ អាចារគោចរសម្បន្នោតិ ។

ចូលចិត្តគប់រក ចូលទៅជិត កាន់ត្រកូលទាំងឡាយមានសភាពដូច្នោះ នេះហៅថា អគោចរ ។ បណ្ដាគោចរ និងអគោចរទាំងនោះ គោចរតើដូចម្ដេច ។ ភិក្ខុខ្លះ ក្នុងសាសនានេះ ជាអ្នកមិនត្រាច់ទៅកាន់ទីនៃស្ត្រីពេស្យា មិនត្រាច់ទៅកាន់ទីនៃស្ត្រីមេម៉ាយ មិនត្រាច់ទៅកាន់ទីនៃស្ត្រីក្រមុំ មិនត្រាច់ទៅកាន់ទីនៃមនុស្សបណ្ឌក មិនត្រាច់ទៅកាន់ទីនៃភិក្ខុនី មិនត្រាច់ទៅកាន់រោងសុរា ជាអ្នកមិនច្រឡូកច្រឡំ ដោយពួកស្ដេច ដោយពួកមហាមាត្ររបស់ស្ដេច ដោយពួកតិរ្ថិយ ដោយពួកសាវ័ករបស់តិរ្ថិយ ឬ ដោយការច្រឡូកច្រឡំនឹងគ្រហស្ថ មិនសមគួរ មួយទៀតត្រកូលណា មានសទ្ធា ជ្រះថ្លា ជាអណ្ដូង រុងរឿងដោយសំពត់កាសាវៈដែលផ្សព្វផ្សាយដោយខ្យល់នៃឥសី ជាអ្នកប្រាថ្នាសេចក្ដីចម្រើន ប្រាថ្នាប្រយោជន៍ ប្រាថ្នាសេចក្ដីសប្បាយ ប្រាថ្នាព្រះនិព្វានជាធម៌ក្សេមចាកយោគៈ ដល់ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ភិក្ខុនោះ ចូលចិត្តគប់រក ចូលទៅជិត កាន់ត្រកូលទាំងឡាយមានសភាពដូច្នោះ នេះហៅថា គោចរ ។ ភិក្ខុ ជាអ្នកព្រមព្រៀង ។ បេ ។ ប្រកបព្រមដោយអាចារៈនេះផង ដោយគោចរនេះផង ព្រោះហេតុនោះ ទើបពោលថា ភិក្ខុនោះ បរិបូណ៌ដោយអាចារៈនិងគោចរ ។

[៣៤១] អណុមត្តេសុ វជ្ជេសុ ភយទស្សាវីតិ តត្ថ កតមេ អណុមត្តា វជ្ជា ។ យានិ តានិ វជ្ជានិ អប្បមត្តកានិ ឱរមត្តកានិ លហុសានិ លហុសម្មត្តានិ សញ្ញមករណីយានិ សំវរករណីយានិ ចិត្តុប្បាទករណីយានិ មនសិការប្បដិពទ្ធានិ ឥមេ វុច្ចន្តិ អនុមត្តា វជ្ជា[១] ឥមេសុ អណុមត្តេសុ វជ្ជេសុ វជ្ជទស្សាវី ច ហោតិ ភយទស្សាវី ច អាទីនវទស្សាវី ច និស្សរណទស្សាវី ច តេន វុច្ចតិ អណុមត្តេសុ វជ្ជេសុ ភយទស្សាវីតិ ។

[៣៤២] សមាទាយ សិក្ខតិ សិក្ខាបទេសូតិ តត្ថ កតមា សិក្ខា ។ ចតស្សោ សិក្ខា ភិក្ខូនំ ភិក្ខុសិក្ខា ភិក្ខុនីនំ ភិក្ខុនីសិក្ខា ឧបាសកានំ ឧបាសកសិក្ខា ឧបាសិកានំ ឧបាសិកាសិក្ខា ឥមា វុច្ចន្តិ សិក្ខាយោ ឥមាសុ សិក្ខាសុ សព្វេន សព្វំ សព្វថា សព្វំ អសេសំ និស្សេសំ សមាទាយ វត្តតិ តេន វុច្ចតិ សមាទាយ សិក្ខតិ សិក្ខាបទេសូតិ ។

១ ឱ. ម. ឯត្ថន្តរេ ឥតិ-សទ្ទោ ទិស្សតិ ។

[៣៥១] ត្រង់ពាក្យថា ឃើញភ័យ ក្នុងទោសទាំងឡាយមានប្រមាណតិច មានសេចក្តីថា បណ្តាពាក្យទាំងនោះ ទោសមានប្រមាណតិច តើដូចម្តេច ។ ទោសទាំងឡាយណា មានប្រមាណតិច ស្តួចស្តើង ស្រាល ដល់នូវអំពើស្រាល គួរធ្វើសេចក្តីសង្រួម គួរធ្វើការប្រយ័ត្ន គួរធ្វើការកើតឡើងនៃចិត្ត ជាទោសជាប់ចំពោះដោយមនសិការៈទាំងនេះហៅថា ទោសមានប្រមាណតិច ភិក្ខុ ជាអ្នកឃើញទោសក្នុងទោសទាំងឡាយមានប្រមាណតិចនេះផង ឃើញភ័យផង ឃើញកំហុសផង ឃើញការរលាស់ខ្លួនចេញផង ព្រោះហេតុនោះ ទើបពោលថា ឃើញភ័យ ក្នុងទោសទាំងឡាយមានប្រមាណតិច ។

[៣៥២] ត្រង់ពាក្យថា សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ មានសេចក្តីថា បណ្តាពាក្យទាំងនោះ សិក្ខា តើដូចម្តេច ។ សិក្ខាមាន ៤ គឺ ភិក្ខុសិក្ខា របស់ពួកភិក្ខុ ១ ភិក្ខុនីសិក្ខា របស់ពួកភិក្ខុនី ១ ឧបាសកសិក្ខា របស់ពួកឧបាសក ១ ឧបាសិកាសិក្ខា របស់ពួកឧបាសិកា ១ ទាំងនេះហៅថា សិក្ខា បុគ្គលសមាទានក្នុងសិក្ខាទាំងឡាយនេះ ដោយសព្វគ្រប់ អស់កាលទាំងពួង ដោយប្រការទាំងពួង អស់កិច្ចគ្រប់យ៉ាង មិនមានសល់ ឥតសេសសល់ ហើយប្រព្រឹត្ត ព្រោះហេតុនោះ ទើបពោលថា សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ។

[៣៩៣] ឥន្ទ្រិយេសុ គុត្តទ្វារោតិ អត្ថិ ឥន្ទ្រិយេសុ គុត្តទ្វារតា អត្ថិ ឥន្ទ្រិយេសុ អគុត្តទ្វារតា ។ តត្ថ កតមា ឥន្ទ្រិយេសុ អគុត្តទ្វារតា ។ ឥធេកច្ចោ ចក្ខុនា រូបំ ទិស្វា និមិត្តគ្គាហី ហោតិ អនុព្យញ្ជនគ្គាហី យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ ន បដិបជ្ជតិ ន រក្ខតិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ ន សំវរំ អាបជ្ជតិ សោតេន សទ្ទំ សុត្វា ។ បេ ។ ឃានេន គន្ធំ ឃាយិត្វា ។ បេ ។ ជិវ្ហាយ រសំ សាយិត្វា ។ បេ ។ កាយេន ផោដ្ឋព្វំ ផុសិត្វា ។ បេ ។ មនសា ធម្មំ វិញ្ញាយ និមិត្តគ្គាហី ហោតិ អនុព្យញ្ជនគ្គាហី យត្វាធិករណមេនំ មនិន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ ន បដិបជ្ជតិ ន រក្ខតិ មនិន្ទ្រិយំ មនិន្ទ្រិយេ ន សំវរំ អាបជ្ជតិ យា ឥមេសំ ឆន្នំ ឥន្ទ្រិយានំ អគុត្តិ អគោបនា អនារក្ខោ អសំវរោ

[៣៩៣] ត្រង់ពាក្យថា មានទ្វារគ្រប់គ្រង ក្នុងឥន្ទ្រិយទាំងឡាយ អធិប្បាយថា ភាពនៃបុគ្គលអ្នកមានទ្វារគ្រប់គ្រង ក្នុងឥន្ទ្រិយទាំងឡាយ ក៏មាន ភាពនៃបុគ្គលអ្នកមានទ្វារមិនគ្រប់គ្រង ក្នុងឥន្ទ្រិយទាំងឡាយ ក៏មាន ។ បណ្តាធម៌ទាំងនោះ ភាពនៃបុគ្គលអ្នកមានទ្វារមិនគ្រប់គ្រង ក្នុងឥន្ទ្រិយទាំងឡាយ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយភ្នែកហើយ ជាអ្នកកាន់យកនូវនិមិត្ត កាន់យកនូវអនុព្យញ្ជនៈ អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈានិងទោមនស្សគប្បីជាប់តាម នូវបុគ្គលជាអ្នកមិនសង្រួមចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុមិនសង្រួមចក្ខុន្ទ្រិយ ណា មិនប្រតិបត្តិដើម្បីសង្រួមចក្ខុន្ទ្រិយនោះ មិនរក្សាចក្ខុឥន្ទ្រិយ មិនដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ឮសំឡេងដោយត្រចៀក ។ បេ ។ ធុំក្លិនដោយច្រមុះ ។ បេ ។ លិទ្ធភ្លក្សរសដោយអណ្តាត ។ បេ ។ ពាល់ត្រូវផ្សព្វដោយកាយ ។ បេ ។ ដឹងច្បាស់នូវធម៌ដោយចិត្តហើយ ជាអ្នកកាន់យកនូវនិមិត្ត ជាអ្នកកាន់យកនូវអនុព្យញ្ជនៈ អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈានិងទោមនស្សគប្បីជាប់តាម នូវបុគ្គលជាអ្នកមិនសង្រួមមនិន្ទ្រិយនុ៎ះ ព្រោះហេតុមិនសង្រួមមនិន្ទ្រិយ ណា មិនប្រតិបត្តិដើម្បីសង្រួមមនិន្ទ្រិយនោះ មិនរក្សាមនិន្ទ្រិយ មិនដល់នូវការសង្រួមក្នុងមនិន្ទ្រិយ ការមិនថែទាំ មិនគ្រប់គ្រង មិនរក្សា មិនសង្រួម នូវឥន្ទ្រិយទាំង ៦ នេះ ណា

អយំ វុច្ចតិ ឥន្ទ្រិយេសុ អគុត្តទ្វារតា ។ តត្ថ កតមា ឥន្ទ្រិយេសុ គុត្តទ្វារតា ។ ឥធេកច្ចោ ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជតិ សោតេន សទ្ទំ សុត្វា ។ បេ ។ ឃានេន គន្ធំ ឃាយិត្វា ។ បេ ។ ជិវ្ហាយ រសំ សាយិត្វា ។ បេ ។ កាយេន ផោដ្ឋព្វំ ផុសិត្វា ។ បេ ។ មនសា ធម្មំ វិញ្ញាយ ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ មនិន្ទ្រិយំ សំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ មនិន្ទ្រិយំ មនិន្ទ្រិយេ សំវរំ អាបជ្ជតិ យា ឥមេសំ ឆន្នំ ឥន្ទ្រិយានំ គុត្តិ គោបនា អារក្ខោ សំវរោ អយំ វុច្ចតិ ឥន្ទ្រិយេសុ គុត្តទ្វារតា ។ ឥមាយ ឥន្ទ្រិយេសុ គុត្តទ្វារតាយ ឧបេតោ ហោតិ ។ បេ ។

នេះហៅថា ភាពនៃបុគ្គលមានទ្វារមិនគ្រប់គ្រង ក្នុងឥន្ទ្រិយទាំងឡាយ ។ បណ្តាធម៌ទាំងនោះ ភាពនៃបុគ្គលអ្នកមានទ្វារគ្រប់គ្រង ក្នុងឥន្ទ្រិយទាំងឡាយ តើដូចម្តេច ។ ភិក្ខុខ្លះ ក្នុងសាសនានេះ ឃើញរូបដោយភ្នែកហើយ ជាអ្នកមិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈានិងទោមនស្ស គប្បីជាប់តាមនូវបុគ្គលជាអ្នកមិនសង្រួមចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុមិនសង្រួមចក្ខុន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមចក្ខុន្ទ្រិយនោះ រក្សាចក្ខុន្ទ្រិយ ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ឮសំឡេងដោយត្រចៀក ។ បេ ។ ធុំក្លិនដោយច្រមុះ ។ បេ ។ លិទ្ធភ្លក្សរសដោយអណ្តាត ។ បេ ។ ពាល់ត្រូវផ្សព្វដោយកាយ ។ បេ ។ ដឹងច្បាស់នូវធម៌ដោយចិត្តហើយ ជាអ្នកមិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈានិងទោមនស្ស គប្បីជាប់តាម នូវបុគ្គលជាអ្នកមិនសង្រួមមនិន្ទ្រិយនុ៎ះ ព្រោះហេតុមិនសង្រួមមនិន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមមនិន្ទ្រិយនោះ រក្សាមនិន្ទ្រិយ ដល់នូវការសង្រួមក្នុងមនិន្ទ្រិយ ការថែទាំ គ្រប់គ្រង រក្សាសង្រួម នូវឥន្ទ្រិយទាំង ៦ នេះ ណា នេះហៅថា ភាពនៃបុគ្គលអ្នកមានទ្វារគ្រប់គ្រង ក្នុងឥន្ទ្រិយទាំងឡាយ ។ ភិក្ខុ ជាអ្នកព្រមព្រៀង ។ បេ ។

សមន្នាគតោ តេន វុច្ចតិ ឥន្ទ្រិយេសុ គុត្តទ្វារោតិ ។

[៣៤៨] ភោជនេ មត្តញ្ញូតិ អត្ថិ ភោជនេ មត្តញ្ញុតា អត្ថិ ភោជនេ អមត្តញ្ញុតា ។ តត្ថ កតមា ភោជនេ អមត្តញ្ញុតា ។ ឥធេកច្ចោ អប្បដិសង្ខា អយោនិសោ អាហារំ អាហារេតិ ទវាយ មទាយ មណ្ឌនាយ វិភូសនាយ យា តត្ថ អសន្តុដ្ឋិតា អមត្តញ្ញុតា អប្បដិសង្ខា ភោជនេ អយំ វុច្ចតិ ភោជនេ អមត្តញ្ញុតា ។ តត្ថ កតមា ភោជនេ មត្តញ្ញុតា ។ ឥធេកច្ចោ បដិសង្ខា យោនិសោ អាហារំ អាហារេតិ នេវ ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសុបរតិយា ព្រហ្មចរិយានុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ យាត្រា ច មេ ភវិស្សតិ

ប្រកបព្រមដោយភាពនៃខ្លួន ជាអ្នកមានទ្វារគ្រប់គ្រង ក្នុងឥន្ទ្រិយទាំង-ឡាយនេះ ព្រោះហេតុនោះ ទើបពោលថា មានទ្វារគ្រប់គ្រង ក្នុងឥន្ទ្រិយទាំងឡាយ ។

[៣៩៤] ត្រង់ពាក្យថា អ្នកដឹងប្រមាណ ក្នុងភោជន អធិប្បាយថា ការដឹងប្រមាណ ក្នុងភោជនក៏មាន ការមិនដឹងប្រមាណ ក្នុងភោជនក៏មាន ។ បណ្ដាធម៌ទាំងនោះ ការមិនដឹងប្រមាណ ក្នុងភោជន តើដូចម្ដេច ។ ភិក្ខុខ្លះ ក្នុងសាសនានេះ មិនបានពិចារណាដោយឧបាយហើយបរិភោគអាហារ ដើម្បីលេង ដើម្បីស្រវឹង ដើម្បីប្រដាប់ ដើម្បីស្អិតស្អាង សេចក្ដីមិនសន្ដោស សេចក្ដីមិនដឹងប្រមាណ សេចក្ដីមិនពិចារណា ក្នុងភោជននោះ ណា នេះហៅថា ការមិនដឹងប្រមាណ ក្នុងភោជន ។ បណ្ដាធម៌ទាំងនោះ ការដឹងប្រមាណ ក្នុងភោជន តើដូចម្ដេច ។ ភិក្ខុខ្លះ ក្នុងសាសនានេះ ពិចារណាដោយឧបាយ ហើយបរិ-ភោគអាហារ មិនមែនដើម្បីលេង មិនមែនដើម្បីស្រវឹង មិនមែនដើម្បីប្រដាប់ មិនមែនដើម្បីស្អិតស្អាង (គឺបរិភោគ) ដើម្បីតាំងនៅនៃកាយនេះ ដើម្បីញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅ ដើម្បីកម្ចាត់បង់សេចក្ដីលំបាក ដើម្បីអនុ-គ្រោះព្រហ្មចារ្យ គឺអាត្មាអញ នឹងបន្ទោបង់វេទនាចាស់ផង នឹងញ៉ាំងវេទនាថ្មី មិនឲ្យកើតឡើងផង ការត្រាច់ទៅក្ដី សេចក្ដីមិនមានទោស

អនវជ្ជតា ច ផាសុវិហារោ ចាតិ យា តត្ថ សន្តុដ្ឋិតា មត្តញ្ញុតា បដិសង្ខា ភោជនេ អយំ វុច្ចតិ ភោជនេ មត្តញ្ញុតា ។ ឥមាយ ភោជនេ មត្តញ្ញុតាយ ឧបេតោ ហោតិ ។ បេ ។ សមន្នាគតោ តេន វុច្ចតិ ភោជនេ មត្តញ្ញូតិ ។

[៣៤៩] កថញ្ច ភិក្ខុ បុព្វរត្តាបររត្តំ ជាគរិយានុយោគមនុយុត្តោ ហោតិ ។ ឥធ ភិក្ខុ ទិវសំ ចង្កមេន និសជ្ជាយ អាវរណិយេហិ ធម្មេហិ ចិត្តំ បរិសោធេតិ រត្តិយា បឋមំ យាមំ ចង្កមេន និសជ្ជាយ អាវរណិយេហិ ធម្មេហិ ចិត្តំ បរិសោធេតិ រត្តិយា មជ្ឈិមំ យាមំ ទក្ខិណេន បស្សេន សីហសេយ្យំ កប្បេតិ ចាទេន ចាទំ អច្ចាធាយ សតោ សម្បជានោ ឧដ្ឋានសញ្ញំ មនសិករិត្វា រត្តិយា បច្ឆិមំ យាមំ បច្ចុដ្ឋាយ ចង្កមេន និសជ្ជាយ អាវរណិយេហិ ធម្មេហិ ចិត្តំ បរិសោធេតិ ឯវំ ភិក្ខុ បុព្វរត្តាបររត្តំ ជាគរិយានុយោគមនុយុត្តោ ហោតិ ។

មានមិនប្រអូសកាយជាដើមក្តី កិរិយានៅជាសុខ (ដោយឥរិយាបថទាំង ៤) ក្តី នឹងមានដល់អាត្មាអញ សេចក្តីសន្តោស សេចក្តីដឹងប្រមាណ សេចក្តីពិចារណា ក្នុងភោជននោះ ណា នេះហៅថា ការដឹងប្រមាណ ក្នុងភោជន ។ ភិក្ខុជាអ្នកព្រមព្រៀង ។ បេ ។ ប្រកបព្រម ដោយ សេចក្តីដឹងប្រមាណ ក្នុងភោជននេះ ព្រោះហេតុនោះ ទើបពោលថា អ្នកដឹងប្រមាណ ក្នុងភោជន ។

[៣៥៥] ចុះភិក្ខុជាអ្នកប្រកបរឿយៗ ក្នុងការព្យាយាមជាគ្រឿងភ្ញាក់រឭក ក្នុងពេលមុនរាត្រី និងក្រោយរាត្រី តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ញុំាងចិត្តឲ្យស្អាត ចាកធម៌ទាំងឡាយដែលរារាំង ដោយការដើរទៅមក ដោយការអង្គុយ អស់មួយថ្ងៃ ញុំាងចិត្តឲ្យស្អាត ចាកធម៌ទាំង-ឡាយដែលរារាំង ដោយការដើរទៅមក ដោយការអង្គុយ អស់បឋម-យាមនៃរាត្រី សម្រេចសីហសេយ្យាដោយចំហៀងខាងស្តាំ អស់មជ្ឈិម-យាមនៃរាត្រី តម្រួតជើងដោយជើង ជាអ្នកមានស្មារតី ដឹងខ្លួន ធ្វើទុកក្នុងចិត្ត ចំពោះឧដ្ឋានសញ្ញា ហើយក្រោក ក្នុងបច្ឆិមយាមនៃរាត្រី ញុំាងចិត្តឲ្យស្អាត ចាកធម៌ទាំងឡាយដែលរារាំង ដោយការដើរ ដោយការអង្គុយ ភិក្ខុជាអ្នកប្រកបរឿយ ៗ ក្នុងការព្យាយាមជាគ្រឿងភ្ញាក់រឭក ក្នុងពេលមុនរាត្រី និងក្រោយរាត្រី យ៉ាងនេះឯង ។

[៣៤៦] សាតច្ចន្តិ យោ ចេតសិកោ វីរិយារម្ភោ ។ បេ ។ សម្មាវាយាមោ ។ នេបក្កន្តិ យា បញ្ញា បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ។

[៣៤៧] ពោធិបក្ខិកានំ ធម្មានំ ភាវនានុយោគមនុយុត្តោតិ តត្ថ កតមេ ពោធិបក្ខិកា ធម្មា ។ សត្ត ពោជ្ឈង្គា សតិសម្ពោជ្ឈង្គោ ធម្មវិចយសម្ពោជ្ឈង្គោ វីរិយសម្ពោជ្ឈង្គោ បីតិសម្ពោជ្ឈង្គោ បស្សទ្ធិសម្ពោជ្ឈង្គោ សមាធិសម្ពោជ្ឈង្គោ ឧបេក្ខាសម្ពោជ្ឈង្គោ ឥមេ វុច្ចន្តិ ពោធិបក្ខិកា ធម្មា ឥមេ ពោធិបក្ខិកេ ធម្មេ អាសេវតិ ភាវេតិ ពហុលីករោតិ តេន វុច្ចតិ ពោធិបក្ខិកានំ ធម្មានំ ភាវនានុយោគមនុយុត្តោតិ ។

[៣៤៨] កថញ្ច ភិក្ខុ អភិក្កន្តេ បដិក្កន្តេ សម្បជានការី ហោតិ អាលោកិតេ វិលោកិតេ សម្បជានការី ហោតិ សម្មិញ្ជិតេ បសារិតេ សម្បជានការី ហោតិ សង្ឃាដិបត្តចីវរធារណេ

[៣៥៦] ត្រង់ពាក្យថា ជាប់មិនដាច់ បានដល់ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សេចក្តីព្យាយាមត្រូវ ប្រព្រឹត្តទៅក្នុងចិត្ត ។ ពាក្យថា ចាស់ក្វា បានដល់បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការសង្កេតនូវធម៌ សេចក្តីយល់ត្រូវ ។

[៣៥៧] ត្រង់ពាក្យថា ប្រកបរឿយ ៗ ក្នុងការព្យាយាមចម្រើន នូវធម៌ទាំងឡាយ ជាចំណែកនៃការត្រាស់ដឹង មានសេចក្តីថា បណ្តាធម៌ទាំងនោះ ពួកធម៌ជាចំណែកនៃការត្រាស់ដឹង តើដូចម្តេច ។ ពោជ្ឈង្គ ៧ គឺ សតិសម្ពោជ្ឈង្គ ធម្មវិចយសម្ពោជ្ឈង្គ វីរិយសម្ពោជ្ឈង្គ បីតិ-សម្ពោជ្ឈង្គ បស្សទ្ធិសម្ពោជ្ឈង្គ សមាធិសម្ពោជ្ឈង្គ ឧបេក្ខាសម្ពោជ្ឈង្គ នេះហៅថា ធម៌ជាចំណែកនៃការត្រាស់ដឹង ភិក្ខុគប់រក អប់រំ ធ្វើឲ្យច្រើន ចំពោះពួកធម៌ ជាចំណែកនៃការត្រាស់ដឹងទាំងនេះ ព្រោះហេតុនោះ ទើបពោលថា ប្រកបរឿយ ៗ ក្នុងការព្យាយាម ចម្រើននូវធម៌ទាំងឡាយ ជាចំណែកនៃការត្រាស់ដឹង ។

[៣៥៨] ចុះភិក្ខុជាអ្នកធ្វើសេចក្តីដឹងខ្លួន ក្នុងការដើរទៅមុខនិងការដើរថយក្រោយ ធ្វើសេចក្តីដឹងខ្លួនក្នុងការក្រឡេកមើលទៅមុខនិងការក្រឡេកមើលទៅទិសផ្សេង ៗ ធ្វើសេចក្តីដឹងខ្លួន ក្នុងការបត់ដៃជើងនិងការលាតដៃជើង ធ្វើសេចក្តីដឹងខ្លួន ក្នុងការទ្រទ្រង់សង្ឃាដី បាត្រនិងចីវរ

សម្បជានការី ហោតិ អសិតេ បីតេ ខាយិតេ សាយិតេ សម្បជានការី ហោតិ ឧច្ចារបស្សាវកម្មេ សម្បជានការី ហោតិ គតេ ឋិតេ និសិន្នេ សុត្តេ ជាគរិតេ ភាសិតេ តុណ្ហីភាវេ សម្បជានការី ហោតិ ។ ឥធ ភិក្ខុ សតោ សម្បជានោ អភិក្កមតិ សតោ សម្បជានោ បដិក្កមតិ សតិ សម្បជានោ អា-លោកេតិ សតោ សម្បជានោ វិលោកេតិ សតោ សម្បជានោ សម្មិញ្ជេតិ សតោ សម្បជានោ ប-សារេតិ សតោ សម្បជានការី ហោតិ សង្ឃាដិ-បត្តចីវរធារណេ សតោ សម្បជានការី ហោតិ អសិតេ បីតេ ខាយិតេ សាយិតេ សតោ សម្បជាន-ការី ហោតិ ឧច្ចារបស្សាវកម្មេ សតោ សម្បជាន-ការី ហោតិ គតេ ឋិតេ និសិន្នេ សុត្តេ ជាគរិតេ ភាសិតេ តុណ្ហីភាវេ ។ សតោតិ តត្ថ កតមា សតិ ។ យា សតិ អនុស្សតិ បដិស្សតិ សតិ សរណតា ធារណតា អបិលាបនតា អសម្មុសនតា សតិ សតិ-ន្ទ្រិយំ សតិពលំ សម្មាសតិ អយំ វុច្ចតិ សតិ ។

ធ្វើសេចក្ដីដឹងខ្លួន ក្នុងការបរិភោគភោជន ការផឹកទឹក ការទំពាស៊ីខាទនីយៈ និងការជញ្ជាប់ (ភេសជ្ជៈ) ធ្វើសេចក្ដីដឹងខ្លួន ក្នុងការបន្ទោបង់ឧច្ចារៈ បស្សាវៈ ធ្វើសេចក្ដីដឹងខ្លួន ក្នុងការដើរ ឈរ អង្គុយ ដេកលក់ ភ្ញាក់ឡើង និយាយ ឬការស្ងៀម តើដូចម្ដេច ។ ភិក្ខុក្នុងសាសនានេះ ឈានដើរទៅមុខ មានស្មារតីដឹងខ្លួន ឈានថយក្រោយ មានស្មារតីដឹងខ្លួន ក្រឡេកមើលទៅមុខ មានស្មារតីដឹងខ្លួន ក្រឡេកមើលទៅទិសផ្សេង ៗ មានស្មារតីដឹងខ្លួន បត់ដៃជើង មានស្មារតីដឹងខ្លួន លាតដៃជើង មានស្មារតីដឹងខ្លួន ជាអ្នកមានស្មារតី ធ្វើសេចក្ដីដឹងខ្លួន ក្នុងការទ្រទ្រង់សង្ឃាដី បាត្រ និងចីវរ ជាអ្នកមានស្មារតី ធ្វើសេចក្ដីដឹងខ្លួន ក្នុងការបរិភោគ ការផឹក ការទំពាស៊ី ការជញ្ជាប់ ជាអ្នកមានស្មារតី ធ្វើសេចក្ដីដឹងខ្លួន ក្នុងការបន្ទោបង់ឧច្ចារៈ បស្សាវៈ ជាអ្នកមានស្មារតី ធ្វើសេចក្ដីដឹងខ្លួន ក្នុងការដើរ ឈរ អង្គុយ ដេកលក់ ភ្ញាក់ឡើង និយាយ និងការស្ងៀម ។ ពាក្យថា មានស្មារតី សេចក្ដីថា បណ្ដាធម៌ទាំងនោះ ស្មារតី តើដូចម្ដេច ។ ការរលឹក ការនឹកឃើញ ការរលឹកចំពោះ សតិ សេចក្ដីរលឹក សេចក្ដីចាំបាន សេចក្ដីមិនភ្លេច សេចក្ដីមិនវង្វេង គឺ សតិ សតិន្ទ្រិយ សតិពលៈ សម្មាសតិ ណា នេះហៅថា ស្មារតី ។

សម្បជានោតិ តត្ថ កតមំ សម្បជញ្ញំ យា បញ្ញា បជានដា វិចយោ បវិចយោ ធម្មវិចយោ សល្លក្ខ-ណា ឧបលក្ខណា បច្ចុបលក្ខណា បណ្ឌិច្ចំ កោ-សល្លំ នេបុញ្ញំ វេភព្យា ចិន្តា ឧបបរិក្ខា ភូរី មេធា បរិណាយិកា វិបស្សនា សម្បជញ្ញំ បតោ-ទោ បញ្ញា បញ្ញិន្ទ្រិយំ បញ្ញាពលំ បញ្ញាសត្ថំ បញ្ញា-ចាសាទោ បញ្ញាអាលោកោ បញ្ញាឱភាសោ បញ្ញា-បជ្ជោតោ បញ្ញារតនំ អមោហោ ធម្មវិចយោ សម្មា-ទិដ្ឋិ ឥទំ វុច្ចតិ សម្បជញ្ញំ ។ ឥតិ ឥមាយ ច សតិយា ឥមិនា ច សម្បជញ្ញេន ឧបេតោ ហោតិ ។ បេ ។ សមន្នាគតោ ។ ឯវំ ភិក្ខុ សតោ សម្បជានោ អភិក្កមតិ សតោ សម្បជានោ ប-ដិក្កមតិ សតោ សម្បជានោ អាលោកេតិ សតោ សម្បជានោ វិលោកេតិ សតោ សម្បជានោ សមិញ្ជេតិ សតោ សម្បជានោ បសារេតិ សតោ សម្បជានការី ហោតិ សង្ឃាដិបត្តចីវរធារណេ

ពាក្យថា អ្នកដឹងខ្លួន មានសេចក្ដីថា បណ្ដាធម៌ទាំងនោះ ការដឹងខ្លួន តើដូចម្ដេច បញ្ញា ការដឹងច្បាស់ ការរំពឹង ការពិនិត្យ ការពិចារណាធម៌ ការកំណត់ ការកត់សម្គាល់ ការកំណត់ចំពោះ ភាពជាបណ្ឌិត ការឈ្លាសវៃ គំនិតដ៏ល្អិត គំនិតទូលាយ ការពិចារណាឃើញច្បាស់ បញ្ញាដូចជាផែនដី បញ្ញាផ្ទុះផ្ដាយ បញ្ញាឱនទៅ បញ្ញា-ឃើញវិសេស សេចក្ដីដឹងខ្លួន សភាពដូចជាជន្ទួញ គឺ បញ្ញា បញ្ញិ-ន្ទ្រិយ បញ្ញាពលៈ កាំបិត គឺបញ្ញា ប្រាសាទ គឺ បញ្ញា ពន្លឺ គឺបញ្ញារស្មីគឺបញ្ញា គ្រឿងបំភ្លឺគឺបញ្ញា កែវគឺបញ្ញា ការមិនវង្វេង ការពិចារណាធម៌ សេចក្ដីឃើញត្រូវ ណា នេះហៅថា សេចក្ដីដឹងខ្លួន ។ ភិក្ខុជាអ្នកព្រមព្រៀង ។ បេ ។ ប្រកបព្រមហើយដោយសតិនេះផង ដោយសម្បជញ្ញៈនេះផង ដោយប្រកាដូច្នេះ ។ ភិក្ខុឈានដើរទៅមុខ មានស្មារតីដឹងខ្លួន ឈានថយក្រោយ មានស្មារតីដឹងខ្លួន ក្រឡេកមើលទៅមុខ មានស្មារតីដឹងខ្លួន ក្រឡេកមើលទៅទិសផ្សេង ៗ មានសេចក្ដីដឹងខ្លួន បត់ដៃជើង មានស្មារតីដឹងខ្លួន លាតដៃជើង មានស្មារតីដឹងខ្លួន មានស្មារតី ធ្វើសេចក្ដីដឹងខ្លួន ក្នុងការទ្រទ្រង់សង្ឃាដី បាត្រនិងចីវរ

សតោ សម្បជានការី ហោតិ អសិតេ បីតេ ខាយិតេ សាយិតេ សតោ សម្បជានការី ហោតិ ឧច្ចារបស្សាវកម្មេ សតោ សម្បជានការី ហោតិ គតេ ឋិតេ និសិន្នេ សុត្តេ ជាគរិតេ ភាសិតេ តុណ្ហីភាវេ[១] ។

[៣៥៩] វិវិត្តន្តិ សន្តិកេ ចេបិ សេនាសនំ ហោតិ តញ្ច អនាកិណ្ណំ គហដ្ឋេហិ បព្វជិតេហិ តេន តំ វិវិត្តំ ។ ទូរេ ចេបិ សេនាសនំ ហោតិ តញ្ច អនាកិណ្ណំ គហដ្ឋេហិ បព្វជិតេហិ តេន តំ វិវិត្តំ ។

[៣៦០] សេនាសនន្តិ មញ្ចោបិ សេនាសនំ បីឋំបិ សេនាសនំ ភិសិបិ សេនាសនំ ពិម្ពោហនំបិ សេនាសនំ វិហារោបិ សេនាសនំ អឌ្ឍយោគោបិ សេនាសនំ បាសាទោបិ សេនាសនំ អដ្ដោបិ សេនាសនំ មាឡោបិ សេនាសនំ លេណំបិ សេនាសនំ គុហាបិ សេនាសនំ រុក្ខមូលំបិ សេនាសនំ វេឡុគុម្ពោបិ សេនាសនំ យត្ថ វា បន ភិក្ខូ បដិក្កមន្តិ សព្វមេតំ សេនាសនំ ។

១ ម. ឥតោ បរំ (សតោ) សម្បជានការី ហោតីតិ ទិស្សន្តិ ។

មានស្មារតី ធ្វើសេចក្តីដឹងខ្លួន ក្នុងការបរិភោគ ការផឹក ការទំពាស៊ីខាទនីយៈ និងការជញ្ជាប់ មានស្មារតី ធ្វើសេចក្តីដឹងខ្លួន ក្នុងការបន្ទោបង់ឧច្ចារៈ បស្សាវៈ មានស្មារតី ធ្វើសេចក្តីដឹងខ្លួន ក្នុងការដើរ ឈរ អង្គុយ ដេកលក់ ភ្ញាក់ឡើង និយាយ ឬការស្ងៀម ។

[៣៥៩] ត្រង់ពាក្យថា ស្ងាត់ សេចក្តីថា បើសេនាសនៈនៅក្នុងទីជិត តែសេនាសនៈនោះ មិនច្រឡូកច្រឡំដោយពួកគ្រហស្ថ និងពួកបព្វជិត ព្រោះហេតុនោះ ទីនោះឈ្មោះថាស្ងាត់ ។ បើសេនាសនៈនៅក្នុងទីឆ្ងាយ តែសេនាសនៈនោះ មិនច្រឡូកច្រឡំដោយពួកគ្រហស្ថ និងពួកបព្វជិត ព្រោះហេតុនោះ នោះឈ្មោះថា ស្ងាត់ ។

[៣៦០] ត្រង់ពាក្យថា សេនាសនៈ គឺ គ្រែ ឈ្មោះថា សេនាសនៈ តាំង ឈ្មោះថា សេនាសនៈ ពូក ឈ្មោះថា សេនាសនៈ ខ្នើយ ឈ្មោះថា សេនាសនៈ វិហារ ឈ្មោះថា សេនាសនៈ អឌ្ឍយោគ ឈ្មោះថា សេនាសនៈ ប្រាសាទ ឈ្មោះថា សេនាសនៈ ប៉ម ឈ្មោះថា សេនាសនៈ រោង ឈ្មោះថា សេនាសនៈ ទីពួន ឈ្មោះថា សេនាសនៈ គុហា ឈ្មោះថា សេនាសនៈ គល់ឈើ ឈ្មោះថា សេនាសនៈ គុម្ពឫស្សី ក៏ឈ្មោះថា សេនាសនៈ ពុំនោះសោត ពួកភិក្ខុដើចូលទៅក្នុងទីណា ទីទាំងអស់នុ៎ះ ក៏ឈ្មោះថា សេនាសនៈដែរ ។

[៣៦១] ភជតីតិ ឥមំ វិវិត្តំ សេនាសនំ ភជតិ សម្ភជតិ សេវតិ និសេវតិ សំសេវតិ តេន វុច្ចតិ ភជតីតិ ។

[៣៦២] អរញ្ញន្តិ និក្ខមិត្វា ពហិឥន្ទខីលា សព្វមេតំ អរញ្ញំ ។

[៣៦៣] រុក្ខមូលន្តិ រុក្ខមូលំយេវ ។ បព្វតោយេវ បព្វតោ ។ កន្ទរាយេវ កន្ទរា ។ គិរិគុហាយេវ គិរិគុហា ។ សុសានំយេវ សុសានំ ។ អព្ភោកាសោយេវ អព្ភោកាសោ ។ បលាលបុញ្ជោ-យេវ បលាលបុញ្ជោ ។

[៣៦៤] វនបត្ថន្តិ ទូរានមេតំ សេនាសនានំ អធិវចនំ ។ វនបត្ថន្តិ វនសណ្ឌានមេតំ សេនាសនានំ អធិវចនំ ។ វនបត្ថន្តិ ភីសនកានមេតំ សេនាសនានំ អធិវចនំ ។ វនបត្ថន្តិ សលោមហំសានមេតំ សេ-នាសនានំ អធិវចនំ ។ វនបត្ថន្តិ បរិយន្តានមេតំ សេនាសនានំ អធិវចនំ ។ វនបត្ថន្តិ ន មនុស្សូ-បចារានមេតំ សេនាសនានំ អធិវចនំ ។ វនបត្ថន្តិ ទុរភិសម្ភវានមេតំ សេនាសនានំ អធិវចនំ ។

[៣៦១] ត្រង់ពាក្យថា គប់រក គឺភិក្ខុ រមែងគប់រក ឈម ទៅ ចូលចិត្ត អាស្រ័យ ពឹងពាក់ ចំពោះសេនាសនៈដ៏ស្ងាត់នេះ ព្រោះហេតុនោះ ទើបពោលថា គប់រក ។

[៣៦២] ត្រង់ពាក្យថា ព្រៃ គឺ ទីទាំងអស់នុ៎ះ ដែលចេញផុតអំពីសសរគោលខាងក្រៅ ឈ្មោះថា ព្រៃ ។

[៣៦៣] ត្រង់ពាក្យថា គល់ឈើ គឺគល់ឈើហ្នឹងឯង ។ ភ្នំ គឺភ្នំប្រាកដមែន ។ ជ្រោះ គឺជ្រោះប្រាកដមែន ។ គុហាភ្នំ គឺគុហាភ្នំប្រាកដមែន ។ ព្រៃស្មសាន គឺព្រៃស្មសានប្រាកដមែន ។ ទីវាល គឺទីវាលប្រាកដមែន ។ គំនរចំបើង គឺគំនរចំបើងប្រាកដមែន ។

[៣៦៤] ពាក្យថា ព្រៃញៀតស្ងាត នុ៎ះជាឈ្មោះនៃសេនាសនៈទាំងឡាយដែលឆ្ងាយ ។ ពាក្យថា ព្រៃញៀតស្ងាត នុ៎ះជាឈ្មោះនៃសេនាសនៈទាំងឡាយ ដែលជាដងព្រៃ ។ ពាក្យថា ព្រៃញៀតស្ងាត នុ៎ះជាឈ្មោះនៃសេនាសនៈទាំងឡាយ ដែលគួរខ្លាច ។ ពាក្យថា ព្រៃញៀតស្ងាត នុ៎ះជាឈ្មោះនៃសេនាសនៈទាំងឡាយ ដែលប្រកបដោយសេចក្ដីព្រឺរោម ។ ពាក្យថា ព្រៃញៀតស្ងាត នុ៎ះជាឈ្មោះនៃសេនាសនៈទាំងឡាយ ដែលមានក្នុងទីបំផុត ។ ពាក្យថា ព្រៃញៀតស្ងាត នុ៎ះជាឈ្មោះនៃសេនាសនៈទាំងឡាយ ដែលមិនមែនជាឧបចារៈរបស់មនុស្ស ។ ពាក្យថា ព្រៃញៀតស្ងាត នុ៎ះជាឈ្មោះនៃសេនាសនៈទាំងឡាយ ដែលបុគ្គលសម្ងំនៅបានដោយក្រ ។

[៣៦៥] អប្បសទ្ទន្តិ សន្តិកេ ចេបិ សេនាសនំ ហោតិ តញ្ច អនាកិណ្ណំ គហដ្ឋេហិ បព្វជិតេហិ តេន តំ អប្បសទ្ទំ ។ ទូរេ ចេបិ សេនាសនំ ហោតិ តញ្ច អនាកិណ្ណំ គហដ្ឋេហិ បព្វជិតេហិ តេន តំ អប្បសទ្ទំ ។

[៣៦៦] អប្បនិគ្ឃោសន្តិ យទេវ តំ អប្បសទ្ទំ តទេវ តំ អប្បនិគ្ឃោសំ យទេវ តំ អប្បនិគ្ឃោសំ តទេវ តំ វិជនវាតំ យទេវ តំ វិជនវាតំ តទេវ តំ មនុស្សរាហសេយ្យកំ យទេវ តំ មនុស្សរាហសេយ្យកំ តទេវ តំ បដិសល្លានសារុប្បំ ។

[៣៦៧] អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វាតិ អរញ្ញគតោ វា ហោតិ រុក្ខមូលគតោ វា សុញ្ញាគារគតោ វា ។

[៣៦៨] និសីទតិ បល្លង្កំ អាភុជិត្វាតិ និសិន្នោ ហោតិ បល្លង្កំ អាភុជិត្វា ។

[៣៦៩] ឧជុំ កាយំ បណិធាយាតិ ឧជុកោ ហោតិ កាយោ ឋិតោ បណិហិតោ ។

[៣៦៥] ត្រង់ពាក្យថា ទីមិនមានសំឡេង គឺថា បើសេនាសនៈ នៅក្នុងទីជិត តែសេនាសនៈនោះ មិនច្រឡូកច្រឡំដោយពួកគ្រហស្ថនិង ពួកបព្វជិត ព្រោះហេតុនោះ ទីនោះ ឈ្មោះថា ទីមិនមានសំឡេង ។ បើសេនាសនៈ នៅក្នុងទីឆ្ងាយ តែសេនាសនៈនោះ មិនច្រឡូកច្រឡំ ដោយពួកគ្រហស្ថ និងពួកបព្វជិត ព្រោះហេតុនោះ ទីនោះឈ្មោះថា ទីមិនមានសំឡេង ។

[៣៦៦] ត្រង់ពាក្យថា ទីមិនគឹកកង គឺ ទីណា មិនមានសំឡេង ទីនោះឈ្មោះថា ទីមិនគឹកកង ទីណាមិនគឹកកង ទីនោះឈ្មោះថា ទីប្រាសចាកខ្យល់ដែលកើតអំពីសរីរៈនៃជន ទីណាដែលប្រាសចាកខ្យល់ កើតអំពីសរីរៈនៃជន ទីនោះឈ្មោះថា ទីស្ងាត់កំបាំងរបស់មនុស្ស ទីណា ដែលស្ងាត់កំបាំងរបស់មនុស្ស ទីនោះឈ្មោះថាទីសមគួរដល់ការពួនសម្ងំ ។

[៣៦៧] ត្រង់ពាក្យថា ទៅកាន់ព្រៃក្តី ទៅកាន់ម្លប់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី គឺ ភិក្ខុជាអ្នកនៅក្នុងព្រៃក្តី នៅក្រោមម្លប់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី ។

[៣៦៨] ត្រង់ពាក្យថា អង្គុយផ្គត់ភ្នែន គឺភិក្ខុជាអ្នកអង្គុយផ្គត់ភ្នែន ។

[៣៦៩] ត្រង់ពាក្យថា តាំងកាយឲ្យត្រង់ គឺភិក្ខុជាអ្នកមាន កាយត្រង់ ឋិតនៅ តម្កល់នៅមាំមួន ។

[៣៧០] បរិមុខំ សតឹ ឧបដ្ឋបេត្វាតិ តត្ថ កតមា សតិ ។ យា សតិ អនុស្សតិ ។ បេ ។ សម្មាសតិ អយំ វុច្ចតិ សតិ អយំ សតិ ឧបដ្ឋិតា ហោតិ សុបដ្ឋិតា នាសិកគ្គេ វា មុខនិមិត្តេ វា តេន វុច្ចតិ បរិមុខំ សតឹ ឧបដ្ឋបេត្វាតិ ។

[៣៧១] អភិជ្ឈំ លោកេ បហាយាតិ តត្ថ កតមា អភិជ្ឈា ។ យោ រាគោ សារាគោ ។ បេ ។ ចិត្តស្ស សារាគោ អយំ វុច្ចតិ អភិជ្ឈា ។ តត្ថ កតមោ លោកោ ។ បញ្ចុបាទានក្ខន្ធា លោកោ អយំ វុច្ចតិ លោកោ ។ អយំ អភិជ្ឈា ឥមម្ហិ លោកេ សន្តា ហោតិ សមិតា វូបសន្តា អត្ថង្គតា អព្ភត្ថង្គតា អប្បិតា ព្យប្បិតា សោសិតា វិសោសិតា ព្យន្តីកតា តេន វុច្ចតិ អភិជ្ឈំ លោកេ បហាយាតិ ។

[៣៧០] ត្រង់ពាក្យថា តម្កល់សតិឲ្យមានមុខឆ្ពោះទៅរក (កម្មដ្ឋាន) សេចក្តីថា បណ្តាធម៌ទាំងនោះ សតិ តើដូចម្តេច ។ ការរលឹក ការនឹកឃើញ ។ បេ ។ សេចក្តីរលឹកត្រូវ ណា នេះហៅថា សតិ សតិនេះ ដែលបុគ្គលតម្កល់ទុកហើយ តាំងទុកល្អហើយ ត្រង់ទីបំផុតនៃច្រមុះក្តី ត្រង់និមិត្តនៃមាត់ក្តី ព្រោះហេតុនោះ ទើបពោលថា តម្កល់សតិឲ្យមានមុខឆ្ពោះទៅរក (កម្មដ្ឋាន) ។

[៣៧១] ត្រង់ពាក្យថា លះបង់អភិជ្ឈាក្នុងលោក មានសេចក្តីថា បណ្តាធម៌ទាំងនោះ អភិជ្ឈា តើដូចម្តេច ។ តម្រេក តម្រេកខ្លាំង ។ បេ ។ តម្រេកខ្លាំង នៃចិត្ត ណា នេះហៅថា អភិជ្ឈា ។ បណ្តាធម៌ទាំងនោះ លោក តើដូចម្តេច ។ ឧបាទានក្ខន្ធទាំង ៥ ឈ្មោះថាលោក នេះហៅថា លោក ។ អភិជ្ឈានេះ ជាធម្មជាតិស្ងប់-រម្ងាប់ រលត់ ខ្ជាត់ចេញ វិនាស សាបសូន្យ ខូចខាត ហីន-ហោច រីង ស្ងួត ធ្វើឲ្យអស់ទៅ ក្នុងលោកនេះ ព្រោះហេតុនោះ ទើបពោលថា លះបង់អភិជ្ឈាក្នុងលោក ។

[៣៧២] វិតក្កាភិនិរោបនេ ចេតសោតិ តត្ថ កតមំ ចិត្តំ ។ យំ ចិត្តំ មនោ មានសំ ។ បេ ។ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ ចិត្តំ ឥទំ ចិត្តំ វិ-តក្កាភិជ្ឈំ ហោតិ តេន វុច្ចតិ វិតក្កាភិនិរោបនេ ចេត-សោតិ ។

[៣៧៣] វិហរតីតិ ឥរិយតិ វត្តតិ ចាលេតិ យបេតិ យាបេតិ ចរតិ វិហរតិ តេន វុច្ចតិ វិហ-រតីតិ ។

[៣៧៤] អភិជ្ឈាយ ចិត្តំ បរិសោធេតីតិ តត្ថ កតមា អភិជ្ឈា ។ យោ រាគោ សារាគោ ។ បេ ។ ចិត្តស្ស សារាគោ អយំ វុច្ចតិ អភិជ្ឈា ។ តត្ថ កតមំ ចិត្តំ ។ យំ ចិត្តំ មនោ មានសំ ។ បេ ។ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ ចិត្តំ ។ ឥទំ ចិត្តំ ឥមាយ អភិជ្ឈាយ សោធេតិ វិសោធេតិ ប-រិសោធេតិ មោចេតិ វិមោចេតិ បរិមោចេតិ តេន វុច្ចតិ អភិជ្ឈាយ ចិត្តំ បរិសោធេតីតិ ។

[៣៧២] ត្រង់ពាក្យថា មានចិត្តប្រាសចាកអភិជ្ឈា មានសេចក្តីថា បណ្តាធម៌ទាំងនោះ ចិត្ត តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។ បេ ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ ណា នេះហៅថាចិត្ត ចិត្តនេះ ជាធម្មជាតមានអភិជ្ឈាទៅប្រាសហើយ ព្រោះហេតុនោះ ទើបពោលថា មានចិត្តប្រាសចាកអភិជ្ឈា ។

[៣៧៣] ត្រង់ពាក្យថា សម្រេចឥរិយាបថ គឺ សម្រេចប្រព្រឹត្ត រក្សា រស់នៅ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ត្រាច់ទៅ នៅ ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

[៣៧៤] ត្រង់ពាក្យថា ជម្រះចិត្តឲ្យស្អាតចាកអភិជ្ឈា មានសេចក្តីថា បណ្តាធម៌ទាំងនោះ អភិជ្ឈា តើដូចម្តេច ។ តម្រេក តម្រេកខ្លាំង ។ បេ ។ តម្រេកខ្លាំង ណា នៃចិត្ត នេះហៅថា អភិជ្ឈា ។ បណ្តាធម៌ទាំងនោះ ចិត្ត តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។ បេ ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ ណា នេះហៅថា ចិត្ត ។ ភិក្ខុញុំាងចិត្តនេះឲ្យស្អាត ឲ្យបរិសុទ្ធ ឲ្យផូរផង់ ឲ្យរួច ឲ្យរួចស្រឡះ ឲ្យរបូតចេញ ចាកអភិជ្ឈានេះ ព្រោះហេតុនោះ ទើបពោលថា ជម្រះចិត្តឲ្យស្អាតចាកអភិជ្ឈា ។

[៣៧៥] ព្យាបាទប្បទោសំ បហាយាតិ អត្ថិ ព្យាបាទោ អត្ថិ បទោសោ ។ តត្ថ កតមោ ព្យាបាទោ ។ យោ ចិត្តស្ស អាឃាតោ បដិឃាតោ បដិឃំ បដិវិរោធោ កោបោ បកោបោ សម្បកោបោ ទោសោ បទោសោ សម្បទោសោ ចិត្តស្ស ព្យាបត្តិ មនោបទោសោ កោធោ កុជ្ឈនា កុជ្ឈិតត្តំ ទោសោ ទុស្សនា ទុស្សិតត្តំ ព្យាបត្តិ ព្យាបជ្ជនា ព្យាបជ្ជិតត្តំ វិរោធោ បដិវិរោធោ ចណ្ឌិក្កំ អសុរោបោ អនត្តមនតា ចិត្តស្ស អយំ វុច្ចតិ ព្យាបាទោ ។ តត្ថ កតមោ បទោសោ ។ យោ ព្យាបាទោ សោ បទោសោ យោ បទោសោ សោ ព្យាបាទោ ។ ឥតិ អយញ្ច ព្យាបាទោ អយញ្ច បទោសោ សន្តា ហោន្តិ សមិតា វូបសន្តា អត្ថង្គតា អព្ភត្ថង្គតា អប្បិតា ព្យប្បិតា សោសិតា វិសោសិតា ព្យន្តីកតា តេន វុច្ចតិ ព្យាបាទប្បទោសំ បហាយាតិ ។

[៣៧៦] អព្យាបន្នចិត្តោតិ តត្ថ កតមំ ចិត្តំ ។ យំ ចិត្តំ មនោ មានសំ ។ បេ ។ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ ចិត្តំ ឥទំ ចិត្តំ អព្យាបន្នំ ហោតិ តេន វុច្ចតិ អព្យាបន្នចិត្តោតិ ។

[៣៧៥] ត្រង់ពាក្យថា លះបង់ព្យាបាទ និងសេចក្តីប្រទូស្ត អធិប្បាយថា ព្យាបាទក៏មាន សេចក្តីប្រទូស្តក៏មាន ។ បណ្តាធម៌ទាំងនោះ ព្យាបាទ តើដូចម្តេច ។ សេចក្តីគុំក្ហួន ចងគំនុំ ថ្នាំងថ្នាក់ អាក់អន់ កម្រើក ញាប់ញ័រ កម្រើកខ្លាំង ខឹង ខឹងខ្លាំង ខឹងខ្លាំងក្រៃពេកនៃចិត្ត ចង្អៀតចិត្ត ប្រទូស្តក្នុងចិត្ត ក្រោធ អាការក្រោធ ភាពក្រោធ ខឹង អាការខឹង ភាពខឹង ចង្អៀតចិត្ត អាការចង្អៀតចិត្ត ភាពចង្អៀតចិត្ត ស្រពន់ចិត្ត អាក់អន់ចិត្ត ភាពនៃចិត្តកាច សេចក្តីខឹង ភាពនៃចិត្តមិនត្រេកអរ ណា នេះហៅថា ព្យាបាទ ។ បណ្តាធម៌ទាំងនោះ សេចក្តីប្រទូស្ត តើដូចម្តេច ។ សេចក្តីព្យាបាទ គឺសេចក្តីប្រទូស្ត សេចក្តីប្រទូស្ត គឺសេចក្តីព្យាបាទ ។ ព្យាបាទនេះផង សេចក្តីប្រទូស្តនេះផង ជាធម៌ស្ងប់រម្ងាប់ រលត់ ខ្ចាត់ចេញ វិនាស សាបសូន្យ ខូចខាត ហីនហោច រីង ស្ងួត ធ្វើឲ្យអស់ទៅ ព្រោះហេតុនោះ ទើបពោលថា លះព្យាបាទ និងសេចក្តីប្រទូស្ត ។

[៣៧៦] ត្រង់ពាក្យថា មានចិត្តមិនព្យាបាទ សេចក្តីថា បណ្តាធម៌ទាំងនោះ ចិត្ត តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។ បេ ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ ណា នេះហៅថា ចិត្ត ចិត្តនេះ ជាធម្មជាតមិនគុំក្ហួន ព្រោះហេតុនោះ ទើបពោលថា មានចិត្តមិនព្យាបាទ ។

[៣៧៧] វិហរតីតិ ឥរិយតិ ។ បេ ។ វិហរតិ តេន វុច្ចតិ វិហរតីតិ ។

[៣៧៨] ព្យាបាទប្បទោសា ចិត្តំ បរិសោធេតីតិ អត្ថិ ព្យាបាទោ អត្ថិ បទោសោ ។ តត្ថ កតមោ ព្យាបាទោ ។ យោ ចិត្តស្ស អាឃាតោ បដិឃាតោ បដិឃំ បដិវិរោធោ កោបោ បកោបោ សម្បកោ-បោ ទោសោ បទោសោ សម្បទោសោ ចិត្តស្ស ព្យាបត្តិ មនោបទោសោ កោធោ កុជ្ឈនា កុជ្ឈិតត្តំ ទោសោ ទុស្សនា ទុស្សិតត្តំ ព្យាបត្តិ ព្យាបជ្ជនា ព្យាបជ្ជិតត្តំ វិរោធោ បដិវិរោធោ ចណ្ឌិក្កំ អសុរោ-បោ អនត្តមនតា ចិត្តស្ស អយំ វុច្ចតិ ព្យាបាទោ ។ តត្ថ កតមោ បទោសោ ។ យោ ព្យាបាទោ សោ បទោសោ យោ បទោសោ សោ ព្យាបាទោ ។ តត្ថ កតមំ ចិត្តំ ។ យំ ចិត្តំ មនោ មានសំ ។ បេ ។ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ ចិត្តំ ។ ឥទំ ចិត្តំ ឥមម្ហា ព្យាបាទប្បទោសា សោធេតិ វិសោធេតិ បរិសោធេតិ មោចេតិ វិមោចេតិ បរិមោចេតិ តេន វុច្ចតិ ព្យាបាទប្បទោសា ចិត្តំ បរិសោធេតីតិ ។

[៣៧៧] ត្រង់ពាក្យថា សម្រេចឥរិយាបថ គឺ សម្រេច ។ បេ ។ នៅ ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

[៣៧៨] ត្រង់ពាក្យថា ជម្រះចិត្តឲ្យស្អាត ចាកព្យាបាទនិងសេចក្ដីប្រទូស្ត អធិប្បាយថា ព្យាបាទក៏មាន សេចក្ដីប្រទូស្តក៏មាន ។ បណ្ដាធម៌ទាំងនោះ ព្យាបាទ តើដូចម្ដេច ។ សេចក្ដីគុំកួន ចងគំនុំ ថ្នាំងថ្នាក់ អាក់អន់ កម្រើក ញាប់ញ័រ កម្រើកខ្លាំង ខឹង ខឹងខ្លាំង ខឹងខ្លាំងក្រៃពេកនៃចិត្ត ចង្អៀតចិត្ត ប្រទូស្តក្នុងចិត្ត ក្រោធ អាការក្រោធ ភាពក្រោធ ខឹង អាការខឹង ភាពខឹង ចង្អៀតចិត្ត អាការចង្អៀតចិត្ត ភាពចង្អៀតចិត្ត ស្រពន់ចិត្ត អាក់អន់ចិត្ត ភាពនៃចិត្តកាចសេចក្ដីខឹង ភាពនៃចិត្តមិនត្រេកអរ ណា នេះហៅថា ព្យាបាទ ។ បណ្ដាធម៌ទាំងនោះ សេចក្ដីប្រទូស្ត តើដូចម្ដេច ។ សេចក្ដីព្យាបាទគឺសេចក្ដីប្រទូស្ត សេចក្ដីប្រទូស្ត គឺសេចក្ដីព្យាបាទ ។ បណ្ដាធម៌ទាំងនោះ ចិត្ត តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ។ បេ ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ ណា នេះហៅថា ចិត្ត ។ ភិក្ខុញុាំងចិត្តនេះឲ្យស្អាត ឲ្យបរិសុទ្ធ ឲ្យផូរផង់ ឲ្យរួច ឲ្យរួចស្រឡះ ឲ្យរបូតចេញ ចាកព្យាបាទនិងសេចក្ដីប្រទូស្ត ព្រោះហេតុនោះ ទើបពោលថា ជម្រះចិត្តឲ្យស្អាត ចាកព្យាបាទនិងសេចក្ដីប្រទូស្ត ។

[៣៧៩] ថីនមិទ្ធំ បហាយាតិ អត្ថិ ថីនំ អត្ថិ មិទ្ធំ ។ តត្ថ កតមំ ថីនំ ។ យា ចិត្តស្ស អ-
កល្យតា អកម្មញ្ញតា ឱលីយនា សល្លីយនា លីនំ
លីយនា លីយិតត្តំ ថីនំ ថីយនា ថីយិតត្តំ ចិត្ត-
ស្ស ឥទំ វុច្ចតិ ថីនំ ។ តត្ថ កតមំ មិទ្ធំ ។ យា
កាយស្ស អកល្យតា អកម្មញ្ញតា ឱនាហោ ប-
រិយោនាហោ អន្តោសមោរោធោ មិទ្ធំ សោប្បំ
បចលាយិកា សោប្បំ សុបនា សុបិតត្តំ ឥទំ វុច្ចតិ
មិទ្ធំ ។ ឥតិ ឥទញ្ច ថីនំ ឥទញ្ច មិទ្ធំ សន្តា
ហោន្តិ សមិតា វូបសន្តា អត្ថង្គតា អព្ភត្ថង្គតា
អប្បិតា ព្យប្បិតា សោសិតា វិសោសិតា ព្យន្តីក-
តា តេន វុច្ចតិ ថីនមិទ្ធំ បហាយាតិ ។

[៣៨០] វិគតថីនមិទ្ធោតិ តស្ស ថីនមិទ្ធស្ស
ចត្តត្តា វន្តត្តា មុត្តត្តា បហីនត្តា បដិនិស្សដ្ឋត្តា
បហីនប្បដិនិស្សដ្ឋត្តា តេន វុច្ចតិ វិគតថីនមិទ្ធោតិ ។
វិហរតីតិ ។ បេ ។ តេន វុច្ចតិ វិហរតីតិ ។

[៣៧៩] ត្រង់ពាក្យថា លះបង់ថីនៈនិងមិទ្ធៈ សេចក្តីថា ថីនៈក៏មាន មិទ្ធៈក៏មាន ។ បណ្តាធម៌ទាំងនោះ ថីនៈ តើដូចម្តេច ។ ភាពនៃចិត្តមិនស្រួល ភាពនៃចិត្តមិនគួរដល់ការនាកម្ម អាការក្រាញ អាការកៀចក្រាញ ការរួញរា អាការរួញរា ភាពនៃចិត្តរួញរា ការរួញថយ អាការរួញថយ ភាពនៃចិត្តរួញថយ ណា នេះហៅថា ថីនៈ ។ បណ្តាធម៌ទាំងនោះ មិទ្ធៈ តើដូចម្តេច ។ ភាពនៃកាយមិនស្រួល ភាពនៃកាយមិនគួរដល់ការនាកម្ម សេចក្តីងងុយ ការងោកងក់ ការរលត់សូន្យខាងក្នុង ការជ្រប់ចុះ ការលក់ ការស្រពោនចុះ ការលក់ស៊ប់ អាការលក់ ភាពនៃការលក់ ណា នេះហៅថា មិទ្ធៈ ។ ថីនៈនេះផង មិទ្ធៈនេះផង ជាធម្មជាតស្ងប់រម្ងាប់ រលត់ ខ្ចាត់ចេញ វិនាស សាបសូន្យ ខូចខាត ហីនហោច រីង ស្ងួត ធ្វើឲ្យអស់ទៅ ព្រោះហេតុនោះ ទើបពោលថា លះបង់ថីនៈនិងមិទ្ធៈ ។

[៣៨០] ពាក្យថា ជាអ្នកប្រាសចាកថីនៈនិងមិទ្ធៈដូច្នេះ ព្រោះភាពនៃថីនៈនិងមិទ្ធៈនោះ លោកលះបង់ ខ្ចាក់ចេញ រួចស្រឡះ បន្សាត់បង់រលាស់ចេញ បន្សាត់បង់ ទាំងរលាស់ចេញអស់ហើយ ព្រោះហេតុនោះ ទើបពោលថា ជាអ្នកប្រាសចាកថីនៈនិងមិទ្ធៈ ។ ពាក្យថា សម្រេចឥរិយាបថ ។ បេ ។ ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

[៣៨១] អាលោកសញ្ញីតិ តត្ថ កាតមា សញ្ញា ។ យា សញ្ញា សញ្ជានដា សញ្ជានិតត្តំ អយំ វុច្ចតិ សញ្ញា អយំ សញ្ញា អាលោកា ហោតិ វិវដា បរិសុទ្ធា បរិយោទាតា តេន វុច្ចតិ អាលោកសញ្ញីតិ ។

[៣៨២] សតិ សម្បជានោតិ តត្ថ កាតមា សតិ ។ យា សតិ អនុស្សតិ ។ បេ ។ សម្មាសតិ អយំ វុច្ចតិ សតិ ។ តត្ថ កាតមំ សម្បជញ្ញំ ។ យា បញ្ញា បជានដា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ឥទំ វុច្ចតិ សម្បជញ្ញំ ។ ឥតិ ឥមាយ ច សតិយា ឥមិនា ច សម្បជញ្ញេន ឧបេតោ ហោតិ ។ បេ ។ សមន្នាគតោ តេន វុច្ចតិ សតិ សម្បជានោតិ ។

[៣៨៣] ថីនមិទ្ធា ចិត្តំ បរិសោធេតីតិ អត្ថិ ថីនំ អត្ថិ មិទ្ធំ ។ តត្ថ កាតមំ ថីនំ ។ យា ចិត្តស្ស អកាល្យតា ។ បេ ។ ថីយិតត្តំ ចិត្តស្ស ឥទំ វុច្ចតិ ថីនំ ។ តត្ថ កាតមំ មិទ្ធំ ។ យា កាយស្ស អកាល្យតា ។ បេ ។ សុបិតត្តំ ឥទំ វុច្ចតិ មិទ្ធំ ។

[៣៨១] ត្រង់ពាក្យថា មានសេចក្ដីសម្គាល់ជាពន្លឺ សេចក្ដីថា បណ្ដាពាក្យទាំងនោះ សេចក្ដីសម្គាល់ តើដូចម្ដេច ។ សញ្ញា អាការសម្គាល់ ភាពនៃការសម្គាល់ ណា នេះហៅថា សេចក្ដីសម្គាល់ សញ្ញានេះ ជាពន្លឺ ដែលបើកហើយ បរិសុទ្ធ ផូរផង់ ព្រោះហេតុនោះ ទើបពោលថា មានសេចក្ដីសម្គាល់ជាពន្លឺ ។

[៣៨២] ត្រង់ពាក្យថា ជាអ្នកមានសតិនិងសម្បជញ្ញៈ សេចក្ដីថា បណ្ដាធម៌ទាំងនោះ សតិ តើដូចម្ដេច ។ ការរលឹក ការនឹកឃើញ ។ បេ ។ ការរលឹកត្រូវ ណា នេះហៅថា សតិ ។ បណ្ដាធម៌ទាំងនោះ សម្បជញ្ញៈ តើដូចម្ដេច ។ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការសង្កេតនូវធម៌ ការយល់ត្រូវ ណា នេះហៅថា សម្បជញ្ញៈ ។ ភិក្ខុជាអ្នកព្រមព្រៀង ។ បេ ។ ប្រកបព្រម ដោយសតិនេះផង ដោយសម្បជញ្ញៈនេះផង ព្រោះហេតុនោះ ទើបពោលថា អ្នកមានសតិនិងសម្បជញ្ញៈ ។

[៣៨៣] ត្រង់ពាក្យថា ជម្រះចិត្តឲ្យស្អាត ចាកថីនៈនិងមិទ្ធៈ សេចក្ដីថា ថីនៈក៏មាន មិទ្ធៈក៏មាន ។ បណ្ដាធម៌ទាំងនោះ ថីនៈ តើដូចម្ដេច ។ ភាពនៃចិត្តមិនស្រួល ។ បេ ។ ភាពនៃចិត្តរួញថយ ណា នេះហៅថា ថីនៈ ។ បណ្ដាធម៌ទាំងនោះ មិទ្ធៈ តើដូចម្ដេច ។ ភាពនៃកាយមិនស្រួល ។ បេ ។ ភាពនៃការលក់ ណា នេះហៅថា មិទ្ធៈ ។

តត្ថ កាតមំ ចិត្តំ ។ យំ ចិត្តំ មនោ មានសំ ។ បេ ។ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ ចិត្តំ ។ ឥទំ ចិត្តំ ឥមម្ហា ថីនមិទ្ធា សោធេតិ វិសោធេតិ បរិ-សោធេតិ មោចេតិ វិមោចេតិ បរិមោចេតិ តេន វុច្ចតិ ថីនមិទ្ធា ចិត្តំ បរិសោធេតីតិ ។

[៣៨៤] ឧទ្ធច្ចកុក្កុច្ចំ បហាយាតិ អត្ថិ ឧទ្ធច្ចំ អត្ថិ កុក្កុច្ចំ ។ តត្ថ កាតមំ ឧទ្ធច្ចំ ។ យំ ចិត្តស្ស ឧទ្ធច្ចំ អវូបសមោ ចេតសោ វិក្ខេបោ ភន្តត្តំ ចិត្តស្ស ឥទំ វុច្ចតិ ឧទ្ធច្ចំ ។ តត្ថ កាតមំ កុក្កុច្ចំ ។ អកប្បិយេ កប្បិយសញ្ញិតា កប្បិយេ អកប្បិយ-សញ្ញិតា អវជ្ជេ វជ្ជសញ្ញិតា វជ្ជេ អវជ្ជសញ្ញិតា យំ ឯវរូបំ កុក្កុច្ចំ កុក្កុច្ចាយនា កុក្កុច្ចាយិតត្តំ ចេត-សោ វិប្បដិសារោ មនោវិលេខោ ឥទំ វុច្ចតិ កុក្កុ-ច្ចំ ។ ឥតិ ឥទញ្ច ឧទ្ធច្ចំ ឥទញ្ច កុក្កុច្ចំ សន្តា ហោន្តិ សមិតា វូបសន្តា អត្ថង្គតា អព្ភត្ថង្គតា អប្បីតា ព្យប្បីតា សោសិតា វិសោសិតា ព្យន្តីកតា តេន វុច្ចតិ ឧទ្ធច្ចកុក្កុច្ចំ បហាយាតិ ។

បណ្តាធម៌ទាំងនោះ ចិត្ត តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។ បេ ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ ណា នេះហៅថា ចិត្ត ។ ភិក្ខុញ៉ាំងចិត្តនេះឲ្យស្អាត ឲ្យបរិសុទ្ធ ឲ្យផូរផង់ ឲ្យរួច ឲ្យរួចស្រឡះ ឲ្យរបូតចេញ ចាកថីនៈនិងមិទ្ធៈនេះ ព្រោះហេតុនោះ ទើបពោលថា ជម្រះចិត្តឲ្យស្អាត ចាកថីនៈនិងមិទ្ធៈ ។

[៣៨៤] ត្រង់ពាក្យថា លះបង់ឧទ្ធច្ចៈនិងកុក្កុច្ចៈ សេចក្តីថា ឧទ្ធច្ចៈក៏មាន កុក្កុច្ចៈក៏មាន ។ បណ្តាធម៌ទាំងនោះ ឧទ្ធច្ចៈ តើដូចម្តេច ។ សេចក្តីអណ្តែតអណ្តូងនៃចិត្ត ការមិនស្ងប់រម្ងាប់ ការរាយមាយនៃចិត្ត ភាពនៃចិត្តភ្ញាក់ផ្អើល ណា នេះហៅថា ឧទ្ធច្ចៈ ។ បណ្តាធម៌ទាំងនោះ កុក្កុច្ចៈ តើដូចម្តេច ។ សេចក្តីសម្គាល់ថាគួរ ក្នុងវត្ថុដែលមិនគួរ សម្គាល់ថាមិនគួរ ក្នុងវត្ថុដែលគួរ សម្គាល់ថាជាទោស ក្នុងវត្ថុដែលមិនមានទោស សម្គាល់ថាមិនមានទោស ក្នុងវត្ថុដែលជាទោស សេចក្តីរពឹស អាការរពឹស ភាពនៃចិត្តរពឹស សេចក្តីក្តៅក្រហាយនៃចិត្ត សេចក្តីសាំញ៉ាំនៃចិត្ត ណា នេះហៅថា កុក្កុច្ចៈ ។ ឧទ្ធច្ចៈនេះផង កុក្កុច្ចៈនេះផង ជាធម៌ស្ងប់រម្ងាប់ រលត់ ខ្ជាត់ចេញ វិនាស សាបសូន្យ ខូចខាត ហីនហោច រីង ស្ងួត ធ្វើឲ្យអស់ទៅ ព្រោះហេតុនោះ ទើបពោលថា លះបង់ឧទ្ធច្ចៈនិងកុក្កុច្ចៈ ។

[៣៨៥] អនុទ្ទតោតិ តស្ស ឧទ្ធច្ចកុក្កុច្ចស្ស ចត្តត្តា វន្តត្តា មុត្តត្តា បហីនត្តា បដិនិស្សដ្ឋត្តា តេន វុច្ចតិ អនុទ្ធតោតិ ។

[៣៨៦] វិហរតីតិ ឥរិយតិ ។ បេ ។ វិហរតិ តេន វុច្ចតិ វិហរតីតិ ។

[៣៨៧] អជ្ឈត្តន្តិ យំ អជ្ឈត្តំ បច្ចត្តំ ។ វូ-បសន្តចិត្តោតិ តត្ថ កតមំ ចិត្តំ ។ យំ ចិត្តំ មនោ មានសំ ។ បេ ។ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ ចិត្តំ ឥទំ ចិត្តំ អជ្ឈត្តំ សន្តំ ហោតិ សមិតំ វូបសន្តំ តេន វុច្ចតិ អជ្ឈត្តំ វូបសន្តចិត្តោតិ ។

[៣៨៨] ឧទ្ធច្ចកុក្កុច្ចា ចិត្តំ បរិសោធេតីតិ អត្ថិ ឧទ្ធច្ចំ អត្ថិ កុក្កុច្ចំ ។ តត្ថ កតមំ ឧទ្ធច្ចំ ។ យំ ចិត្តស្ស ឧទ្ធច្ចំ អវូបសមោ ចេតសោ វិក្ខេបោ ភន្តត្តំ ចិត្តស្ស ឥទំ វុច្ចតិ ឧទ្ធច្ចំ ។ តត្ថ កតមំ កុក្កុច្ចំ ។ អកប្បិយេ កប្បិយសញ្ញិតា ។ បេ ។

[៣៨៥] ពាក្យថា ជាអ្នកមិនរាយមាយដូច្នេះ ព្រោះភាពនៃឧទ្ធច្ចៈ និងកុក្កុច្ចៈនោះ លោកលះបង់ ខ្ជាក់ចេញ រួចស្រឡះ បន្សាត់បង់ រលាស់ចោល ព្រោះហេតុនោះ ទើបពោលថា ជាអ្នកមិនរាយមាយ ។

[៣៨៦] ត្រង់ពាក្យថា សម្រេចឥរិយាបថ គឺ សម្រេច ។ បេ ។ នៅ ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

[៣៨៧] ត្រង់ពាក្យថា ខាងក្នុងសន្តាន បានដល់ធម្មជាតដែលជាក់ច្បាស់ខាងក្នុងសន្តាន ។ ពាក្យថា មានចិត្តស្ងប់រម្ងាប់ សេចក្តីថា បណ្តាពាក្យទាំងនោះ ចិត្ត តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។ បេ ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ ណា នេះហៅថា ចិត្ត ចិត្តនេះ ជាធម្មជាតស្ងប់រម្ងាប់រលត់ ខ្ជាត់ចេញ ខាងក្នុងសន្តាន ព្រោះហេតុនោះ ទើបពោលថា មានចិត្តស្ងប់រម្ងាប់ខាងក្នុងសន្តាន ។

[៣៨៨] ត្រង់ពាក្យថា ជម្រះចិត្តឲ្យស្អាតចាកឧទ្ធច្ចៈនិងកុក្កុច្ចៈ សេចក្តីថា ឧទ្ធច្ចៈក៏មាន កុក្កុច្ចៈក៏មាន ។ បណ្តាធម៌ទាំងនោះ ឧទ្ធច្ចៈ តើដូចម្តេច ។ សេចក្តីអណ្តែតអណ្តូងនៃចិត្ត ការមិនស្ងប់រម្ងាប់ ការរាយមាយនៃចិត្ត ភាពនៃចិត្តភ្ញាក់ផ្អើល ណា នេះហៅថា ឧទ្ធច្ចៈ ។ បណ្តាធម៌ទាំងនោះ កុក្កុច្ចៈ តើដូចម្តេច ។ សេចក្តីសម្គាល់ថាគួរ ក្នុងវត្ថុដែលមិនគួរ ។ បេ ។

មនោវិលេខោ ឥទំ វុច្ចតិ កុក្កុច្ចំ ។ តត្ថ កាតមំ ចិត្តំ ។ យំ ចិត្តំ មនោ មានសំ ។ បេ ។ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ ចិត្តំ ។ ឥទំ ចិត្តំ ឥមម្ហា ឧទ្ធច្ចកុក្កុច្ចា សោធេតិ វិសោធេតិ បរិសោធេតិ មោចេតិ វិមោចេតិ បរិមោចេតិ តេន វុច្ចតិ ឧទ្ធច្ចកុក្កុច្ចា ចិត្តំ បរិសោធេតីតិ ។

[៣៨៩] វិចិកិច្ឆំ បហាយាតិ តត្ថ កាតមា វិចិកិច្ឆា ។ យា កង្ខា កង្ខាយនា កង្ខាយិតត្តំ វិមតិ វិចិកិច្ឆា ទ្វេឡ្ហកំ ទ្វេធាបថោ សំសយោ អនេកំសគ្គាហោ អាសប្បនា បរិសប្បនា អបរិយោគាហនា ថម្ភិតត្តំ ចិត្តស្ស មនោវិលេខោ អយំ វុច្ចតិ វិចិកិច្ឆា ។ អយំ វិចិកិច្ឆា សន្តា ហោតិ សមិតា វូបសន្តា អត្ថង្គតា អព្ភត្ថង្គតា អប្បិតា ព្យប្បិតា សោសិតា វិសោសិតា ព្យន្តីកតា តេន វុច្ចតិ វិចិកិច្ឆំ បហាយាតិ ។

[៣៩០] តិណ្ណវិចិកិច្ឆោតិ ឥមំ វិចិកិច្ឆំ តិណ្ណោ ហោតិ ឧត្តិណ្ណោ និត្តិណ្ណោ បារគតោ បារមនុប្បត្តោ តេន វុច្ចតិ តិណ្ណវិចិកិច្ឆោតិ ។

សេចក្ដីសាំញ៉ាំនៃចិត្ត ណា នេះហៅថា កុក្កុច្ចៈ ។ បណ្ដាធម៌ទាំងនោះ ចិត្ត តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាជ្ញា ។ បេ ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ ណា នេះហៅថា ចិត្ត ។ ភិក្ខុញ៉ាំងចិត្តនេះ ឲ្យស្អាត ឲ្យបរិសុទ្ធ ឲ្យផូរផង់ ឲ្យរួច ឲ្យរួចស្រឡះ ឲ្យរបូតចេញ ចាកឧទ្ធច្ចៈនិងកុក្កុច្ចៈនេះ ព្រោះហេតុនោះ ទើបពោលថា ជម្រះចិត្តឲ្យស្អាតចាកឧទ្ធច្ចៈនិងកុក្កុច្ចៈ ។

[៣៨៩] ត្រង់ពាក្យថា លះបង់វិចិកិច្ឆា សេចក្ដីថា បណ្ដាធម៌ទាំងនោះ វិចិកិច្ឆា តើដូចម្ដេច ។ ការងឿងឆ្ងល់ អាការងឿងឆ្ងល់ ភាពងឿងឆ្ងល់ ការប្រាសចាកគំនិត ការសន្ទិះសង្ស័យ ការកន្ទែកចិត្ត ការបែកផ្លូវពីរ ការសង្ស័យ ការកាន់យកចំណែកច្រើនយ៉ាង ការអង្គឹអង្គែ ការអល់អែក ការមិនកាន់យកជាកំណត់ ភាពនៃចិត្តរឹងត្អឹង ការរសេមរសាមនៃចិត្ត ណា នេះហៅថា វិចិកិច្ឆា ។ វិចិកិច្ឆានេះ ជាធម្មជាតិស្ងប់រម្ងាប់ រលត់ ខ្ចាត់ចេញ វិនាសសាបសូន្យ ខូចខាត ហីនហោច រីង ស្ងួត ធ្វើឲ្យអស់ទៅ ព្រោះហេតុនោះ ទើបពោលថា លះបង់វិចិកិច្ឆា ។

[៣៩០] ត្រង់ពាក្យថា ជាអ្នកឆ្លងផុតចាកវិចិកិច្ឆា គឺ ភិក្ខុជាអ្នកឆ្លង ឆ្លងឡើង ឆ្លងកាត់ នូវវិចិកិច្ឆានេះ ហើយទៅកាន់ត្រើយដល់ត្រើយ ព្រោះហេតុនោះ ទើបពោលថា ជាអ្នកឆ្លងផុតចាកវិចិកិច្ឆា ។

[៣៩១] វិហរតីតិ ឥរិយតិ ។ បេ ។ វិហរតិ តេន វុច្ចតិ វិហរតីតិ ។

[៣៩២] អកថង្កថីតិ កុសលេសុ ធម្មេសូតិ ឥមាយ វិចិកិច្ឆាយ កុសលេសុ ធម្មេសុ ន កង្ខតិ ន វិចិកិច្ឆតិ អកថង្កថី ហោតិ និក្កថង្កថោ វិគតកថង្កថោ តេន វុច្ចតិ អកថង្កថី កុសលេសុ ធម្មេសូតិ ។

[៣៩៣] វិចិកិច្ឆាយ ចិត្តំ បរិសោធេតីតិ តត្ថ កតមា វិចិកិច្ឆា ។ យា កង្ខា កង្ខាយនា កង្ខាយិតត្តំ ។ បេ ។ ថម្ភិតត្តំ ចិត្តស្ស មនោវិលេខោ អយំ វុច្ចតិ វិចិកិច្ឆា ។ តត្ថ កតមំ ចិត្តំ ។ យំ ចិត្តំ មនោ មានសំ ។ បេ ។ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ ចិត្តំ ។ ឥទំ ចិត្តំ ឥមាយ វិចិកិច្ឆាយ សោធេតិ វិសោធេតិ បរិសោធេតិ មោចេតិ វិមោចេតិ បរិមោចេតិ តេន វុច្ចតិ វិចិកិច្ឆាយ ចិត្តំ បរិសោធេតីតិ ។

[៣៩១] ត្រង់ពាក្យថា សម្រេចឥរិយាបថ គឺ សម្រេច ។ បេ ។ នៅ ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

[៣៩២] ត្រង់ពាក្យថា អ្នកមិនមានសេចក្ដីងឿងឆ្ងល់ ក្នុងពួកធម៌ជាកុសល គឺ ភិក្ខុ មិនងឿងឆ្ងល់ មិនសន្ទិះ ក្នុងពួកធម៌ជាកុសល ដោយវិចិកិច្ឆានេះ គឺជាអ្នកមិនសង្ស័យ ឥតមានសេចក្ដីងឿងឆ្ងល់ ប្រាសចាកសេចក្ដីសង្ស័យ ព្រោះហេតុនោះ ទើបពោលថា អ្នកមិនមានសេចក្ដីងឿងឆ្ងល់ ក្នុងពួកធម៌ជាកុសល ។

[៣៩៣] ត្រង់ពាក្យថា ជម្រះចិត្តឲ្យស្អាត ចាកវិចិកិច្ឆា ។ សេចក្ដីថា បណ្ដាធម៌ទាំងនោះ វិចិកិច្ឆា តើដូចម្ដេច ។ ការងឿងឆ្ងល់ អាការងឿងឆ្ងល់ ភាពនៃសេចក្ដីងឿងឆ្ងល់ ។ បេ ។ ភាពនៃចិត្តរឹងត្អឹង ការសេមរសាមនៃចិត្ត ណា នេះហៅថា វិចិកិច្ឆា ។ បណ្ដាធម៌ទាំងនោះ ចិត្ត តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ។ បេ ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ ណា នេះហៅថា ចិត្ត ។ ភិក្ខុញុំាងចិត្តនេះ ឲ្យស្អាត ឲ្យបរិសុទ្ធ ឲ្យផូរផង់ ឲ្យរួច ឲ្យរួចស្រឡះ ឲ្យរបូតចេញ ចាកវិចិកិច្ឆានេះ ព្រោះហេតុនោះ ទើបពោលថា ជម្រះចិត្តឲ្យស្អាតចាកវិចិកិច្ឆា ។

[៣៩៤] ឥមេ បញ្ច នីវរណេ បហាយាតិ ឥមេ បញ្ច នីវរណា សន្តា ហោន្តិ សមិតា វូបសន្តា អត្ថង្គតា អព្ភត្ថង្គតា អប្បិតា ព្យប្បិតា សោសិតា វិសោសិតា ព្យន្តីកតា តេន វុច្ចតិ ឥមេ បញ្ច នីវរណេ បហាយាតិ ។

[៣៩៥] ចេតសោ ឧបក្កិលេសេតិ ឥមេ បញ្ច នីវរណា ចិត្តស្ស ឧបក្កិលេសា ។

[៣៩៦] បញ្ញាយ ទុព្វលីករណេតិ ឥមេហិ បញ្ចហិ នីវរណេហិ អនុប្បន្នា ចេវ បញ្ញា ន ឧប្បជ្ជតិ ឧប្បន្នា ច បញ្ញា និរុជ្ឈតិ តេន វុច្ចតិ បញ្ញាយ ទុព្វលីករណេតិ ។

[៣៩៧] វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហីតិ តត្ថ កតមេ កាមា ។ ឆន្ទោ កាមោ រាគោ កាមោ ឆន្ទរាគោ កាមោ សង្កប្បោ កាមោ រាគោ កាមោ សង្កប្បរាគោ កាមោ ឥមេ វុច្ចន្តិ កាមា ។ តត្ថ កតមេ អកុសលា ធម្មា ។ កាមច្ឆន្ទោ ព្យាបាទោ ថីនមិទ្ធំ ឧទ្ធច្ចកុក្កុច្ចំ វិចិកិច្ឆា ឥមេ វុច្ចន្តិ អកុសលា ធម្មា ។

[៣៩៤] ត្រង់ពាក្យថា លះបង់នីវរណៈទាំង ៥ នេះ សេចក្តីថា នីវរណៈទាំង ៥ នេះ ជាធម៌ស្ងប់រម្ងាប់ រលត់ ខ្ចាត់ចេញ វិនាស សាបសូន្យ ខូចខាត ហិនហោច រីង ស្ងួត ធ្វើឲ្យអស់ទៅ ព្រោះ ហេតុនោះ ទើបពោលថា លះបង់នីវរណៈទាំង ៥ នេះ ។

[៣៩៥] ត្រង់ពាក្យថា ជាគ្រឿងសៅហ្មងនៃចិត្ត គឺ នីវរណៈ ទាំង ៥ នេះ ជាគ្រឿងសៅហ្មងនៃចិត្ត ។

[៣៩៦] ត្រង់ពាក្យថា ជាគ្រឿងធ្វើបញ្ញាឲ្យមានកម្លាំងថយ គឺ បញ្ញាដែលមិនទាន់កើត ក៏មិនកើតឡើងផង បញ្ញាដែលកើតឡើង ហើយ ក៏រលត់ទៅវិញផង ព្រោះនីវរណៈទាំង ៥ នេះ ព្រោះហេតុនោះ ទើបពោលថា ជាគ្រឿងធ្វើបញ្ញាឲ្យមានកម្លាំងថយ ។

[៣៩៧] ត្រង់ពាក្យថា ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុ-សលធម៌ទាំងឡាយ សេចក្តីថា បណ្តាធម៌ទាំងនោះ កាមទាំងឡាយ តើ ដូចម្តេច ។ ឆន្ទៈ ឈ្មោះថាកាម រាគៈ ឈ្មោះថាកាម ឆន្ទរាគៈ ឈ្មោះថា កាម ការត្រិះរិះ ឈ្មោះថាកាម រាគៈ ឈ្មោះថាកាម ការត្រិះរិះនិងរាគៈ ឈ្មោះថាកាម កិលេសទាំងនេះ ហៅថា កាម ។ បណ្តាធម៌ទាំងនោះ ពួកធម៌ជាអកុសល តើដូចម្តេច ។ កាមច្ឆន្ទៈ ព្យាបាទៈ ថីនមិទ្ធៈ ឧទ្ធច្ចកុក្កុច្ចៈ វិចិកិច្ឆា ពួកកិលេសទាំងនេះ ហៅថា អកុសលធម៌ ។

ឥតិ ឥមេហិ ច កាមេហិ ឥមេហិ ច អកុស-
លេហិ ធម្មេហិ វិវិត្តោ ហោតិ តេន វុច្ចតិ វិវិច្ចេវ
កាមេហិ វិវិច្ច អកុសលេហិ ធម្មេហីតិ ។

[៣៩៨] សវិតក្កំ សវិចារន្តិ អត្ថិ វិតក្កោ
អត្ថិ វិចារោ ។ តត្ថ កតមោ វិតក្កោ ។ យោ
តក្កោ វិតក្កោ សង្កប្បោ អប្បនា ព្យប្បនា ចេ-
តសោ អភិនិរោបនា សម្មាសង្កប្បោ អយំ វុច្ចតិ
វិតក្កោ ។ តត្ថ កតមោ វិចារោ ។ យោ ចារោ
វិចារោ អនុវិចារោ ឧបវិចារោ ចិត្តស្ស អនុសន្ធ-
នតា អនុបេក្ខនតា អយំ វុច្ចតិ វិចារោ ។ ឥតិ
ឥមិនា ច វិតក្កេន ឥមិនា ច វិចារេន ឧបេតោ
ហោតិ ។ បេ ។ សមន្នាគតោ តេន វុច្ចតិ សវិតក្កំ
សវិចារន្តិ ។

[៣៩៩] វិវេកជន្តិ វិតក្កោ វិចារោ បីតិ សុខំ
ចិត្តស្ស ឯកគ្គតា តេ ឥមស្មិំ វិវេកេ ជាតា ហោន្តិ
សញ្ជាតា និព្វត្តា អភិនិព្វត្តា បាតុភូតា តេន វុច្ចតិ
វិវេកជន្តិ ។

ភិក្ខុជាអ្នកស្ងាត់ ចាកកាមទាំងនេះផង ចាកអកុសលធម៌ទាំងនេះផង ព្រោះហេតុនោះ ទើបពោលថា ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ដោយប្រការដូច្នេះ ។

[៣៩៨] ត្រង់ពាក្យថា ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ មានសេចក្ដីថា វិតក្កៈក៏មាន វិចារៈក៏មាន ។ បណ្ដាធម៌ទាំងនោះ វិតក្កៈ តើដូចម្ដេច ។ ការត្រិះរិះ ការរិះគិត តម្រិះ រំពឹង ជញ្ជឹង ការលើកឡើងនូវចិត្ត សម្មាសង្កប្បៈ ណា នេះហៅថា វិតក្កៈ ។ បណ្ដាធម៌ទាំងនោះ វិចារៈ តើដូចម្ដេច ។ ការត្រួតត្រា ពិចារណា ពិចារណារឿយ ៗ ពិនិត្យមើល សម្រឹងរឿយ ៗ នៃចិត្ត សង្កេតឃើញរឿយ ៗ នៃចិត្ត ណា នេះហៅថា វិចារៈ ។ ភិក្ខុជាអ្នកព្រមព្រៀង ។ បេ ។ ប្រកបព្រម ដោយវិតក្កៈនេះផង ដោយវិចារៈនេះផង ព្រោះហេតុនោះ ទើបពោលថា ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ ដោយប្រការដូច្នេះ ។

[៣៩៩] ត្រង់ពាក្យថា កើតក្នុងវិវេក គឺ វិតក្កៈ វិចារៈ បីតិ សុខ ឯកគ្គតា នៃចិត្ត ធម៌ទាំងនោះ កើត ដុះដាល លូតលាស់ ចម្រើន កើតប្រាកដ ក្នុងវិវេកនេះ ព្រោះហេតុនោះ ទើបពោលថា កើតក្នុងវិវេក ។

[៤០០] បីតិសុខន្តិ អត្ថិ បីតិ អត្ថិ សុខំ ។ តត្ថ កតមា បីតិ ។ យា បីតិ ចាមោជ្ជំ អាមោ-ទនា បមោទនា ហាសោ បហាសោ វិត្តិ ឱទគ្យំ អត្តមនតា ចិត្តស្ស អយំ វុច្ចតិ បីតិ ។ តត្ថ កតមំ សុខំ ។ យំ ចេតសិកំ សាតំ ចេតសិកំ សុខំ ចេតោសម្ផស្សជំ សាតំ សុខំ វេទយិតំ ចេតោសម្ផ-ស្សជា សាតា សុខា វេទនា ឥទំ វុច្ចតិ សុខំ ។ ឥទំ សុខំ ឥមាយ បីតិយា សហគតំ ហោតិ ស-ហជាតំ សំសដ្ឋំ សម្បយុត្តំ តេន វុច្ចតិ បីតិសុខន្តិ ។

[៤០១] បឋមន្តិ គណនានុបុព្វតោ បឋមំ ឥទំ បឋមំ សមាបជ្ជតីតិ បឋមំ ។

[៤០២] ឈានន្តិ វិតក្កោ វិចារោ បីតិ សុខំ ចិត្តស្ស ឯកគ្គតា ។

[៤០៣] ឧបសម្បជ្ជាតិ យោ បឋមស្ស ឈា-នស្ស លាភោ បដិលាភោ បត្តិ សម្បត្តិ ផុសនា សច្ឆិកិរិយា ឧបសម្បទា ។

[៤០០] ត្រង់ពាក្យថា បីតិ និងសុខ សេចក្ដីថា បីតិក៏មាន សុខក៏មាន ។ បណ្ដាធម៌ទាំងនោះ បីតិ តើដូចម្ដេច ។ សេចក្ដីឆ្អែតចិត្ត រីករាយ សប្បាយ ស្រស់ស្រាយ ញញឹម ស្រស់បស់ត្រេកអរ អណ្ដែតអណ្ដូង ភាពនៃចិត្តត្រេកអរ ណា នេះហៅថា បីតិ ។ បណ្ដាធម៌ទាំងនោះ សុខ តើដូចម្ដេច ។ សេចក្ដីត្រេកអរប្រព្រឹត្តទៅក្នុងចិត្ត សេចក្ដីសុខ ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ជាទីត្រេកអរ ជាសុខ ដែលកើតអំពីចេតោសម្ផស្ស សុខវេទនាជាទីត្រេកអរ ដែលកើតអំពីចេតោសម្ផស្ស ណា នេះហៅថា សុខ ។ សេចក្ដីសុខនេះ ជាធម្មជាតប្រព្រឹត្តទៅជាមួយ កើតជាមួយ ច្រឡំប្រកប ដោយបីតិនេះ ព្រោះហេតុនោះ ទើបពោលថា បីតិនិងសុខ ។

[៤០១] ត្រង់ពាក្យថា បឋម គឺ ទីមួយ ដោយលំដាប់នៃគិរិយារាប់ បុគ្គលរមែងចូលកាន់ឈានទីមួយនេះ ព្រោះហេតុនោះ ទើបពោលថា បឋម ។

[៤០២] ត្រង់ពាក្យថា ឈាន គឺ វិតក្កៈ វិចារៈ បីតិ សុខ ឯកគ្គតា នៃចិត្ត ។

[៤០៣] ត្រង់ពាក្យថា ចូល គឺ ការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ ការធ្វើឲ្យជាក់ច្បាស់ ការបំពេញនូវបឋមជ្ឈាន ។

[៤០៤] វិហរតីតិ ឥរិយតិ ។ បេ ។ វិហរតិ តេន វុច្ចតិ វិហរតីតិ ។

[៤០៥] វិតក្កវិចារជំ រូបសមាតិ អត្ថិ វិតក្កោ អត្ថិ វិចារោ ។ តត្ថ កតមោ វិតក្កោ ។ យោ តក្កោ វិតក្កោ ។ បេ ។ សម្មាសង្កប្បោ អយំ វុច្ចតិ វិតក្កោ ។ តត្ថ កតមោ វិចារោ ។ យោ ចារោ វិចារោ អនុវិចារោ ឧបវិចារោ ចិត្តស្ស អនុសន្ធ-នតា អនុបេក្ខនតា អយំ វុច្ចតិ វិចារោ ។ ឥតិ អយញ្ច វិតក្កោ អយញ្ច វិចារោ សន្តា ហោន្តិ សមិតា វូបសន្តា អត្ថង្គតា អព្ភត្ថង្គតា អប្បីតា ព្យប្បីតា សោសិតា វិសោសិតា ព្យន្តីកតា តេន វុច្ចតិ វិតក្កវិចារជំ វូបសមាតិ ។

[៤០៦] អជ្ឈត្តន្តិ យំ អជ្ឈត្តំ បច្ចត្តំ ។ ស-ម្បសាទនន្តិ យា សទ្ធា សទ្ទហនា ឱកប្បនា អ-ភិប្បសាទោ ។

[៤០៧] ចេតសោ ឯកោទិភាវន្តិ យា ចិត្ត-ស្ស ឋិតិ ។ បេ ។ សម្មាសមាធិ ។

[៤០៤] ត្រង់ពាក្យថា សម្រេចឥរិយាបថ គឺ សម្រេច ។ បេ ។ នៅ ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

[៤០៥] ត្រង់ពាក្យថា ព្រោះរម្ងាប់ នូវវិតក្កៈនិងវិចារៈ សេចក្តីថា វិតក្កៈក៏មាន វិចារៈក៏មាន ។ បណ្តាធម៌ទាំងនោះ វិតក្កៈ តើដូចម្តេច ។ ការត្រិះរិះ ការរិះគិត ។ បេ ។ សម្មាសង្កប្បៈ ណា នេះហៅថា វិតក្កៈ ។ បណ្តាធម៌ទាំងនោះ វិចារៈ តើដូចម្តេច ។ ការត្រួតត្រា ពិចារណា ពិចារណារឿយ ៗ ពិនិត្យមើល សម្រឹងរឿយ ៗ នៃចិត្ត សង្កេតឃើញរឿយ ៗ នៃចិត្ត ណា នេះហៅថា វិចារៈ ។ វិតក្កៈនេះផង វិចារៈនេះផង ជាធម៌ស្ងប់រម្ងាប់ រលត់ ខ្ចាត់ចេញ វិនាស សាបសូន្យ ខូចខាត ហីនហោច រីង ស្ងួត ធ្វើឲ្យអស់ទៅ ព្រោះហេតុនោះ ទើបពោលថា ព្រោះរម្ងាប់ នូវវិតក្កៈនិងវិចារៈ ដោយប្រការដូច្នេះ ។

[៤០៦] ត្រង់ពាក្យថា ខាងក្នុងសន្តាន គឺ ជាក់ច្បាស់ខាងក្នុងសន្តាន ។ ពាក្យថា ជ្រះថ្លាស៊ប់ គឺ សទ្ធា អាការជឿ អាការចុះចិត្តស៊ប់ សេចក្តីជ្រះថ្លាក្រៃលែង ។

[៤០៧] ត្រង់ពាក្យថា មានសភាពជាចិត្តខ្ពស់ឯក បានដល់ការឋិតនៅនៃចិត្ត ។ បេ ។ សម្មាសមាធិ ។

[៤០៨] អវិតក្កំ អវិចារន្តិ អត្ថិ វិតក្កោ អត្ថិ វិចារោ ។ តត្ថ កតមោ វិតក្កោ ។ យោ តក្កោ វិតក្កោ ។ បេ ។ សម្មាសង្កប្បោ អយំ វុច្ចតិ វិតក្កោ ។ តត្ថ កតមោ វិចារោ ។ យោ ចារោ វិចារោ អនុវិចារោ ឧបវិចារោ ចិត្តស្ស អនុសន្ធនតា អនុ-បេក្ខនតា អយំ វុច្ចតិ វិចារោ ។ ឥតិ អយញ្ច វិតក្កោ អយញ្ច វិចារោ សន្តា ហោន្តិ សមិតា វូបសន្តា អត្ថង្គតា អព្ភត្ថង្គតា អប្បីតា ព្យប្បីតា សោសិតា វិសោសិតា ព្យន្តីកតា តេន វុច្ចតិ អ-វិតក្កំ អវិចារន្តិ ។

[៤០៩] សមាធិជន្តិ សម្បសាទោ បីតិ សុខំ ចិត្តស្ស ឯកគ្គតា តេ ឥមម្ហិ សមាធិម្ហិ ជាតា ហោន្តិ សញ្ជាតា និព្វត្តា អភិនិព្វត្តា ចាតុភូតា តេន វុច្ចតិ សមាធិជន្តិ ។

[៤១០] បីតិសុខន្តិ អត្ថិ បីតិ អត្ថិ សុខំ ។ តត្ថ កតមា បីតិ ។ យា បីតិ ចាមោជ្ជំ ។ បេ ។ អត្តមនតា ចិត្តស្ស អយំ វុច្ចតិ បីតិ ។

[៦០៨] ត្រង់ពាក្យថា មិនមានវិតក្កៈ មិនមានវិចារៈ សេចក្តីថា វិតក្កៈក៏មាន វិចារៈក៏មាន ។ បណ្តាធម៌ទាំងនោះ វិតក្កៈ តើដូចម្តេច ។ ការត្រិះរិះ ការរិះគិត ។ បេ ។ សម្មាសង្កប្បៈ ណា នេះហៅថា វិតក្កៈ ។ បណ្តាធម៌ទាំងនោះ វិចារៈ តើដូចម្តេច ។ ការត្រួតត្រា ពិចារណា ពិចារណារឿយ ៗ ពិនិត្យមើល សម្រឹងរឿយ ៗ នៃចិត្ត សង្កេតឃើញរឿយ ៗ នៃចិត្ត ណា នេះហៅថា វិចារៈ ។ វិតក្កៈនេះផង វិចារៈនេះផង ជាធម៌ស្ងប់រម្ងាប់ រលត់ ខ្ចាត់ចេញ វិនាស សាបសូន្យ ខូចខាត ហីនហោច រីង ស្ងួត ធ្វើឲ្យអស់ទៅ ព្រោះហេតុនោះ ទើបពោលថា មិនមានវិតក្កៈ មិនមានវិចារៈ ដោយប្រការដូច្នេះ ។

[៦០៩] ត្រង់ពាក្យថា កើតក្នុងសមាធិ គឺ សេចក្តីជ្រះថ្លាស៊ប់ បីតិ សុខ ឯកគ្គតានៃចិត្ត ធម៌ទាំងនោះ កើត ដុះដាល លូតលាស់ ចម្រើន កើតប្រាកដហើយ ក្នុងសមាធិនេះ ព្រោះហេតុនោះ ទើបពោលថា កើតក្នុងសមាធិ ។

[៦១០] ត្រង់ពាក្យថា បីតិនិងសុខ សេចក្តីថា បីតិក៏មាន សុខក៏មាន ។ បណ្តាធម៌ទាំងនោះ បីតិ តើដូចម្តេច ។ បីតិ (សេចក្តីឆ្អែតចិត្ត) ការរីករាយ ។ បេ ។ ភាពនៃចិត្តត្រេកអរ ណា នេះហៅថា បីតិ ។

តត្ថ កតមំ សុខំ ។ យំ ចេតសិកំ សាតំ ។ បេ ។ សុខា វេទនា ឥទំ វុច្ចតិ សុខំ ។ ឥទំ សុខំ ឥមាយ បីតិយា សហគតំ ហោតិ សហជាតំ សំសដ្ឋំ សម្ប-យុត្តំ តេន វុច្ចតិ បីតិសុខន្តិ ។

[៤១១] ទុតិយន្តិ គណនានុបុព្វតោ ទុតិយំ ឥទំ ទុតិយំ សមាបជ្ជតីតិ ទុតិយំ ។

[៤១២] ឈានន្តិ សម្បសាទោ បីតិ សុខំ ចិត្តស្ស ឯកគ្គតា ។

[៤១៣] ឧបសម្បជ្ជាតិ យោ ទុតិយស្ស ឈា-នស្ស លាភោ បដិលាភោ បត្តិ សម្បត្តិ ផុសនា សច្ឆិកិរិយា ឧបសម្បទា ។

[៤១៤] វិហរតីតិ ឥរិយតិ ។ បេ ។ វិហរតិ តេន វុច្ចតិ វិហរតីតិ ។

[៤១៥] បីតិយា ច វិរាគាតិ តត្ថ កតមា បីតិ ។ យា បីតិ បាមោជ្ជំ អាមោទនា បមោទ-នា ហាសោ បហាសោ វិត្តិ ឱទគ្យំ អត្តមនតា ចិត្តស្ស អយំ វុច្ចតិ បីតិ អយំ បីតិ សន្តា ហោតិ

បណ្ដាធម៌ទាំងនោះ សុខ តើដូចម្ដេច ។ សេចក្ដីត្រេកអរ ប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សុខវេទនា នេះហៅថា សុខ ។ សុខនេះ ជាធម្មជាតប្រព្រឹត្តទៅជាមួយ កើតជាមួយ ច្រឡំ ប្រកប ដោយបីតិ នេះ ព្រោះហេតុនោះ ទើបពោលថា បីតិនិងសុខ ។

[៤១១] ត្រង់ពាក្យថា ទុតិយៈ គឺ គម្រប់ពីរ ដោយលំដាប់នៃ គិរិយារាប់ បុគ្គលចូលកាន់ឈានទីពីរនេះ ព្រោះហេតុនោះ ទើបឈ្មោះ ថា ទុតិយៈ ។

[៤១២] ត្រង់ពាក្យថា ឈាន គឺ សេចក្ដីជ្រះថ្លាស៊ប់ បីតិ សុខ ឯកគ្គតានៃចិត្ត ។

[៤១៣] ត្រង់ពាក្យថា ចូល គឺ ការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ ការធ្វើឲ្យជាក់ច្បាស់ ការបំពេញ នូវទុតិយជ្ឈាន ។

[៤១៤] ត្រង់ពាក្យថា សម្រេចឥរិយាបថ គឺ សម្រេច ។ បេ ។ នៅ ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

[៤១៥] ត្រង់ពាក្យថា ព្រោះនឿយណាយចាកបីតិ សេចក្ដីថា បណ្ដា ធម៌ទាំងនោះ បីតិ តើដូចម្ដេច ។ សេចក្ដីឆ្អែតចិត្ត រីករាយ សប្បាយ ស្រស់ស្រាយ ស្រស់បស់ ញញឹម ត្រេកអរ អណ្ដែតអណ្ដូង ភាព នៃចិត្តត្រេកអរ ណា នេះហៅថា បីតិ បីតិនេះ ជាធម្មជាតស្ងប់រម្ងាប់

សមិតា រូបសទ្ធា អត្តង្គតា អព្ភុត្តង្គតា អប្បីតា ព្យប្បីតា សោសិតា វិសោសិតា ព្យន្តីកតា តេន វុច្ចតិ បីតិយា ច វិរាគាតិ ។

[៥១៦] ឧបេក្ខកោតិ តត្ថ កាតមា ឧបេក្ខា ។ យា ឧបេក្ខា ឧបេក្ខនា អជ្ឈុបេក្ខនា មជ្ឈត្តតា ចិត្តស្ស អយំ វុច្ចតិ ឧបេក្ខា ឥមាយ ឧបេក្ខាយ ឧបេតោ ហោតិ ។ បេ ។ សមន្នាគតោ តេន វុច្ចតិ ឧបេក្ខកោតិ ។

[៥១៧] វិហរតីតិ ឥរិយតិ ។ បេ ។ វិហរតិ តេន វុច្ចតិ វិហរតីតិ ។

[៥១៨] សតិ ច សម្បជានោតិ តត្ថ កា-តមា សតិ ។ យា សតិ អនុស្សតិ ។ បេ ។ សម្មាសតិ អយំ វុច្ចតិ សតិ ។ តត្ថ កាតមំ សម្បជញ្ញំ ។ យា បញ្ញា បជានានា ។ បេ ។ អ-មោហោ ធម្មវិចយោ សម្មាទិដ្ឋិ ឥទំ វុច្ចតិ សម្ប-ជញ្ញំ ។ ឥតិ ឥមាយ ច សតិយា ឥមិនា ច សម្បជញ្ញេន ឧបេតោ ហោតិ ។ បេ ។ សមន្នា-គតោ តេន វុច្ចតិ សតោ ច សម្បជានោតិ ។

រលត់ ខ្ចាត់ចេញ វិនាស សាបសូន្យ ខូចខាត ហិនហោច រីង ស្ងួត ធ្វើឲ្យអស់ទៅ ព្រោះហេតុនោះ ទើបពោលថា ព្រោះនឿយ ណាយចាកបីតិ ។

[៤១៦] ត្រង់ពាក្យថា ប្រកបដោយឧបេក្ខា សេចក្តីថា បណ្តាធម៌ ទាំងនោះ ឧបេក្ខា តើដូចម្តេច ។ ការព្រងើយកន្តើយ អាការព្រងើយ កន្តើយ អាការសម្លឹងឃើញជាក់ ភាពនៃចិត្តជាកណ្តាល ណា នេះ ហៅថា ឧបេក្ខា បុគ្គលជាអ្នកព្រមព្រៀង ។ បេ ។ ប្រកបព្រម ដោយ ឧបេក្ខានេះ ព្រោះហេតុនោះ ទើបពោលថា ប្រកបដោយឧបេក្ខា ។

[៤១៧] ត្រង់ពាក្យថា សម្រេចឥរិយាបថ គឺសម្រេច ។ បេ ។ នៅ ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

[៤១៨] ត្រង់ពាក្យថា មានស្មារតី ដឹងខ្លួន ។ បណ្តា ពាក្យទាំងនោះ ស្មារតី តើដូចម្តេច ។ ការរលឹក ការនឹកឃើញ ។ បេ ។ ការរលឹកត្រូវ ណា នេះហៅថា ស្មារតី ។ បណ្តា ពាក្យទាំងនោះ ការដឹងខ្លួន តើដូចម្តេច ។ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការសង្កេតនូវធម៌ សេចក្តីឃើញត្រូវ ណា នេះហៅថា ការដឹងខ្លួន ។ បុគ្គលជាអ្នកព្រមព្រៀង ។ បេ ។ ប្រកប ព្រម ដោយស្មារតីនេះផង ដោយការដឹងខ្លួននេះផង ព្រោះហេតុនោះ ទើបពោលថា មានស្មារតី ដឹងខ្លួន ។

[៤១៩] សុខញ្ច កាយេន បដិសំវេទេតីតិ តត្ថ កតមំ សុខំ ។ យំ ចេតសិកំ សាតំ ចេតសិកំ សុខំ ចេតោសម្ផស្សជំ សាតំ សុខំ វេទយិតំ ចេតោសម្ផស្សជា សាតា សុខា វេទនា ឥទំ វុច្ចតិ សុខំ ។ តត្ថ កតមោ កាយោ ។ សញ្ញាខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ អយំ វុច្ចតិ កាយោ ។ ឥទំ សុខំ ឥមិនា កាយេន បដិសំវេទេតិ តេន វុច្ចតិ សុខញ្ច កាយេន បដិសំវេទេតិ ។

[៤២០] យន្តំ អរិយា អាចិក្ខន្តីតិ តត្ថ កតមេ អរិយា ។ អរិយា វុច្ចន្តិ ពុទ្ធា ច ពុទ្ធសាវកា ច តេ ឥមំ អាចិក្ខន្តិ ទេសេន្តិ បញ្ញាបេន្តិ បដ្ឋបេន្តិ វិវរន្តិ វិភជន្តិ ឧត្តានីករោន្តិ បកាសេន្តិ តេន វុច្ចតិ យន្តំ អរិយា អាចិក្ខន្តីតិ ។

[៤១៩] ត្រង់ពាក្យថា ទទួលសុខដោយនាមកាយ ។ បណ្តាពាក្យទាំងនោះ សុខ តើដូចម្តេច ។ សេចក្តីត្រេកអរ ប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីសុខ ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ ជាទីត្រេកអរ ជាសុខ ដែលកើតអំពីចេតោសម្ផស្ស សុខវេទនា ជាទីត្រេកអរ ដែលកើតអំពីចេតោសម្ផស្ស ណា នេះហៅថា សុខ ។ បណ្តាពាក្យទាំងនោះ នាមកាយ តើដូចម្តេច ។ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ នេះហៅថា នាមកាយ ។ បុគ្គលទទួលសេចក្តីសុខនេះ ដោយនាមកាយនេះ ព្រោះហេតុនោះ ទើបពោលថា ទទួលសុខ ដោយនាមកាយ ។

[៤២០] ត្រង់ពាក្យថា ព្រះអរិយៈទាំងឡាយ តែងសរសើរនូវបុគ្គលអ្នកព្រមព្រៀងដោយតតិយជ្ឈាននោះ សេចក្តីថា បណ្តាពាក្យទាំងនោះ ព្រះអរិយៈទាំងឡាយ តើដូចម្តេច ។ ព្រះពុទ្ធទាំងឡាយក្តី សាវ័កនៃព្រះពុទ្ធទាំងឡាយក្តី ហៅថា ព្រះអរិយៈ ពួកព្រះអរិយៈទាំងនោះ សរសើរ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាស នូវបុគ្គលអ្នកព្រមព្រៀងដោយតតិយជ្ឈាននេះ ព្រោះហេតុនោះ ទើបពោលថា ព្រះអរិយៈទាំងឡាយ តែងសរសើរនូវបុគ្គលអ្នកព្រមព្រៀងដោយតតិយជ្ឈាននោះ ។

[៤២១] ឧបេក្ខកោ សតិមា សុខវិហារីតិ តត្ថ កតមា ឧបេក្ខា ។ យា ឧបេក្ខា ឧបេក្ខ-ជា អជ្ឈុបេក្ខនា មជ្ឈត្តតា ចិត្តស្ស អយំ វុច្ចតិ ឧបេក្ខា ។ តត្ថ កតមា សតិ ។ យា សតិ អនុស្សតិ ។ បេ ។ សម្មាសតិ អយំ វុច្ចតិ សតិ ។ តត្ថ កតមំ សុខំ ។ យំ ចេតសិកំ សាតំ ចេ-តសិកំ សុខំ ចេតោសម្ផស្សជំ សាតំ សុខំ វេទ-យិតំ ចេតោសម្ផស្សជា សាតា សុខា វេទនា ឥទំ វុច្ចតិ សុខំ ។ ឥតិ ឥមាយ ឧបេក្ខាយ ឥមាយ ច សតិយា ឥមិនា ច សុខេន សមន្នាគតោ ឥរិយតិ វត្តតិ ចាលេតិ យបេតិ យាបេតិ ចរតិ វិហរតិ តេន វុច្ចតិ ឧបេក្ខកោ សតិមា សុខ-វិហារីតិ ។

[៤២២] តតិយន្តិ គណនានុបុព្វតោ[១] តតិយំ ឥទំ តតិយំ សមាបជ្ជតីតិ តតិយំ ។

---

១ ឱ. ម. គណនានុបុព្វតាតិ ទិស្សតិ ។

[៤២១] ត្រង់បទថា ជាអ្នកប្រកបដោយឧបេក្ខា មានស្មារតី នៅជាសុខ សេចក្ដីថា បណ្ដាពាក្យទាំងនោះ ឧបេក្ខា តើដូចម្ដេច ។ ការព្រងើយកន្ដើយ អាការព្រងើយកន្ដើយ អាការសម្លឹងឃើញជាក់ ភាពនៃចិត្តតាំងនៅជាកណ្ដាល ណា នេះហៅថា ឧបេក្ខា ។ បណ្ដាពាក្យទាំងនោះ ស្មារតី តើដូចម្ដេច ។ ការរឭក ការនឹកឃើញ ។ បេ ។ ការរឭកត្រូវ ណា នេះហៅថា ស្មារតី ។ បណ្ដាពាក្យទាំងនោះ សុខ តើដូចម្ដេច ។ សេចក្ដីត្រេកអរ ប្រព្រឹត្តទៅក្នុងចិត្ត សេចក្ដីសុខ ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ ជាទីត្រេកអរ ជាសុខ ដែលកើតអំពីចេតោសម្ផស្ស សុខវេទនា ជាទីត្រេកអរ ដែលកើតអំពីចេតោសម្ផស្ស នេះហៅថា សុខ ។ បុគ្គល ប្រកបដោយឧបេក្ខានេះផង ដោយស្មារតីនេះផង ដោយសុខនេះផង ហើយសម្រេចឥរិយាបថ ប្រព្រឹត្ត រក្សា រស់នៅ ញុំាងជីវិតឲ្យរស់នៅ ត្រាច់ទៅ សម្រាកនៅ ព្រោះហេតុនោះ ទើបពោលថា ជាអ្នកប្រកបដោយឧបេក្ខា មានស្មារតី នៅជាសុខ ។

[៤២២] ត្រង់ពាក្យថា តតិយៈ គឺជាគម្រប់បី ដោយលំដាប់នៃកិរិយារាប់ បុគ្គលចូលកាន់តតិយជ្ឈាននេះ ព្រោះហេតុនោះ ទើបឈ្មោះថា តតិយៈ ។

[៥២៣] ឈានន្តិ ឧបេក្ខា សតិ សម្បជញ្ញំ សុខំ ចិត្តស្ស ឯកគ្គតា ។

[៥២៤] ឧបសម្បជ្ជាតិ យោ តតិយស្ស ឈា-នស្ស លាភោ បដិលាភោ បត្តិ សម្បត្តិ ផុសនា សច្ឆិកិរិយា ឧបសម្បទា ។

[៥២៥] វិហរតីតិ ឥរិយតិ ។ បេ ។ វិហរតិ តេន វុច្ចតិ វិហរតីតិ ។

[៥២៦] សុខស្ស ច បហានា ទុក្ខស្ស ច បហានាតិ អត្ថិ សុខំ អត្ថិ ទុក្ខំ ។ តត្ថ កតមំ សុខំ ។ យំ កាយិកំ សាតំ កាយិកំ សុខំ កាយសម្ផស្សជំ សាតំ សុខំ វេទយិតំ កាយសម្ផ-ស្សជា សាតា សុខា វេទនា ឥទំ វុច្ចតិ សុខំ ។ តត្ថ កតមំ ទុក្ខំ ។ យំ កាយិកំ អសាតំ កាយិកំ ទុក្ខំ កាយសម្ផស្សជំ អសាតំ ទុក្ខំ វេទយិតំ កាយសម្ផស្សជា អសាតា ទុក្ខា វេទនា

[៦២៣] ត្រង់ពាក្យថា ឈាន គឺ ឧបេក្ខា សតិ សម្ប-ជញ្ញៈ សុខ ឯកគ្គតានៃចិត្ត ។

[៦២៤] ត្រង់ពាក្យថា ចូល គឺការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ ការធ្វើឲ្យជាក់ច្បាស់ ការបំ-ពេញ នូវតតិយជ្ឈាន ។

[៦២៥] ត្រង់ពាក្យថា សម្រេចឥរិយាបថ គឺ សម្រេច ។ បេ ។ នៅ ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

[៦២៦] ត្រង់ពាក្យថា ព្រោះលះបង់សុខផង ព្រោះលះបង់ទុក្ខ ផង សេចក្តីថា សុខក៏មាន ទុក្ខក៏មាន ។ បណ្តាពាក្យទាំងនោះ សុខ តើ ដូចម្តេច ។ សេចក្តីត្រេកអរ ប្រព្រឹត្តទៅក្នុងកាយ សេចក្តីសុខ ប្រព្រឹត្ត ទៅក្នុងកាយ ការទទួលអារម្មណ៍ ជាទីត្រេកអរ ជាសុខ ដែលកើតអំពី កាយសម្ផស្ស សុខវេទនា ជាទីត្រេកអរ ដែលកើតអំពីកាយសម្ផស្ស ណា នេះហៅថា សុខ ។ បណ្តាធម៌ទាំងនោះ ទុក្ខ តើដូចម្តេច ។ សេចក្តីមិនត្រេកអរ ប្រព្រឹត្តទៅក្នុងកាយ សេចក្តីទុក្ខ ប្រព្រឹត្តទៅក្នុង កាយ ការទទួលអារម្មណ៍ មិនជាទីត្រេកអរ ជាទុក្ខ ដែលកើតអំពីកាយ-សម្ផស្ស ទុក្ខវេទនា មិនជាទីត្រេកអរ ដែលកើតអំពីកាយសម្ផស្ស ណា

ឥទំ វុច្ចតិ ទុក្ខំ ។ ឥតិ ឥទញ្ច សុខំ ឥទញ្ច ទុក្ខំ សន្តា ហោន្តិ សមិតា វូបសន្តា អត្ថង្គតា អព្ភត្ថង្គតា អប្បិតា ព្យប្បិតា សោសិតា វិសោសិតា ព្យន្តីកតា តេន វុច្ចតិ សុខស្ស ច បហានា ទុក្ខស្ស ច បហានាតិ ។

[៤២៧] បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមាតិ អត្ថិ សោមនស្សំ អត្ថិ ទោមនស្សំ ។ តត្ថ កតមំ សោមនស្សំ ។ យំ ចេតសិកំ សាតំ ចេតសិកំ សុខំ ចេតោសម្ផស្សជំ សាតំ សុខំ វេទយិតំ ចេតោសម្ផស្សជា សាតា សុខា វេទនា ឥទំ វុច្ចតិ សោមនស្សំ ។ តត្ថ កតមំ ទោមនស្សំ ។ យំ ចេតសិកំ អសាតំ ចេតសិកំ ទុក្ខំ ចេតោសម្ផស្សជំ អសាតំ ទុក្ខំ វេទយិតំ ចេតោសម្ផស្សជា អសាតា ទុក្ខា វេទនា ឥទំ វុច្ចតិ ទោមនស្សំ ។ ឥតិ ឥទញ្ច សោមនស្សំ ឥទញ្ច ទោមនស្សំ បុព្វេវ សន្តា ហោន្តិ សមិតា វូបសន្តា អត្ថង្គតា អព្ភត្ថង្គតា អប្បិតា ព្យប្បិតា សោសិតា វិសោសិតា ព្យន្តីកតា តេន វុច្ចតិ បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមាតិ ។

នេះហៅថា ទុក្ខ ។ សុខនេះផង ទុក្ខនេះផង ជាធម៌ស្ងប់រម្ងាប់ រលត់ ខ្ចាត់ចេញ វិនាស សាបសូន្យ ខូចខាត ហីនហោច រីង ស្ងួត ធ្វើឲ្យអស់ទៅ ព្រោះហេតុនោះ ទើបពោលថា ព្រោះលះបង់សុខផង ព្រោះលះបង់ទុក្ខផង ។

[៤២៧] ត្រង់ពាក្យថា ព្រោះវិនាសទៅ នៃសោមនស្ស និងទោមនស្ស ក្នុងកាលមុន សេចក្តីថា សោមនស្សក៏មាន ទោមនស្សក៏មាន ។ បណ្តាធម៌ទាំងនោះ សោមនស្ស តើដូចម្តេច ។ សេចក្តីត្រេកអរ ប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីសុខ ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ ជាទីត្រេកអរ ជាសុខ ដែលកើតអំពីចេតោសម្ផស្ស សុខ-វេទនា ជាទីត្រេកអរ ដែលកើតអំពីចេតោសម្ផស្ស ណា នេះហៅថា សោមនស្ស ។ បណ្តាធម៌ទាំងនោះ ទោមនស្ស តើដូចម្តេច ។ សេចក្តីមិនត្រេកអរ ប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីទុក្ខ ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ មិនជាទីត្រេកអរ ជាទុក្ខ ដែលកើតអំពីចេតោសម្ផស្ស ទុក្ខវេទនា មិនជាទីត្រេកអរ ដែលកើតអំពីចេតោសម្ផស្ស ណា នេះហៅថា ទោមនស្ស ។ សោមនស្សនេះផង ទោមនស្សនេះផង ជាធម៌ស្ងប់រម្ងាប់ រលត់ ខ្ចាត់ចេញ វិនាស សាបសូន្យ ខូចខាត ហីនហោច រីង ស្ងួត ធ្វើឲ្យអស់ទៅ ក្នុងកាលមុន ព្រោះហេតុនោះ ទើបពោលថា ព្រោះវិនាសទៅ នៃសោមនស្សនិងទោមនស្ស ក្នុងកាលមុន ។

[៤២៨] អទុក្ខមសុខន្តិ យំ ចេតសិកំ នេវ សាតំ នាសាតំ ចេតោសម្ផស្សជំ អទុក្ខមសុខំ វេ-ទយិតំ ចេតោសម្ផស្សជា អទុក្ខមសុខា វេទនា តេន វុច្ចតិ អទុក្ខមសុខន្តិ ។

[៤២៩] ឧបេក្ខាសតិបារិសុទ្ធិន្តិ តត្ថ កតមា ឧបេក្ខា ។ យា ឧបេក្ខា ឧបេក្ខនា អជ្ឈុបេក្ខនា មជ្ឈត្តតា ចិត្តស្ស អយំ វុច្ចតិ ឧបេក្ខា ។ តត្ថ កតមា សតិ ។ យា សតិ អនុស្សតិ ។ បេ ។ សម្មាសតិ អយំ វុច្ចតិ សតិ ។ អយំ សតិ ឥ-មាយ ឧបេក្ខាយ វិវដា ហោតិ បរិសុទ្ធា បរិយោ-ទាតា តេន វុច្ចតិ ឧបេក្ខាសតិបារិសុទ្ធិន្តិ ។

[៤៣០] ចតុត្ថន្តិ គណនានុបុព្វតោ[១] ចតុត្ថំ ឥទំ ចតុត្ថំ សមាបជ្ជតីតិ ចតុត្ថំ ។

[៤៣១] ឈានន្តិ ឧបេក្ខា សតិ ចិត្តស្ស ឯកគ្គតា ។

---

១ ឱ. ម. គណនានុបុព្វតាតិ ទិស្សន្តិ ។

[៤២៨] ត្រង់ពាក្យថា មិនជាទុក្ខ មិនជាសុខ គឺ សេចក្ដីត្រេកអរ ក៏មិនមែន សេចក្ដីមិនត្រេកអរក៏មិនមែន ដែលប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ មិនជាទុក្ខ មិនជាសុខ ដែលកើតអំពីចេតោសម្ផស្ស អទុក្ខមសុខវេទនា ដែលកើតអំពីចេតោសម្ផស្ស ណា ព្រោះហេតុនោះ ទើបពោលថា មិនជាទុក្ខ មិនជាសុខ ។

[៤២៩] ត្រង់ពាក្យថា មានសតិដ៏បរិសុទ្ធដោយឧបេក្ខា សេចក្ដីថា បណ្ដាធម៌ទាំងនោះ ឧបេក្ខា តើដូចម្ដេច ។ ការព្រងើយកន្តើយ អាការព្រងើយកន្តើយ អាការសម្ងឹងឃើញជាក់ ភាពនៃចិត្តតាំងនៅជាកណ្ដាល ណា នេះហៅថា ឧបេក្ខា ។ បណ្ដាពាក្យទាំងនោះ សតិ តើដូចម្ដេច ។ ការរឭក រឭកឃើញ ។ បេ ។ ការរឭកត្រូវ ណា នេះហៅថា សតិ ។ សតិនេះ ជាធម្មជាតិបើក បរិសុទ្ធ ផូរផង់ ដោយឧបេក្ខានេះ ព្រោះហេតុនោះ ទើបពោលថា មានសតិដ៏បរិសុទ្ធដោយឧបេក្ខា ។

[៤៣០] ត្រង់ពាក្យថា ចតុត្ថៈ គឺជាគម្រប់ ៤ ដោយលំដាប់នៃកិរិយារាប់ បុគ្គលចូលកាន់ឈានទី ៤ នេះ ព្រោះហេតុនោះ ទើបឈ្មោះថា ចតុត្ថៈ ។

[៤៣១] ត្រង់ពាក្យថា ឈាន គឺ ឧបេក្ខា សតិ ឯកគ្គតានៃចិត្ត ។

[៤៣២] ឧបសម្បជ្ជាតិ យោ ចតុត្ថស្ស ឈានស្ស លាភោ បដិលាភោ បត្តិ សម្បត្តិ ផុសនា សច្ឆិកិរិយា ឧបសម្បទា ។

[៤៣៣] វិហរតីតិ ឥរិយតិ ។ បេ ។ វិហរតិ តេន វុច្ចតិ វិហរតីតិ ។

[៤៣៤] សព្វសោ រូបសញ្ញានំ សមតិក្កមាតិ តត្ថ កតមា រូបសញ្ញាយោ ។ យា រូបាវចរសមាបត្តឹ សមាបន្នស្ស វា ឧបបន្នស្ស វា ទិដ្ឋធម្មសុខវិហារិស្ស វា សញ្ញា សញ្ជានានា សញ្ជានិតត្តំ ឥមា វុច្ចន្តិ រូបសញ្ញាយោ ឥមា រូបសញ្ញាយោ អតិក្កន្តោ ហោតិ វីតិក្កន្តោ សមតិក្កន្តោ តេន វុច្ចតិ សព្វសោ រូបសញ្ញានំ សមតិក្កមាតិ ។

[៤៣៥] បដិឃសញ្ញានំ អត្ថង្គមាតិ តត្ថ កតមា បដិឃសញ្ញាយោ ។ រូបសញ្ញា សទ្ទសញ្ញា គន្ធសញ្ញា រសសញ្ញា ផោដ្ឋព្វសញ្ញា ឥមា វុច្ចន្តិ

[៤៣២] ត្រង់ពាក្យថា ចូល គឺ ការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ ការធ្វើឲ្យជាក់ច្បាស់ ការបំពេញ នូវចតុត្ថជ្ឈាន ។

[៤៣៣] ត្រង់ពាក្យថា សម្រេចឥរិយាបថ គឺ សម្រេច ។ បេ ។ សម្រាកនៅ ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

[៤៣៤] ត្រង់ពាក្យថា ព្រោះកន្លងរូបសញ្ញា ដោយសព្វគ្រប់ សេចក្ដីថា បណ្ដាធម៌ទាំងនោះ រូបសញ្ញា តើដូចម្ដេច ។ ការសម្គាល់ អាការសម្គាល់ ភាពនៃការសម្គាល់ ណា របស់បុគ្គលអ្នកចូលកាន់រូបសមាបត្តិក្ដី របស់បុគ្គលអ្នកប្រកប (ដោយរូបសមាបត្តិ) ក្ដី របស់បុគ្គលអ្នកនៅជាសុខក្នុងបច្ចុប្បន្ន (ដោយរូបាវចរសមាបត្តិ) ក្ដី នេះហៅថា រូបសញ្ញា បុគ្គល កន្លង ប្រព្រឹត្តកន្លង ឈានកន្លង នូវរូបសញ្ញាទាំងនេះ ព្រោះហេតុនោះ ទើបពោលថា ព្រោះកន្លងរូបសញ្ញា ដោយសព្វគ្រប់ ។

[៤៣៥] ត្រង់ពាក្យថា ព្រោះវិនាសទៅនៃបដិឃសញ្ញាទាំងឡាយ សេចក្ដីថា បណ្ដាធម៌ទាំងនោះ បដិឃសញ្ញា តើដូចម្ដេច ។ រូបសញ្ញា សទ្ទសញ្ញា គន្ធសញ្ញា រសសញ្ញា ផោដ្ឋព្វសញ្ញា នេះហៅថា

បជិយសញ្ញាយោ ឥមា បជិយសញ្ញាយោ សន្តា ហោន្តិ សមិតា វូបសន្តា អត្ថង្គតា អព្ភត្ថង្គតា អប្បិតា ព្យប្បិតា សោសិតា វិសោសិតា ព្យន្តីកតា តេន វុច្ចតិ បជិយសញ្ញានំ អត្ថង្គមាតិ ។

[៤៣៦] ជានត្តសញ្ញានំ អមនសិការាតិ តត្ថ កតមា ជានត្តសញ្ញាយោ ។ យា អសមាបន្នស្ស មនោធាតុសមង្គិស្ស វា មនោវិញ្ញាណធាតុសមង្គិស្ស វា សញ្ញា សញ្ជានជា សញ្ជានិតត្តំ ឥមា វុច្ចន្តិ ជានត្តសញ្ញាយោ ឥមា ជានត្តសញ្ញាយោ ន មនសិការោតិ តេន វុច្ចតិ ជានត្តសញ្ញានំ អមនសិការាតិ ។

[៤៣៧] អនន្តោ អាកាសោតិ តត្ថ កតមោ អាកាសោ ។ យោ អាកាសោ អាកាសគតំ អឃំ អឃគតំ វិវរោ វិវរគតំ អសម្ផុដ្ឋំ ចតូហិ មហាភូតេហិ អយំ វុច្ចតិ អាកាសោ តស្មឹ អាកាសេ ចិត្តំ ឋបេតិ សណ្ឋាបេតិ អនន្តំ ផរតិ តេន វុច្ចតិ អនន្តោ អាកាសោតិ ។

បដិឃសញ្ញា បដិឃសញ្ញាទាំងនេះ ជាធម៌ស្ងប់រម្ងាប់ រលត់ ខ្ចាត់ចេញ វិនាស សាបសូន្យ ខូចខាត ហីនហោច រីង ស្ងួត ធ្វើឲ្យអស់ទៅ ព្រោះហេតុនោះ ទើបពោលថា ព្រោះវិនាសទៅនៃបដិឃសញ្ញាទាំងឡាយ ។

[៤៣៦] ត្រង់ពាក្យថា ព្រោះមិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា សេចក្តីថា បណ្តាធម៌ទាំងនោះ នានត្តសញ្ញា តើដូចម្តេច ។ ការសម្គាល់ អាការសម្គាល់ ភាពនៃការសម្គាល់ ណា របស់បុគ្គលអ្នកមិនចូលកាន់ (រូបសមាបត្តិ) ជាអ្នកព្រមព្រៀងដោយមនោធាតុក្តី ព្រមព្រៀងដោយមនោវិញ្ញាណធាតុក្តី នេះហៅថា នានត្តសញ្ញា បុគ្គលមិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញាទាំងនេះ ព្រោះហេតុនោះ ទើបពោលថា ព្រោះមិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ។

[៤៣៧] ត្រង់ពាក្យថា អាកាសមិនមានទីបំផុត សេចក្តីថា បណ្តាធម៌ទាំងនោះ អាកាស តើដូចម្តេច ។ កន្លែងណា ដែលមិនអាចក្តួរពាស់បាន អាកាស ទីឥតទើស ទីអាកាស ទីចន្លោះ វាល មិនប៉ះពាល់ដោយមហាភូតរូបទាំង ៤ នេះហៅថា អាកាស ភិក្ខុតម្កល់ តាំងទុក នូវចិត្ត ក្នុងអាកាសនោះ ផ្សាយចិត្តទៅកាន់ទីដែលមិនមានទីបំផុត ព្រោះហេតុនោះ ទើបពោលថា អាកាសមិនមានទីបំផុត ។

[៤៣៨] អាកាសានញ្ចាយតនន្តិ អាកាសានញ្ចាយតនំ សមាបន្នស្ស វា ឧបបន្នស្ស វា ទិដ្ឋធម្មសុខវិហារិស្ស វា ចិត្តចេតសិកា ធម្មា ។

[៤៣៩] ឧបសម្បជ្ជាតិ យោ អាកាសានញ្ចាយតនស្ស លាភោ បដិលាភោ បត្តិ សម្បត្តិ ផុសនា សច្ឆិកិរិយា ឧបសម្បទា ។

[៤៤០] វិហរតីតិ ឥរិយតិ ។ បេ ។ វិហរតិ តេន វុច្ចតិ វិហរតីតិ ។

[៤៤១] សព្វសោ អាកាសានញ្ចាយតនំ សមតិក្កមាតិ ឥមំ អាកាសានញ្ចាយតនំ អតិក្កន្តោ ហោតិ វីតិក្កន្តោ សមតិក្កន្តោ តេន វុច្ចតិ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កមាតិ ។

[៤៤២] អនន្តំ វិញ្ញាណន្តិ តំយេវ អាកាសំ វិញ្ញាណេន ផុដំ មនសិករោតិ អនន្តំ ផរតិ តេន វុច្ចតិ អនន្តំ វិញ្ញាណន្តិ ។

[៤៣៨] ត្រង់ពាក្យថា អាកាសានញ្ចាយតនៈ បានដល់ពួកធម៌ គឺចិត្ត និងចេតសិក របស់បុគ្គលអ្នកចូលកាន់អាកាសានញ្ចាយតនជ្ឈានក្តី របស់បុគ្គលអ្នកប្រកប (ដោយអាកាសានញ្ចាយតនជ្ឈាន) ក្តី របស់បុគ្គលអ្នកនៅជាសុខក្នុងបច្ចុប្បន្ន (ដោយអាកាសានញ្ចាយតនជ្ឈាន)ក្តី ។

[៤៣៩] ត្រង់ពាក្យថា ចូល គឺ ការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ ការធ្វើឲ្យជាក់ច្បាស់ ការបំពេញ នូវអាកាសានញ្ចាយតនជ្ឈាន ។

[៤៤០] ត្រង់ពាក្យថា សម្រេចឥរិយាបថ គឺ សម្រេច ។ បេ ។ នៅ ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

[៤៤១] ត្រង់ពាក្យថា ព្រោះកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង គឺភិក្ខុជាអ្នកកន្លង ប្រព្រឹត្តកន្លង ឈានកន្លងនូវអាកាសានញ្ចាយតនជ្ឈាននេះ ព្រោះហេតុនោះ ទើបពោលថា ព្រោះកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ។

[៤៤២] ត្រង់ពាក្យថា វិញ្ញាណ មិនមានទីបំផុត គឺ ភិក្ខុ ធ្វើទុកក្នុងចិត្ត ចំពោះអាកាសនោះឯង ដែលពាល់ត្រូវដោយវិញ្ញាណ ផ្សាយទៅកាន់ទីមិនមានទីបំផុត ព្រោះហេតុនោះ ទើបពោលថា វិញ្ញាណ មិនមានទីបំផុត ។

[៤៤៣] វិញ្ញាណញ្ចាយតនន្តិ វិញ្ញាណញ្ចាយតនំ សមាបន្នស្ស វា ឧបបន្នស្ស វា ទិដ្ឋធម្មសុខវិហារិស្ស វា ចិត្តចេតសិកា ធម្មា ។

[៤៤៤] ឧបសម្បជ្ជាតិ យោ វិញ្ញាណញ្ចាយតនស្ស លាភោ បដិលាភោ បត្តិ សម្បត្តិ ផុសនា សច្ឆិកិរិយា ឧបសម្បទា ។

[៤៤៥] វិហរតីតិ ឥរិយតិ ។ បេ ។ វិហរតិ តេន វុច្ចតិ វិហរតីតិ ។

[៤៤៦] សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កមាតិ ឥមំ វិញ្ញាណញ្ចាយតនំ អតិក្កន្តោ ហោតិ វីតិក្កន្តោ សមតិក្កន្តោ តេន វុច្ចតិ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កមាតិ ។

[៤៤៧] នត្ថិ កិញ្ចីតិ តំយេវ វិញ្ញាណំ អភាវេតិ វិភាវេតិ អន្តរធាបេតិ នត្ថិ កិញ្ចីតិ បស្សតិ តេន វុច្ចតិ នត្ថិ កិញ្ចីតិ ។

[៤៤៣] ត្រង់ពាក្យថា វិញ្ញាណញ្ចាយតនៈ បានដល់ពួកធម៌ គឺចិត្ត និងចេតសិក របស់បុគ្គលអ្នកចូលកាន់វិញ្ញាណញ្ចាយតនជ្ឈានក្តី របស់បុគ្គលអ្នកប្រកប (ដោយវិញ្ញាណញ្ចាយតនជ្ឈាន) ក្តី របស់បុគ្គលអ្នកនៅជាសុខក្នុងបច្ចុប្បន្ន (ដោយវិញ្ញាណញ្ចាយតនជ្ឈាន) ក្តី ។

[៤៤៤] ត្រង់ពាក្យថា ចូល គឺ ការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ ការធ្វើឲ្យជាក់ច្បាស់ ការបំពេញ នូវវិញ្ញាណញ្ចាយតនជ្ឈាន ។

[៤៤៥] ត្រង់ពាក្យថា សម្រេចឥរិយាបថ គឺសម្រេច ។ បេ ។ នៅ ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

[៤៤៦] ត្រង់ពាក្យថា ព្រោះកន្លងនូវវិញ្ញាណញ្ចាយតនៈ ដោយប្រការទាំងពួង គឺ ភិក្ខុជាអ្នកកន្លង ប្រព្រឹត្តកន្លង ឈានកន្លង នូវវិញ្ញាណញ្ចាយតនជ្ឈាននេះ ព្រោះហេតុនោះ ទើបពោលថា ព្រោះកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ។

[៤៤៧] ត្រង់ពាក្យថា វត្ថុតិចតួចមិនមាន គឺ ភិក្ខុ ចម្រើនទូទៅ ចម្រើនវិសេស នូវវិញ្ញាណនោះឯង ធ្វើឲ្យបាត់វិញ្ញាណ រមែងឃើញថា វត្ថុតិចតួច មិនមាន ព្រោះហេតុនោះ ទើបពោលថា វត្ថុតិចតួច មិនមាន ។

[៤៤៨] អាកិញ្ចញ្ញាយតនន្តិ អាកិញ្ចញ្ញាយតនំ សមាបន្នស្ស វា ឧបបន្នស្ស វា ទិដ្ឋធម្មសុខវិហារិស្ស វា ចិត្តចេតសិកា ធម្មា ។

[៤៤៩] ឧបសម្បជ្ជាតិ យោ អាកិញ្ចញ្ញាយតនស្ស លាភោ បដិលាភោ បត្តិ សម្បត្តិ ផុសនា សច្ឆិកិរិយា ឧបសម្បទា ។

[៤៥០] វិហរតីតិ ឥរិយតិ ។ បេ ។ វិហរតិ តេន វុច្ចតិ វិហរតីតិ ។

[៤៥១] សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កមាតិ ឥមំ អាកិញ្ចញ្ញាយតនំ អតិក្កន្តោ ហោតិ វីតិក្កន្តោ សមតិក្កន្តោ តេន វុច្ចតិ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កមាតិ ។

[៤៥២] នេវសញ្ញានាសញ្ញីតិ តំយេវ អាកិញ្ចញ្ញាយតនំ សន្តតោ មនសិករោតិ សង្ខារាវសេសសមាបត្តឹ ភាវេតិ តេន វុច្ចតិ នេវសញ្ញានាសញ្ញីតិ ។

[៤៤៨] ត្រង់ពាក្យថា អាកិញ្ចញ្ញាយតនៈ បានដល់ពួកធម៌ គឺចិត្ត និងចេតសិក របស់បុគ្គលអ្នកចូលកាន់អាកិញ្ចញ្ញាយតនជ្ឈានក្តី របស់បុគ្គលអ្នកប្រកប (ដោយអាកិញ្ចញ្ញាយតនជ្ឈាន) ក្តី របស់បុគ្គលអ្នកនៅជាសុខក្នុងបច្ចុប្បន្ន (ដោយអាកិញ្ចញ្ញាយតនជ្ឈាន) ក្តី ។

[៤៤៩] ត្រង់ពាក្យថា ចូល គឺ ការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ ការធ្វើឲ្យជាក់ច្បាស់ ការបំពេញនូវអាកិញ្ចញ្ញាយតនជ្ឈាន ។

[៤៥០] ត្រង់ពាក្យថា សម្រេចឥរិយាបថ គឺ សម្រេច ។ បេ ។ នៅ ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

[៤៥១] ត្រង់ពាក្យថា ព្រោះកន្លងនូវអាកិញ្ចញ្ញាយតនៈ ដោយប្រការទាំងពួង គឺ ភិក្ខុជាអ្នកកន្លង ប្រព្រឹត្តកន្លង ឈានកន្លង នូវអាកិញ្ចញ្ញាយតនជ្ឈាននេះ ព្រោះហេតុនោះ ទើបពោលថា ព្រោះកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ។

[៤៥២] ត្រង់ពាក្យថា នេវសញ្ញានាសញ្ញា គឺ ភិក្ខុធ្វើទុកក្នុងចិត្តនូវអាកិញ្ចញ្ញាយតនជ្ឈាននោះឯង ដោយល្អិត ចម្រើននូវសមាបត្តិមានសង្ខារសេសនៅ ព្រោះហេតុនោះ ទើបពោលថា នេវសញ្ញានាសញ្ញា ។

[៤៩៣] នេវសញ្ញានាសញ្ញាយតនន្តិ នេវសញ្ញានាសញ្ញាយតនំ សមាបន្នស្ស វា ឧបបន្នស្ស វា ទិដ្ឋធម្មសុខវិហារិស្ស វា ចិត្តចេតសិកា ធម្មា ។

[៤៩៤] ឧបសម្បជ្ជាតិ យោ នេវសញ្ញានាសញ្ញាយតនស្ស លាភោ បដិលាភោ បត្តិ សម្បត្តិ ផុសនា សច្ឆិកិរិយា ឧបសម្បទា ។

[៤៩៥] វិហរតីតិ ឥរិយតិ វត្តតិ បាលេតិ យបេតិ យាបេតិ ចរតិ វិហរតិ តេន វុច្ចតិ វិហរតីតិ ។

សុត្តន្តភាជនីយំ ។

[៤៩៦] ចត្តារិ ឈានានិ បឋមំ ឈានំ ទុតិយំ ឈានំ តតិយំ ឈានំ ចតុត្ថំ ឈានំ ។

[៤៩៧] តត្ថ កតមំ បឋមំ ឈានំ ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ បឋវីកសិណំ តស្មឹ សមយេ

[៤៩៣] ត្រង់ពាក្យថា នេវសញ្ញានាសញ្ញាយតនៈ បានដល់ពួកធម៌ គឺចិត្តនិងចេតសិក របស់បុគ្គលអ្នកចូលកាន់នេវសញ្ញានាសញ្ញាយតនជ្ឈានក្តី របស់បុគ្គលអ្នកប្រកប (ដោយនេវសញ្ញានាសញ្ញាយតនជ្ឈាន) ក្តី របស់បុគ្គលអ្នកនៅជាសុខក្នុងបច្ចុប្បន្ន (ដោយនេវសញ្ញានាសញ្ញាយតនជ្ឈាន) ក្តី ។

[៤៩៤] ត្រង់ពាក្យថា ចូល គឺ ការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ ការធ្វើឲ្យជាក់ច្បាស់ ការបំពេញ នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ។

[៤៩៥] ត្រង់ពាក្យថា សម្រេចឥរិយាបថ គឺ សម្រេច ប្រព្រឹត្ត រក្សា រស់នៅ ញុំាងជីវិតឲ្យរស់នៅ ត្រាច់ទៅ សម្រាកនៅ ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

ចប់ សុត្តន្តភាជនីយ ។

[៤៩៦] ឈាន ៤ យ៉ាង គឺ បឋមជ្ឈាន ១ ទុតិយជ្ឈាន ១ តតិយជ្ឈាន ១ ចតុត្ថជ្ឈាន ១ ។

[៤៩៧] បណ្តាឈានទាំងនោះ បឋមជ្ឈាន តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន មានបឋវីកសិណ (ជាអារម្មណ៍) ហើយសម្រាកនៅ ក្នុងសម័យនោះ

បញ្ចង្គិកំ ឈានំ ហោតិ វិតក្កោ វិចារោ បីតិ សុខំ ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ បឋមំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

[៥៥៨] តត្ថ កតមំ ទុតិយំ ឈានំ ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ បឋវីកសិណំ តស្មឹ សមយេ តិវង្គិកំ ឈានំ ហោតិ បីតិ សុខំ ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ ទុតិយំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

[៥៥៩] តត្ថ កតមំ តតិយំ ឈានំ ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ បីតិយា ច វិរាគា ។ បេ ។ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ បឋវីកសិណំ តស្មឹ សមយេ ទុវង្គិកំ ឈានំ ហោតិ សុខំ ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ តតិយំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

[៥៦០] តត្ថ កតមំ ចតុត្ថំ ឈានំ ។

ឈានមានអង្គ ៥ គឺ វិតក្កៈ វិចារៈ បីតិ សុខ ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា បឋមជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[៤៥៨] បណ្ដាឈានទាំងនោះ ទុតិយជ្ឈាន តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះរម្ងាប់វិតក្កៈនិងវិចារៈ ។ បេ ។ ចូលកាន់ទុតិយជ្ឈាន មានបឋវីកសិណ (ជាអារម្មណ៍ ) ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ៣ គឺ បីតិ សុខ ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា ទុតិយជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[៤៥៩] បណ្ដាឈានទាំងនោះ តតិយជ្ឈាន តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះនឿយណាយចាកបីតិ ។ បេ ។ ចូលកាន់តតិយជ្ឈាន មានបឋវីកសិណ (ជាអារម្មណ៍) ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺ សុខ ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា តតិយជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[៤៦០] បណ្ដាឈានទាំងនោះ ចតុត្ថជ្ឈាន តើដូចម្ដេច ។

ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ សុខស្ស ច បហានា ។ បេ ។ ចតុត្ថំ ឈានំ ឧប-សម្បជ្ជ វិហរតិ បឋវីកសិណំ តស្មឹ សមយេ ទុវង្គិកំ ឈានំ ហោតិ ឧបេក្ខា ចិត្តស្ស ឯក-គ្គតា ឥទំ វុច្ចតិ ចតុត្ថំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

[៤៦១] ឥធ ភិក្ខុ យស្មឹ សមយេ រូបូប-បត្តិយា មគ្គំ ភាវេតិ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ បឋវីកសិណំ តស្មឹ សមយេ បញ្ចង្គិកំ ឈានំ ហោតិ វិតក្កោ វិចារោ បីតិ សុខំ ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ បឋមំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

[៤៦២] ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ អវិតក្កំ វិចារមត្តំ វិវេកជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ បឋវីកសិណំ តស្មឹ សមយេ ចតុរង្គិកំ ឈានំ ហោតិ វិចារោ បីតិ សុខំ ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ ទុតិយំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះលះបង់នូវសុខផង ។ បេ ។ ចូលកាន់ចតុត្ថជ្ឈាន មានបឋវីកសិណ (ជាអារម្មណ៍) ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺ ឧបេក្ខា ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា ចតុត្ថជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[៤៦១] ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គដើម្បីកើតក្នុងរូបភព ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន មានបឋវីកសិណ (ជាអារម្មណ៍) ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ៥ គឺ វិតក្កៈ វិចារៈ បីតិ សុខ ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា បឋមជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[៤៦២] ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គដើម្បីកើតក្នុងរូបភព ចូលកាន់ទុតិយជ្ឈាន មិនមានវិតក្កៈ មានត្រឹមតែវិចារៈ មានបីតិនិងសុខកើតអំពីសេចក្ដីស្ងាត់ មានបឋវីកសិណ (ជាអារម្មណ៍) ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ៤ គឺ វិចារៈ បីតិ សុខ ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា ទុតិយជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[៦៦៣] ឥធ ភិក្ខុ យស្មឹ សមយេ រូបូប-
បត្តិយា មគ្គំ ភាវេតិ វិតក្កវិចារានំ វូបសមា ។ បេ ។
តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ បឋវីកសិណំ
តស្មឹ សមយេ តិវង្គិកំ ឈានំ ហោតិ បីតិ សុខំ ចិ-
ត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ តតិយំ ឈានំ អវ-
សេសា ធម្មា ឈានសម្បយុត្តា ។

[៦៦៤] ឥធ ភិក្ខុ យស្មឹ សមយេ រូបូប-
បត្តិយា មគ្គំ ភាវេតិ បីតិយា ច វិរាគា ។ បេ ។
ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ បឋវីកសិណំ
តស្មឹ សមយេ ទុវង្គិកំ ឈានំ ហោតិ សុខំ ចិ-
ត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ ចតុត្ថំ ឈានំ អវ-
សេសា ធម្មា ឈានសម្បយុត្តា ។

[៦៦៥] ឥធ ភិក្ខុ យស្មឹ សមយេ រូបូប-
បត្តិយា មគ្គំ ភាវេតិ សុខស្ស ច បហានា ។ បេ ។
បញ្ចមំ ឈានំ ឧបសម្បជ្ជ វិហរតិ បឋវីកសិណំ
តស្មឹ សមយេ ទុវង្គិកំ ឈានំ ហោតិ ឧបេក្ខា
ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ បញ្ចមំ ឈានំ អ-
វសេសា ធម្មា ឈានសម្បយុត្តា ។

[៤៦៣] ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះរម្ងាប់វិតក្កៈ និងវិចារៈ ។ បេ ។ ចូលកាន់តតិយជ្ឈាន មានបឋវីកសិណ (ជាអារម្មណ៍) ហើយសម្រាកនៅក្នុងសម័យនោះ ឈានមានអង្គ ៣ គឺ បីតិ សុខ ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា តតិយជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[៤៦៤] ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះនឿយណាយចាកបីតិផង ។ បេ ។ ចូលកាន់ចតុត្ថជ្ឈាន មានបឋវីកសិណ (ជាអារម្មណ៍) ហើយសម្រាកនៅក្នុងសម័យនោះ ឈានមានអង្គ ២ គឺ សុខ ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា ចតុត្ថជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[៤៦៥] ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះលះបង់សុខផង ។ បេ ។ ចូលកាន់បញ្ចម-ជ្ឈាន មានបឋវីកសិណ (ជាអារម្មណ៍) ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺ ឧបេក្ខា ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា បញ្ចមជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[៤៦៦] ឥធ ភិក្ខុ យស្មឹ សមយេ អរូបូបបត្តិយា មគ្គំ ភាវេតិ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនសញ្ញាសហគតំ សុខស្ស ច បហានា ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ តស្មឹ សមយេ ទុវង្គិកំ ឈានំ ហោតិ ឧបេក្ខា ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ ចតុត្ថំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

[៤៦៧] ចត្តារិ ឈានានិ បឋមំ ឈានំ ទុតិយំ ឈានំ តតិយំ ឈានំ ចតុត្ថំ ឈានំ ។

[៤៦៨] តត្ថ កតមំ បឋមំ ឈានំ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ បញ្ចង្គិកំ ឈានំ ហោតិ វិតក្កោ វិចារោ បីតិ សុខំ ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ បឋមំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

[៤៦៦] ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងអរូបភព កន្លងនូវអាកិញ្ចញ្ញាយតនៈ ដែលប្រកបដោយនេវ-សញ្ញានាសញ្ញាយតនសញ្ញា ដោយប្រការទាំងពួង ព្រោះលះបង់សុខផង ។ បេ ។ ចូលកាន់ចតុត្ថជ្ឈាន ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺ ឧបេក្ខា ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា ចតុត្ថជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[៤៦៧] ឈាន ៤ គឺ បឋមជ្ឈាន ១ ទុតិយជ្ឈាន ១ តតិ-យជ្ឈាន ១ ចតុត្ថជ្ឈាន ១ ។

[៤៦៨] បណ្ដាឈានទាំងនោះ បឋមជ្ឈាន តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យា-និកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកម្មក្កិលេស) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ៥ គឺ វិតក្កៈ វិចារៈ បីតិ សុខ ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា បឋមជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[៤៦៩] តត្ថ កាតមំ ទុតិយំ ឈានំ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ តិវង្គិកំ ឈានំ ហោតិ បីតិ សុខំ ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ ទុតិយំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

[៤៧០] តត្ថ កាតមំ តតិយំ ឈានំ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា បីតិយា ច វិរាគា ។ បេ ។ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ ទុវង្គិកំ ឈានំ ហោតិ សុខំ ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ តតិយំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

[៤៧១] តត្ថ កាតមំ ចតុត្ថំ ឈានំ ។

[៤៦៩] បណ្តាឈានទាំងនោះ ទុតិយជ្ឈាន តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកម្មក្កិលេស) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ព្រោះរម្ងាប់នូវវិតក្កៈ និងវិចារៈ ។ បេ ។ ចូលកាន់ទុតិយជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ៣ គឺ បីតិ សុខ ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា ទុតិយជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[៤៧០] បណ្តាឈានទាំងនោះ តតិយជ្ឈាន តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកម្មក្កិលេស) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ព្រោះនឿយណាយចាកបីតិផង ។ បេ ។ ចូលកាន់តតិយជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺ សុខ ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា តតិយជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[៤៧១] បណ្តាឈានទាំងនោះ ចតុត្ថជ្ឈាន តើដូចម្តេច ។

ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា សុខស្ស ច បហានា ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ ចតុរង្គិកំ ឈានំ ហោតិ ឧបេក្ខា ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ ចតុត្ថំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

[៤៧២] ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ បញ្ចង្គិកំ ឈានំ ហោតិ វិតក្កោ វិចារោ បីតិ សុខំ ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ បឋមំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

[៤៧៣] ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា

ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកម្មក្កិលេស) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ព្រោះលះសុខផង ។ បេ ។ ចូលកាន់ចតុត្ថជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺ ឧបេក្ខា ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា ចតុត្ថជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[៤៧២] ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកម្មក្កិលេស) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ៥ គឺ វិតក្កៈ វិចារៈ បីតិ សុខ ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា បឋមជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[៤៧៣] ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកម្មក្កិលេស) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ (លុះស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយហើយ)

បត្តិយា[១] អវិតក្កំ វិចារមត្តំ វិវេកជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ ចតុរង្គិកំ ឈានំ ហោតិ វិចារោ បីតិ សុខំ ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ ទុតិយំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

[៤៧៤] ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិតក្កវិចារានំ វូបសមា ។ បេ ។ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ តិវង្គិកំ ឈានំ ហោតិ បីតិ សុខំ ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ តតិយំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

[៤៧៥] ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា បីតិយា ច វិរាគា ។ បេ ។ ចតុត្ថំ ឈានំ

១ ម. ឯត្ថន្តរេ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហីតិ ទិស្សន្តិ ។

ចូលកាន់ទុតិយជ្ឈាន មិនមានវិតក្កៈ មានត្រឹមតែវិចារៈ មានបីតិនិងសុខ កើតក្នុងវិវេក ជាទុក្ខាបដិបទាទន្ធាភិញ្ញា ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ៤ គឺ វិចារៈ បីតិ សុខ ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា ទុតិយជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[៤៧៤] ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកម្មកិលេស) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ព្រោះរម្ងាប់វិតក្កៈនិងវិចារៈ ។ បេ ។ ចូលកាន់តតិយជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ៣ គឺ បីតិ សុខ ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា តតិយជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[៤៧៥] ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់ នូវការមិនសន្សំ (នូវកម្មកិលេស) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ព្រោះនឿយណាយ ចាកបីតិផង ។ បេ ។ ចូលកាន់ចតុត្ថជ្ឈាន

ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ ទុវង្គិកំ ឈានំ ហោតិ សុខំ ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ ចតុត្ថំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

[៤៧៦] ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា សុខស្ស ច បហានា ។ បេ ។ បញ្ចមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ ទុវង្គិកំ ឈានំ ហោតិ ឧបេក្ខា ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ បញ្ចមំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

[៤៧៧] ចត្តារិ ឈានានិ បឋមំ ឈានំ ទុតិយំ ឈានំ តតិយំ ឈានំ ចតុត្ថំ ឈានំ ។

[៤៧៨] តត្ថ កតមំ បឋមំ ឈានំ ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ បឋវីកសិណំ តស្មឹ សមយេ ផស្សោ

ជាទុក្ខាបដិបទាទន្ធាភិញ្ញា ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺ សុខ ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា ចតុត្ថជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[៤៧៦] ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកម្មកិលេស) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ព្រោះលះបង់សុខផង ។ បេ ។ ចូលកាន់បញ្ចមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺ ឧបេក្ខា ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា បញ្ចមជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[៤៧៧] ឈាន ៤ គឺ បឋមជ្ឈាន ១ ទុតិយជ្ឈាន ១ តតិយជ្ឈាន ១ ចតុត្ថជ្ឈាន ១ ។

[៤៧៨] បណ្ដាឈានទាំងនោះ បឋមជ្ឈាន តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន មានបឋវីកសិណ (ជាអារម្មណ៍) ហើយសម្រាកនៅ ក្នុងសម័យនោះ ផស្សៈ

ហោតិ ។ បេ ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា តស្សេវ រូបាវចរស្ស កុសលស្ស កម្មស្ស កតត្តា ឧបចិតត្តា វិបាកំ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ បឋវីកសិណំ តស្មឹ សមយេ បញ្ចង្គិកំ ឈានំ ហោតិ វិតក្កោ វិចារោ បីតិ សុខំ ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ បឋមំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

[៤៧៩] តត្ថ កតមំ ទុតិយំ ឈានំ ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ វិតក្ក-វិចារានំ វូបសមា ។ បេ ។ ទុតិយំ ឧបសម្បជ្ជ វិហរតិ បឋវីកសិណំ តស្មឹ សមយេ ផស្សោ ហោតិ ។ បេ ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា តស្សេវ រូបាវចរស្ស កុសលស្ស កម្មស្ស កតត្តា ឧបចិតត្តា វិបាកំ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយំ ឈានំ ។ បេ ។ តតិយំ ឈានំ ។ បេ ។ ចតុត្ថំ ឈានំ ។ បេ ។ បឋមំ ឈានំ ។ បេ ។ បញ្ចមំ ឈានំ ឧបសម្បជ្ជ វិហរតិ បឋវីកសិណំ តស្មឹ សមយេ ទុវង្គិកំ ឈានំ

ក៏កើតមាន ។ បេ ។ អវិក្ខេបៈ (ការមិនរាយមាយ) ក៏កើតមាន ធម៌ទាំងនេះ ឈ្មោះថាជាកុសល ភិក្ខុស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់ បឋមជ្ឈាន ជាវិបាក មានបឋវីកសិណ (ជាអារម្មណ៍) ហើយសម្រាក នៅ ព្រោះភាពនៃកម្មជារូបាវចរកុសលនោះឯង ដែលលោកធ្វើហើយ សន្សំហើយ ក្នុងសម័យនោះ ឈានមានអង្គ ៥ គឺ វិតក្កៈ វិចារៈ បីតិ សុខ ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា បឋមជ្ឈាន ធម៌ ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[៤៧៩] បណ្តាឈានទាំងនោះ ទុតិយជ្ឈាន តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះរម្ងាប់វិតក្កៈនិងវិចារៈ ។ បេ ។ ចូលកាន់ទុតិយជ្ឈាន មានបឋវីក-សិណ (ជាអារម្មណ៍) ហើយសម្រាកនៅ ក្នុងសម័យនោះ ផស្សៈ ក៏កើតមាន ។ បេ ។ អវិក្ខេបៈ ក៏កើតមាន ធម៌ទាំងនេះឈ្មោះថាជា កុសល ព្រោះរម្ងាប់វិតក្កៈនិងវិចារៈ ។ បេ ។ ចូលកាន់ទុតិយជ្ឈាន ។ បេ ។ តតិយជ្ឈាន ។ បេ ។ ចតុត្ថជ្ឈាន ។ បេ ។ បឋមជ្ឈាន ។ បេ ។ ចូលកាន់បញ្ចមជ្ឈាន ជាវិបាក ព្រោះភាពនៃកម្មជារូបាវចរកុសល នោះឯង ដែលលោកធ្វើហើយ សន្សំហើយ មានបឋវីកសិណ (ជាអា-រម្មណ៍) ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺ

ហោតិ ឧបេក្ខា ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ បញ្ចមំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។ បេ ។ ឥធ ភិក្ខុ យស្មឹ សមយេ អរូបូបបត្តិយា មគ្គំ ភាវេតិ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនសញ្ញាសហគតំ សុខស្ស ច បហានា ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ តស្មឹ សមយេ ផស្សោ ហោតិ ។ បេ ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា តស្សេវ អរូបាវចរស្ស កុសលស្ស កម្មស្ស កតត្តា ឧបចិតត្តា វិបាកំ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនសញ្ញាសហគតំ សុខស្ស ច បហានា ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ តស្មឹ សមយេ ទុវង្គិកំ ឈានំ ហោតិ ឧបេក្ខា ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ ចតុត្ថំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

[៤៨០] ចត្តារិ ឈានានិ បឋមំ ឈានំ ទុតិយំ ឈានំ តតិយំ ឈានំ ចតុត្ថំ ឈានំ ។

ឧបេក្ខា ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា បញ្ចមជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។ បេ ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងអរូបភព កន្លងអាកិញ្ចញ្ញាយតនៈ ដែលប្រឡំដោយនេវសញ្ញានាសញ្ញាយតនសញ្ញា ដោយប្រការទាំងពួង ព្រោះលះបង់សុខផង ។ បេ ។ ចូលកាន់ចតុត្ថជ្ឈាន ហើយសម្រាកនៅ ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។ បេ ។ អវិក្ខេបៈក៏កើតមាន ធម៌ទាំងនេះ ឈ្មោះថាជាកុសល កន្លងអាកិញ្ចញ្ញាយតនៈ ដែលប្រឡំដោយនេវសញ្ញានាសញ្ញាយតនសញ្ញា ដោយប្រការទាំងពួង ព្រោះលះសុខផង ។ បេ ។ ចូលកាន់ចតុត្ថជ្ឈាន ជាវិបាក ព្រោះភាពនៃកម្មជាអរូបាវចរកុសលនោះឯង ដែលលោកធ្វើហើយ សន្សំហើយ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺ ឧបេក្ខា ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា ចតុត្ថជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[៤៨០] ឈាន ៤ គឺ បឋមជ្ឈាន ១ ទុតិយជ្ឈាន ១ តតិយជ្ឈាន ១ ចតុត្ថជ្ឈាន ១ ។

[៤៨១] តត្ថ កតមំ បឋមំ ឈានំ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ ផស្សោ ហោតិ ។ បេ ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា តស្សេវ លោកុត្តរស្ស កុសលស្ស ឈានស្ស កតត្តា ភាវិតត្តា វិបាកំ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ សុញ្ញតំ តស្មឹ សមយេ បញ្ចង្គិកំ ឈានំ ហោតិ វិតក្កោ វិចារោ បីតិ សុខំ ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ បឋមំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

[៤៨២] តត្ថ កតមំ ទុតិយំ ឈានំ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ

[៤៨១] បណ្ដាឈានទាំងនោះ បឋមជ្ឈាន តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិក-ធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកម្មកិលេស) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ហើយសម្រាកនៅ ក្នុងសម័យនោះ ផស្សៈ ក៏កើតមាន ។ បេ ។ អវិក្ខេបៈ ក៏កើតមាន ធម៌ទាំងនេះ ឈ្មោះថា ជាកុសល ភិក្ខុស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន ជាវិបាក ព្រោះភាពនៃឈានជាលោកុត្តរកុសលនោះឯង ដែលលោកធ្វើហើយ អប់រំហើយ ជាទុក្ខាបដិបទាទន្ធាភិញ្ញា ជាសុញ្ញតៈ ក្នុងសម័យនោះ ឈានមានអង្គ ៥ គឺ វិតក្កៈ វិចារៈ បីតិ សុខ ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា បឋមជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[៤៨២] បណ្ដាឈានទាំងនោះ ទុតិយជ្ឈាន តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់

បឋមាយ ភូមិយា បត្តិយា វិតក្កវិចារាជំ រូបសមា ។ បេ ។ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ ផស្សោ ហោតិ ។ បេ ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា តស្សេវ លោកុត្តរស្ស កុសលស្ស ឈានស្ស កតត្តា ភាវិតត្តា វិបាកំ វិតក្កវិចារាជំ រូបសមា ។ បេ ។ បឋមំ ឈានំ ។ បេ ។ បញ្ចមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ សុញ្ញតំ តស្មឹ សមយេ ទុវង្គិកំ ឈានំ ហោតិ ឧបេក្ខា ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ បញ្ចមំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

[៤៨៣] ចត្តារិ ឈានានិ បឋមំ ឈានំ ទុតិយំ ឈានំ តតិយំ ឈានំ ចតុត្ថំ ឈានំ ។

[៤៨៤] តត្ថ កតមំ បឋមំ ឈានំ ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបាវចរំ ឈានំ ភាវេតិ កិរិយំ នេវ កុសលំ នាកុសលំ ន ច កម្មវិបាកំ ទិដ្ឋធម្មសុខវិហារំ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ បឋវីកសិណំ

នូវបឋមភូមិ ព្រោះរម្ងាប់វិតក្កៈ និងវិចារៈ ។ បេ ។ ចូលកាន់ទុតិយជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ហើយសម្រាកនៅ ក្នុងសម័យនោះ ផស្សៈ ក៏កើតមាន ។ បេ ។ អវិក្ខេបៈ ក៏កើតមាន ធម៌ទាំងនេះ ឈ្មោះថា ជាកុសល ព្រោះរម្ងាប់វិតក្កៈ និងវិចារៈ ។ បេ ។ ចូលកាន់បឋមជ្ឈាន ។ បេ ។ ចូលកាន់បញ្ចមជ្ឈាន ជាវិបាក ព្រោះភាពនៃឈាន ជាលោកុត្តរកុសលនោះឯង ដែលលោកធ្វើហើយ អប់រំហើយ ជាទុក្ខាបដិបទាទន្ធាភិញ្ញា ជាសុញ្ញតៈ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺ ឧបេក្ខា ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា បញ្ចមជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[៤៨៣] ឈាន ៤ គឺ បឋមជ្ឈាន ១ ទុតិយជ្ឈាន ១ តតិយជ្ឈាន ១ ចតុត្ថជ្ឈាន ១ ។

[៤៨៤] បណ្ដាឈានទាំងនោះ បឋមជ្ឈាន តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនរូបាវចរជ្ឈាន ជាកិរិយា មិនមែនកុសល មិនមែនអកុសល ទាំងមិនមែនជាកម្មវិបាក ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន មានបឋវីកសិណ (ជាអារម្មណ៍) ហើយសម្រាកនៅ

តស្មឹ សមយេ បញ្ចង្គិកំ ឈានំ ហោតិ វិតក្កោ វិចារោ បីតិ សុខំ ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ បឋមំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

[៤៨៤] តត្ថ កតមំ ទុតិយំ ឈានំ ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបាវចរំ ឈានំ ភាវេតិ កិរិយំ នេវ កុសលំ នាកុសលំ ន ច កម្មវិបាកំ ទិដ្ឋធម្មសុខវិហារំ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយំ ឈានំ ។ បេ ។ តតិយំ ឈានំ ។ បេ ។ ចតុត្ថំ ឈានំ ។ បេ ។ បឋមំ ឈានំ ។ បេ ។ បញ្ចមំ ឈានំ ឧបសម្បជ្ជ វិហរតិ បឋវីកសិណំ តស្មឹ សមយេ ទុវង្គិកំ ឈានំ ហោតិ ឧបេក្ខា ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ បញ្ចមំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។ បេ ។ ឥធ ភិក្ខុ យស្មឹ សមយេ អរូបាវចរំ ឈានំ ភាវេ-តិ កិរិយំ នេវ កុសលំ នាកុសលំ ន ច កម្មវិបាកំ ទិដ្ឋធម្មសុខវិហារំ សព្វសោ អាកិ-ញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតន-សញ្ញាសហគតំ សុខស្ស ច បហានា ។ បេ ។

ក្នុងសម័យនោះ ឈានមានអង្គ ៥ គឺ វិតក្កៈ វិចារៈ បីតិ សុខ ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា បឋមជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[៤៨៥] បណ្តាឈានទាំងនោះ ទុតិយជ្ឈាន តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនរូបាវចរជ្ឈាន ជាកិរិយា មិនមែនកុសល មិនមែនអកុសល ទាំងមិនមែនជាកម្មវិបាក ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ព្រោះរម្ងាប់វិតក្កៈនិងវិចារៈ ។ បេ ។ ចូលកាន់ទុតិយជ្ឈាន ។ បេ ។ តតិយជ្ឈាន ។ បេ ។ ចតុត្ថជ្ឈាន ។ បេ ។ បឋមជ្ឈាន ។ បេ ។ បញ្ចមជ្ឈាន មានបឋវីកសិណ (ជាអារម្មណ៍) ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺ ឧបេក្ខា ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា បញ្ចមជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។ បេ ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនអរូបាវចរជ្ឈាន ជាកិរិយា មិនមែនកុសល មិនមែនអកុសល ទាំងមិនមែនជាកម្មវិបាក ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន កន្លងនូវអាកិញ្ចញ្ញាយតនៈ ដែលប្រកបដោយនេវសញ្ញានាសញ្ញាយតនសញ្ញា ដោយប្រការទាំងពួង ព្រោះលះសុខផង ។ បេ ។

ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ តស្មឹ សមយេ ចតុរង្គិកំ ឈានំ ហោតិ ឧបេក្ខា ចិត្តស្ស ឯកគ្គ-តា ឥទំ វុច្ចតិ ចតុត្ថំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

អភិធម្មភាជនីយំ ។

[៤៨៦] ចត្តារិ ឈានានិ ឥធ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧប-សម្បជ្ជ វិហរតិ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិ-ចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជានោ សុខញ្ច កាយេន បដិ-សំវេទេតិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ សុខស្ស ច បហានា ទុក្ខស្ស ច បហានា

ចូលកាន់ចតុត្ថជ្ឈាន ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺ ឧបេក្ខា ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា ចតុត្ថជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

ចប់ អភិធម្មភាជនីយ ។

[៤៨៦] ឈាន ៤ គឺ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយចូលកាន់បឋម-ជ្ឈាន ប្រកបដោយវិតក្កៈនិងវិចារៈ មានបីតិនិងសុខកើតក្នុងវិវេក ភិក្ខុព្រោះរម្ងាប់វិតក្កៈនិងវិចារៈហើយ ក៏ចូលកាន់ទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្តាន ប្រកបដោយសេចក្តីជ្រះថ្លាគឺសទ្ធា មានភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខ ដែលកើតក្នុងសមាធិគឺបឋមជ្ឈាន ព្រោះនឿយណាយចាកបីតិផង ប្រកបដោយឧបេក្ខាផង មានសតិនិង សម្បជញ្ញៈផង ទទួលសុខដោយនាមកាយផង ព្រះអរិយៈទាំងឡាយ តែងសរសើរ នូវបុគ្គលដែលព្រមព្រៀង ដោយតតិយជ្ឈាននោះថា បុគ្គល ប្រកបដោយឧបេក្ខាមានស្មារតី មានធម៌ជាគ្រឿងនៅជាសុខដូច្នេះ ព្រោះតតិយជ្ឈានណាក៏ចូលកាន់តតិយជ្ឈាននោះ ព្រោះលះសុខផង ព្រោះលះទុក្ខផង

បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខ-
មសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថំ ឈានំ ឧប-
សម្បជ្ជ វិហរតិ ។ ចតុន្នំ ឈានានំ កតិ កុស-
លា កតិ អកុសលា កតិ អព្យាកតា ។ បេ ។
កតិ សរណា កតិ អរណា ។

[៤៨៧] សិយា កុសលា សិយា អព្យាកតា ។
តីណិ ឈានា ឯត្ថុប្បន្នំ សុខំ វេទនំ ឋបេត្វា
សុខាយ វេទនាយ សម្បយុត្តា ចតុត្ថំ ឈានំ
ឯត្ថុប្បន្នំ អទុក្ខមសុខំ វេទនំ ឋបេត្វា អទុក្ខ-
មសុខាយ វេទនាយ សម្បយុត្តំ ។ សិយា
វិបាកា សិយា វិបាកធម្មធម្មា សិយា នេវ
វិបាកនវិបាកធម្មធម្មា សិយា ឧបាទិន្នុបាទានិយា
សិយា អនុបាទិន្នុបាទានិយា សិយា អនុបា-
ទិន្នានុបាទានិយា សិយា អសង្កិលិដ្ឋសង្កិលេ-
សិកា សិយា អសង្កិលិដ្ឋាសង្កិលេសិកា ។
បឋមំ ឈានំ ឯត្ថុប្បន្នេ វិតក្កវិចារេ ឋបេត្វា សវិ-
តក្កសវិចារំ តីណិ ឈានា អវិតក្កាវិចារា ។

ព្រោះវិនាសទៅនៃសោមនស្សនិងទោមនស្សក្នុងកាលមុនផង ហើយចូលកាន់ចតុត្ថជ្ឈាន មានអារម្មណ៍មិនមែនទុក្ខមិនមែនសុខ មានសតិដ៏បរិសុទ្ធដោយឧបេក្ខា ។ បណ្តាឈានទាំង ៤ ឈាន ជាកុសលប៉ុន្មាន ជាអកុសលប៉ុន្មាន ជាអព្យាក្រឹតប៉ុន្មាន ។ បេ ។ ជាសរណៈប៉ុន្មាន ជាអរណៈប៉ុន្មាន ។

[៤៨៧] ឈានជាកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។ ឈាន ៣ ប្រកបដោយសុខវេទនា វៀរលែងតែសុខវេទនា ដែលកើតក្នុងឈាននុ៎ះចេញ ឈានទី ៤ ប្រកបដោយអទុក្ខមសុខវេទនា វៀរលែងតែអទុក្ខមសុខវេទនា ដែលកើតក្នុងឈាននុ៎ះចេញ ។ ឈាន ជាវិបាកក៏មាន មានវិបាកធម៌ជាប្រក្រតីក៏មាន មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតីក៏មាន មានកម្មប្រកបដោយកិលេសមានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន មានកម្មប្រកបដោយកិលេសមានតណ្ហាជាដើមមិនកាន់យក តែជាប្រយោជន៍ដល់ឧបាទាន ក៏មាន មានកម្មប្រកបដោយកិលេសមានតណ្ហាជាដើមមិនកាន់យក ទាំងមិនជាប្រយោជន៍ដល់ឧបាទានក៏មាន មិនសៅហ្មងតែគួរដល់សេចក្តីសៅហ្មងក៏មាន មិនសៅហ្មងទាំងមិនគួរដល់សេចក្តីសៅហ្មងក៏មាន ។ ឈានទី ១ ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ វៀរលែងតែវិតក្កៈនិងវិចារៈ ដែលកើតក្នុងឈាននុ៎ះចេញ ឈាន ៣ មិនមានវិតក្កៈ មិនមានវិចារៈ ។

ឈានវិភង្គេ បញ្ហាបុច្ឆកំ

ទ្វេ ឈានា ឯត្ថុប្បន្នំ បីតឹ ឋបេត្វា បីតិសហគតា តីណិ ឈានា ឯត្ថុប្បន្នំ សុខំ ឋបេត្វា សុខសហគតា ចតុត្ថំ ឈានំ ឯត្ថុប្បន្នំ ឧបេក្ខំ ឋបេត្វា ឧបេក្ខាសហគតំ ។ នេវ ទស្សនេន ន ភាវនាយ បហាតព្វា នេវ ទស្សនេន ន ភាវនាយ បហាតព្វហេតុកា សិយា អាចយគាមិនោ សិយា អបចយគាមិនោ សិយា នេវាចយគាមិនោ នាបចយគាមិនោ សិយា សេក្ខា សិយា អសេក្ខា សិយា នេវ សេក្ខា នាសេក្ខា សិយា មហគ្គតា សិយា អប្បមាណា ។ តីណិ ឈានា ន វត្តព្វា បរិត្តារម្មណាតិបិ មហគ្គតារម្មណាតិបិ សិយា អប្បមាណារម្មណា សិយា ន វត្តព្វា អប្បមាណារម្មណាតិ ចតុត្ថំ ឈានំ សិយា បរិត្តារម្មណំ សិយា មហគ្គតារម្មណំ សិយា អប្បមាណារម្មណំ សិយា ន វត្តព្វំ បរិត្តារម្មណន្តិបិ មហគ្គតារម្មណន្តិបិ អប្បមាណារម្មណន្តិបិ ។ សិយា មជ្ឈិមា សិយា បណីតា សិយា សម្មត្តនិយតា សិយា អនិយតា ។

ឈាន ២ ប្រទ្បំដោយបីតិ វៀរលែងតែបីតិដែលកើតក្នុងឈានទុំះចេញ ឈាន ៣ ប្រទ្បំដោយសុខ វៀរលែងតែសុខដែលកើតក្នុងឈានទុំះចេញ ឈានទី ៤ ប្រទ្បំដោយឧបេក្ខា វៀរលែងតែឧបេក្ខាដែលកើតក្នុងឈានទុំះចេញ ។ ឈាន ដែលមិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនា មានហេតុមិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនា ដល់នូវការសន្សំ (នូវកម្មក្កិលេស) ក៏មាន ដល់នូវការមិនសន្សំក៏មាន មិនដល់នូវការសន្សំ ទាំងមិនដល់នូវការមិនសន្សំក៏មាន ជារបស់សេក្ខបុគ្គលក៏មាន ជារបស់អសេក្ខបុគ្គលក៏មាន មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គលក៏មាន ដល់នូវសភាពធំក៏មាន មិនមានប្រមាណក៏មាន ។ ឈាន ៣ មិនគួរពោលថា មានអារម្មណ៍តូចផង ថា មានអារម្មណ៍ដល់នូវសភាពធំផងឡើយ មានអារម្មណ៍ប្រមាណមិនបានក៏មាន មិនគួរពោលថា មានអារម្មណ៍មិនមានប្រមាណក៏មាន ឈានទី ៤ មានអារម្មណ៍តូចឆ្មារក៏មាន មានអារម្មណ៍ដល់នូវសភាពធំក៏មាន មានអារម្មណ៍មិនមានប្រមាណក៏មាន មិនគួរពោលថា មានអារម្មណ៍តូចឆ្មារផង ថា មានអារម្មណ៍ដល់នូវភាពធំផង ថា មានអារម្មណ៍មិនមានប្រមាណផងក៏មាន ។ ឈានជាកណ្តាលក៏មាន ឧត្តមក៏មាន មានសភាពត្រូវនិងទៀងក៏មាន មានសភាពមិនទៀងក៏មាន

តីណិ ឈានា ន មគ្គារម្មណា សិយា មគ្គហេតុកា សិយា មគ្គាធិបតិនោ សិយា ន វត្តព្វា មគ្គហេតុកាតិបិ មគ្គាធិបតិនោតិបិ ចតុត្ថំ ឈានំ សិយា មគ្គារម្មណំ សិយា មគ្គហេតុកំ សិយា មគ្គាធិបតិ សិយា ន វត្តព្វំ មគ្គារម្មណន្តិបិ មគ្គហេតុកន្តិបិ មគ្គាធិបតីតិបិ ។ សិយា ឧប្បន្នា សិយា អនុប្បន្នា សិយា ឧប្បាទិនោ សិយា អតីតា សិយា អនាគតា សិយា បច្ចុប្បន្នា ។ តីណិ ឈានា ន វត្តព្វា អតីតារម្មណាតិបិ អនាគតារម្មណាតិបិ បច្ចុប្បន្នារម្មណាតិបិ ចតុត្ថំ ឈានំ សិយា អតីតារម្មណំ សិយា អនាគតារម្មណំ សិយា បច្ចុប្បន្នារម្មណំ សិយា ន វត្តព្វំ អតីតារម្មណន្តិបិ អនាគតារម្មណន្តិបិ បច្ចុប្បន្នារម្មណន្តិបិ ។ សិយា អជ្ឈត្តា សិយា ពហិទ្ធា សិយា អជ្ឈត្តពហិទ្ធា ។ តីណិ ឈានា ពហិទ្ធារម្មណា ចតុត្ថំ ឈានំ សិយា អជ្ឈត្តារម្មណំ សិយា ពហិទ្ធារម្មណំ សិយា អជ្ឈត្តពហិទ្ធារម្មណំ សិយា ន វត្តព្វំ អជ្ឈត្តារម្មណន្តិបិ ពហិទ្ធារម្មណន្តិបិ អជ្ឈត្តពហិទ្ធារម្មណន្តិបិ ។ អនិទស្សនាប្បដិឃា ។

ឈាន ៣ មិនមានមគ្គជាអារម្មណ៍ តែមានមគ្គជាហេតុក៏មាន មានមគ្គជាអធិបតីក៏មាន មិនគួរពោលថា មានមគ្គជាហេតុផង ថា មានមគ្គជាអធិបតីផងក៏មាន ឈានទី ៤ មានមគ្គជាអារម្មណ៍ក៏មាន មានមគ្គជាហេតុក៏មាន មានមគ្គជាអធិបតីក៏មាន មិនគួរពោលថា មានមគ្គជាអារម្មណ៍ផង ថា មានមគ្គជាហេតុផង ថា មានមគ្គជាអធិបតីផងក៏មាន ។ ឈាន ដែលកើតហើយក៏មាន មិនទាន់កើតក៏មាន បម្រុងនឹងកើតក៏មាន ជាអតីតក៏មាន ជាអនាគតក៏មាន ជាបច្ចុប្បន្នក៏មាន ។ ឈាន ៣ មិនគួរពោលថា មានអារម្មណ៍ជាអតីតផង ថា មានអារម្មណ៍ជាអនាគតផង ថា មានអារម្មណ៍ជាបច្ចុប្បន្នផងឡើយ ឈានទី ៤ មានអារម្មណ៍ជាអតីតក៏មាន មានអារម្មណ៍ជាអនាគតក៏មាន មានអារម្មណ៍ជាបច្ចុប្បន្នក៏មាន មិនគួរពោលថា មានអារម្មណ៍ជាអតីតផង ថា មានអារម្មណ៍ជាអនាគតផង ថា មានអារម្មណ៍ជាបច្ចុប្បន្នផងក៏មាន ។ ឈាន ខាងក្នុងក៏មាន ខាងក្រៅក៏មាន ទាំងខាងក្នុងទាំងខាងក្រៅក៏មាន ។ ឈាន ៣ មានអារម្មណ៍ខាងក្រៅ ឈានទី ៤ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ខាងក្នុងនិងខាងក្រៅក៏មាន មិនគួរពោលថា មានអារម្មណ៍ខាងក្នុងផង ថា មានអារម្មណ៍ខាងក្រៅផង ថា មានអារម្មណ៍ខាងក្នុងនិងខាងក្រៅផងក៏មាន ។ ឈាន មិនប្រកបដោយការឃើញ ទាំងមិនប្រកបដោយការប៉ះពាល់ ។

[៤៨៨] ន ហេតូ សហេតុកា ហេតុសម្បយុត្តា ន វត្តព្វា ហេតូ ចេវ សហេតុកា ចាតិ សហេតុកា ចេវ ន ច ហេតូ ន វត្តព្វា ហេតូ ចេវ ហេតុសម្បយុត្តា ចាតិ ហេតុសម្បយុត្តា ចេវ ន ច ហេតូ ន ហេតូ សហេតុកា ។ សប្បច្ចយា សង្ខតា អនិទស្សនា អប្បដិឃា អរូបា សិយា លោកិយា សិយា លោកុត្តរា កេនចិ វិញ្ញេយ្យា កេនចិ ន វិញ្ញេយ្យា ។ នោ អាសវា សិយា សាសវា សិយា អនាសវា អាសវវិប្បយុត្តា ន វត្តព្វា អាសវា ចេវ សាសវា ចាតិ សិយា សាសវា ចេវ នោ ច អាសវា សិយា ន វត្តព្វា សាសវា ចេវ នោ ច អាសវាតិ ន វត្តព្វា អាសវា ចេវ អាសវសម្បយុត្តា ចាតិបិ អាសវសម្បយុត្តា ចេវ នោ ច អាសវាតិបិ សិយា អាសវវិប្បយុត្តសាសវា សិយា អាសវវិប្បយុត្តអនាសវា ។ នោ សញ្ញោជនា ។ បេ ។

[៤៨៨] ពួកឈានមិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុ ប្រកបដោយហេតុ មិនគួរពោលថា ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុទេ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុ មិនគួរពោលថា ជាហេតុ ទាំងប្រកបដោយហេតុឡើយ គ្រាន់តែប្រកបដោយហេតុ តែមិនមែនហេតុ គឺមិនមែនហេតុ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ ។ ពួកឈាន ប្រកបដោយបច្ច័យ ត្រូវបច្ច័យតាក់តែង មិនប្រកបដោយការឃើញ មិនប្រកបដោយការប៉ះពាល់ ឥតរូប ជាលោកិយក៏មាន ជាលោកុត្តរក៏មាន ដែលបុគ្គលគប្បីដឹងដោយវិញ្ញាណណាមួយ ដែលបុគ្គលមិនគប្បីដឹងដោយវិញ្ញាណណាមួយក៏មាន ។ ពួកឈាន មិនមែនអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន មិនមានអាសវៈ ទាំងប្រាសចាកអាសវៈ តែមិនគួរពោលថា ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនអាសវៈក៏មាន មិនគួរពោលថា ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនជាអាសវៈ ក៏មាន មិនគួរពោលថា ជាអាសវៈ ទាំងប្រកបដោយអាសវៈផង ថា ប្រកបដោយអាសវៈ តែមិនមែនជាអាសវៈផង ក៏មាន ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈក៏មាន ។ ពួកឈាន មិនមែនសំយោជនៈ ។ បេ ។

នោ គន្ថា ។ បេ ។ នោ ឱឃា ។ បេ ។ នោ យោគា ។ បេ ។ នោ នីវរណា ។ បេ ។ នោ បរាមាសា ។ បេ ។ សារម្មណា នោ ចិត្តា ចេតសិកា ចិត្តសម្បយុត្តា ចិត្តសំសដ្ឋា ចិត្តសមុដ្ឋានា ចិត្តសហភុនោ ចិត្តានុបរិវត្តិនោ ចិត្តសំសដ្ឋសមុដ្ឋានា ចិត្តសំសដ្ឋសមុដ្ឋានសហភុនោ ចិត្តសំសដ្ឋានុបរិវត្តិនោ ពាហិរា នុបាទា សិយា ឧបាទិន្នា សិយា អនុបាទិន្នា ។ នុបាទានា ។ បេ ។ នោ កិលេសា ។ បេ ។

[៤៨៩] ន ទស្សនេន បហាតព្វា ន ភាវនាយ បហាតព្វា ន ទស្សនេន បហាតព្វហេតុកា ។ បឋមំ ឈានំ ឯត្ថុប្បន្នំ វិតក្កំ ឋបេត្វា សវិតក្កំ តីណិ ឈានា អវិតក្កា ។ បឋមំ ឈានំ ឯត្ថុប្បន្នំ វិចារំ ឋបេត្វា សវិចារំ តីណិ ឈានា អវិចារា ។ ទ្វេ ឈានា ឯត្ថុប្បន្នំ បីតឹ ឋបេត្វា សប្បីតិកា ទ្វេ ឈានា អប្បីតិកា ។ ទ្វេ ឈានា ឯត្ថុប្បន្នំ បីតឹ ឋបេត្វា បីតិសហគតា ទ្វេ ឈានា ន បីតិសហគតា ។

មិនមែនគន្ថៈ ។ បេ ។ មិនមែនឱឃៈ ។ បេ ។ មិនមែនយោគៈ ។ បេ ។ មិនមែននីវរណៈ ។ បេ ។ មិនមែនបរាមាសៈ ។ បេ ។ ពួកឈាន ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ មិនមែនចិត្ត ជាចេតសិក ប្រកបដោយចិត្ត ប្រឡំដោយចិត្ត តាំងឡើងអំពីចិត្ត កើតជាមួយនឹងចិត្ត ប្រព្រឹត្តទៅតាមនូវចិត្ត ប្រឡំទាំងតាំងឡើងអំពីចិត្ត ប្រឡំទាំងតាំងឡើងទាំងកើតជាមួយនឹងចិត្ត ប្រឡំទាំងប្រព្រឹត្តទៅតាមចិត្ត ជាខាងក្រៅ មិនមែនឧបាទា មានកម្មប្រកបដោយកិលេសមានតណ្ហាជាដើមកាន់យកហើយក៏មាន មិនមានកម្មប្រកបដោយកិលេសមានតណ្ហាជាដើមកាន់យកហើយក៏មាន ។ ពួកឈាន មិនមែនឧបាទាន ។ បេ ។ មិនមែនកិលេស ។ បេ ។

[៤៨៩] ពួកឈានមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា មានហេតុមិនគួរលះដោយទស្សនៈ ។ ឈានទី ១ ប្រកបដោយវិតក្កៈ វៀរលែងតែវិតក្កៈដែលកើតក្នុងឈាននុ៎ះចេញ ឈាន ៣ មិនមានវិតក្កៈទេ ។ ឈានទី ១ ប្រកបដោយវិចារៈ វៀរលែងតែវិចារៈដែលកើតក្នុងឈាននុ៎ះចេញ ឈាន ៣ មិនមានវិចារៈទេ ។ ឈាន ២ ប្រកបដោយបីតិ វៀរលែងតែបីតិដែលកើតក្នុងឈាននុ៎ះចេញ ឈាន ២ មិនមានបីតិទេ ។ ឈាន ២ ប្រឡំដោយបីតិ វៀរលែងតែបីតិដែលកើតក្នុងឈាននុ៎ះចេញ ឈាន ២ មិនប្រឡំដោយបីតិទេ ។

តីណិ ឈានា ឯត្ថុប្បន្នំ សុខំ ឋបេត្វា សុខសហ-
គតា ចតុត្ថំ ឈានំ ន សុខសហគតំ ។ ចតុត្ថំ
ឈានំ ឯត្ថុប្បន្នំ ឧបេក្ខំ ឋបេត្វា ឧបេក្ខាសហគតំ
តីណិ ឈានា ន ឧបេក្ខាសហគតា ។ ន កាមា-
វចរា សិយា រូបាវចរា សិយា ន រូបាវចរា ។
តីណិ ឈានា ន អរូបាវចរា ចតុត្ថំ ឈានំ សិយា
អរូបាវចរំ សិយា ន អរូបាវចរំ ។ សិយា បរិយាបន្នា
សិយា អបរិយាបន្នា សិយា និយ្យានិកា សិយា
អនិយ្យានិកា សិយា និយតា សិយា អនិយតា
សិយា សឧត្តរា សិយា អនុត្តរា អរណាតិ ។

បញ្ហាបុច្ឆកំ ។

ឈានវិភង្គោ សមត្តោ ។

---

*ឈាន ៣ ប្រកបដោយសុខ វៀរលែងតែសុខដែលកើតក្នុងឈាននុ៎ះចេញ ឈានទី ៤ មិនប្រកបដោយសុខទេ ។ ឈានទី ៤ ប្រកបដោយឧបេក្ខា វៀរលែងតែឧបេក្ខាដែលកើតក្នុងឈាននុ៎ះចេញ ឈាន ៣ មិនប្រកបដោយឧបេក្ខាទេ ។ ពួកឈានមិនមែនជាកាមាវចរ តែជារូបាវចរក៏មាន មិនមែនរូបាវចរក៏មាន ។ ឈាន ៣ មិនមែនអរូបាវចរ ឈានទី ៤ ជាអរូបាវចរក៏មាន មិនមែនអរូបាវចរក៏មាន ។ ពួកឈាន ជាបរិយាបន្នៈក៏មាន ជាអបរិយាបន្នៈក៏មាន ជានិយ្យានិកៈក៏មាន ជាអនិយ្យានិកៈក៏មាន ជានិយតៈក៏មាន ជាអនិយតៈក៏មាន ជាសឧត្តរៈក៏មាន ជាអនុត្តរៈ ជាអរណៈក៏មាន ។*

ចប់ បញ្ហាបុច្ឆកៈ ។

ចប់ ឈានវិភង្គ ។

# អប្បមញ្ញាវិភង្គោ

[៤៩០] ចតស្សោ អប្បមញ្ញាយោ ។ ឥធ ភិក្ខុ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហ-រតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហរតិ ។ ករុណាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ករុណាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេ-រេន អព្យាបជ្ជេន ផរិត្វា វិហរតិ ។ មុទិតាសហគ-តេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិ-យំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ

# អប្បមញ្ញាវិភង្គ

[៦៩០] អប្បមញ្ញា ៤ យ៉ាង ។ គឺ ភិក្ខុក្នុងសាសនានេះ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិស ១ ផ្សាយទៅកាន់ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម ទិសទទឹងគឺទិសតូច មានចិត្តប្រកបដោយមេត្តា ដ៏ធំទូលាយ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ ក្នុងទីទាំងពួង ហើយសម្រាកនៅ ១ ។ ភិក្ខុ មានចិត្តប្រកបដោយករុណា ផ្សាយទៅកាន់ទិស ១ ផ្សាយទៅកាន់ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម ទិសទទឹងគឺទិសតូច មានចិត្តប្រកបដោយករុណា ដ៏ធំ ទូលាយ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ ក្នុងទីទាំងពួង ហើយសម្រាកនៅ ១ ។ ភិក្ខុ មានចិត្តប្រកបដោយមុទិតា ផ្សាយទៅកាន់ទិស ១ ផ្សាយទៅកាន់ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម ទិសទទឹងគឺទិសតូច

សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មុទិតាស-
ហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមា-
ណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហរតិ ។
ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា
វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ
ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វា-
វន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន
មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន
ផរិត្វា វិហរតិ ។

[៤៩១] កថញ្ច ភិក្ខុ មេត្តាសហគតេន
ចេតសោ ឯកំ ទិសំ ផរិត្វា វិហរតិ ។ សេយ្យថាបិ
នាម ឯកំ បុគ្គលំ បិយំ មនាបំ ទិស្វា មេត្តា-
យេយ្យ ឯវមេវ សព្វេ សត្តេ មេត្តាយ ផរតិ ។

[៤៩២] តត្ថ កតមា មេត្តា ។ យា សត្តេសុ
មេត្តិ មេត្តាយនា មេត្តាយិតត្តំ មេត្តា ចេតោវិមុត្តិ
អយំ វុច្ចតិ មេត្តា ។ តត្ថ កតមំ ចិត្តំ ។

មានចិត្តប្រកបដោយមុទិតា ដ៏ធំ ទូលាយ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ ក្នុងទីទាំងពួង ហើយសម្រាកនៅ ១ ។ ភិក្ខុ មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិស ១ ផ្សាយទៅកាន់ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម ទិសទទឹងគឺទិសតូច មានចិត្តប្រកបដោយឧបេក្ខា ដ៏ធំ ទូលាយ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ ក្នុងទីទាំងពួង ហើយសម្រាកនៅ ១ ។

[៤៩១] ចុះភិក្ខុមានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិស ១ តើដូចម្តេច ។ បុគ្គលឃើញបុគ្គលម្នាក់ ជាទីស្រឡាញ់ ជាទីពេញចិត្ត គប្បីផ្សាយមេត្តា យ៉ាងណា ភិក្ខុរមែងផ្សាយមេត្តា ចំពោះពួកសត្វទាំងពួង ក៏យ៉ាងនោះឯង ។

[៤៩២] បណ្តាអប្បមញ្ញាទាំងនោះ មេត្តា តើដូចម្តេច ។ ការរាប់អាន អាការរាប់អាន ភាពនៃការរាប់អាន ការរាប់រក ចេតោវិមុត្តិ (ការរួចស្រឡះចាកព្យាបាទដោយអំណាចចិត្ត) ណា ចំពោះពួកសត្វ នេះហៅថា មេត្តា ។ បណ្តាធម៌ទាំងនោះ ចិត្ត តើដូចម្តេច ។

យំ ចិត្តំ មនោ មានសំ ហទយំ បណ្ឌរំ មនោ មនាយតនំ មនិន្ទ្រិយំ វិញ្ញាណំ វិញ្ញាណក្ខន្ធោ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ ចិត្តំ ។ ឥទំ ចិត្តំ ឥមាយ មេត្តាយ សហគតំ ហោតិ សហជាតំ សំសដ្ឋំ សម្បយុត្តំ តេន វុច្ចតិ មេត្តាសហគតេន ចេតសាតិ ។ ឯកំ ទិសន្តិ បុរត្ថិមំ វា ទិសំ បច្ឆិមំ វា ទិសំ ឧត្តរំ វា ទិសំ ទក្ខិណំ វា ទិសំ ឧទ្ធំ វា អធោ វា តិរិយំ វា វិទិសំ វា ។ ផរិត្វាតិ ផរិត្វា អធិមុច្ចិត្វា ។ វិហរតីតិ ឥរិយតិ វត្តតិ បា-លេតិ យបេតិ យាបេតិ ចរតិ វិហរតិ តេន វុច្ចតិ វិហរតីតិ ។ តថា ទុតិយន្តិ យថេវ ឯកំ ទិសំ តថា ទុតិយំ ទិសំ តថា តតិយំ ទិសំ តថា ចតុត្ថំ ទិសំ តថា ឧទ្ធំ តថា អធោ តថា តិរិយំ តថា វិទិសំ ។ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកន្តិ សព្វេន សព្វំ សព្វថា សព្វំ អសេ-សំ និស្សេសំ បរិយាទាយ វចនមេតំ សព្វធិ

ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ហទយៈ បណ្ឌរៈ (ធម្មជាតដ៏ផូរផង់) មនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ ណា នេះហៅថា ចិត្ត ។ ចិត្តនេះ ជាធម្មជាតទៅជាមួយគ្នា កើតជាមួយគ្នា ច្រឡំគ្នា ប្រកបព្រមដោយមេត្តានេះ ព្រោះហេតុនោះ ទើបពោលថា មានចិត្តប្រកបដោយមេត្តា ។ ពាក្យថា ទិស ១ គឺ ទិសខាងកើតក្ដី ទិសខាងលិចក្ដី ទិសខាងជើងក្ដី ទិសខាងត្បូងក្ដី ទិសខាងលើក្ដី ទិសខាងក្រោមក្ដី ទិសទទឹងក្ដី ទិសផ្សេង ៗ ក្ដី ។ ពាក្យថា ផ្សាយ គឺ ផ្សាយចិត្តទៅ បញ្ជូនចិត្តទៅ ។ ពាក្យថា សម្រាកនៅ គឺ សម្រេចឥរិយាបថ ប្រព្រឹត្ត រក្សា រស់នៅ ញុំាងជីវិតឲ្យរស់នៅ ត្រាច់ទៅ សម្រាន្តនៅ ព្រោះហេតុនោះ ទើបពោលថា សម្រាកនៅ ។ ពាក្យថា ទិសទី ២ ក៏ដូចគ្នា គឺ ផ្សាយចិត្តទៅកាន់ទិស ១ យ៉ាងណា ផ្សាយចិត្តទៅកាន់ទិសទី ២ ទិសទី ៣ ទិសទី ៤ ទិសខាងលើ ទិសខាងក្រោម ទិសទទឹង ទិសផ្សេង ៗ ក៏យ៉ាងនោះដែរ ។ ពាក្យថា ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ ក្នុងទីទាំងពួង មានសេចក្ដីថា ពាក្យថា ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ ក្នុងទីទាំងពួង នុ៎ះជាពាក្យរួបរួមសត្វទាំងពួង ទាំងអស់ រាល់រូប គ្រប់រូប

សព្វត្តតាយ សព្វាវន្តំ លោកន្តិ ។ មេត្តាសហគតេន ចេតសាតិ តត្ថ កតមា មេត្តា ។ យា សត្តេសុ មេត្តិ មេត្តាយនា មេត្តាយិតត្តំ មេត្តា ចេតោវិមុត្តិ អយំ វុច្ចតិ មេត្តា ។ តត្ថ កតមំ ចិត្តំ ។ យំ ចិត្តំ មនោ មានសំ ។ បេ ។ តជ្ជា មនោវិញ្ញាណ-ធាតុ ឥទំ វុច្ចតិ ចិត្តំ ។ ឥទំ ចិត្តំ ឥមាយ មេត្តា-យ សហគតំ ហោតិ សហជាតំ សំសដ្ឋំ សម្ប-យុត្តំ តេន វុច្ចតិ មេត្តាសហគតេន ចេតសាតិ ។ វិបុលេនាតិ យំ វិបុលំ តំ មហគ្គតំ យំ មហគ្គតំ តំ អប្បមាណំ យំ អប្បមាណំ សោ អវេរោ យោ អវេរោ សោ អព្យាបជ្ឈោ ។ ផរិត្វាតិ ផរិត្វា អធិ-មុច្ចិត្វា ។ វិហរតីតិ ឥរិយតិ ។ បេ ។ វិហរតិ តេន វុច្ចតិ វិហរតីតិ ។

[៤៩៣] កថញ្ច ភិក្ខុ ករុណាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ ។ សេយ្យថាបិ នាម ឯកំ បុគ្គលំ ទុគ្គតំ ទុរូបេតំ ទិស្វា ករុណា-យេយ្យ ឯវមេវ សព្វេ សត្តេ ករុណាយ ផរតិ ។

មិនមានសល់ ឥតសេសសល់ ។ ពាក្យថា មានចិត្តប្រកបដោយ មេត្តា សេចក្តីថា បណ្តាអប្បមញ្ញាទាំងនោះ មេត្តា តើដូចម្តេច ។ ការរាប់អាន អាការរាប់អាន ភាពនៃការរាប់អាន ការរាប់រក ចេតោវិមុត្តិ ណា ចំពោះពួកសត្វ នេះហៅថា មេត្តា ។ បណ្តាធម៌ទាំងនោះ ចិត្ត តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។ បេ ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ ណា នេះហៅថា ចិត្ត ។ ចិត្តនេះ ជាធម្មជាតទៅជាមួយគ្នា កើតជាមួយគ្នា ច្រឡំគ្នា ប្រកបព្រម ដោយមេត្តានេះ ព្រោះហេតុនោះ ទើបពោលថា មានចិត្តប្រកបដោយមេត្តា ។ ពាក្យថា ទូលាយ គឺ គុណជាតណា ដ៏ទូលាយ គុណជាតនោះ ដល់នូវភាពជាធំ គុណជាតណា ដល់នូវភាពជាធំ គុណជាតនោះ មិនមានប្រមាណ គុណជាតណា មិនមានប្រមាណ សភាវៈនោះ មិនមានពៀរ សភាវៈណា មិនមានពៀរ សភាវៈនោះ មិនមានព្យាបាទ ។ ពាក្យថា ផ្សាយ គឺ ផ្សាយចិត្តទៅ បញ្ជូនចិត្តទៅ ។ ពាក្យថា សម្រាកនៅ គឺ សម្រេចឥរិយាបថ ។ បេ ។ សម្រាន្តនៅ ព្រោះហេតុនោះ ទើបពោលថា សម្រាកនៅ ។

[៤៩៣] ចុះភិក្ខុ មានចិត្តប្រកបដោយករុណា ផ្សាយទៅកាន់ទិស ១ តើដូចម្តេច ។ បុគ្គល ឃើញបុគ្គលម្នាក់ ជាអ្នកក្រីក្រ ដល់នូវសេចក្តីលំបាក ហើយផ្សាយករុណា យ៉ាងណា ភិក្ខុផ្សាយករុណា ចំពោះពួកសត្វទាំងពួង ក៏យ៉ាងនោះឯង ។

[៤៩៤] តត្ថ កតមា ករុណា ។ យា សត្តេសុ ករុណា ករុណាយនា ករុណាយិតត្តំ ករុណា ចេតោវិមុត្តិ អយំ វុច្ចតិ ករុណា ។ តត្ថ កតមំ ចិត្តំ ។ យំ ចិត្តំ មនោ មានសំ ។ បេ ។ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ ចិត្តំ ។ ឥទំ ចិត្តំ ឥមាយ ករុណាយ សហគតំ ហោតិ សហ-ជាតំ សំសដ្ឋំ សម្បយុត្តំ តេន វុច្ចតិ ករុណា-សហគតេន ចេតសាតិ ។ ឯកំ ទិសន្តិ បុរត្ថិមំ វា ទិសំ បច្ឆិមំ វា ទិសំ ឧត្តរំ វា ទិសំ ទក្ខិណំ វា ទិសំ ឧទ្ធំ វា អធោ វា តិរិយំ វា វិទិសំ វា ។ ផរិត្វាតិ ផរិត្វា អធិមុច្ចិត្វា ។ វិហរតីតិ ឥរិយតិ វត្តតិ បាលេតិ យបេតិ យាបេតិ ចរតិ វិហរតិ តេន វុច្ចតិ វិហរ-តីតិ ។ តថា ទុតិយន្តិ យថេវ ឯកំ ទិសំ តថា ទុតិយំ ទិសំ តថា តតិយំ ទិសំ តថា ចតុត្ថំ ទិសំ តថា ឧទ្ធំ តថា អធោ តថា តិរិយំ តថា វិទិ-សំ ។ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកន្តិ

[៤៩៤] បណ្ដាធម៌ទាំងនោះ ករុណា តើដូចម្ដេច ។ ការអាណិត អាការអាណិត ភាពនៃការអាណិត ការអាណិតអាសូរ ចេតោវិមុត្តិ ណា ចំពោះពួកសត្វ នេះហៅថា ករុណា ។ បណ្ដាធម៌ទាំងនោះ ចិត្ត តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ។ បេ ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ ណា នោះហៅថា ចិត្ត ។ ចិត្តនេះ ជាធម្មជាតទៅជាមួយគ្នា កើតជាមួយគ្នា ច្រឡំគ្នា ប្រកបព្រម ដោយករុណានេះ ព្រោះហេតុនោះ ទើបពោលថា មានចិត្តប្រកបដោយករុណា ។ ពាក្យថា ទិស ១ គឺ ទិសខាងកើតក្ដី ទិសខាងលិចក្ដី ទិសខាងជើងក្ដី ទិសខាងត្បូងក្ដី ទិសខាងលើក្ដី ទិសខាងក្រោមក្ដី ទិសទទឹងក្ដី ទិសផ្សេង ៗ ក្ដី ។ ពាក្យថា ផ្សាយ គឺ ផ្សាយចិត្តទៅ បញ្ជូនចិត្តទៅ ។ ពាក្យថា សម្រាកនៅ គឺ សម្រេចឥរិយាបថ ប្រព្រឹត្ត រក្សា រស់នៅ ញ៉ាំងជីវិតឲ្យរស់នៅ ត្រាច់ទៅ សម្រាន្តនៅ ព្រោះហេតុនោះ ទើបពោលថា សម្រាកនៅ ។ ពាក្យថា ទិសទី ២ ក៏ដូចគ្នា គឺ ផ្សាយចិត្តទៅកាន់ទិស ១ យ៉ាងណា ផ្សាយចិត្តទៅកាន់ទិសទី ២ ទិសទី ៣ ទិសទី ៤ ទិសខាងលើ ទិសខាងក្រោម ទិសទទឹង ទិសផ្សេង ៗ ក៏យ៉ាងនោះដែរ ។ ពាក្យថា ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វលោកទាំងអស់ ក្នុងទីទាំងពួង

សព្វេន សព្វំ សព្វថា សព្វំ អសេសំ និស្សេសំ បរិយាទាយ វចនមេតំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកន្តិ ។ ករុណាសហគតេន ចេតសាតិ តត្ថ កតមា ករុណា ។ យា សត្តេសុ ករុណា ករុណាយនា ករុណាយិតត្តំ ករុណា ចេតោវិមុត្តិ អយំ វុច្ចតិ ករុណា ។ តត្ថ កតមំ ចិត្តំ ។ យំ ចិត្តំ មនោ មានសំ ។ បេ ។ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ ចិត្តំ ។ ឥទំ ចិត្តំ ឥមាយ ករុណាយ សហគតំ ហោតិ សហជាតំ សំសដ្ឋំ សម្បយុត្តំ តេន វុច្ចតិ ករុណាសហគតេន ចេតសាតិ ។ វិបុលេនាតិ យំ វិបុលំ តំ មហគ្គតំ យំ មហគ្គតំ តំ អប្បមាណំ យំ អប្បមាណំ សោ អវេរោ យោ អវេរោ សោ អព្យាបជ្ឈោ ។ ផរិត្វាតិ ផរិត្វា អធិមុច្ចិត្វា ។ វិហរតីតិ ឥរិយតិ ។ បេ ។ វិហរតិ តេន វុច្ចតិ វិហរតីតិ ។

មានសេចក្ដីថា ពាក្យថា ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ ក្នុងទីទាំងពួង នុ៎ះជាពាក្យរួបរួមសត្វទាំងពួង ទាំងអស់ ពល់រូប គ្រប់រូប មិនមានសល់ ឥតសេសសល់ ។ ពាក្យថា មានចិត្តប្រកបដោយករុណា សេចក្ដីថា បណ្ដាអប្បមញ្ញាទាំងនោះ ករុណា តើដូចម្ដេច ។ ការអាណិត អាការអាណិត ភាពនៃការអាណិត ការអាណិតអាសូរ ចេតោវិមុត្តិ ណាចំពោះពួកសត្វ នេះហៅថា ករុណា ។ បណ្ដាធម៌ទាំងនោះ ចិត្តតើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ។ បេ ។ មនោវិញ្ញាណធាតុដែលកើតអំពីវិញ្ញាណនោះ ណា នេះហៅថា ចិត្ត ។ ចិត្តនេះ ជាធម្មជាតទៅជាមួយគ្នា កើតជាមួយគ្នា ច្រឡំគ្នា ប្រកបព្រម ដោយករុណានេះ ព្រោះហេតុនោះ ទើបពោលថា មានចិត្តប្រកបដោយករុណា ។ ពាក្យថា ទូលាយ គឺ គុណជាតណា ដ៏ទូលាយ គុណជាតនោះ ដល់នូវភាពជាធំ គុណជាតណា ដល់នូវភាពជាធំ គុណជាតនោះ មានប្រមាណមិនបាន គុណជាតណា មិនមានប្រមាណ សភាវៈនោះ មិនមានពៀរ សភាវៈណា មិនមានពៀរសភាវៈនោះ មិនមានព្យាបាទ ។ ពាក្យថា ផ្សាយ គឺ ផ្សាយចិត្តទៅបញ្ជូនចិត្តទៅ ។ ពាក្យថា សម្រាកនៅ គឺ សម្រេចឥរិយាបថ ។ បេ ។ សម្រាន្តនៅ ព្រោះហេតុនោះ ទើបពោលថា សម្រាកនៅ ។

[៤៩៥] កថញ្ច ភិក្ខុ មុទិតាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ ។ សេយ្យថាបិ នាម ឯកំ បុគ្គលំ បិយំ មនាបំ ទិស្វា មុទិតោ អស្ស ឯវមេវ សព្វេ សត្តេ មុទិតាយ ផរតិ ។

[៤៩៦] តត្ថ កតមា មុទិតា ។ យា សត្តេសុ មុទិតា មុទិតាយនា មុទិតាយិតត្តំ មុទិតា ចេតោវិមុត្តិ អយំ វុច្ចតិ មុទិតា ។ តត្ថ កតមំ ចិត្តំ ។ យំ ចិត្តំ មនោ មានសំ ។ បេ ។ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ ចិត្តំ ។ ឥទំ ចិត្តំ ឥមាយ មុទិតាយ សហគតំ ហោតិ សហជាតំ សំសដ្ឋំ សម្បយុត្តំ តេន វុច្ចតិ មុទិតាសហគតេន ចេតសាតិ ។ ឯកំ ទិសន្តិ បុរត្ថិមំ វា ទិសំ បច្ឆិមំ វា ទិសំ ឧត្តរំ វា ទិសំ ទក្ខិណំ វា ទិសំ ឧទ្ធំ វា អធោ វា តិរិយំ វា វិទិសំ វា ។ ផរិត្វាតិ ផរិត្វា អធិមុច្ចិត្វា ។ វិហរតីតិ ឥរិយតិ ។ បេ ។ វិហរតិ តេន វុច្ចតិ វិហរតីតិ ។ តថា ទុតិយន្តិ យថេវ ឯកំ ទិសំ តថា ទុតិយំ ទិសំ តថា

[៤៩៥] ចុះភិក្ខុ មានចិត្តប្រកបដោយមុទិតា ផ្សាយទៅកាន់ទិស ១ តើដូចម្តេច ។ បុគ្គលឃើញបុគ្គលម្នាក់ ជាទីស្រឡាញ់ ជាទីពេញចិត្ត ហើយជាអ្នករីករាយ យ៉ាងណា ភិក្ខុផ្សាយមុទិតា ចំពោះពួកសត្វទាំងពួង ក៏យ៉ាងនោះឯង ។

[៤៩៦] បណ្តាអប្បមញ្ញាទាំងនោះ មុទិតា តើដូចម្តេច ។ ការរីករាយ អាការរីករាយ ភាពនៃការរីករាយ ការស្រស់ស្រាយ ចេតោវិមុត្តិណា ចំពោះពួកសត្វ នេះហៅថា មុទិតា ។ បណ្តាធម៌ទាំងនោះ ចិត្តតើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។ បេ ។ មនោ-វិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណ ណា នេះហៅថា ចិត្ត ។ ចិត្តនេះជាធម្មជាតទៅជាមួយគ្នា កើតជាមួយគ្នា ច្រឡំគ្នា ប្រកបព្រម ដោយមុទិតានេះ ព្រោះហេតុនោះ ទើបពោលថា មានចិត្តប្រកបដោយមុទិតា ។ ពាក្យថា ទិស ១ គឺទិសខាងកើតក្តី ទិសខាងលិចក្តី ទិសខាងជើងក្តី ទិសខាងត្បូងក្តី ទិសខាងលើក្តី ទិសខាងក្រោមក្តី ទិសទទឹងក្តី ទិសផ្សេង ៗ ក្តី ។ ពាក្យថា ផ្សាយ គឺ ផ្សាយចិត្តទៅ បញ្ជូនចិត្តទៅ ។ ពាក្យថា សម្រាកនៅ គឺ សម្រេចឥរិយាបថ ។ បេ ។ សម្រាន្តនៅ ព្រោះហេតុនោះ ទើបពោលថា សម្រាកនៅ ។ ពាក្យថា ទិសទី ២ ក៏ដូចគ្នា គឺ ផ្សាយចិត្តទៅកាន់ទិស ១ យ៉ាងណា ផ្សាយចិត្តទៅកាន់ទិសទី ២

តតិយំ ទិសំ តថា ចតុត្ថំ ទិសំ តថា ឧទ្ធំ តថា អធោ តថា តិរិយំ តថា វិទិសំ ។ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកន្តិ សព្វេន សព្វំ សព្វថា សព្វំ អសេសំ និស្សេសំ បរិយាទាយ វចនមេតំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកន្តិ ។ មុទិតាសហគតេន ចេតសាតិ តត្ថ កតមា មុទិតា ។ យា សត្តេសុ មុទិតា មុទិតាយនា មុទិតាយិតត្តំ មុទិតា ចេតោវិមុត្តិ អយំ វុច្ចតិ មុទិតា ។ តត្ថ កតមំ ចិត្តំ ។ យំ ចិត្តំ មនោ មានសំ ។ បេ ។ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ ចិត្តំ ។ ឥទំ ចិត្តំ ឥមាយ មុទិតាយ សហគតំ ហោតិ សហជាតំ សំសដ្ឋំ សម្បយុត្តំ តេន វុច្ចតិ មុទិតាសហគតេន ចេតសាតិ ។ វិបុលេនាតិ យំ វិបុលំ តំ មហគ្គតំ យំ មហគ្គតំ តំ អប្បមាណំ យំ អប្បមាណំ សោ អវេរោ យោ អវេរោ សោ អព្យាបជ្ឈោ ។

ទិសទី ៣ ទិសទី ៤ ទិសខាងលើ ទិសខាងក្រោម ទិសទទឹង ទិសផ្សេង ៗ ក៏យ៉ាងនោះដែរ ។ ពាក្យថា ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបផ្ទឹម នឹងសត្វទាំងអស់ ក្នុងទីទាំងពួង មានសេចក្ដីថា ពាក្យថា ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបផ្ទឹម នឹងសត្វទាំងអស់ ក្នុងទីទាំងពួង នុ៎ះជាពាក្យប្រមូលសត្វទាំងពួង ទាំងអស់ រាល់រូប គ្រប់រូប មិនមានសល់ ឥតសេសសល់ ។ ពាក្យថាមានចិត្តប្រកបដោយមុទិតា សេចក្ដីថា បណ្ដាអប្បមញ្ញាទាំងនោះ មុទិតា តើដូចម្ដេច ។ ការរីករាយ អាការរីករាយ ភាពនៃការរីករាយ ការស្រស់ស្រាយ ចេតោវិមុត្តិ ណា ចំពោះពួកសត្វ នេះហៅថា មុទិតា ។ បណ្ដាធម៌ទាំងនោះ ចិត្ត តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ។ បេ ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ ណា នេះហៅថា ចិត្ត ។ ចិត្តនេះ ជាធម្មជាតទៅជាមួយគ្នា កើតជាមួយគ្នា ច្រឡំគ្នា ប្រកបព្រម ដោយមុទិតានេះ ព្រោះហេតុនោះ ទើបពោលថា មានចិត្តប្រកប ដោយមុទិតា ។ ពាក្យថា ទូលាយ គឺ គុណជាតណា ដ៏ទូលាយ គុណជាតនោះ ដល់នូវភាពជាធំ គុណជាតណា ដល់នូវភាពជាធំ គុណជាតនោះ មិនមានប្រមាណ គុណជាតណា មិនមានប្រមាណ សភាវៈនោះ មិនមានពៀរ សភាវៈណា មិនមានពៀរ សភាវៈនោះ មិនមានព្យាបាទ ។

ផរិត្វាតិ ផរិត្វា អធិមុច្ចិត្វា ។ វិហរតីតិ ឥរិយតិ ។ បេ ។ វិហរតិ តេន វុច្ចតិ វិហរតីតិ ។

[៤៩៧] កថញ្ច ភិក្ខុ ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ ។ សេយ្យថាបិ នាម ឯកំ បុគ្គលំ នេវ មនាបំ ន អមនាបំ ទិស្វា ឧបេក្ខកោ អស្ស ឯវមេវ សព្វេ សត្តេ ឧបេក្ខាយ ផរតិ ។

[៤៩៨] តត្ថ កតមា ឧបេក្ខា ។ យា សត្តេសុ ឧបេក្ខា ឧបេក្ខាយនា ឧបេក្ខាយិតត្តំ ឧបេក្ខា ចេតោវិមុត្តិ អយំ វុច្ចតិ ឧបេក្ខា ។ តត្ថ កតមំ ចិត្តំ ។ យំ ចិត្តំ មនោ មានសំ ។ បេ ។ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ ចិត្តំ ។ ឥទំ ចិត្តំ ឥមាយ ឧបេក្ខាយ សហគតំ ហោតិ សហជាតំ សំសដ្ឋំ សម្បយុត្តំ តេន វុច្ចតិ ឧបេក្ខាសហគតេន ចេតសាតិ ។ ឯកំ ទិសន្តិ បុរត្ថិមំ វា ទិសំ បច្ឆិមំ វា ទិសំ ឧត្តរំ វា ទិសំ ទក្ខិណំ វា ទិសំ ឧទ្ធំ វា អធោ វា តិរិយំ វា វិទិសំ វា ។ ផរិត្វាតិ ផរិត្វា

ពាក្យថា ផ្សាយ គឺ ផ្សាយចិត្តទៅ បញ្ជូនចិត្តទៅ ។ ពាក្យថា សម្រាកនៅ គឺ សម្រេចឥរិយាបថ ។ បេ ។ សម្រាន្តនៅ ព្រោះហេតុនោះ ទើបពោលថា សម្រាកនៅ ។

[៤៩៧] ចុះភិក្ខុ មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិស ១ តើដូចម្តេច ។ បុគ្គល ឃើញបុគ្គលម្នាក់ ជាទីពេញចិត្តក៏មិនមែន មិនជាទីពេញចិត្តក៏មិនមែន ហើយជាអ្នកព្រងើយកន្តើយ យ៉ាងណា ភិក្ខុផ្សាយឧបេក្ខា ចំពោះសត្វទាំងពួង យ៉ាងនោះឯង ។

[៤៩៨] បណ្តាអប្បមញ្ញាទាំងនោះ ឧបេក្ខា តើដូចម្តេច ។ ការព្រងើយ អាការព្រងើយ ភាពនៃការព្រងើយ ការតោះតើយ ចេតោវិមុត្តិ ណា ចំពោះពួកសត្វ នេះហៅថា ឧបេក្ខា ។ បណ្តាធម៌ទាំងនោះ ចិត្ត តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។ បេ ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ ណា នេះហៅថា ចិត្ត ។ ចិត្តនេះ ជាធម្មជាតទៅជាមួយគ្នា កើតជាមួយគ្នា ច្រឡំគ្នា ប្រកបព្រមដោយឧបេក្ខានេះ ព្រោះហេតុនោះ ទើបពោលថា មានចិត្តប្រកបដោយឧបេក្ខា ។ ពាក្យថា ទិស ១ គឺ ទិសខាងកើតក្តី ទិសខាងលិចក្តី ទិសខាងជើងក្តី ទិសខាងត្បូងក្តី ទិសខាងលើក្តី ទិសខាងក្រោមក្តី ទិសទទឹងក្តី ទិសផ្សេង ៗ ក្តី ។ ពាក្យថា ផ្សាយ គឺ ផ្សាយចិត្តទៅ

អធិមុច្ចិត្វា ។ វិហរតីតិ ឥរិយតិ ។ បេ ។ វិហរតិ តេន វុច្ចតិ វិហរតីតិ ។ តថា ទុតិយន្តិ យថេវ ឯកំ ទិសំ តថា ទុតិយំ ទិសំ តថា តតិយំ ទិសំ តថា ចតុត្ថំ ទិសំ តថា ឧទ្ធំ តថា អធោ តថា តិរិយំ តថា វិទិសំ ។ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកន្តិ សព្វេន សព្វំ សព្វថា សព្វំ អសេសំ និស្សេសំ បរិយាទាយ វចនមេតំ សព្វធិ សព្វត្ត-តាយ សព្វាវន្តំ លោកន្តិ ។ ឧបេក្ខាសហគតេន ចេតសាតិ តត្ថ កតមា ឧបេក្ខា ។ យា សត្តេសុ ឧបេក្ខា ឧបេក្ខាយនា ឧបេក្ខាយិតត្តំ ឧបេក្ខា ចេតោវិមុត្តិ អយំ វុច្ចតិ ឧបេក្ខា ។ តត្ថ កតមំ ចិត្តំ ។ យំ ចិត្តំ មនោ មានសំ ។ បេ ។ តជ្ជា មនោ-វិញ្ញាណធាតុ ឥទំ វុច្ចតិ ចិត្តំ ។ ឥទំ ចិត្តំ ឥមាយ ឧបេក្ខាយ សហគតំ ហោតិ សហជាតំ សំសដ្ឋំ សម្បយុត្តំ តេន វុច្ចតិ ឧបេក្ខាសហគតេន ចេតសាតិ ។

បញ្ជូនចិត្តទៅ ។ ពាក្យថា សម្រាកនៅ គឺ សម្រេចឥរិយាបថ ។ បេ ។ សម្រាន្តនៅ ព្រោះហេតុនោះ ទើបពោលថា សម្រាកនៅ ។ ពាក្យថា ទិសទី ២ ក៏ដូចគ្នា គឺ ផ្សាយចិត្តទៅកាន់ទិស ១ យ៉ាងណា ទិសទី ២ ទិសទី ៣ ទិសទី ៤ ទិសខាងលើ ទិសខាងក្រោម ទិសទទឹង ឬ ទិសផ្សេង ៗ ក៏យ៉ាងនោះដែរ ។ ពាក្យថា ផ្សាយទៅកាន់សត្វលោក ទាំងពួង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ ក្នុងទីទាំងពួង មានសេចក្ដីថា ពាក្យថា ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការ យកខ្លួនទៅប្រៀបផ្ទឹម នឹងសត្វទាំងអស់ ក្នុងទីទាំងពួង នុ៎ះជាពាក្យរួប រួមសត្វទាំងពួង ទាំងអស់ រាល់រូប គ្រប់រូប មិនសល់ ឥតសេស សល់ ។ ពាក្យថា មិនចិត្តប្រកបដោយឧបេក្ខា សេចក្ដីថា បណ្ដាអប្ប-មញ្ញាទាំងនោះ ឧបេក្ខា តើដូចម្ដេច ។ ការព្រងើយ អាការព្រងើយ ភាពនៃការព្រងើយ ការតោះតើយ ចេតោវិមុត្តិ ណា ចំពោះពួកសត្វ នេះហៅថា ឧបេក្ខា ។ បណ្ដាធម៌ទាំងនោះ ចិត្ត តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ។ បេ ។ មនោវិញ្ញាណធាតុ ដែល កើតអំពីវិញ្ញាណនោះ ណា នេះហៅថា ចិត្ត ។ ចិត្តនេះ ជាធម្មជាត ទៅជាមួយគ្នា កើតជាមួយគ្នា ច្រឡំគ្នា ប្រកបព្រម ដោយឧបេក្ខា នេះ ព្រោះហេតុនោះ ទើបពោលថា មានចិត្តប្រកបដោយឧបេក្ខា ។

វិបុលេនាតិ យំ វិបុលំ តំ មហគ្គតំ យំ មហគ្គតំ តំ អប្បមាណំ យំ អប្បមាណំ សោ អវេរោ យោ អវេរោ សោ អព្យាបជ្ជោ ។ ផរិត្វាតិ ផរិត្វា អធិ-មុច្ចិត្វា ។ វិហរតីតិ ឥរិយតិ ។ បេ ។ វិហរតិ តេន វុច្ចតិ វិហរតីតិ ។

សុត្តន្តភាជនីយំ ។

[៤៩៩] ចតស្សោ អប្បមញ្ញាយោ មេត្តា ករុណា មុទិតា ឧបេក្ខា ។

[៥០០] តត្ថ កតមា មេត្តា ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ មេត្តាសហគតំ យា តស្មឹ សមយេ មេត្តិ មេត្តា-យនា មេត្តាយិតត្តំ មេត្តា ចេតោវិមុត្តិ អយំ វុច្ចតិ មេត្តា អវសេសា ធម្មា មេត្តាយ សម្បយុត្តា ។ តត្ថ កតមា មេត្តា ។ ឥធ ភិក្ខុ យស្មឹ សមយេ

ពាក្យថា ទូលាយ គឺ គុណជាតណា ដ៏ទូលាយ គុណជាតនោះ ដល់នូវភាពជាធំ គុណជាតណា ដល់នូវភាពជាធំ គុណជាតនោះ មិនមានប្រមាណ គុណជាតណា មិនមានប្រមាណ សភាវៈនោះ មិនមានពៀរ សភាវៈណា មិនមានពៀរ សភាវៈនោះ មិនមានព្យាបាទ ។ ពាក្យថា ផ្សាយ គឺ ផ្សាយចិត្តទៅ បញ្ជូនចិត្តទៅ ។ ពាក្យថា សម្រាកនៅ គឺ សម្រេចឥរិយាបថ ។ បេ ។ សម្រាន្តនៅ ព្រោះហេតុនោះ ទើបពោលថា សម្រាកនៅ ។

ចប់ សុត្តន្តភាជនីយ ។

[៦៩៩] អប្បមញ្ញា ៤ យ៉ាង គឺ មេត្តា ១ ករុណា ១ មុទិតា ១ ឧបេក្ខា ១ ។

[៧០០] បណ្ដាអប្បមញ្ញាទាំងនោះ មេត្តា តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន ប្រកបដោយមេត្តា ក្នុងសម័យនោះ ការរាប់អាន អាការរាប់អាន ភាពនៃការរាប់អាន ការរាប់រក ចេតោវិមុត្តិ ណា នេះហៅថា មេត្តា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមេត្តា ។ បណ្ដាអប្បមញ្ញាទាំងនោះ មេត្តា តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ

រូបូបបត្តិយា មគ្គំ ភាវេតិ វិតក្កវិចារាជំ រូបសមា ។ បេ ។ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ មេត្តាសហគតំ យា តស្មឹ សមយេ មេត្តិ មេត្តាយនា មេត្តាយិតត្តំ មេត្តា ចេតោវិមុត្តិ អយំ វុច្ចតិ មេត្តា អវសេសា ធម្មា មេត្តាយ សម្បយុត្តា ។ តត្ថ កាតមា មេត្តា ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ បីតិយា ច វិរាគា ។ បេ ។ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ មេត្តាសហគតំ យា តស្មឹ សមេយ មេត្តិ មេត្តាយនា មេត្តាយិតត្តំ មេត្តា ចេតោវិមុត្តិ អយំ វុច្ចតិ មេត្តា អវសេសា ធម្មា មេត្តាយ សម្បយុត្តា ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ មេត្តាសហគតំ យា តស្មឹ សមយេ មេត្តិ មេត្តាយនា មេត្តាយិតត្តំ មេត្តា ចេតោវិមុត្តិ អយំ វុច្ចតិ មេត្តា អវសេសា ធម្មា មេត្តាយ សម្បយុត្តា ។ ឥធ ភិក្ខុ យស្មឹ សមយេ

ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះរម្ងាប់នូវវិតក្កៈនិងវិចារៈ ។ បេ ។ ចូលកាន់ទុតិយជ្ឈាន ប្រកបដោយមេត្តា ក្នុងសម័យនោះ ការរាប់អាន អាការរាប់អាន ភាពនៃការរាប់អាន ការរាប់រក ចេតោវិមុត្តិ ណា នេះហៅថា មេត្តា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមេត្តា ។ បណ្ដាអប្បមញ្ញាទាំងនោះ មេត្តា តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះនឿយណាយចាកបីតិផង ។ បេ ។ ចូលកាន់តតិយជ្ឈាន ប្រកបដោយមេត្តា ក្នុងសម័យនោះ ការរាប់អាន អាការរាប់អាន ភាពនៃការរាប់អាន ការរាប់រក ចេតោវិមុត្តិ ណា នេះហៅថា មេត្តា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមេត្តា ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន ប្រកបដោយមេត្តា ក្នុងសម័យនោះ ការរាប់អាន អាការរាប់អាន ភាពនៃការរាប់អាន ការរាប់រក ចេតោ-វិមុត្តិ ណា នេះហៅថា មេត្តា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមេត្តា ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ

រូប្បូបបត្តិយា មគ្គំ ភាវេតិ អវិតក្កំ វិចារមត្តំ វិវេក-
ជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ
មេត្តាសហគតំ យា តស្មឹ សមយេ មេត្តិ មេត្តាយនា
មេត្តាយិតត្តំ មេត្តា ចេតោវិមុត្តិ អយំ វុច្ចតិ មេត្តា
អវសេសា ធម្មា មេត្តាយ សម្បយុត្តា ។ ឥធ ភិក្ខុ
យស្មឹ សមយេ រូប្បូបបត្តិយា មគ្គំ ភាវេតិ វិតក្ក-
វិចារានំ វូបសមា ។ បេ ។ តតិយំ ឈានំ ឧប-
សម្បជ្ជ វិហរតិ មេត្តាសហគតំ យា តស្មឹ សមយេ
មេត្តិ មេត្តាយនា មេត្តាយិតត្តំ មេត្តា ចេតោវិមុត្តិ
អយំ វុច្ចតិ មេត្តា អវសេសា ធម្មា មេត្តាយ សម្ប-
យុត្តា ។ ឥធ ភិក្ខុ យស្មឹ សមយេ រូប្បូបបត្តិយា
មគ្គំ ភាវេតិ បីតិយា ច វិរាគា ។ បេ ។ ចតុត្ថំ
ឈានំ ឧបសម្បជ្ជ វិហរតិ មេត្តាសហគតំ យា
តស្មឹ សមយេ មេត្តិ មេត្តាយនា មេត្តាយិតត្តំ មេត្តា
ចេតោវិមុត្តិ អយំ វុច្ចតិ មេត្តា អវសេសា ធម្មា
មេត្តាយ សម្បយុត្តា ។

ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ចូលកាន់ទុតិយជ្ឈាន មិនមានវិតក្កៈ មាន ត្រឹមតែវិចារៈ មានបីតិនិងសុខកើតក្នុងវិវេក ប្រកបដោយមេត្តា ក្នុង សម័យនោះ ការរាប់អាន អាការរាប់អាន ភាពនៃការរាប់អាន ការ រាប់រក ចេតោវិមុត្តិ ណា នេះហៅថា មេត្តា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមេត្តា ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះរម្ងាប់នូវវិតក្កៈនិងវិចារៈ ។ បេ ។ ចូលកាន់តតិយជ្ឈាន ប្រកបដោយមេត្តា ក្នុងសម័យនោះ ការរាប់អាន អាការរាប់អាន ភាពនៃការរាប់អាន ការរាប់រក ចេតោវិមុត្តិ ណា នេះហៅថា មេត្តា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយ មេត្តា ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើត ក្នុងរូបភព ព្រោះនឿយណាយចាកបីតិផង ។ បេ ។ ចូលកាន់ចតុត្ថ-ជ្ឈានប្រកបដោយមេត្តា ក្នុងសម័យនោះ ការរាប់អាន អាការរាប់អាន ភាពនៃការរាប់អាន ការរាប់រក ចេតោវិមុត្តិ ណា នេះហៅថា មេត្តា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមេត្តា ។

[៨០១] តត្ថ កតមា ករុណា ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ករុណាសហគតំ យា តស្មឹ សមយេ ករុណា ករុណាយនា ករុណាយិតត្តំ ករុណា ចេតោវិមុត្តិ អយំ វុច្ចតិ ករុណា អវសេសា ធម្មា ករុណាយ សម្បយុត្តា ។ តត្ថ កតមា ករុណា ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ករុណាសហគតំ យា តស្មឹ សមយេ ករុណា ករុណាយនា ករុណាយិតត្តំ ករុណា ចេតោវិមុត្តិ អយំ វុច្ចតិ ករុណា អវសេសា ធម្មា ករុណាយ សម្បយុត្តា ។ តត្ថ កតមា ករុណា ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ បីតិយា ច វិរាគា ។ បេ ។ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ករុណាសហគតំ យា តស្មឹ សមយេ ករុណា ករុណាយនា ករុណាយិតត្តំ ករុណា ចេតោវិមុត្តិ អយំ វុច្ចតិ ករុណា អវសេសា ធម្មា

[៥០១] បណ្ដាអប្បមញ្ញាទាំងនោះ ករុណា តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន ប្រកបដោយករុណា ក្នុងសម័យនោះ ការអាណិត អាការអាណិត ភាពនៃការអាណិត ការអាណិតអាសូរ ចេតោវិមុត្តិ ណា នេះហៅថា ករុណា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយករុណា ។ បណ្ដាអប្បមញ្ញាទាំងនោះ ករុណា តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះរម្ងាប់វិតក្កៈនិងវិចារៈ ។ បេ ។ ចូលកាន់ទុតិយជ្ឈាន ប្រកបដោយករុណា ក្នុងសម័យនោះ ការអាណិត អាការអាណិត ភាពនៃការអាណិត ការអាណិតអាសូរ ចេតោវិមុត្តិ ណា នេះហៅថា ករុណា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយករុណា ។ បណ្ដាអប្បមញ្ញាទាំងនោះ ករុណា តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះនឿយណាយចាកបីតិផង ។ បេ ។ ចូលកាន់តតិយជ្ឈាន ប្រកបដោយករុណា ក្នុងសម័យនោះ ការអាណិត អាការអាណិត ភាពនៃការអាណិត ការអាណិតអាសូរ ចេតោវិមុត្តិ ណា នេះហៅថា ករុណា ធម៌ទាំងឡាយដ៏សេស

ករុណាយ សម្បយុត្តា ។ ឥធ ភិក្ខុ យស្មឹ សម-
យេ រូបូបបត្តិយា មគ្គំ ភាវេតិ វិវិច្ចេវ កាមេហិ
។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ករុ-
ណាសហគតំ យា តស្មឹ សមយេ ករុណា
ករុណាយនា ករុណាយិតត្តំ ករុណា ចេតោវិមុត្តិ
អយំ វុច្ចតិ ករុណា អវសេសា ធម្មា ករុណាយ
សម្បយុត្តា ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិ-
យា មគ្គំ ភាវេតិ អវិតក្កំ វិចារមត្តំ វិវេកជំ បីតិ-
សុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ករុណា-
សហគតំ យា តស្មឹ សមយេ ករុណា ករុណា-
យនា ករុណាយិតត្តំ ករុណា ចេតោវិមុត្តិ អយំ
វុច្ចតិ ករុណា អវសេសា ធម្មា ករុណាយ សម្ប-
យុត្តា ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិ-
យា មគ្គំ ភាវេតិ វិតក្កវិចារានំ វូបសមា ។ បេ ។
តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ករុណាសហ-
គតំ យា តស្មឹ សមយេ ករុណា ករុណាយនា
ករុណាយិតត្តំ ករុណា ចេតោវិមុត្តិ អយំ វុច្ចតិ
ករុណា អវសេសា ធម្មា ករុណាយ សម្បយុត្តា ។

ក៏ឈ្មោះថា ប្រកបដោយករុណា ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន ប្រកបដោយករុណា ក្នុងសម័យនោះ ការអាណិត អាការអាណិត ភាពនៃការអាណិត ការអាណិតអាសូរ ចេតោ-វិមុត្តិ ណា នេះហៅថា ករុណា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយករុណា ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ចូលកាន់ទុតិយជ្ឈាន មិនមានវិតក្កៈ មានត្រឹមតែវិចារៈ មានបីតិនិងសុខ កើតក្នុងវិវេក ប្រកបដោយករុណា ក្នុងសម័យនោះ ការអាណិត អាការអាណិត ភាពនៃការអាណិត ការអាណិតអាសូរ ចេតោវិមុត្តិ ណា នេះហៅថា ករុណា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយករុណា ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះរម្ងាប់វិតក្កៈនិងវិចារៈ ។ បេ ។ ចូលកាន់តតិយជ្ឈាន ប្រកបដោយករុណា ក្នុងសម័យនោះ ការអាណិត អាការអាណិត ភាពនៃការអាណិត ការអាណិតអាសូរ ចេតោវិមុត្តិ ណា នេះហៅថា ករុណា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយករុណា ។

ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ បីតិយា ច វិរាគា ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ករុណាសហគតំ យា តស្មឹ សមយេ ករុណា ករុណាយនា ករុណាយិតត្តំ ករុណា ចេតោវិមុត្តិ អយំ វុច្ចតិ ករុណា អវសេសា ធម្មា ករុណាយ សម្បយុត្តា ។

[៥០២] តត្ថ កតមា មុទិតា ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ មុទិតាសហគតំ យា តស្មឹ សមយេ មុទិតា មុទិតាយនា មុទិតាយិតត្តំ មុទិតា ចេតោវិមុត្តិ អយំ វុច្ចតិ មុទិតា អវសេសា ធម្មា មុទិតាយ សម្បយុត្តា ។ តត្ថ កតមា មុទិតា ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ មុទិតាសហគតំ យា តស្មឹ សមយេ មុទិតា មុទិតាយនា មុទិតាយិតត្តំ មុទិតា

ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះនឿយណាយចាកបីតិផង ។ បេ ។ ចូលកាន់ចតុត្ថជ្ឈាន ប្រកបដោយករុណា ក្នុងសម័យនោះ ការអាណិត អាការអាណិត ភាពនៃការអាណិត ការអាណិតអាសូរ ចេតោវិមុត្តិ ណា នេះហៅថា ករុណា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយករុណា ។

[៩០២] បណ្ដាអប្បមញ្ញាទាំងនោះ មុទិតា តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន ប្រកបដោយមុទិតា ក្នុងសម័យនោះ ការរីករាយ អាការរីករាយ ភាពនៃការរីក-រាយ ការស្រស់ស្រាយ ចេតោវិមុត្តិ ណា នេះហៅថា មុទិតា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមុទិតា ។ បណ្ដាអប្បមញ្ញាទាំងនោះ មុទិតា តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះរម្ងាប់វិតក្កៈនិងវិចារៈ ។ បេ ។ ចូលកាន់ទុតិយជ្ឈាន ប្រកបដោយមុទិតា ក្នុងសម័យនោះ ការរីករាយ អាការរីករាយ ភាពនៃការរីករាយ ការស្រស់ស្រាយ

ចេតោវិមុត្តិ អយំ វុច្ចតិ មុទិតា អវសេសា ធម្មា មុទិតាយ សម្បយុត្តា ។ តត្ថ កតមា មុទិតា ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ បីតិយា ច វិរាគា ។ បេ ។ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ មុទិតាសហគតំ យា តស្មឹ សមយេ មុទិតា មុទិតាយនា មុទិតាយិតត្តំ មុទិតា ចេតោវិមុត្តិ អយំ វុច្ចតិ មុទិតា អវសេសា ធម្មា មុទិតាយ សម្បយុត្តា ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ វិវិច្ចេវ កាមេ-ហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ មុទិតាសហគតំ យា តស្មឹ សមយេ មុទិតា មុទិតា-យនា មុទិតាយិតត្តំ មុទិតា ចេតោវិមុត្តិ អយំ វុច្ចតិ មុទិតា អវសេសា ធម្មា មុទិតាយ សម្បយុត្តា ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ អវិតក្កំ វិចារមត្តំ វិវេកជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ មុទិតាសហគតំ យា តស្មឹ សមយេ មុទិតា មុទិតាយនា មុទិតាយិតត្តំ មុទិតា ចេតោវិមុត្តិ អយំ វុច្ចតិ មុទិតា អវសេសា ធម្មា

ចេតោវិមុត្តិ ណា នេះហៅថា មុទិតា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមុទិតា ។ បណ្តាអប្បមញ្ញាទាំងនោះ មុទិតាតើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះនឿយណាយចាកបីតិផង ។ បេ ។ ចូលកាន់តតិយជ្ឈាន ប្រកបដោយមុទិតា ក្នុងសម័យនោះ ការរីករាយ អាការរីករាយ ភាពនៃការរីករាយ ការស្រស់ស្រាយ ចេតោវិមុត្តិ ណា នេះហៅថា មុទិតា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមុទិតា ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន ប្រកបដោយមុទិតា ក្នុងសម័យនោះ ការរីករាយ អាការរីករាយ ភាពនៃការរីករាយ ការស្រស់ស្រាយ ចេតោវិមុត្តិ ណា នេះហៅថា មុទិតា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមុទិតា ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ចូលកាន់ទុតិយជ្ឈាន មិនមានវិតក្កៈ មានត្រឹមតែវិចារៈ មានបីតិនិងសុខ កើតអំពីសេចក្តីស្ងប់ស្ងាត់ ប្រកបដោយមុទិតា ក្នុងសម័យនោះ ការរីករាយ អាការរីករាយ ភាពនៃការរីករាយ ការស្រស់ស្រាយ ចេតោវិមុត្តិ ណា នេះហៅថា មុទិតា ធម៌ទាំងឡាយដ៏សេស

មុទិតាយ សម្បយុត្តា ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ វិតក្កវិចារានំ វូបសមា ។ បេ ។ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ មុទិតាសហគតំ យា តស្មឹ សមយេ មុទិតា មុទិតាយនា មុទិតាយិតត្តំ មុទិតា ចេតោវិមុត្តិ អយំ វុច្ចតិ មុទិតា អវសេសា ធម្មា មុទិតាយ សម្បយុត្តា ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ បីតិយា ច វិរាគា ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ មុទិតាសហគតំ យា តស្មឹ សមយេ មុទិតា មុទិតាយនា មុទិតាយិតត្តំ មុទិតា ចេតោវិមុត្តិ អយំ វុច្ចតិ មុទិតា អវសេសា ធម្មា មុទិតាយ សម្បយុត្តា ។

[៥០៣] តត្ថ កតមា ឧបេក្ខា ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ សុខស្ស ច បហានា ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ឧបេក្ខាសហគតំ យា តស្មឹ សមយេ ឧបេក្ខា ឧបេក្ខាយនា ឧបេក្ខាយិតត្តំ ឧបេក្ខា ចេតោវិមុត្តិ អយំ វុច្ចតិ ឧបេក្ខា អវសេសា ធម្មា ឧបេក្ខាយ សម្បយុត្តា ។

ក៏ឈ្មោះថា ប្រកបដោយមុទិតា ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះរម្ងាប់វិតក្កៈនិងវិចារៈ ។ បេ ។ ចូលកាន់តតិយជ្ឈាន ប្រកបដោយមុទិតា ក្នុងសម័យនោះ ការរីករាយ អាការរីករាយ ភាពនៃការរីករាយ ការស្រស់ស្រាយ ចេតោវិមុត្តិ ណា នេះហៅថា មុទិតា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកប ដោយមុទិតា ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះនឿយណាយចាកបីតិផង ។ បេ ។ ចូល កាន់ចតុត្ថជ្ឈាន ប្រកបដោយមុទិតា ក្នុងសម័យនោះ ការរីករាយ អាការរីករាយ ភាពនៃការរីករាយ ការស្រស់ស្រាយ ចេតោវិមុត្តិ ណា នេះហៅថា មុទិតា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយ មុទិតា ។

[៥០៣] បណ្តាអប្បមញ្ញាទាំងនោះ ឧបេក្ខា តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះលះបង់សុខផង ។ បេ ។ ចូលកាន់ចតុត្ថជ្ឈាន ប្រកបដោយ ឧបេក្ខា ក្នុងសម័យនោះ ការព្រងើយ អាការព្រងើយ ភាពនៃការ ព្រងើយ ការតោះតើយ ចេតោវិមុត្តិ ណា នេះហៅថា ឧបេក្ខា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឧបេក្ខា ។

[៤០៤] ចតស្សោ អប្បមញ្ញាយោ មេត្តា ករុណា មុទិតា ឧបេក្ខា ។

[៤០៥] តត្ថ កតមា មេត្តា ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ មេត្តាសហគតំ តស្មឹ សមយេ ផស្សោ ហោតិ ។ បេ ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា តស្សេវ រូបាវចរស្ស កុសលស្ស កម្មស្ស កតត្តា ឧបចិតត្តា វិបាកំ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ មេត្តាសហគតំ យា តស្មឹ សមយេ មេត្តិ មេត្តាយនា មេត្តាយិតត្តំ មេត្តា ចេតោវិមុត្តិ អយំ វុច្ចតិ មេត្តា អវសេសា ធម្មា មេត្តាយ សម្បយុត្តា ។ តត្ថ កតមា មេត្តា ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ មេត្តាសហគតំ តស្មឹ សមយេ ផស្សោ ហោតិ ។ បេ ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា តស្សេវ រូបាវចរស្ស កុសលស្ស

[៥០៤] អប្បមញ្ញា ៤ យ៉ាង គឺ មេត្តា ១ ករុណា ១ មុទិតា ១ ឧបេក្ខា ១ ។

[៥០៥] បណ្តាអប្បមញ្ញាទាំងនោះ មេត្តា តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន ប្រកបដោយមេត្តា ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។ បេ ។ អវិក្ខេបៈក៏កើតមាន ធម៌ទាំងនេះ ឈ្មោះថាជាកុសល ភិក្ខុ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន ជាវិបាក ប្រកបដោយមេត្តា ព្រោះភាពនៃកម្មជារូបាវចរកុសលនោះឯង ដែលលោកធ្វើហើយ សន្សំហើយ ក្នុងសម័យនោះ ការរាប់អាន អាការរាប់អាន ភាពនៃការរាប់អាន ការរាប់រកចេតោវិមុត្តិ ណា នេះហៅថា មេត្តា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមេត្តា ។ បណ្តាអប្បមញ្ញាទាំងនោះ មេត្តា តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះរម្ងាប់វិតក្កៈនិងវិចារៈ ។ បេ ។ ចូលកាន់ទុតិយជ្ឈាន ប្រកបដោយមេត្តា ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។ បេ ។ អវិក្ខេបៈក៏កើតមាន ធម៌ទាំងនេះ ឈ្មោះថាជាកុសល ភិក្ខុ

កម្មស្ស កតត្តា ឧបចិតត្តា វិបាកំ វិតក្កវិចារាជំ រូបសមា ។ បេ ។ ទុតិយំ ឈានំ ។ បេ ។ តតិយំ ឈានំ ។ បេ ។ បឋមំ ឈានំ ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ មេត្តាសហគតំ យា តស្មឹ សមយេ មេត្តិ មេត្តាយនា មេត្តាយិតត្តំ មេត្តា ចេតោវិមុត្តិ អយំ វុច្ចតិ មេត្តា អវសេសា ធម្មា មេត្តាយ សម្បយុត្តា ។

[៤០៦] តត្ថ កតមា ករុណា ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ករុណាសហគតំ តស្មឹ សមយេ ផស្សោ ហោតិ ។ បេ ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា តស្សេវ រូបាវចរស្ស កុសលស្ស កម្មស្ស កតត្តា ឧបចិតត្តា វិបាកំ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ករុណាសហគតំ យា តស្មឹ សមយេ ករុណា ករុណាយនា ករុណា-យិតត្តំ ករុណា ចេតោវិមុត្តិ អយំ វុច្ចតិ ករុណា អវសេសា ធម្មា ករុណាយ សម្បយុត្តា ។ តត្ថ

ព្រោះរម្ងាប់វិតក្កៈនិងវិចារៈ ។ បេ ។ ចូលកាន់ទុតិយជ្ឈាន ។ បេ ។ តតិយជ្ឈាន ។ បេ ។ បឋមជ្ឈាន ។ បេ ។ ចតុត្ថជ្ឈាន ជាវិបាក ប្រកបដោយមេត្តា ព្រោះភាពនៃកម្មជារូបាវចរកុសលនោះឯង ដែលលោកធ្វើហើយ សន្សំហើយ ក្នុងសម័យនោះ ការរាប់អាន អាការរាប់អាន ភាពនៃការរាប់អាន ការរាប់រក ចេតោវិមុត្តិ ណា នេះហៅថា មេត្តា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមេត្តា ។

[៩០៦] បណ្តាអប្បមញ្ញាទាំងនោះ ករុណា តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន ប្រកបដោយករុណា ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។ បេ ។ អវិក្ខេបៈក៏កើតមាន ធម៌ទាំងនេះ ឈ្មោះថាជាកុសល ភិក្ខុ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន ជាវិបាក ប្រកបដោយករុណា ព្រោះភាពនៃកម្មជារូបាវចរកុសលនោះឯង ដែលលោកធ្វើហើយ សន្សំហើយ ក្នុងសម័យនោះ ការអាណិត អាការអាណិត ភាពនៃការអាណិត ការអាណិតអាសូរ ចេតោវិមុត្តិ ណា នេះហៅថា ករុណា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយករុណា ។ បណ្តា

កតមា ករុណា ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ករុណាសហគតំ តស្មឹ សមយេ ផស្សោ ហោតិ ។ បេ ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា តស្សេវ រូបាវចរស្ស កុសលស្ស កម្មស្ស កតត្តា ឧបចិតត្តា វិបាកំ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយំ ឈានំ ។ បេ ។ តតិយំ ឈានំ ។ បេ ។ បឋមំ ឈានំ ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ករុណាសហគតំ យា តស្មឹ សមយេ ក-រុណា ករុណាយនា ករុណាយិតត្តំ ករុណា ចេតោ-វិមុត្តិ អយំ វុច្ចតិ ករុណា អវសេសា ធម្មា ករុ-ណាយ សម្បយុត្តា ។

[៨០៧] តត្ថ កតមា មុទិតា ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ មុទិតាសហគតំ តស្មឹ សមយេ ផស្សោ ហោតិ ។ បេ ។

អប្បមញ្ញាទាំងនោះ ករុណា តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះរម្ងាប់វិតក្កៈនិងវិចារៈ ។ បេ ។ ចូលកាន់ទុតិយជ្ឈាន ប្រកបដោយករុណា ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។ បេ ។ អវិក្ខេបៈក៏កើតមាន ធម៌ទាំងនេះ ឈ្មោះថាជាកុសល ភិក្ខុ ព្រោះរម្ងាប់វិតក្កៈនិងវិចារៈ ។ បេ ។ ចូលកាន់ទុតិយជ្ឈាន ។ បេ ។ តតិយជ្ឈាន ។ បេ ។ បឋមជ្ឈាន ។ បេ ។ ចតុត្ថជ្ឈាន ជាវិបាក ប្រកបដោយករុណា ព្រោះភាពនៃកម្មជារូបាវចរ-កុសលនោះឯង ដែលលោកធ្វើហើយ សន្សំហើយ ក្នុងសម័យនោះ ការអាណិត អាការអាណិត ភាពនៃការអាណិត ការអាណិតអាស្រូវចេតោវិមុត្តិ ណា នេះហៅថា ករុណា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយករុណា ។

[៩០៧] បណ្តាអប្បមញ្ញាទាំងនោះ មុទិតា តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន ប្រកបដោយមុទិតា ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។ បេ ។

អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា តស្សេវ រូបាវចរស្ស កុសលស្ស កម្មស្ស កតត្តា ឧបចិតត្តា វិបាកំ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ មុទិតាសហគតំ យា តស្មឹ សមយេ មុទិតា មុទិតាយនា មុទិតាយិតត្តំ មុទិតា ចេតោវិមុត្តិ អយំ វុច្ចតិ មុទិតា អវសេសា ធម្មា មុទិតាយ សម្បយុត្តា ។ តត្ថ កតមា មុទិតា ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ មុទិតាសហគតំ តស្មឹ សមយេ ផស្សោ ហោតិ ។ បេ ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា តស្សេវ រូបាវចរស្ស កុសលស្ស កម្មស្ស កតត្តា ឧបចិតត្តា វិបាកំ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយំ ឈានំ ។ បេ ។ តតិយំ ឈានំ ។ បេ ។ បឋមំ ឈានំ ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ មុទិតាសហគតំ យា តស្មឹ សមយេ មុទិតា មុទិតាយនា មុទិតាយិតត្តំ មុទិតា ចេតោវិមុត្តិ អយំ វុច្ចតិ មុទិតា អវសេសា ធម្មា មុទិតាយ សម្បយុត្តា ។

អវិក្ខេបៈក៏កើតមាន ធម៌ទាំងនេះ ឈ្មោះថាជាកុសល ភិក្ខុស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន ជាវិបាក ប្រកបដោយមុទិតា ព្រោះភាពនៃកម្មជារូបាវចរកុសលនោះឯង ដែលលោកធ្វើហើយ សន្សំហើយ ក្នុងសម័យនោះ ការរីករាយ អាការរីករាយ ភាពនៃការរីករាយ ការស្រស់ស្រាយ ចេតោវិមុត្តិ ណា នេះហៅថា មុទិតា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមុទិតា ។ បណ្ដាអប្បមញ្ញាទាំងនោះ មុទិតា តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះរម្ងាប់វិតក្កៈនិងវិចារៈ ។ បេ ។ ចូលកាន់ទុតិយជ្ឈាន ប្រកបដោយមុទិតា ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។ បេ ។ អវិក្ខេបៈក៏កើតមាន ធម៌ទាំងនេះ ឈ្មោះថាជាកុសល ភិក្ខុ ព្រោះរម្ងាប់វិតក្កៈនិងវិចារៈ ។ បេ ។ ចូលកាន់ទុតិយជ្ឈាន ។ បេ ។ តតិយជ្ឈាន ។ បេ ។ បឋមជ្ឈាន ។ បេ ។ ចតុត្ថជ្ឈាន ជាវិបាក ប្រកបដោយមុទិតា ព្រោះភាពនៃកម្មជារូបាវចរកុសលនោះឯង ដែលលោកធ្វើហើយ សន្សំហើយ ក្នុងសម័យនោះ ការរីករាយ អាការរីករាយ ភាពនៃការរីករាយ ការស្រស់ស្រាយ ចេតោវិមុត្តិ ណា នេះហៅថា មុទិតា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមុទិតា ។

[៤០៨] តត្ថ កតមា ឧបេក្ខា ។ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ សុខស្ស ច បហានា ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ឧបេក្ខាសហគតំ តស្មឹ សមយេ ផស្សោ ហោតិ ។ បេ ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា តស្សេវ រូបាវចរស្ស កុសលស្ស កម្មស្ស កតត្តា ឧបចិតត្តា វិបាកំ សុខស្ស ច បហានា ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ឧបេក្ខាសហគតំ យា តស្មឹ សមយេ ឧបេក្ខា ឧបេក្ខាយនា ឧបេក្ខាយិតត្តំ ឧបេក្ខា ចេតោវិមុត្តិ អយំ វុច្ចតិ ឧបេក្ខា អវសេសា ធម្មា ឧបេក្ខាយ សម្បយុត្តា ។

[៤០៩] ចតស្សោ អប្បមញ្ញាយោ មេត្តា ករុណា មុទិតា ឧបេក្ខា ។

[៤១០] តត្ថ កតមា មេត្តា ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបាវចរំ ឈានំ ភាវេតិ កិរិយំ នេវ កុសលំ នាកុសលំ ន ច កម្មវិបាកំ ទិដ្ឋធម្មសុខវិហារំ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ មេត្តាសហគតំ យា តស្មឹ សមយេ មេត្តិ

[៥០៨] បណ្ដាអប្បមញ្ញាទាំងនោះ ឧបេក្ខា តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះលះសុខផង ។ បេ ។ ចូលកាន់ចតុត្ថជ្ឈាន ប្រកបដោយឧបេក្ខា ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។ បេ ។ អវិក្ខេបៈក៏កើតមាន ធម៌ទាំងនេះ ឈ្មោះថាជាកុសល ភិក្ខុ ព្រោះលះសុខផង ។ បេ ។ ចូលកាន់ចតុត្ថជ្ឈាន ជាវិបាក ប្រកបដោយឧបេក្ខា ព្រោះភាពនៃកម្ម ជារូបាវចរកុសលនោះឯង ដែលលោកធ្វើហើយ សន្សំហើយ ក្នុងសម័យនោះ ការព្រងើយ អាការព្រងើយ ភាពនៃការព្រងើយ ការតោះ-តើយ ចេតោវិមុត្តិ ណា នេះហៅថា ឧបេក្ខា ធម៌ទាំងឡាយដ៏សេសក៏ឈ្មោះថា ប្រកបដោយឧបេក្ខា ។

[៥០៩] អប្បមញ្ញា ៤ យ៉ាង គឺ មេត្តា ១ករុណា ១ មុទិតា ១ ឧបេក្ខា ១ ។

[៥១០] បណ្ដាអប្បមញ្ញាទាំងនោះ មេត្តា តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនរូបាវចរជ្ឈាន ជាកិរិយា មិនមែនកុសល មិនមែនអកុសល ទាំងមិនមែនកម្មវិបាក គឺជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន ប្រកបដោយមេត្តា ក្នុងសម័យនោះ ការរាប់អាន

មេត្តាយនា មេត្តាយិតត្តំ មេត្តា ចេតោវិមុត្តិ អយំ វុច្ចតិ មេត្តា អវសេសា ធម្មា មេត្តាយ សម្បយុត្តា ។ តត្ថ កតមា មេត្តា ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបាវចរំ ឈានំ ភាវេតិ កិរិយំ នេវ កុសលំ នាកុសលំ ន ច កម្មវិបាកំ ទិដ្ឋធម្មសុខវិហារំ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយំ ឈានំ ។ បេ ។ តតិយំ ឈានំ ។ បេ ។ បឋមំ ឈានំ ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ មេត្តាសហគតំ យា តស្មឹ សមយេ មេត្តិ មេត្តាយនា មេត្តាយិតត្តំ មេត្តា ចេតោវិមុត្តិ អយំ វុច្ចតិ មេត្តា អវសេសា ធម្មា មេត្តាយ សម្បយុត្តា ។ តត្ថ កតមា ករុណា ។ បេ ។ តត្ថ កតមា មុទិតា ។ បេ ។ តត្ថ កតមា ឧបេក្ខា ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបាវចរំ ឈានំ ភាវេតិ កិរិយំ នេវ កុសលំ នាកុសលំ ន ច កម្មវិបាកំ ទិដ្ឋធម្មសុខវិហារំ សុខស្ស ច បហានា ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ឧបេក្ខាសហគតំ យា តស្មឹ សមយេ ឧបេក្ខា ឧបេក្ខាយនា ឧបេក្ខាយិតត្តំ ឧបេក្ខា ចេតោវិមុត្តិ

អាការរាប់អាន ភាពនៃការរាប់អាន ការរាប់រក ចេតោវិមុត្តិ ណា នេះហៅថា មេត្តា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមេត្តា ។ បណ្តាអប្បមញ្ញាទាំងនោះ មេត្តា តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនរូបាវចរជ្ឈាន ជាកិរិយា មិនមែនកុសល មិនមែនអកុសល ទាំងមិនមែនកម្មវិបាក គឺជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ព្រោះរម្ងាប់វិតក្កៈនិងវិចារៈ ។ បេ ។ ចូលកាន់ទុតិយជ្ឈាន ។ បេ ។ តតិយជ្ឈាន ។ បេ ។ បឋមជ្ឈាន ។ បេ ។ ចតុត្ថជ្ឈាន ប្រកបដោយមេត្តា ក្នុងសម័យនោះ ការរាប់អាន អាការរាប់អាន ភាពនៃការរាប់អាន ការរាប់រក ចេតោវិមុត្តិ ណា នេះហៅថា មេត្តា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមេត្តា ។ បណ្តាអប្បមញ្ញាទាំងនោះ ករុណា តើដូចម្តេច ។ បេ ។ បណ្តាអប្បមញ្ញាទាំងនោះ មុទិតា តើដូចម្តេច ។ បេ ។ បណ្តាអប្បមញ្ញាទាំងនោះ ឧបេក្ខា តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនរូបាវចរជ្ឈាន ជាកិរិយា មិនមែនកុសល មិនមែនអកុសល ទាំងមិនមែនកម្មវិបាក គឺជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ព្រោះលះសុខផង ។ បេ ។ ចូលកាន់ចតុត្ថជ្ឈាន ប្រកបដោយឧបេក្ខា ក្នុងសម័យនោះ ការព្រងើយ អាការព្រងើយ ភាពនៃការព្រងើយ ការតោះតើយ ចេតោវិមុត្តិ ណា

អយំ វុច្ចតិ ឧបេក្ខា អវសេសា ធម្មា ឧបេក្ខាយ សម្បយុត្តា ។

អភិធម្មភាជនីយំ ។

[៤១១] ចតស្សោ អប្បមញ្ញាយោ ។ ឥធ ភិក្ខុ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហរតិ ។ ករុណាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ករុណាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហរតិ ។ មុទិតាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ

នេះហៅថា ឧបេក្ខា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឧបេក្ខា ។

ចប់ អភិធម្មភាជនីយ ។

[៦១១] អប្បមញ្ញា ៤ យ៉ាង ។ គឺ ភិក្ខុក្នុងសាសនានេះ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិស ១ ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម ទិសទទឹងគឺទិសតូច មានចិត្តប្រកបដោយមេត្តា ជាចិត្តធំ ទូលាយ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ ក្នុងទីទាំងពួង ១ ។ ភិក្ខុ មានចិត្តប្រកបដោយករុណា ផ្សាយទៅកាន់ទិស ១ ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម ទិសទទឹងគឺទិសតូច មានចិត្តប្រកបដោយករុណា ជាចិត្តធំ ទូលាយ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ ក្នុងទីទាំងពួង ១ ។ ភិក្ខុ មានចិត្តប្រកបដោយមុទិតា ផ្សាយទៅកាន់ទិស ១ ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម ទិសទទឹងគឺទិសតូច

សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មុទិតាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហរតិ ។ ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហរតិ ។ ចតុន្នំ អប្បមញ្ញានំ កតិ កុសលា កតិ អកុសលា កតិ អព្យាកតា ។ បេ ។ កតិ សរណា កតិ អរណា ។

[៥១២] សិយា កុសលា សិយា អព្យាកតា ។ តិស្សោ អប្បមញ្ញាយោ សុខាយ វេទនាយ សម្បយុត្តា ឧបេក្ខា អទុក្ខមសុខាយ វេទនាយ សម្បយុត្តា ។ សិយា វិបាកា សិយា វិបាកធម្មធម្មា សិយា នេវវិបាកនវិបាកធម្មធម្មា សិយា ឧបាទិន្នុបាទានិយា សិយា អនុបាទិន្នុបាទានិយា អសង្កិលិដ្ឋសង្កិលេសិកា ។ តិស្សោ អប្បមញ្ញាយោ

មានចិត្តប្រកបដោយមុទិតា ជាចិត្តធំ ទូលាយ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ ក្នុងទីទាំងពួង ១ ។ ភិក្ខុមានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិស ១ ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម ទិសទទឹងគឺទិសតូច មានចិត្តប្រកបដោយឧបេក្ខា ជាចិត្តធំ ទូលាយ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ ក្នុងទីទាំងពួង ១ ។ បណ្តាអប្បមញ្ញា ៤ យ៉ាង អប្បមញ្ញា ជាកុសលប៉ុន្មាន ជាអកុសលប៉ុន្មាន ជាអព្យាក្រឹតប៉ុន្មាន ។ បេ ។ ជាសរណៈប៉ុន្មាន ជាអរណៈប៉ុន្មាន ។

[៩១២] ពួកអប្បមញ្ញា ជាកុសល ក៏មាន ជាអព្យាក្រឹត ក៏មាន ។ អប្បមញ្ញា ៣ ប្រកបដោយសុខវេទនា ឧបេក្ខា ប្រកបដោយអទុក្ខមសុខវេទនា ។ អប្បមញ្ញា ជាវិបាកក៏មាន មានវិបាកធម៌ជាប្រក្រតី ក៏មាន មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតី ក៏មាន មានកម្មប្រកបដោយកិលេសមានតណ្ហាជាដើមកាន់យក ទាំងជាប្រយោជន៍ដល់ឧបាទាន ក៏មាន មានកម្មប្រកបដោយកិលេសមានតណ្ហាជាដើមមិនបានកាន់យក តែជាប្រយោជន៍ដល់ឧបាទាន ដែលមិនសៅហ្មង តែគួរដល់សេចក្តីសៅហ្មង ក៏មាន ។ អប្បមញ្ញា ៣

៣៣៨



សិយា សវិតក្កសវិចារា សិយា អវិតក្កវិចារមត្តា សិយា អវិតក្កាវិចារា ឧបេក្ខា អវិតក្កាវិចារា ។ តិស្សោ អប្បមញ្ញាយោ សិយា បីតិសហគតា សិយា សុខសហគតា ន ឧបេក្ខាសហគតា សិយា ន វត្តព្វា បីតិសហគតាតិ ឧបេក្ខា ឧបេក្ខាសហគតា ។ នេវ ទស្សនេន ន ភាវនាយ បហាតព្វា នេវ ទស្សនេន ន ភាវនាយ បហាតព្វហេតុកា សិយា អាចយគាមិនោ សិយា នេវាចយគាមិនោ នាបចយគាមិនោ នេវ សេក្ខា នាសេក្ខា មហគ្គតា ន វត្តព្វា បរិត្តារម្មណាតិបិ មហគ្គតារម្មណាតិបិ អប្បមាណារម្មណាតិបិ មជ្ឈិមា អនិយតា ន វត្តព្វា មគ្គារម្មណាតិបិ មគ្គហេតុកាតិបិ មគ្គាធិបតិនោតិបិ សិយា ឧប្បន្នា សិយា អនុប្បន្នា សិយា ឧប្បាទិនោ សិយា អតីតា សិយា អនាគតា សិយា បច្ចុប្បន្នា ន វត្តព្វា អតីតារម្មណាតិបិ អនាគតារម្មណាតិបិ បច្ចុប្បន្នារម្មណាតិបិ សិយា អជ្ឈត្តា សិយា ពហិទ្ធា សិយា អជ្ឈត្តពហិទ្ធា ពហិទ្ធារម្មណា អនិទស្សនាប្បដិឃា ។

ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈក៏មាន មិនមានវិតក្កៈមានត្រឹមតែវិចារៈក៏មាន មិនមានវិតក្កៈមិនមានវិចារៈក៏មាន ឧបេក្ខា មិនមានវិតក្កៈមិនមានវិចារៈ ។ អប្បមញ្ញា ៣ ប្រទ្បំដោយបីតិក៏មាន ប្រទ្បំដោយសុខ តែមិនប្រទ្បំដោយឧបេក្ខាក៏មាន មិនគួរពោលថា ប្រទ្បំដោយបីតិក៏មាន ឧបេក្ខា ប្រទ្បំដោយឧបេក្ខា ។ ពួកអប្បមញ្ញា មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនា មានហេតុមិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនា ដល់នូវការសន្សំ (នូវកម្មក្កិលេស) ក៏មាន មិនដល់នូវការសន្សំ ទាំងមិនដល់នូវការមិនសន្សំ មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់សេក្ខបុគ្គល ដល់នូវភាពធំ មិនគួរពោលថា មានអារម្មណ៍ដ៏តូចឆ្មារផង ថា មានអារម្មណ៍ដល់នូវភាពធំផង ថា មានអារម្មណ៍មិនមានប្រមាណផង ជាកណ្តាល ជាសភាពមិនទៀង មិនគួរពោលថា មានមគ្គជាអារម្មណ៍ផង ថា មានមគ្គជាហេតុផង ថា មានមគ្គជាអធិបតីផងក៏មាន ដែលកើតហើយក៏មាន មិនទាន់កើតក៏មាន បម្រុងនឹងកើតក៏មាន ជាអតីតក៏មាន ជាអនាគតក៏មានជាបច្ចុប្បន្ន តែមិនគួរពោលថា មានអារម្មណ៍ជាអតីតផង ថា មានអារម្មណ៍ជាអនាគតផង មានអារម្មណ៍ជាបច្ចុប្បន្នផងក៏មាន ជាខាងក្នុងក៏មាន ជាខាងក្រៅក៏មាន ជាខាងក្នុងនិងខាងក្រៅ មានអារម្មណ៍ជាខាងក្រៅ មិនប្រកបដោយការឃើញ មិនប្រកបដោយការប៉ះពាល់ ក៏មាន ។

[៥១៣] មេត្តា ហេតុ តិស្សោ អប្បមញ្ញាយោ ន ហេតូ ។ សហេតុកា ហេតុសម្បយុត្តា ។ មេត្តា ហេតុ ចេវ សហេតុកា តិស្សោ អប្បមញ្ញាយោ ន វត្តព្វា ហេតូ ចេវ សហេតុកា ចាតិ សហេតុកា ចេវ ន ច ហេតូ ។ មេត្តា ហេតុ ចេវ ហេតុសម្បយុត្តា ច តិស្សោ អប្បមញ្ញាយោ ន វត្តព្វា ហេតូ ចេវ ហេតុសម្បយុត្តា ចាតិ ហេតុសម្បយុត្តា ចេវ ន ច ហេតូ ។ តិស្សោ អប្បមញ្ញាយោ ន ហេតូ សហេតុកា មេត្តា ន វត្តព្វា ន ហេតុ សហេតុកាតិបិ ន ហេតុ អហេតុកាតិបិ ។

[៥១៤] សប្បច្ចយា សង្ខតា អនិទស្សនា អប្បដិឃា អរូបា លោកិយា កេនចិ វិញ្ញេយ្យា កេនចិ ន វិញ្ញេយ្យា ។ នោ អាសវា សាសវា អាសវវិប្បយុត្តា ន វត្តព្វា អាសវា ចេវ សាសវា ចាតិ សាសវា ចេវ នោ ច អាសវា ន វត្តព្វា

[៥១៣] មេត្តា ជាហេតុ អប្បមញ្ញា ៣ មិនមែនហេតុ ។ ពួកអប្បមញ្ញា ប្រព្រឹត្តទៅជាមួយនឹងហេតុ ប្រកបដោយហេតុ ។ មេត្តា ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុ អប្បមញ្ញា ៣ មិនគួរពោលថា ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុទេ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុ ។ មេត្តា ជាហេតុ ទាំងប្រកបដោយហេតុ អប្បមញ្ញា ៣ មិនគួរពោលថា ជាហេតុ ទាំងប្រកបដោយហេតុទេ គ្រាន់តែប្រកបដោយហេតុ តែមិនមែនហេតុ ។ អប្បមញ្ញា ៣ មិនមែនហេតុ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ មេត្តា មិនគួរពោលថា មិនមែនហេតុ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុផង ថា មិនមែនហេតុ ទាំងឥតមានហេតុដូច្នេះផង ។

[៥១៤] ពួកអប្បមញ្ញា ប្រកបដោយបច្ច័យ ត្រូវបច្ច័យតាក់តែង មិនប្រកបដោយការឃើញ មិនប្រកបដោយការប៉ះពាល់ ឥតរូប ជាលោកិយ ដែលគប្បីដឹងដោយវិញ្ញាណណាមួយ ដែលមិនគប្បីដឹងដោយវិញ្ញាណណាមួយ ។ ពួកអប្បមញ្ញា មិនមែនអាសវៈ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ ប្រាសចាកអាសវៈ មិនគួរពោលថា ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈឡើយ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនជាអាសវៈ មិនគួរពោលថា

អាសវា ចេវ អាសវសម្បយុត្តា ចាតិបិ អាសវសម្បយុត្តា ចេវ នោ ច អាសវាតិបិ អាសវវិប្បយុត្តសាសវា ។ នោ សញ្ញោជនា ។ បេ ។ នោ គន្ថា ។ បេ ។ នោ ឱឃា ។ បេ ។ នោ យោគា ។ បេ ។ នោ នីវរណា ។ បេ ។ នោ បរាមាសា ។ បេ ។ សារម្មណា នោ ចិត្តា ចេតសិកា ចិត្តសម្បយុត្តា ចិត្តសំសដ្ឋា ចិត្តសមុដ្ឋានា ចិត្តសហភុនោ ចិត្តានុបរិវត្តិនោ ចិត្តសំសដ្ឋសមុដ្ឋានា ចិត្តសំសដ្ឋសមុដ្ឋានសហភុនោ ចិត្តសំសដ្ឋសមុដ្ឋានានុបរិវត្តិនោ ពាហិរា នុបាទា សិយា ឧបាទិន្នា សិយា អនុបាទិន្នា ។ នុបាទានា ។ បេ ។ នោ កិលេសា ។ បេ ។

[៥១៥] ន ទស្សនេន បហាតព្វា ន ភាវនាយ បហាតព្វា ន ទស្សនេន បហាតព្វហេតុកា ន ភាវនាយ បហាតព្វហេតុកា ។ តិស្សោ អប្បមញ្ញាយោ សិយា សវិតក្កា សិយា អវិតក្កា ឧបេក្ខា អវិតក្កា ។ តិស្សោ អប្បមញ្ញាយោ សិយា សវិចារា សិយា អវិចារា ឧបេក្ខា អវិចារា ។

ជាអាសវៈ ទាំងប្រកបដោយអាសវៈផង ថា ប្រកបដោយអាសវៈ តែមិនមែនជាអាសវៈផងទេ ប្រាសចាកអាសវៈ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ ។ ពួកអប្បមញ្ញា មិនមែនសំយោជនៈ ។ បេ ។ មិនមែនគន្ថៈ ។ បេ ។ មិនមែនឱឃៈ ។ បេ ។ មិនមែនយោគៈ ។ បេ ។ មិនមែននីវរណៈ ។ បេ ។ មិនមែនបរាមាសៈ ។ បេ ។ ប្រកបដោយអារម្មណ៍ មិនមែនចិត្ត ជាចេតសិក ប្រកបដោយចិត្ត ច្រឡំដោយចិត្ត តាំងឡើងដោយចិត្ត កើតជាមួយនឹងចិត្ត ប្រព្រឹត្តទៅតាមចិត្ត ច្រឡំទាំងតាំងឡើងដោយចិត្ត ច្រឡំ ទាំងតាំងឡើង ទាំងកើតជាមួយនឹងចិត្ត ច្រឡំ ទាំងតាំងឡើង ទាំងប្រព្រឹត្តទៅតាមចិត្ត ជាខាងក្រៅ មិនមែនឧបាទា មានកម្មប្រកបដោយកិលេសមានតណ្ហាជាដើមកាន់យកក៏មាន មានកម្មប្រកបដោយកិលេសមានតណ្ហាជាដើមមិនបានកាន់យកក៏មាន ។ មិនមែនឧបាទាន ។ បេ ។ មិនមែនកិលេស ។ បេ ។

[៩១៥] ពួកអប្បមញ្ញា មិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា មានហេតុមិនគួរលះដោយទស្សនៈ មានហេតុមិនគួរលះដោយភាវនា ។ អប្បមញ្ញា ៣ ប្រកបដោយវិតក្កៈក៏មាន មិនមានវិតក្កៈក៏មាន ឧបេក្ខា មិនមានវិតក្កៈ ។ អប្បមញ្ញា ៣ ប្រកបដោយវិចារៈក៏មាន មិនមានវិចារៈក៏មាន ឧបេក្ខា មិនមានវិចារៈ ។

៣៤១



តិស្សោ អប្បមញ្ញាយោ សិយា សប្បីតិកា សិយា អប្បីតិកា ឧបេក្ខា អប្បីតិកា ។ តិស្សោ អប្ប-មញ្ញាយោ សិយា បីតិសហគតា សិយា ន បីតិ-សហគតា ឧបេក្ខា ន បីតិសហគតា ។ តិស្សោ អប្បមញ្ញាយោ សុខសហគតា ឧបេក្ខា ន សុខ-សហគតា ។ ឧបេក្ខា ឧបេក្ខាសហគតា តិស្សោ អប្បមញ្ញាយោ ន ឧបេក្ខាសហគតា ។ ន កាមា-វចរា រូបាវចរា ន អរូបាវចរា បរិយាបន្នា អនិយ្យា-និកា អនិយតា សឧត្តរា អរណាតិ ។

បញ្ហាបុច្ឆកំ ។

អប្បមញ្ញាវិភង្គោ សមត្តោ ។

---

*អប្បមញ្ញា ៣ ប្រកបដោយបីតិក៏មាន មិនមានបីតិក៏មាន ឧបេក្ខា មិនមានបីតិ ។ អប្បមញ្ញា ៣ ប្រទ្បំដោយបីតិក៏មាន មិនប្រទ្បំដោយបីតិក៏មាន ឧបេក្ខា មិនប្រទ្បំដោយបីតិ ។ អប្បមញ្ញា ៣ ប្រទ្បំដោយសុខ ឧបេក្ខា មិនប្រទ្បំដោយសុខ ។ ឧបេក្ខា ប្រទ្បំដោយឧបេក្ខា អប្បមញ្ញា ៣ មិនប្រទ្បំដោយឧបេក្ខា ។ អប្បមញ្ញា មិនមែនកាមាវចរ តែជារូបាវចរ មិនមែនអរូបាវចរ តែជាបរិយាបន្នៈ ជាអនិយ្យានិកៈ ជាអនិយតៈ ជាសឧត្តរៈ ជាអរណៈ ។*

ចប់ បញ្ហាបុច្ឆកៈ ។

ចប់ អប្បមញ្ញាវិភង្គ ។

---

# អភិធម្មបិដកេ

# វិភង្គស្ស ទុតិយោ ភាគោ

# មាតិកាបត្តានិ

មាតិកា　　　　　　　　　　　　　　　　　　　　អង្កេ

## បច្ចយាការវិភង្គោ


*បច្ចយាការវិភង្គេ*　*សុត្តន្តភាជនីយំ*................................................១
*អភិធម្មមាតិកា*................................................ ៨
*អកុសលនិទ្ទេសោ*...........................................១៩
*កុសលនិទ្ទេសោ*............................................... ៧៥
*អព្យាកតនិទ្ទេសោ*........................................... ៨៧
*អវិជ្ជាមូលកកុសលនិទ្ទេសោ*..........................១១២
*កុសលមូលកវិបាកនិទ្ទេសោ*...........................១១៩
*អកុសលមូលកវិបាកនិទ្ទេសោ*.......................១២៥


## សតិប្បដ្ឋានវិភង្គោ


*សតិប្បដ្ឋានវិភង្គេ*　*សុត្តន្តភាជនីយំ*..........................................១៣១
*អភិធម្មភាជនីយំ*..........................................១៥៥
*បញ្ហាបុច្ឆកំ*..................................................១៦២

# អភិធម្មបិដក

# វិភង្គ ទុតិយភាគ

# សន្លឹកប្រាប់មាតិកា

## មាតិកា ទំព័រ

## បច្ចយាការវិភង្គ


*បច្ចយាការវិភង្គ* *សុត្តន្តភាជនីយ*....................................................១
*អភិធម្មមាតិកា*.................................................... ៨
*អកុសលនិទ្ទេស*..................................................១៩
*កុសលនិទ្ទេស*.................................................... ៧៥
*អព្យាកតនិទ្ទេស* ................................................ ៨៧
*អវិជ្ជាមូលកកុសលនិទ្ទេស* ..............................១១២
*កុសលមូលកវិបាកនិទ្ទេស*..............................១១៩
*អកុសលមូលកវិបាកនិទ្ទេស*...........................១២៥


## សតិប្បដ្ឋានវិភង្គ


*សតិប្បដ្ឋានវិភង្គ* *សុត្តន្តភាជនីយ*..............................................១៣១
*អភិធម្មភាជនីយ* .............................................១៥៥
*បញ្ហាបុច្ឆកៈ*....................................................១៦២

# មាតិកាបត្តានិ

មាតិកា អង្កេ

## សម្មប្បធានវិភង្គោ


*សម្មប្បធានវិភង្គេ សុត្តន្តភាជនីយំ ............ ១៦៧*

*អភិធម្មភាជនីយំ ............ ១៧៤*

*បញ្ហាបុច្ឆកំ ............ ១៨៣*


## ឥទ្ធិបាទវិភង្គោ


*ឥទ្ធិបាទវិភង្គេ សុត្តន្តភាជនីយំ ............ ១៨៧*

*អភិធម្មភាជនីយំ ............ ១៩៥*

*បញ្ហាបុច្ឆកំ ............ ២០៤*


## ពោជ្ឈង្គវិភង្គោ


*ពោជ្ឈង្គវិភង្គេ សុត្តន្តភាជនីយំ ............ ២០៩*

*អភិធម្មភាជនីយំ ............ ២១៤*

*បញ្ហាបុច្ឆកំ ............ ២២១*

# សន្លឹកប្រាប់មាតិកា

មាតិកា ទំព័រ

## សម្មប្បធានវិភង្គ

សម្មប្បធានវិភង្គ សុត្តន្តភាជនីយ........................................... ១៦៧
អភិធម្មភាជនីយ ........................................... ១៧៤
បញ្ហាបុច្ឆកៈ................................................... ១៨៣

## ឥទ្ធិបាទវិភង្គ

ឥទ្ធិបាទវិភង្គ សុត្តន្តភាជនីយ............................................. ១៨៧
អភិធម្មភាជនីយ ............................................ ១៩៥
បញ្ហាបុច្ឆកៈ................................................... ២០៤

## ពោជ្ឈង្គវិភង្គ

ពោជ្ឈង្គវិភង្គ សុត្តន្តភាជនីយ............................................. ២០៩
អភិធម្មភាជនីយ ............................................ ២១៤
បញ្ហាបុច្ឆកៈ................................................... ២២១

# មាតិកាបត្តានិ

**មាតិកា** **អង្កេ**

## មគ្គវិភង្គោ

*មគ្គវិភង្គេ* *សុត្តន្តភាជនីយំ* ........................................ ២២៦
*អភិធម្មភាជនីយំ* ........................................ ២៣០
*បញ្ហាបុច្ឆកំ* ........................................ ២៤០

## ឈានវិភង្គោ

*ឈានវិភង្គេ* *សុត្តន្តភាជនីយំ* ........................................ ២៤៥
*អភិធម្មភាជនីយំ* ........................................ ២៩១
*បញ្ហាបុច្ឆកំ* ........................................ ៣០៥

## អប្បមញ្ញាវិភង្គោ

*អប្បមញ្ញាវិភង្គេ* *សុត្តន្តភាជនីយំ* ........................................ ៣១២
*អភិធម្មភាជនីយំ* ........................................ ៣២២
*បញ្ហាបុច្ឆកំ* ........................................ ៣៣៦

---

# សន្លឹកប្រាប់មាតិកា

**មាតិកា** **ទំព័រ**

## មគ្គវិភង្គ


មគ្គវិភង្គ សុត្តន្តភាជនីយ............................................២២៦
អភិធម្មភាជនីយ ..........................................២៣០
បញ្ហាបុច្ឆកៈ.................................................២៤០


## ឈានវិភង្គ


ឈានវិភង្គ សុត្តន្តភាជនីយ............................................២៤៥
អភិធម្មភាជនីយ ............................................២៩១
បញ្ហាបុច្ឆកៈ.................................................៣០៥


## អប្បមញ្ញាវិភង្គ


អប្បមញ្ញាវិភង្គ សុត្តន្តភាជនីយ............................................៣១២
អភិធម្មភាជនីយ ..........................................៣២២
បញ្ហាបុច្ឆកៈ.................................................៣៣៦

## រៀបចំវាយអក្សរឡើងវិញនិងពិនិត្យតាមច្បាប់ដើមដោយ

## គណៈកម្មការពុទ្ធិកវប្បធម៌អង្គការមូលនិធិវត្តបញ្ញាធំ

ការវាយអក្សរ និងបោះពុម្ពសាឡើងវិញនូវសៀវភៅព្រះត្រៃបិដកបាលី និងសេចក្ដីប្រែជាភាសាខ្មែរ ដែលជាស្នាដៃ របស់លោកអ្នកប្រាជ្ញជំនាន់មុន គឺអាស្រ័យដោយការមើលឃើញនូវកត្តាចាំបាច់មួយចំនួនដូចខាងក្រោម ៖

- ឯកសារដើម ត្រូវបានថតចម្លងច្រើនសា ធ្វើឲ្យមានលក្ខណៈមិនច្បាស់ពិបាកក្នុងការអាន
- រក្សាស្នាដៃវប្បធម៌ព្រះពុទ្ធសាសនាឲ្យគង់វង្សស្ថិតស្ថេរ
- តម្រូវការរបស់សិក្ខាកាមអ្នកប្រាថ្នាចង់យល់ដឹងនូវខ្លឹមសារពុទ្ធសាសនា
- ផ្សាយនូវធម្មទាន ធ្វើឲ្យព្រះពុទ្ធសាសនាកាន់តែមានភាពរីកចម្រើនរុងរឿងក្នុងលោក

ដោយកុសលផលបុណ្យទាំងអម្បាលមាណ ដែលកើតអំពីធម្មទាននេះ

សូមឲ្យព្រះពុទ្ធសាសនាផ្សាយទៅគ្រប់ទិសទីទូទាំងសកលលោក

សូមឲ្យសព្វសត្វទាំងឡាយទាំងពួងបាននូវសេចក្ដីសុខសួស្ដី

សូមឲ្យមនុស្សគ្រប់ជាតិសាសន៍មានភាតរភាពនឹងគ្នា

សូមឲ្យពិភពលោកទាំងមូលមានសុខសន្តិភាព ។

ក្នុងករណីដែលលោកអ្នកអានបានពើបប្រទះនូវកំហុសឆ្គងណាមួយ ចង់ឲ្យយើងកែតម្រូវ ឬចង់បានសៀវភៅធម៌យកទៅអាន សូមទាក់ទងមកយើងខ្ញុំតាមអាសយដ្ឋានដូចខាងក្រោមៈ

វត្តបញ្ញា សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

លេខទូរស័ព្ទ: (៨៥៥) ១២ ៩៦១ ៤២៩, (៨៥៥) ៨៨៧ ៩៦១ ៤២៩

អ៊ីមែល: maha.panna@gmail.com

គេហទំព័រ: http://www.mahapanna.org

*“Wherever the Buddha’s teachings have flourished,*

*either in cities or countrysides,*

*people would gain inconceivable benefits.*

*The land and people would be enveloped in peace.*

*The sun and moon will shine clear and bright.*

*Wind and rain would appear accordingly,*

*and there will be no disasters.*

*Nations would be prosperous*

*and there would be no use for soldiers or weapons.*

*People would abide by morality and accord with laws.*

*They would be courteous and humble,*

*and everyone would be content without injustices.*

*There would be no thefts or violence.*

*The strong would not dominate the weak*

*and everyone would get their fair share.”*

~THE BUDDHA SPEAKS OF
THE INFINITE LIFE SUTRA OF
ADORNMENT, PURITY, EQUALITY
AND ENLIGHTENMENT OF
THE MAHAYANA SCHOOL~

With bad advisors forever left behind,
From paths of evil he departs for eternity,
Soon to see the Buddha of Limitless Light
And perfect Samantabhadra's Supreme Vows.

The supreme and endless blessings
of Samantabhadra's deeds,
I now universally transfer.
May every living being, drowning and adrift,
Soon return to the Pure Land of Limitless Light!

**✻ The Vows of Samantabhadra ✻**

I vow that when my life approaches its end,
All obstructions will be swept away;
I will see Amitabha Buddha,
And be born in His Western Pure Land of
Ultimate Bliss and Peace.

When reborn in the Western Pure Land,
I will perfect and completely fulfill
Without exception these Great Vows,
To delight and benefit all beings.

**✻ The Vows of Samantabhadra Avatamsaka Sutra ✻**